សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ 2013

# លីអាហូណា



**ការបំផុសគំនិតមកពី ខ្សែជីវិត និង ការបង្រៀន របស់ប្រធាន ឡូរ៉ែនសូ ស្នូ ទំព័រ 12, 18**

ដើម្បីស្វែងរកប្រាជ្ញា ទំព័រ 20

កិច្ចការសាលា និង ជីវិតបេសកកម្មរបស់អ្នក ទំព័រ 54

តើយើងអាចក្លាយជាមិត្តនឹងគ្នាបានទេ ? ទំព័រ 58



*« មនុស្សយើងបើប្រៀបធៀបទៅនឹងព្រះគឺគ្មានជាអ្វីសោះ ប៉ុន្តែយើងគឺជាអ្វីៗទាំងអស់ចំពោះទ្រង់ ។ »*

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « អ្នកសំខាន់ចំពោះទ្រង់ » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 20 ។

# លីអាហូណា ខែ មករា ឆ្នាំ 2013




32

## សារលិខិត

**4** **សារលិខិតគណៈប្រធានទីមួយ ៖ សម្លេងនៃព្រះអម្ចាស់**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង

**7** **សារលិខិតការបង្រៀនសួរសុខទុក្ខ ៖ កិច្ចការផ្សព្វផ្សាយសាសនា**

## អត្ថបទពិសេសៗ

**12** **ជ្រក់ត្រសក់, មើមឆៃថាវ និង ទីបន្ទាល់ ៖ ការបំផុសគំនិតមកពីខ្សែជីវិត និង ការបង្រៀនរបស់ ឡូរែនសូ ស្នូ**
ដោយ អើរ៉ុន អិល វែស
*សេចក្តីណែនាំសម្រាប់កម្មវិធីសិក្សានៃថ្នាក់បព្វជិតភាពមិលគីស្សាដែក និង ថ្នាក់សមាគមសង្គ្រោះ នៅឆ្នាំនេះ ។*

**20** **គារវភាពចំពោះព្រះគឺជាការដើមចមនៃប្រាជ្ញា**
ដោយ អែលឌើរ នែល អិល អាន់ឌើរសិន
*ភាពរំជើបរំជួលនៃព័ត៌មានសព្វថ្ងៃ នោះយើងពិតជាត្រូវការប្រាជ្ញាយ៉ាងខ្លាំង ។*

**28** **ការបង្រៀនក្នុងផ្ទះដែលប្រកបដោយអត្ថន័យ**
ដោយ ដារែន អ៊ី ស្មីត
*វិធីបួនយ៉ាងដែលយើងបង្រៀនកូនចៅរបស់យើងអំពីមេរៀនសំខាន់ៗនៃជីវិត ។*

**32** **យុវនារី និងការសម្រេចចិត្តដើម្បីបម្រើបេសកកម្ម**
*យុវនារីទាំងនេះ អនុវត្តតាមដំបូន្មានរបស់ព្យាការីស្តីអំពីការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង*

**36** **តើបេសកកម្មអ្វីដែលល្អបំផុតនោះ ?**
*មិនថាស្ថានភាពរបស់អ្នកយ៉ាងណាទេ ឱកាសជាអ្នកផ្សព្វផ្សាយសាសនាជាប្តីប្រពន្ធគឺមានសម្រាប់អ្នក ។*

## ផ្នែកទាំងឡាយ

**8** **សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា**

**10** **យើងនិយាយអំពីព្រះគ្រីស្ទ ៖ ពេញល្មមគ្រប់គ្រាន់ហើយ**
ដោយ ម៉ៃយល រ៉ស៍

**31** **ការបង្រៀន *ដើម្បីកម្លាំងនៃយុវជន* ៖ តម្លៃនៃការសិក្សាអប់រំ**

**38** **សម្លេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**74** **ព័ត៌មានសាសនាចក្រ**

**79** **យោបល់ទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ**

**80** **លុះត្រាជួបទៀត ៖ មេរៀនរយៈពេលប្រាំនាទី**
ដោយ គ្រីស្តូហ្វើ ជេ ស្មីធ

**នៅលើគម្រប**
ខាងមុខ ៖ រូបភាពរបស់ ប្រធាន ឡូរែនសូ ស្នូ ដោយ ស៊ី អ័រ សាវ៉ែក, រចនាលម្អនៃ ស្នាដៃពិសេសៗរបស់ អិល. ថម ភែរី, បណ្ណាល័យ ហារ៉ូល ប៊ី លី, សាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ស៊ុមរចនាលម្អនៃបណ្ណាល័យព្រឹទ្ធសភា, វ៉ាសស៊ីងតោន ឌី. ស៊ី ។ ខាងក្រោយ ៖ ផាត់ពណ៌ដោយ ចន វីលាដ ខ្លាសុន © IRI ។ នៅគម្របមុខ ៖ ថតរូបដោយ អែនជ្រៃ ស្ប៊ូមីលីន ។

## ពួកមជ្ឈិមវ័យវ័យក្មេង





42 **សេចក្ដីជំនឿ សេចក្ដីសង្ឃឹម ហើយនឹង ទំនាក់ទំនង**
ដោយអែលឌើរ ម៉ៃកុល ធី រីងវូដ
*របៀបដែលធាតុផ្សំបីយ៉ាងរបស់សេចក្ដីជំនឿ អាចជួយឱ្យការចែចង់ និង ការសម្រេចចិត្តដើម្បី រៀបអាពាហ៍ពិពាហ៍របស់អ្នក ។*





## យុវវ័យ


18 **ការស្គាល់ប្រធាន ឡូរែនសូ ស្នូ**
ដោយ គ្រីស្ទស្តូហ្វើ ឌី ហ្វូស
*រឿងនៃការបំផុសគំនិតពីរបីដែលអ្នកមិនធ្លាប់ដឹង អំពីប្រធាន ស្នូ ។*

46 **ការចែកចាយ—ព្រះគម្ពីរមរមន**
ដោយអែលឌើរ ហ្វ៊ូន អេ យូសេដា
*ការចែកចាយព្រះគម្ពីរមរមនជាមួយមិត្តភក្ដិរបស់ អ្នកអាចនាំឱ្យមានបទពិសោធន៍នៃការផ្លាស់ ចិត្តជឿ ដ៏អស្ចារ្យ ។*

49 **មួយបន្ទាត់ម្ដងៗ ៖ គោលលទ្ធិ និង សេចក្ដីសញ្ញា 87:8**
*បាវចនាម៉ូតឆលឆ្នាំនេះបង្រៀនអ្នកពីកន្លែងដែល ត្រូវឈរឱ្យមានសុវត្ថិភាព ។*

50 **បាវចនាម៉ូតឆលឆ្នាំ 2013**
ដោយ ប្រធានយុវនារី និង យុវជនទូទៅ
*យោបល់ស្ដីពីរបៀបដែលអ្នកអាចឈរនៅក្នុង ទីបរិសុទ្ធ ។*

52 **អ្វីដែលអាហ្គុង បានរៀនមកពីការវាយសី**
ដោយ អ័ដាម ស៊ី អូលសុន
*របៀបដែលសេចក្ដីសង្ឃឹមអាចប្រទានពរដល់ ជីវិតរបស់យើងសព្វថ្ងៃនេះ ។*

54 **ដើម្បីកម្លាំងនៃយុវជន ៖ ការអប់រំ**
ដោយ អែលឌើរ ក្រេក អេ ខារដុន

56 **សូមបន្តអនុវត្ត**
ដោយ វីលលីស ជេនសិន
*ខ្ញុំមិនធ្លាប់សង្ឃឹមថា ថ្ងៃណាមួយមេរៀនព្យាណូ របស់ខ្ញុំអាចជួយខ្ញុំឱ្យទទួលអារម្មណ៍នៃ ព្រះវិញ្ញាណឡើយ ។*

57 **បណ្ណប្រកាស ៖ ឈរនៅក្នុងទីបរិសុទ្ធ**

58 **ការមើលឃើញសេចក្ដីល្អនៅក្នុងខ្លួន ខែលី**
ដោយ ខារីន ស្ដេស៊ី
*ម៉ាក់បានផ្ដល់យោបល់ថា សិស្សកោងនោង សាលាគឺពិតជាត្រូវការមិត្តភក្ដិ ។*


## កុមារ





59 **សាក្សីពិសេស ៖ តើខ្ញុំអាចទទួលទីបន្ទាល់ មួយបានដោយរបៀបណា ?**
ដោយ អែលឌើរ រ៉ូប៊ើត ឌី ហែល

60 **ផែនការមួយសម្រាប់គ្រួសាររបស់យើង**
ដោយ ម៉ារីស្សា វីដឌីស៊ុន
*នៅពេលប្អូនស្រីតូចរបស់ លេរី បានកើតមុនខែ នាងត្រូវការការអធិស្ឋាន និង ការប្រសិទ្ធពរនៃ បព្វជិតភាព ។*

62 **នៅតាមផ្លូវ ៖ ផ្ទះពីរកន្លែង ដែលយ៉ូសែប ស្ម៊ីធ បានរស់នៅ**
ដោយ ជេន ភិនបូរ៉ាហ្វ

64 **រឿងទាំងឡាយអំពីព្រះយេស៊ូវ ៖ ព្រះយេស៊ូវគ្រីស្ទ និង ការនិមិត្តដំបូង**

65 **ទំព័ររបស់យើង**

66 **ត្រៀមខ្លួនជាស្រេចដើម្បីអាន**
ដោយ មើរីលី បូរិន
*មិត្តភាព និង ចិត្តសប្បុរសបានជួយ ម៉ារី យកឈ្នះលើការភ័យខ្លាចរបស់នាង ។*

68 **ការនាំមេរៀនថ្នាក់កុមារមកក្នុងលំនៅដ្ឋាន ៖ ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ ហើយទ្រង់មាន ផែនការមួយសម្រាប់ខ្ញុំ**

70 **សម្រាប់កុមារតូចៗ**

81 **រូបគំនូរព្យាការី ៖ យ៉ូសែប ស្ម៊ីធ**




*ចាំមើលថាតើអ្នកអាចរកឃើញ រូបលីអាហូណាដែលលាក់នៅក្នុងលេខ នេះដែរឬទេ ។ តម្រុយ ៖ « តើខ្ញុំអាច ទទួលបាន » លីអាហូណាមួយក្បាល ដោយរបៀបណា ?*

**ខែ មករា ឆ្នាំ 2013 វ៉ុល 13 លេខទី 1**
**លីអាហូណា 10781 258**

ទស្សនាវដ្ដីអន្តរជាតិជាផ្លូវការនៃសាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទី មួយ ៖** ថូម៉ាស អេស ម៉នសុន, ហិនរី ប៊ី អាវរិង, ឌៀថើរ អេស្វ អុជដូហ្វ

**ក្រុមនៃពួកសាវក 12 នាក់ ៖** ប៊យដ៍ ឃេ ផាកកឺ, អិល ថម ភែរី, រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម រ័សុល បាឡឺដ, រីឆាដ ជេ ស្កត, របឺត ឌី ហែល, ជែហ្វ្រី អរ៍ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិលឃុក, ឌី ថត គ្រីស្តូហ្វឺសិន, និង នែល អិល អាន់ឌើរសិន

**អ្នកបោះពុម្ពផ្សាយ ៖** ក្រេហ្គ អេ. ខាដុន
**អ្នកណែនាំ ៖** ស្បេន អែម. បូវែន, ប៉្រែតលី ឌី. ហ្វូស្ទើរ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ៉ូរ, អាន់ថូនី ឌី. ភើគីន

**នាយកផ្នែកចាត់ការ ៖** ដេវីឌ ធី. វ៉ូនើរ
**នាយកផ្នែកការគាំទ្រដល់គ្រួសារ និង សមាជិក ៖** វិនសិន អេ. វ៉ុន
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អរ. ឡយប៊ើហ្គ

**អ្នកគ្រប់គ្រងអាជីវកម្ម ៖** ហ្គាហ្វ ខានុន
**អ្នកចាត់ការបោះពុម្ពផ្សាយ ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការចាត់ចែងបោះពុម្ពផ្សាយ ៖** ឡារ៉ែន ផតទើរ ហ្គាន
**ជំនួយការផ្នែកបោះពុម្ព ៖** ម៉ាលីសា ហ្សែនទីណូ

**ការសរសេរ និង ការពិនិត្យ ៖** សូសាន បារ៉េត, វ៉ាយអិន ខារ, ដេវីឌ ឌីកសុន, ដេវីឌ អេ. អែតវើត, ម៉ាថាយ ឌី. ហ្លីតតុន, មីនឌី រ៉េ ហ្វ្រីតមែន, ហ៊ីការី លូហ្វតុស, ល្សេ ម៉ាក់ក្លាណាហាន, មីហ្គែល អរ. ម៉ូរីស, រីឆាត អិម. រ៉មនី, ប៉ុល វ៉ានដែនប៊ើរហ្គី, ជូល្សេ វូឌប៊ើរី
**អ្នកបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកចាត់ចែងផ្នែកសិល្បៈ ៖** ជេ ស្កត នូតស៊ិន
**នាយកផ្នែកសិល្បៈ ៖** ថាត អរ. ភីទើរសុន
**ផ្នែករៀបចំតុបតែង ៖** ជេនណិត អាន់ទ្រូ, ហ្វេ ភី. អាន់គ្រស, ស៊ី. ឃឹមប៊ឹល បុត, ថូម៉ាស ឆាល, ខារី លីន ស៊ី. ហែរីន, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស្កត អិម. ម៉យ, ប្រាត ធៀរ
**អ្នកសម្របសម្រួលផ្នែកកម្មសិទ្ធិបញ្ញា ៖** ខូលិត នីប៊ើរឃើរ អុន
**អ្នកគ្រប់គ្រងផលិតកម្ម ៖** ជេន អាន ភិទើរស៍
**ក្រុមផលិតកម្ម ៖** ខុននី បោធប ប្រ៊ីត, ហោវើត ជី. ប្រោណ, ជូលី ប៊ើរឌីត, ប្រាយអិន ដប់ុលយូ. ហ្គីហ្គី, ខាធ្លីន ហោវើត, ដានីស ឌើរប៊ី, ហ្គីននី ជេ. នីលសុន, ធី ភីលឃើ, ហ្គែល ថាត វ៉ាហ្វើរធី
**អ្នកបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រីជ ឃេ ស៊ីជវីគន
**នាយកផ្នែកការចែកចាយ ៖** អ៊ីវ៉ានឡាស៊ិន

**សំរាប់ជំនាវ និងតម្លៃខាងក្រៅសហរដ្ឋអាមេរិក និងកាណាដា សូមទាក់ទងមជ្ឈមណ្ឌលចែកចាយនៃសាសនាចក្រក្នុងមូលដ្ឋាន ឬអ្នកដឹកនាំវួដ ឬសាខា។ ផ្ញើការបោះពុម្ព ឬសំណួរទាំងឡាយតាមអ៊ិនធើរណិត liahona.lds.org, តាម *Liahona*, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។**

*លីអាហូណា* ( ព្រះគម្ពីរមរមនមានន័យថា «ត្រីវិស័យ» ឬ «វត្ថុនាំផ្លូវ» ) ត្រូវបាន បោះពុម្ពជាភាសា អាល់ប៊ើនី, អាមេនី, ប៊ីស្លាម្សេ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហៃទី, ហ៊ិនឌី, ហុងហ្គារី, អាយឡែនឌិច, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាកាស៊ី, ម៉ាស្សែលី, ម៉ុងហ្គោលី, ណរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស៊ីនហាឡា, ស្លូវ៉ានី, អេស្ប៉ាញ, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, តាមីល, តេលូហ្គូ, ថៃ, តុងហ្គា, អ៊ុយគ្រែ,ន អ៊ើឌូ និងវៀតណាម។ ( ភាពញឹកញាប់ប្រែប្រួលតាមភាសា ) ។

© 2013 ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅក្នុងសហរដ្ឋអាមេរិក ។

អត្ថបទ និងរូបភាពផ្សេងៗនៅក្នុងទស្សនាវដ្ដី *លីអាហូណា* អាចថតចម្លងបាន ដើម្បីប្រើប្រាស់នៅតាមគេហដ្ឋាន មិននៅក្នុងសាសនាចក្រ តែមិនមែនសំរាប់ធ្វើអាជីវកម្ម។ រូបភាពមួយចំនួនមិនអាចថតចម្លងបានទេ ចំពោះរូបភាពមួយចំនួនដែលត្រូវបានហាមឃាត់។ បើមានសំណួរ លោកអ្នកអាចទាក់ទងជាមួយ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org.

**For Readers in the United States and Canada:**
January 2013 Vol. 13 No. 1. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address *must* be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (Visa, MasterCard, American Express) may be taken by phone. (Canada Poste Information: Publication Agreement #40017431)

POSTMASTER: Send address changes to Salt Lake Distribution Center, Church Magazines, PO Box 26368, Salt Lake City, UT 84126-0368.

# រឿងជាច្រើនទៀតនៅលើអ៊ិនធើរណែត Liahona.lds.org




**សម្រាប់មជ្ឈិមវ័យ**
អត្ថបទនៅទំព័រទី 12 ណែនាំពីកម្មវិធីសិក្សារបស់ថ្នាក់បព្វជិតភាពមិលគីស្សាដែក និង ថ្នាក់សមាគមសង្គ្រោះនៅឆ្នាំនេះសម្រាប់ការប្រជុំថ្ងៃអាទិត្យ ។ បើសិនអ្នកចង់អានសៀវភៅពុម្ពនៅលើអ៊ីនធើណែត វាមាននៅគេហទំព័រ **LDS.org** ក្រោមពាក្យ “Resources” ។




**សម្រាប់យុវវ័យ**
នៅទំព័រទី 50 អែលឌើរ ក្រេក អេ ខាដុន នៃពួកចិតសិបនាក់បង្រៀនពីរបៀបដែលការអប់រំជះលទ្ធិពលលើជីវិតបេសកកម្មរបស់អ្នក ។ អ្នកអាចរៀនបន្ថែមទៀតអំពីការអប់រំក្នុងផ្នែក*ដើម្បីកម្លាំងនៃយុវជន*នៅគេហទំព័រ **youth.lds.org** ។

## ជាភាសារបស់អ្នក
*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសា សូមចូលទៅកាន់ **www.languages.lds.org**។

## ប្រធានបទទាំងឡាយក្នុងច្បាប់នេះ
*លេខទំព័រទាំងឡាយគឺតំណាងឱ្យទំព័រទីមួយនៃអត្ថបទ ។*

***ភាពមិនអនុគ្រោះ,*** *10*
***សិទ្ធិជ្រើសរើស,*** *80*
***ប្រវត្តិសាស្ត្រសាសនាចក្រ,*** *12, 18, 32, 62*
***និស្ស័យនៃព្រះ,*** *68*
***ការអប់រំ,*** *31, 54, 56*
***សេចក្ដីជំនឿ,*** *42*
***ក្រុមគ្រួសារ,*** *28, 60*
***ហិរញ្ញវត្ថុ,*** *20*
***ការទិមិត្តដំបូង,*** *39, 62, 64*
***មិត្តភាព,*** *58*
***ការព្យាបាល,*** *10*
***ព្រះវិញ្ញាណបរិសុទ្ធ,*** *4*
***សេចក្ដីសង្ឃឹម,*** *42, 52*
***ព្រះយេស៊ូវគ្រីស្ទ,*** *10*
***ចិត្តសប្បុរស,*** *58, 66*
***អាពាហ៍ពិពាហ៍,*** *42*
***កិច្ចការផ្សព្វផ្សាយសាសនា,*** *7, 38, 40, 41, 46*
***ភាពជាមាតា,*** *10*
***តន្ត្រី,*** *56*
***បាវចនាម៉ូតឆល,*** *49, 50*
***ការគោរពប្រតិបត្តិ,*** *32*
***ភាពជាឪពុកម្ដាយ,*** *28*
***ការអធិស្ឋាន,*** *4, 39, 60*
***ពរជ័យនៃបព្វជិតភាព,*** *40, 60*
***វិវរណៈ,*** *32*
***ការសិក្សាព្រះគម្ពីរ,*** *28*
***យ៉ូសែប ស្ម៊ីធ,*** *32, 42, 62, 64, 81*
***ឡូវែនសូ ស្នូ,*** *12, 18*
***ការបង្រៀន,*** *28*
***ព្រះវិហារបរិសុទ្ធ,*** *65, 70*
***ទីបន្ទាល់,*** *39, 46, 59*
***ការបង្រៀនទស្សនសុខទុក្ខ,*** *7*
***គតិបណ្ឌិត,*** *20*



**ដោយ ប្រធាន ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុង គណៈប្រធានទីមួយ

# សម្លេងនៃព្រះ អម្ចាស់



គោលលទ្ធិ និង សេចក្តីសញ្ញាអញ្ជើញមនុស្សទាំងអស់នៅគ្រប់ទិសទីឱ្យស្តាប់សម្លេងនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ (សូមមើលគ.ស. 1:2, 4, 11, 34; 25:16) ។ គោលលទ្ធិ និង សេចក្តីសញ្ញាពោរពេញដោយ សារលិខិត ការព្រមាន និង ការទូន្មានលើកទឹកចិត្តរបស់ទ្រង់ដែលបានប្រទានឱ្យតាមរយៈវិវរណៈដល់ព្យាការីទាំងឡាយដែលបានជ្រើសរើស ។ នៅក្នុងវិវរណៈទាំងនោះ យើងអាចឃើញពីរបៀបដែលព្រះអាចឆ្លើយតបការអធិស្ឋានដោយសេចក្តីជំនឿរបស់យើង តាមរយៈសារលិខិតនៃការណែនាំ សេចក្តីសុខសាន្ត និង ការព្រមាន ។

នៅក្នុងការអធិស្ឋានរបស់យើង យើងស្វែងយល់ដើម្បីដឹងពីអ្វីដែលព្រះចង់ឱ្យយើងធ្វើ, ពីអ្វីដែលយើងគួរធ្វើដើម្បីស្វែងរកភាពសុខសាន្ត និង សុភមង្គលនៅក្នុងជីវិតនេះ និង ជីវិតបន្ទាប់ និង អ្វីៗដែលនឹងកើតឡើងនៅពេលអនាគត ។ គោលលទ្ធិ និង សេចក្តីសញ្ញាពោរពេញដោយចម្លើយចំពោះសំណួរបែបនេះដែលចោទសួរដោយមនុស្សទូទៅ និង ដោយព្យាការីទាំងឡាយនៅក្នុងការអធិស្ឋានដ៏រាបទាប ។ ចម្លើយអាចជាអ្នកនាំផ្លូវដ៏មានតម្លៃដើម្បីបង្រៀនយើង ពីរបៀបដើម្បីទទួលចម្លើយចំពោះសំណួរទាំងឡាយអំពីសុខុមាលភាពខាងសាច់ឈាម និង សេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ច ។

ការបន្ទាបខ្លួន និង សេចក្តីជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទគឺជាគន្លឹះ ។ អូលីវើរ ខៅឌើរី បានទទួលចម្លើយមួយពីព្រះអម្ចាស់ទាក់ទិនទៅនឹងបំណងប្រាថ្នារបស់លោកដើម្បីជួយបកប្រែព្រះគម្ពីរមរមនថា ៖ « ចូរចងចាំថា បើគ្មានសេចក្តីជំនឿ នោះអ្នកពុំអាចធ្វើអ្វីបានទេ ហេតុដូច្នេះហើយ ចូរសុំដោយនូវសេចក្តីជំនឿ ។ ចូរកុំប្រហែស នឹងការណ៍ទាំងឡាយនេះ ចូរកុំសុំអ្វីដែលអ្នកមិនគួរសុំនោះឡើយ » (គ. និង ស. 8:10) ។

ជាម្តងហើយ ម្តងទៀត នៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា ព្រះអម្ចាស់បានតម្រូវឱ្យមានសេចក្តីជំនឿ និង ការបន្ទាបខ្លួន ពីមុនទ្រង់ផ្តល់ជំនួយរបស់ទ្រង់ ។ ហេតុផលមួយសម្រាប់ការណ៍នេះ គឺថាចម្លើយរបស់ទ្រង់មិនអាចមកតាមរបៀបដែលយើងរំពឹងគិតនោះទេ ។ វាក៏មិនងាយស្រួលដើម្បីទទួលបានជានិច្ចផងដែរ ។

ប្រវត្តិសាស្រ្តសាសនាចក្រ និង បទពិសោធន៍ទាំងឡាយនៃបព្វការីជនរបស់យើងបានសឱ្យឃើញពីសេចក្តីពិតនេះ ។ ហិនរី អាវរិង ជីតាទួតរបស់ខ្ញុំ បានអធិស្ឋានដោយស្មោះដើម្បីដឹងពីអ្វីដែលគាត់គួរធ្វើ នៅពេលដែលគាត់បានឮការបង្រៀនពីដំណឹងល្អដែលបានស្តារឡើងវិញក្នុងឆ្នាំ 1855 ។ ចម្លើយនោះបានមកតាមរយៈសុបិនមួយ ។

លោកបានយល់សុបិនឃើញថា លោកបានអង្គុយនៅឯតុជាមួយ អែលឌើរ អ៊ីរ៉ាស្តាស ស្នូ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ជាមួយអែលឌើរម្នាក់ឈ្មោះ វីល្លៀម ប្រោន ។ អែលឌើរ ស្នូ បានបង្រៀនពីគោលការណ៍ទាំងឡាយនៃដំណឹងល្អអស់រយៈពេលប្រហែលជាមួយម៉ោង ។ បន្ទាប់មក អែលឌើរ ស្នូ មានប្រសាសន៍ថា ៖ « នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ខ្ញុំបញ្ជាអ្នកឱ្យទទួលបុណ្យជ្រមុជទឹក ហើយបុរសនេះ [អែលឌើរ ប្រោន] ... នឹងជ្រមុជទឹកអ្នក » ។ [1] គ្រួសាររបស់ខ្ញុំមានអំណរគុណដែល ហិនរី អាវរិង បានមានសេចក្តីជំនឿ និង ការបន្ទាបខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹកនៅម៉ោង 7.30 នាទីព្រឹកនៅអាងហែលទឹកនៅក្នុង ទីក្រុងសេន លូវីស មិសសួរី ស.អ.រ ដោយ អែលឌើរ ប្រោន ។

ចម្លើយចំពោះការអធិស្ឋានរបស់លោកមិនបានឆ្លើយតបជាសម្លេងឮមកពីព្រះអម្ចាស់នោះទេ ។ វាបានឆ្លើយតបតាមរយៈទស្សនទិមិត្ត និង សុបិននៅពេលយប់គឺដូចជាលីហៃផងដែរ (សូមមើល នីហ្វៃទី 1 8:2) ។



*ខាងឆ្វេង ៖ នៅក្នុងសៀវភៅកំណត់ហេតុនេះ ហិនរី អាវរិង (រូបថត នៅខាងឆ្វេង) បានកត់ត្រាទុកនូវព្រឹត្តិការណ៍ទាំងឡាយបន្ទាប់ពីការធ្វើឃាតលើ អែលឌើរ ប៉ាលី ភី ប្រាត្ត (រូបថតខាងក្រោមនៃរូបថត ហិនរី អាវរិង) ។ ទំព័រខាងឆ្វេងនេះនៃសៀវភៅកំណត់ហេតុ រៀបរាប់ពីការធ្វើឃាត ។ នៅខាងក្រោមសៀវភៅកំណត់ហេតុ គឺជា ព្រះគម្ពីរ គោលលទ្ធិ និង សេចក្ដីសញ្ញាមួយក្បាល ដែលបានបោះពុម្ពក្នុងឆ្នាំ 1890 ។*

ព្រះអម្ចាស់បានបង្រៀនយើងថា ចម្លើយក៏អាចឆ្លើយតបតាមរយៈការទទួលអារម្មណ៍ផងដែរ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ទ្រង់បានបង្រៀន អូលីវើរខៅឌើរថា « មើលចុះ យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់អ្នក និង នៅក្នុងចិត្តរបស់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងសណ្ឋិតមកលើអ្នក ហើយដែលនឹងគង់នៅក្នុងចិត្តរបស់អ្នក » (គ. និង ស. 8:2) ។

ហើយទ្រង់បានលើកទឹកចិត្ត អូលីវើរតាមរបៀបនេះថា ៖ « តើយើងពុំបាន និយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នកអំពីការណ៍នោះទេឬអី ? តើអ្នកអាចមានសាក្សីឯណា ដែលអស្ចារ្យជាងសាក្សីមកពីព្រះ ? » (គ. និង ស. 6:23) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ប្រវត្តិសាស្ត្រសាសនាចក្រ និង ប្រវត្តិដែលបានរក្សាទុកដោយ ហិនរី ប៊ី អាវរិង កាលពីបេសកកម្មរបស់លោកគឺបន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់លោកបានបង្រៀនខ្ញុំថា ចម្លើយអាចទទួលបានជាអារម្មណ៍ព្រមាន ព្រមទាំងអារម្មណ៍នៃភាពសុខសាន្ត ។

នៅខែ មេសា ឆ្នាំ 185 អែលឌើរ ប៉ាលី ភី ប្រាត្ត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចូលរួមសន្និសីទមួយ ដែលឥឡូវនេះកន្លែងនោះគឺជារដ្ឋ អូក្លូហូម៉ា ស.អ.រ ។ ហិនរី អាវរិង បានកត់ត្រាទុកថា « ដួងចិត្តរបស់ អែលឌើរ ប្រាត្ត ពេញដោយការស្រយុតចិត្ត ... មិនអាចដឹងពីអនាគត ឬ វិធីណាមួយដើម្បីគេចផុតពីអារម្មណ៍នោះឡើយ ។ [2] ហិនរី បានកត់ត្រាទុកភ្លាមៗ ពីព័តមានដ៏គ្រាមក្រំ បន្ទាប់ពីការធ្វើឃាតដល់សាវក ។ អែលឌើរ ប្រាត្ត បានបន្តដំណើររបស់លោកទៅមុខទៀត មិនគិតពីអារម្មណ៍នៃភាពភ័យខ្លាច គឺដូចជាអ្វីដែលព្យាការី យ៉ូសែបបានធ្វើក្នុងការទៅក្រុងកាតធេច ។

នេះជាទីបន្ទាល់របស់ខ្ញុំថា ព្រះអម្ចាស់តែងតែឆ្លើយតបនូវការអធិស្ឋានដ៏រាបទាបដោយសេចក្ដីជំនឿ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា និង បទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងបង្រៀនយើងពីរបៀបឱ្យទទួលស្គាល់ចម្លើយទាំងនោះ ហើយទទួលចម្លើយនោះដោយសេចក្ដី ជំនឿ ទោះបីជាចម្លើយនោះ ជាការណែនាំ, ការបញ្ជាក់នៃសេចក្ដីពិត ឬ ការព្រមាន ។ ខ្ញុំសូមអធិស្ឋានថា យើងនឹងស្ដាប់ និង ទទួលស្គាល់ជានិច្ចនូវសម្លេងដ៏គួរឱ្យស្រឡាញ់របស់ព្រះអម្ចាស់ជានិច្ច ។ ■

**កំណត់ចំណាំ**

1. "The Journal of Henry Eyring: 1835–1902" (ការសរសេរនៅក្នុងសៀវភៅកម្មសិទ្ធិរបស់អ្នកនិពន្ធ) ។
2. "The Journal of Henry Eyring: 1835–1902."

**ការបង្រៀនចេញពីសារលិខិតនេះ**

1. សូមអានដោយពិចារណាទាំងអស់គ្នា ពីកថាខណ្ឌទាំងឡាយអំពីការអធិស្ឋាននៅក្នុងសារលិខិតនេះ ។ ពេលអ្នកអាន សុំសមាជិកគ្រួសារឱ្យស្ដាប់ដោយយកចិត្តទុកដាក់ពី របៀបដែលព្រះឆ្លើយតបចំពោះការអធិស្ឋាន ។ សូមពិចារណាពីការថ្លែងទីបន្ទាល់នៃសារៈសំខាន់នៃការអធិស្ឋាន ។

2. គោលលទ្ធិ និង សេចក្ដីសញ្ញា ពេញដោយចម្លើយចំពោះសំណួរទាំងឡាយដែលចោទសួរដោយមនុស្សទូទៅក្នុងការអធិស្ឋាន ។ តើមានអ្វីកើតឡើង បើសិនចម្លើយឆ្លើយតបចំពោះសំណួរទាំងឡាយរបស់ពួកគេ (វិវរណៈ) មិនបានកត់ត្រាទុកនោះ ? សូមលើកទឹកចិត្តគ្រួសារដើម្បីរៀនទទួលស្គាល់ និង ធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណ ។ ពួកគេអាចចង់កត់ត្រាគំនិតទាំងឡាយរបស់ពួកគេ ដែលបានមកពីការអធិស្ឋាននៅក្នុងសៀវភៅកំណត់ហេតុរបស់ពួកគេ ។

រូបថតរបស់ ប៉ាលី ភី ប្រាត្ត ... សៀវភៅកំណត់ហេតុ និង រូបថត ហិនរី អាវរិង ... UNIVERSITY OF UTAH MARRIOTT LIBRARY SPECIAL COLLECTIONS ...

## យុវវ័យ

# ការស្តាប់ដើម្បីទទួលការបំផុសគំនិត

ដោយ ម៉ារីយ៉ា អ៊ីសាប៊ែល ម៉ូលីណា

នារាត្រីមួយ ប្អូនស្រីជីដូនមួយរបស់ខ្ញុំបានរត់ចេញពីផ្ទះ ដូច្នេះខ្ញុំបានប្រញាប់ប្រញាល់តាមរកនាង ។ ពេលខ្ញុំបើកឡាន ខ្ញុំបានអធិស្ឋានសុំឱ្យព្រះវិញ្ញាណជួយខ្ញុំ ។ ខ្ញុំបានដឹងថា ព្រះនឹងឆ្លើយតប ហើយដឹកនាំខ្ញុំ ហើយខ្ញុំព្យាយាមស្តាប់តាមការបំផុសគំនិតរបស់ព្រះវិញ្ញាណ ។ ប៉ុន្តែពេលដែលខ្ញុំពុំបានឮអ្វីសោះនោះ ខ្ញុំបានចាប់ផ្តើមទទួលអារម្មណ៍ថា បាក់ទឹកចិត្ត ហើយទទួលអារម្មណ៍ថាព្រះវិញ្ញាណមិនបានបំផុសគំនិតរបស់ខ្ញុំទេ ។

ទោះបីខ្ញុំចង់ទៅឆ្ងាយទៀតដើម្បីស្វែងរកនាងក៏ដោយ ខ្ញុំទទួលអារម្មណ៍ថា ខ្ញុំគួរតែរកនៅក្នុងតំបន់ជិតផ្ទះរបស់ប្អូនជីដូនមួយខ្ញុំ ។ ដូច្នេះខ្ញុំបានសម្រេចចិត្ត បើកឡានជុំវិញតំបន់ នោះម្តងទៀត ។ នៅពេលដែលខ្ញុំឈប់នៅផ្លូវប្រសព្វគ្នា ខ្ញុំបានឃើញស្រមោលក្មេងស្រីម្នាក់កំពុងដើរ ។ ខ្ញុំបានរកឃើញប្អូនជីដូនមួយរបស់ខ្ញុំ !

នៅពេលខ្ញុំបានចេញពីឡាន ហើយរត់សំដៅទៅនាង នោះខ្ញុំដឹងថាព្រះវិញ្ញាណបាននាំផ្លូវខ្ញុំជាប់រហូតមកដោយជួយខ្ញុំឱ្យទទួលអារម្មណ៍ថា ខ្ញុំគួរតែនៅក្នុងបរិវេណដដែលនោះ ។ ដោយសារខ្ញុំបានតាមស្តាប់សម្លេងដ៏ស្ងៀមស្ងាត់ នោះខ្ញុំស្ទើរតែព្រងើយកន្តើយនឹងការបំផុសគំនិតមកពីព្រះវិញ្ញាណ ។ បន្ទាប់ពីនោះមកខ្ញុំបានយល់ថា ជាច្រើនដងច្រើនគ្រានោះយើងនឹងមិនឮជាសម្លេងទេ ប៉ុន្តែយើងនឹងទទួលអារម្មណ៍រំភើបនៅក្នុងដួងចិត្តរបស់យើង ។

ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះការដឹកនាំរបស់ព្រះវិញ្ញាណ ។ ពិតណាស់ ទ្រង់នឹងនៅជិតយើងជានិច្ច ! ដូចជាខគម្ពីរបានប្រាប់ថា « ព្រះវិញ្ញាណបរិសុទ្ធនឹងទៅជាគូកនអ្នកជានិច្ច » (គ. និង ស. 121:46) ។

បើសិនយើងសក្តិសមដើម្បីឱ្យព្រះវិញ្ញាណដឹកនាំ ហើយយើងយកចិត្តទុកដាក់ នោះយើងអាចក្លាយជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះដើម្បីធ្វើកិច្ចការល្អដល់មនុស្សជាច្រើន ។ ដោយមានព្រះវិញ្ញាណបរិសុទ្ធជាគូកនជានិច្ច នោះ យើងអាចដឹងពីផ្លូវដែលយើងគួរទៅ ។

## កុមារ

# ការអធិស្ឋានផ្សងព្រេងមួយ

ប្រធាន អាវរិង បង្រៀនថា ការអធិស្ឋានអាចត្រូវបានឆ្លើយតបតាមរបៀបផ្សេងៗជាច្រើន ។ អ្នកអាចមានការផ្សងព្រេងមួយដើម្បីស្រាវជ្រាវរកខគម្ពីរ ដើម្បីស្វែងរករបៀបមួយចំនួននោះ

សូមប្រើផែនទីនេះ ដើម្បីចាប់ផ្តើមដំណើរការរៀនសូត្ររបស់អ្នក ។ សូមមើលខគម្ពីរនិមួយៗនៅលើផែនទី ។ នៅលើខ្សែបន្ទាត់ទទេ សូមសរសេរពាក្យពីរ ឬ បីម៉ាត់ដើម្បីរៀបរាប់ពីអ្វីដែលខគម្ពីរបានប្រាប់អំពីចម្លើយចំពោះការអធិស្ឋាន ។

នៅតាមផ្លូវ អ្នកអាចសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក អំពីអ្វីដែលកំពុងរៀន ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកអំពីការអធិស្ឋានដែលត្រូវបានឆ្លើយតប ។



**1** យ៉ូហាន 14:26

________________

________________

________________

________________



**2** គោលលទ្ធិ និង សេចក្តីសញ្ញា 6:22–23

________________

________________

________________

**3** គោលលទ្ធិ និង សេចក្តីសញ្ញា 8:2

________________

________________

________________





**4** គោលលទ្ធិ និង សេចក្តីសញ្ញា 9:8–9

________________

________________

________________

________________



**X** សុភាសិត 8:10–11

គំនូរព្រាងដោយ ប្រាយអិន ប៊ីច

## សារលិខិតបង្រៀនសួរសុខទុក្ខ

*សូមសិក្សាឯកសារនេះប្រកបដោយការអធិស្ឋាន បើសមរម្យសូមធ្វើការពិភាក្សាអំពីកិច្ចការនេះជាមួយនឹងបងប្អូនស្ត្រីដែលអ្នកទៅសួរសុខទុក្ខ ។ សូមប្រើសំណួរទាំងឡាយដើម្បីជួយអ្នកពង្រឹងដល់បងប្អូនស្ត្រីទាំងឡាយរបស់អ្នក និង ធ្វើឲ្យថ្នាក់សមាគមសង្គ្រោះក្លាយជាផ្នែកមួយដ៏សកម្មនៅក្នុងជីវិតផ្ទាល់របស់អ្នក ។* ***សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។***

សេចក្ដីជំនឿ, ក្រុមគ្រួសារ, ការសង្គ្រោះ

# កិច្ចការផ្សព្វផ្សាយសាសនា

ពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានបញ្ជូនឲ្យទៅ « ដើម្បីធ្វើការងារនៅក្នុងចម្ការទំពាំងបាយជូរ[របស់ទ្រង់] សម្រាប់សេចក្ដីសង្គ្រោះដល់ព្រលឹងនៃមនុស្សលោក » (គ. និង ស. 138:56) ដែលរួមទាំងកិច្ចការផ្សព្វផ្សាយសាសនា ។ យើងមិនចាំបាច់ដើម្បីមានការហៅបម្រើបេសកកម្មជាផ្លូវការដើម្បីចែកចាយដំណឹងល្អនោះទេ ។ អ្នកដទៃដែលរស់នៅជុំវិញយើងនឹងទទួលពរតាមរយៈដំណឹងល្អ ហើយពេលយើងរៀបចំខ្លួនរបស់យើង នោះព្រះអម្ចាស់នឹងប្រើយើង ។ គ្រូបង្រៀនសួរសុខទុក្ខអាចក្ដាប់ជាប់នូវទំនួលខុសត្រូវខាងវិញ្ញាណរបស់ពួកគេ ហើយជួយ « នាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » (ម៉ូសេ 1:39) ។

នៅពេលដែលព្យាការី យ៉ូសែប ស្ម៊ីធ បានរៀបចំសមាគមសង្គ្រោះក្នុងឆ្នាំ 1842 លោកបានមានប្រសាសន៍ថា ស្ត្រីមិនត្រឹមតែមើលថែរក្សាដល់អ្នកទីទ័លក្រប៉ុណ្ណោះទេ តែថែមទាំងសង្គ្រោះព្រលឹងផងដែរ ។[1] នេះគឺនៅតែជាគោលបំណងរបស់យើង ។

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា « ព្រះអម្ចាស់ … ប្រទានទីបន្ទាល់នៃសេចក្ដីពិតដល់អស់អ្នកដែលនឹងចែកចាយទីបន្ទាល់នោះជាមួយអ្នកដទៃទៀត » « លើសពីនេះទៀត ព្រះអម្ចាស់រំពឹងថា សមាជិកទាំងឡាយនៃសាសនាចក្ររបស់ទ្រង់នឹង ‹ បើក [មាត់របស់ពួកគេ] គ្រប់ពេល ប្រកាសដំណឹងល្អ [របស់ទ្រង់] ដោយសម្លេងរីករាយចុះ › (គ. និង ស. 28:16) ។ … ពេលខ្លះទីបន្ទាល់មួយឃ្លាអាចធ្វើឲ្យមាននូវអារម្មណ៍ ដែលជះឥទ្ធពលលើជីវិតរបស់នរណាម្នាក់សម្រាប់ភាពអស់កល្បជានិច្ច » ។[2]



### ចេញពីព្រះគម្ពីរ

គោលលទ្ធិ និង សេចក្ដីសញ្ញា 1:20–23; 18:15; 123:12

#### កំណត់ចំណាំ

1. សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* (ឆ្នាំ 2007) ទំព័រ 453 ។
2. ឌៀថើរ អេស្វ អុជដូហ្វ "Waiting on the Road to Damascus," *លីអាហូណា* ខែ ឧសភា ឆ្នាំ 2011ទំព័រ 76–77 ។
3. សូមមើល *Daughters in My Kingdom ៖ The History and Work of Relief Society* (ឆ្នាំ 2011), ទំព័រ 92–95 ។

### ចេញពីប្រវត្តិសាស្ត្ររបស់យើង

ដំណើររឿងរបស់ អូលហ្គា កូវ៉ារូវ៉ា របស់ឆែកូស្លូវ៉ាគីពីដើម គឺជាឧទាហរណ៍មួយរបស់សមាជិកអំពីកិច្ចការផ្សព្វផ្សាយសាសនា មកពីប្រវត្តិនៃសមាគមសង្គ្រោះរបស់យើង ។ នៅទស្សវត្សន៍ឆ្នាំ 1970 អូលហ្គា គឺជានិស្សិតពេទ្យ និងមានការចង់ដឹងឲ្យបានជ្រៅជ្រះខាងផ្នែកវិញ្ញាណ ។ នាងបានសម្គាល់មើល ពីពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ឈ្មោះ អូតាកា វ៉ូគូការ អាយុ 75ឆ្នាំ ។ នាងបាននិយាយថា « គាត់មើលទៅ មានអាយុចិតសិបប្រាំឆ្នាំ តែដួងចិត្តរបស់គាត់ហាក់ដូចជាមនុស្សដែលមានអាយុដប់ប្រាំឆ្នាំ ហើយពោរពេញដោយសេចក្ដីអំណរ » ។ « ការនិយាយចំអកបែបនេះវាមិនធម្មតាទេ នៅក្នុងប្រទេស ឆែកូស្លូវ៉ាគីនៅសម័យនោះ » ។

អូលហ្គា បានសួរ អូតាកា និងគ្រួសាររបស់គាត់ពីរបៀបដែលពួកគេស្វែងរកសេចក្ដីអំណរ ។ ពួកគាត់បានណែនាំនាងឲ្យស្គាល់សមាជិកសាសនាចក្រដទៃទៀត ហើយបានឲ្យព្រះគម្ពីរមរមននាងមួយក្បាល ។ នាងបានអានវាដោយចិត្តចង់ដឹង ហើយមិនយូរប៉ុន្មានបានទទួលបុណ្យជ្រមុជទឹក និង បញ្ជាក់ ។ ចាប់តាំងពីពេលនោះមក អូលហ្គា បានក្លាយជាឥទ្ធពលមួយសម្រាប់សេចក្ដីល្អនៅក្នុងពិភពលោកមួយដែលមានការគាបសង្កត់ផ្នែកនយោបាយ និង ការធ្វើទុក្ខបុកម្នេញខាងសាសនា ។ នាងបានបម្រើជាប្រធានសមាគមសង្គ្រោះនៅក្នុងសាខាដ៏តូចរបស់នាង ហើយជួយសង្គ្រោះព្រលឹងទាំងឡាយរបស់មនុស្សដទៃទៀត ដោយនាំពួកគេមកកាន់ព្រះគ្រីស្ទ ។[3]

### តើខ្ញុំអាចធ្វើអ្វីបាន ?

1. តើខ្ញុំបានធ្វើតាមការបំផុសគំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធដែរឬទេ ពេលខ្ញុំចែកចាយទីបន្ទាល់របស់ខ្ញុំជាមួយបងប្អូនស្ត្រីដែលខ្ញុំបានសួរសុខទុក្ខនោះ ?
2. តើខ្ញុំកំពុងជួយបងប្អូនស្ត្រីដែលខ្ញុំមើលថែរក្សាឲ្យរៀនដំណឹងល្អបានដោយរបៀបណា ?

# សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា

*« អ្វីដែលយើងជាព្រះអម្ចាស់បានមានព្រះបន្ទូល នោះយើងបានមានបន្ទូលហើយ... ទោះដោយផាសំឡេងរបស់យើងផ្ទាល់ ឬ ក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្តី គឺដូចតែគ្នា » (គ. និង ស. 1:38)* ។

នៅពេលអ្នកពិនិត្យមើលសន្និសីទទូទៅខែ តុលា ឆ្នាំ 2012 នោះអ្នកអាចប្រើប្រាស់ទំព័រទាំងនេះ (និង សៀវភៅកំណត់ចំណាំសន្និសីទនៅច្បាប់ចេញផ្សាយនាពេលខាងមុខទៀត) ដើម្បីជួយអ្នក សិក្សា និង អនុវត្ត ការបង្រៀនថ្មីៗរបស់ព្យាការី និង សាវក ដែលរស់នៅ និង អ្នកដឹកនាំសាសនាចក្រដទៃផ្សេងទៀត ។

**រឿងទាំងឡាយមកពីសន្និសីទ**

## តើវាជាការចៃដន្យដែលយើងបានជួបឬ ?

នៅយប់ថ្ងៃសៅរ៍ដ៏ត្រជាក់មួយ អំឡុងរដូវរងា ឆ្នាំ 1983–84 ស៊ីស្ទើរ ម៉នសុន និង ខ្ញុំ បានបើកឡានជាច្រើនគីឡូម៉ែត្រទៅកាន់ជ្រលងភ្នំ មីតវ៉េ រដ្ឋ យូថាហ៍ ជាកន្លែងដែលយើងមានផ្ទះមួយនៅទីនោះ ។ អាកាសធាតុនៅយប់នោះគឺ -24 អង្សារ ហ្វារិនហៃគី (-31 អង្សារសេ) យើងចង់ទៅមើលទីនោះថា មិនមានបញ្ហាអ្វីនោះទេ ។ យើងបានពិនិត្យមើល ហើយឃើញថាមិនមានបញ្ហាអ្វីឡើយ ដូច្នេះយើងបានត្រឡប់ទៅកាន់ទីក្រុង សលត៍ លេក វិញ ។ យើងបានធ្វើដំណើរបានប្រហែលជាពីរបីគីឡូម៉ែត្រ... មុនពេលឡានរបស់យើងរលត់ ។ ... យើងបានជាប់គាំងទាំងស្រុង ។ ...

យើងបានចាប់ផ្តើមដើរដោយស្ពាក់ស្ទើរទៅកាន់ទីក្រុងដែលនៅជិតបំផុត ហើយមានឡានជាច្រើនបានបើកហួសយើងទៅ ។ ទីបំផុតមានឡានមួយបានឈប់ ហើយមានយុវជនម្នាក់បានសុំជួយដល់យើង ។ ...



យុវជនចិត្តល្អម្នាក់នេះ បានដឹកយើងត្រឡប់ទៅកាន់ផ្ទះរបស់យើងនៅ មីតវ៉េ វិញ ។ ខ្ញុំព្យាយាមដើម្បីបង់ថ្លៃឈ្នួលសម្រាប់ការបម្រើរបស់គាត់ ... ប៉ុន្តែគាត់ ... បានប្រាប់ថា គាត់គឺជាកាយឫទ្ធិ ហើយចង់ធ្វើការបម្រើ ។ ខ្ញុំបានណែនាំខ្លួនខ្ញុំទៅគាត់ ហើយគាត់បានបង្ហាញនូវអំណរគុណរបស់គាត់ចំពោះឯកសិទ្ធិដើម្បីជួយ ។ ដោយគិតថា គាត់មានអាយុប្រហែលជាអ្នកផ្សព្វផ្សាយសាសនា ខ្ញុំបានសួរគាត់បើសិនជាគាត់មានផែនការចង់បម្រើបេសកកម្ម ។ គាត់បានប្រាប់ថា គាត់មិនច្បាស់ពីអ្វីដែលគាត់ចង់ធ្វើទេ ។

នៅព្រឹកថ្ងៃច័ន្ទបន្ទាប់ ខ្ញុំបានសរសេរសំបុត្រមួយច្បាប់ទៅយុវជនម្នាក់នេះ ហើយអរគុណគាត់ចំពោះសណ្តានចិត្តល្អរបស់គាត់ ។ នៅក្នុងសំបុត្រនោះ ខ្ញុំបានលើកទឹកចិត្តគាត់ដើម្បីឱ្យបម្រើបេសកកម្មពេញម៉ោង ។ ...

ប្រហែលជាមួយសប្តាហ៍ក្រោយមក ម្តាយរបស់យុវជននោះបានទូរស័ព្ទមក ហើយបានប្រាប់ខ្ញុំថា កូនប្រុសរបស់គាត់គឺជាយុវជនឆ្នើមម្នាក់ ប៉ុន្តែដោយសារមានឥទ្ធិពលខ្លះនៅក្នុងជីវិតរបស់គាត់ បំណងប្រាថ្នារបស់គាត់ដើម្បីបម្រើបេសកកម្មត្រូវបានរលត់បាត់ ។ គាត់បាននិយាយថា គាត់ និង ស្វាមីបានតមអាហារ និង អធិស្ឋាន សុំឱ្យដួងចិត្តរបស់គាត់នឹងផ្លាស់ប្តូរ ។ ... [អ្នកម្តាយនោះ] ចង់ឱ្យខ្ញុំដឹងថា គាត់ទន្ទឹងចាំនូវព្រឹត្តការណ៍នៃល្ងាចត្រជាក់នោះ ជាការឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេជំនួសឱ្យកូនរូបនោះ ។ ខ្ញុំបាននិយាយថា « ខ្ញុំឯកភាព ជាមួយអ្នក » ។

ប៉ុន្មានខែក្រោយមក ដោយមាន ទំនាក់ទំនងជាច្រើនជាមួយយុវជននេះ ស៊ីស្ទើរ ម៉នសុន និង ខ្ញុំរីករាយយ៉ាងខ្លាំង ដើម្បីចូលរួមក្នុងពិធីចេញធ្វើជាអ្នកផ្សព្វផ្សាយសាសនារបស់គាត់ មុនពេលការចេញដំណើររបស់គាត់ទៅបេសកកម្ម វ៉ានខូវើរ កាណាដា ។

តើវាជាការចៃដន្យដែលយើងបានជួបគ្នានៅយប់ដ៏ត្រជាក់ក្នុងខែធ្នូនោះឬ ? ខ្ញុំពុំជឿថាដូច្នោះទេ ។ តែខ្ញុំជឿថាការជួបរបស់យើង គឺជាចម្លើយចំពោះការអធិស្ឋានរបស់ម្តាយ និង ឪពុកគាត់ សម្រាប់កូនប្រុសដែលពួកគេស្រឡាញ់ ។

ប្រធាន ថូម៉ាស អេស. ម៉នសុន « សូមពិចារណាពីពរជ័យ » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 88 ។

**សំណួរដើម្បីពិចារណា ៖**

- តើការបម្រើបេសកកម្មអាចពង្រឹងអ្នក និង អស់អ្នកដែលអ្នកបង្រៀនបានដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីរៀបចំខ្លួនរបស់អ្នកដើម្បីបម្រើបេសកកម្ម ?

សូមពិចារណានូវការសរសេរគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ឬ ពិភាក្សាអំពីគំនិតទាំងនោះជាមួយមនុស្សដទៃទៀត ។

ធនធានបន្ថែមទៀតស្តីអំពីប្រធានបទនេះ ៖ *ប្រកាសដំណឹងល្អរបស់យើង សៀវភៅណែនាំចំពោះកិច្ចការផ្សព្វផ្សាយសាសនា* (ឆ្នាំ 2004); វ័សុល អិម. ណិលសុន « សូមសួរអ្នកផ្សព្វផ្សាយទៅ ! ពួកគេអាចជួយអ្នកបាន ! » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 18–21 ។



## ការសន្យានៃការព្យាករណ៍

« ព្រះវរបិតាសួគ៌របស់យើង បានដឹងពីតម្រូវការរបស់យើង ហើយនឹងជួយយើង នៅពេលយើងសុំជំនួយពីទ្រង់ ។ ខ្ញុំជឿថាគ្មានកង្វល់របស់យើងណាមួយ តូចតាចពេក ឬ ពុំសំខាន់នោះទេ ។ ព្រះអម្ចាស់គឺខ្វល់ព្រះទ័យចំពោះរឿងលម្អិតក្នុងជីវិតរបស់យើង » ។

ប្រធាន ថូម៉ាស អេស. ម៉នសុន « សូមពិចារណាពីពរជ័យ » ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 88 ។ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 88 ។

## សេចក្តីណែនាំពី ការផ្លាស់ប្តូរអាយុរបស់អ្នកផ្សព្វផ្សាយសាសនា

នៅក្នុង សន្និសីទទូទៅខែ តុលា ឆ្នាំ 2012 ប្រធាន ថូម៉ាស អេស. ម៉នសុនបានប្រកាសថា ៖ « យុវជនដែលស័ក្តិសម និង មានសមត្ថភាពទាំងអស់ដែលបានបញ្ចប់វិទ្យាល័យ ឬ សាលាប្រហាក់ប្រហែល ... នឹងមានជម្រើសឱ្យបម្រើបេសកកម្មចាប់តាំងពីអាយុ 18 ជំនួសឱ្យអាយុ 19 ឆ្នាំវិញ ។ ... យុវនារីដែលមានសមត្ថភាព មានភាពសក្តិសមដែលមានបំណងចង់បម្រើ អាចលើកទឹកចិត្តឱ្យបម្រើបេសកកម្មចាប់ពីអាយុ 19 ជំនួសឱ្យអាយុ 21 ឆ្នាំ » (« សូមស្វាគមន៍មកកាន់សន្និសីទ » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 4, 5) ។

**សន្និសីទទូទៅ**

# ប្រៀបធៀបអ្វីដែលស្រដៀងគ្នា ៖ ការផ្លាស់ប្រែចិត្តជឿដ៏ពិត

ប្រធានបទសំខាន់ៗបំផុតមួយចំនួនត្រូវបានថ្លែងសុន្ទរកថាលើសពីម្នាក់ ដោយអ្នកនិយាយក្នុងសន្និសីទទូទៅ ។ នេះគឺជាអ្វីដែលអ្នកនិយាយបួនរូបបានមានប្រសាសន៍អំពីការផ្លាស់ប្រែចិត្តជឿដ៏ពិត ។ សូមព្យាយាមរកមើលភាពស្រដៀងគ្នាផ្សេងទៀត នៅពេលអ្នកសិក្សាសុន្ទរកថាសន្និសីទទាំងនេះ ។

- « ការប្រែចិត្តជឿដ៏ពិត ... រួមមានទាំងមនសិការនៃការប្តេជ្ញាចិត្តដើម្បីក្លាយជាសិស្សរបស់ព្រះគ្រីស្ទ » ។[1]
  —អែលឌើរ ដេវីឌ អេ. បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។
- « នៅពិធីបុណ្យជ្រមុជទឹក យើងសន្យានឹងលើកដាក់មកលើយើងនូវ « ព្រះនាមនៃ [ព្រះយេស៊ូវ] គ្រីស្ទ ដោយ *ប្តេជ្ញា* ថានឹងបម្រើទ្រង់ដល់ចុងបំផុត ។ [ម៉ូរ៉ូណៃ 6:3សេចក្តីបញ្ជាក់បន្ថែម ។] សេចក្តីសញ្ញាមួយដូច្នេះ តម្រូវឱ្យមានការខិតខំដោយក្លាហាន ការប្តេជ្ញាចិត្ត និង ភាពសុចរិត » ។[2]
  —អែលឌើរ ឃ្វីនថិន អិល. ឃុក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់
- « យើងគឺជាអ្នកដើរតាមព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។ ការប្រែចិត្តជឿ និង ទំនុកចិត្តបែបនោះ គឺជាលទ្ធផលនៃការខិតខំដ៏ឧស្សាហ៍ និង ការតាំងចិត្ត ។ វាគឺជារឿងបុគ្គល ។ វាគឺជាដំណើរការពេញមួយជីវិត » ។[3]
  —អាន អិម. ឌិប ទីប្រឹក្សាទីពីរ នៅក្នុងគណៈប្រធានយុវនារីទូទៅ
- « នៅពេលដែលទីបន្ទាល់របស់យើងបានរីកចម្រើនឡើងហួសពីអ្វីដែលមាននៅក្នុងគំនិត ហើយចូលទៅក្នុងដួងចិត្តយើង នោះវានឹងជម្រុញឱ្យក្តីស្រឡាញ់ និង បម្រើរបស់យើងក្លាយដូចជាព្រះអង្គសង្គ្រោះ » ។[4]
  —អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

**កំណត់សម្គាល់**

1. ដេវីឌ អេ. បែដណា « បានប្រែចិត្តជឿដល់ព្រះអម្ចាស់ » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 107 ។
2. ឃ្វីនថិន អិល. ឃុក « តើអ្នករាល់គ្នាអាចចាប់អារម្មណ៍យ៉ាងនេះ ឥឡូវនេះទេ ? » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 9 ។
3. អាន អិម. ឌិប « ខ្ញុំស្គាល់វា ។ រស់នៅតាមវា ។ ខ្ញុំស្រឡាញ់វា » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 10 ។
4. អិម រ័សុល បាឡឺដ « ការចូលរួមដោយឧស្សាហ៍ » *លីអាហូណា,* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 30 ។

ដើម្បីអាន មើល ឬ ស្តាប់ សុន្ទរកថាទាំងឡាយនៃសន្និសីទទូទៅ សូមមើលគេហទំព័រ conference.lds.org ។

ថតរូបដោយ វែលឌិន ស៊ីមប៉ើរស និង គ្រីស្ទីណា ស្មីធ

# ពេញល្មមគ្រប់គ្រាន់ហើយ

**ដោយ ម៉ៃឃល រ៉េស៍**

*តើខ្ញុំអាចប្ដូរខោទឹកនោម, រៀបចំអាហារពេលល្ងាច ឬ លួងកូនរបស់ខ្ញុំដោយដៃតែម្ខាងបានដោយរបៀបណា ?*

កាលពីខ្ញុំអាយុ 17ឆ្នាំ ខ្ញុំបានពិការដៃឆ្វេងម្ខាង ស្ទើរតែទាំងស្រុងដោយសារគ្រោះថ្នាក់រថយន្ត ។ គ្រោះថ្នាក់នេះបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំជារៀងរហូត ។ ទោះបីជាមានពេលលំបាក និង ស្មុគស្មាញជាច្រើនក៏ដោយ ឡភ្លើងនៃភាពឈឺចាប់នេះបានផ្ដល់ឱកាសដល់ខ្ញុំដើម្បីធ្វើទីបន្ទាល់ពីអំណាចនៃដង្វាយធួនក្នុងរបៀបដ៏ពិសេសមួយ ។

ឥឡូវនេះ ជីវិតរបស់ខ្ញុំគឺគ្មានអ្វីក្រៅពីធ្វើជាភរិយា និងម្ដាយនោះទេដែលជាតួនាទីពីរដែលខ្ញុំស្រឡាញ់យ៉ាងខ្លាំង ។ មុនពេលកូនរបស់ខ្ញុំកើត ខ្ញុំបានឆ្ងល់ពីភាពពិការរបស់ខ្ញុំដើម្បីធ្វើជាម្ដាយ ។ តើខ្ញុំអាចប្ដូរខោទឹកនោម, រៀបចំអាហារពេលល្ងាច ឬ លួងកូនរបស់ខ្ញុំដោយដៃតែម្ខាងបានដោយរបៀបណា ? ដប់ប្រាំឆ្នាំក្រោយមក ខ្ញុំនៅក្នុងភាពជាម្ដាយដែលមានកូនជាទីស្រឡាញ់ទាំងប្រាំនាក់ ។ ខ្ញុំបានសម្របខ្លួនបានយ៉ាងល្អ ហើយកូនៗរបស់ខ្ញុំកម្រកត់សម្គាល់ថា ខ្ញុំជាម្ដាយម្នាក់ដែលខុសពី ម្ដាយដទៃឡើយ ។ ការបាត់បង់ដៃម្ខាងរបស់ខ្ញុំ ឈប់ជាឧបគ្គសទៀតហើយ ប៉ុន្តែជានិមិត្តសញ្ញានៃសេចក្ដីស្រឡាញ់ ។ វាជាប្រភពនៃការលួងលោមដែលកូនៗរបស់ខ្ញុំទទួលបាននៅពេលពួកគេយំ ឬ ងងុយគេងនៅពេលយប់ ។ បញ្ហានេះអាចមានដោយសារមូលហេតុជាច្រើន ប៉ុន្តែខ្ញុំឃើញថាវាជាភស្ដុតាងនៃសមត្ថភាពរបស់ព្រះអង្គសង្គ្រោះដើម្បីធ្វើអ្វីៗដែលល្អចេញពីភាពសោកនាដកម្ម ។

ខ្ញុំមិនអាចរៀបរាប់ពីភាពផ្អែមល្ហែមដែលខ្ញុំបានទទួលនោះទេ នៅពេលដែលភាពពិការរបស់ខ្ញុំនោះបានក្លាយជាផ្នែកមួយដែលផ្ដល់ការលួងលោមបែបនោះដល់កូនៗរបស់ខ្ញុំ ។ ភាពជាម្ដាយបាននាំមកនូវទស្សនវិស័យដល់ភាពពិការខាងរូបកាយរបស់ខ្ញុំ ហើយខ្ញុំបានទទួលអារម្មណ៍ពីដង្វាយធួនដែលបានធ្វើឱ្យខ្ញុំធូរស្រាលកន្លងមក ។

តម្រូវការប្រចាំថ្ងៃនៃភាពជាម្ដាយមានពេលខ្លះពិបាក ។ ពេលលំបាកនានាបានផ្ដល់ហេតុផលជាច្រើនដល់ខ្ញុំឱ្យគិតពីសេចក្ដីពិតនៃដំណើររស់ឡើងវិញ និងសម្ថតភាពរបស់ព្រះអង្គសង្គ្រោះដើម្បីព្យាបាលខ្ញុំ ។ ហេតុនេះហើយ គំរូនៃការជម្រុញសេចក្ដីជំនឿនៃការព្យាបាលដែលមាននៅក្នុងខគម្ពីរមានអត្ថន័យពិសេសចំពោះខ្ញុំ ។ ខមួយដែលខ្ញុំពេញចិត្តនោះ គឺពេលដែលព្រះអង្គសង្គ្រោះបានយាងមកជួបប្រជាជននៅក្នុងទ្វីបអាមេរិក ហើយបានព្យាបាលពួកអ្នកឈឺ ។ ខ្ញុំបានស្រមៃពីអ្វីដែលអាចកើតឡើងដូចមនុស្សម្នាក់ដែលបានព្យាបាលដោយព្រះអង្គសង្គ្រោះ ។ ដំណើររឿងនោះបានចាប់ផ្ដើមដោយការអញ្ជើញដ៏គួរឱ្យស្រឡាញ់របស់ទ្រង់ថា ៖

« តើនៅក្នុងចំណោមអ្នករាល់គ្នា មានអ្នកណាឈឺទេ ? ចូរនាំអ្នកទាំងនោះមកទីនេះចុះ ។ តើមាននរណាខ្វិន ឬ ខ្វាក់ ឬគ ឬ បាក់ដៃបាក់ជើង...ឬក៏ត្រូវរងទុក្ខ



**កម្លាំងដើម្បីរស់នៅជាមួយនឹងឧបគ្គសរបស់អ្នក**

« ឧបគ្គសខ្លះនៅក្នុងជីវិតនេះនឹងមិនអាចដោះស្រាយបានទេនៅលើផែនដីនេះ ។ ប៉ុលបានទូលអង្វរបីដងថា សូមឱ្យ ‹ បន្លាមួយដែលចាក់មកក្នុងសាច់ឈាមខ្ញុំ › នោះបានដកចេញ ។ ព្រះអម្ចាស់បានឆ្លើយតបយ៉ាងសាមញ្ញថា ‹ គុណរបស់អញល្មមដល់ឯងហើយ › (កូរិនថូសទី 2 12:7, 9) ។ ... ទ្រង់បានប្រទានកម្លាំងឱ្យប៉ុលជាការឆ្លើយតបដូចនេះគាត់អាចរស់នៅក្នុងជីវិតដ៏មានអត្ថន័យបំផុត ។ ទ្រង់ចង់ឱ្យអ្នករៀនពីរបៀបដើម្បីទទួលការព្យាបាល ទៅតាមព្រះឆន្ទៈរបស់ទ្រង់ និង ពីរបៀបដើម្បីទទួលកម្លាំងដើម្បីរស់នៅជាមួយនឹងឧបគ្គសរបស់អ្នក នៅពេលដែលទ្រង់ចង់ឱ្យវាក្លាយជារបៀបមួយដើម្បីឱ្យយើងរីកចម្រើន ។ នៅក្នុងករណីណាក៏ដោយ ព្រះប្រោសលោះនឹងគាំទ្រអ្នក » ។

**អែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ “To Be Healed,” *Ensign* ខែ ឧសភា ឆ្នាំ 1994 7 ។**



ខាងលើ ៖ ថតរូបដោយ រ៉ូប៊ើត ខាស៊ី

ដោយហេតុណាផ្សេងទៀតទេ ? ចូរនាំពួកគេមកទីនេះចុះ ហើយយើងនឹងប្រោសឱ្យ ពួកគេបានជា ត្បិតយើងមានចិត្តអាណិតអាសូរដល់ពួកអ្នករាល់គ្នា ចិត្តយើងពោរពេញទៅដោយសេចក្ដីមេត្តាករុណា ។ ...

«... យើងឃើញថា សេចក្ដីជំនឿរបស់អ្នកល្មមគ្រប់គ្រាន់ ដើម្បីឱ្យយើងប្រោសអ្នកឱ្យបានជាហើយ ។

«... កាលទ្រង់មានព្រះបន្ទូលដូច្នោះហើយ នោះហ្វូងមនុស្សទាំងអស់ ក៏ដើរឆ្ពោះទៅមុខព្រមគ្នា ជាមួយនឹងអ្នកឈឺរបស់គេ និង អ្នករងទុក្ខរបស់គេ និង អ្នកខ្វិនរបស់គេ និង អ្នកខ្វាក់របស់គេ និង អ្នកថ្លង់របស់គេ និង អស់ទាំងអ្នកដែលរងទុក្ខដោយជំងឺណាក៏ដោយ ហើយទ្រង់បានប្រោសឱ្យជាសះស្បើយគ្រប់ៗគ្នា » (នីហ្វៃទី 3 17:7–9) ។

សម្រាប់ខ្ញុំ ការណ៍ដែលបានរៀបរាប់នៅក្នុងព្រះគម្ពីរនេះ គឺជាព្រឹត្តិការណ៍ដែលបានដក់ក្នុងដួងចិត្តរបស់ខ្ញុំបំផុត ។ ប៉ុន្តែទស្សនវិស័យរបស់ខ្ញុំបានផ្លាស់ប្ដូរ ពេលខ្ញុំបានបញ្ចូលភាពជាម្ដាយដែលមានតែដៃម្ខាង ។ មានម្ដងនោះ ខ្ញុំបានគិតថា ខ្ញុំជាមនុស្សម្នាក់ដែលអន្ទះសារបំផុតចំពោះការរស់ឡើងវិញ ហើយមានគំនិតដើម្បីមានរូបកាយពេញលេញវិញ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនមានការប្រញាប់ប្រញាល់ដូច្នោះពេកទេ ។ ឥឡូវនេះ ខ្ញុំទទួលអារម្មណ៍ថា ដង្វាយធួនមានឥទ្ធិពលក្នុងជីវិតរបស់ខ្ញុំ *កាន់តែខ្លាំងឡើង* ។ ខ្ញុំបានទទួលស្គាល់ថា អំណាចនៃការព្យាបាលមិនមែនចាប់ផ្ដើមតែនៅពេលដំណើររស់ឡើងវិញកើតឡើងប៉ុណ្ណោះទេ ។ រាល់យប់ ភាពពេញលេញនោះបានចាប់ផ្ដើមមាន នៅពេលដែលកូនម្នាក់របស់ខ្ញុំបានកាន់ដៃកំបុតរបស់ខ្ញុំយ៉ាងស្រទន់ ហើយអង្អែលរហូតគេងលក់យ៉ាងស្កប់ស្កល់ ។ ការណ៍បែបនេះ វាមានអត្ថន័យដ៏ជ្រាលជ្រៅចំពោះខ្ញុំ គឺដូចជាអព្ភូតហេតុមួយនៃការព្យាបាលខាងរូបកាយ ។ ឥឡូវនេះ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំមានកាយសម្បទាពេញលេញដូចខ្ញុំត្រូវការ ។ ■

***ការបាត់បង់ដៃម្ខាងរបស់ខ្ញុំ ឈប់ជាឧបគ្គសម្រាប់ខ្ញុំទៀតហើយ ប៉ុន្តែជានិមិត្តសញ្ញានៃសេចក្ដីស្រឡាញ់ ។ វាជាប្រភពនៃការលួងលោមកូនៗរបស់ខ្ញុំឱ្យទទួលបាននៅពេលពួកគេយំ ឬ ងងុយគេងនៅពេលយប់ ។***

**ហេតុអ្វីរឿងនេះកើតឡើងចំពោះខ្ញុំ ?**

អែលឌើរ រ៉ូណាល អេ រ៉ាសបាន នៃគណៈប្រធាននៃពួកចិតសិប បានឆ្លើយសំណួរនេះនៅក្នុងសុន្ទរកថារបស់លោក កាលពីសន្និសីទទូទៅ ខែ មេសា ឆ្នាំ 2012 ក្នុងអត្ថបទ « មេរៀនពិសេសៗ » ថា ៖

« ជីវិតនេះជាការហ្វឹកហ្វឺនសម្រាប់ភាពលើកតម្កើងដ៏អស់កល្បជានិច្ច ហើយដំណើរការនោះមានន័យថា ជាការសាកល្បង និង ទុក្ខលំបាក ។ វាតែងតែដូច្នោះ ហើយគ្មាននរណាម្នាក់គេចរួចឡើយ ។

« ការទុកចិត្តលើព្រះហឫទ័យរបស់ព្រះគឺជាការចាំបាច់ចំពោះជីវិតរមែងស្លាប់របស់យើង ។ ដោយក្ដីជំនឿលើទ្រង់ នោះយើងទទួលព្រះចេស្ដានៃដង្វាយធួនរបស់ព្រះគ្រីស្ទ នៅពេលដែលយើងមានសំណួរជាច្រើន ហើយមានចម្លើយតែបន្តិចបន្តួចនោះ ។ ...

« ថ្វីបើយើងនឹងប្រឈមមុខជាមួយនឹងការសាកល្បង, ភាពមិនអនុគ្រោះ, ពិការភាព, ការខូចចិត្ត និង ការរងទុក្ខគ្រប់បែបយ៉ាង ក៏ព្រះអង្គសង្គ្រោះ ពេញដោយក្ដីស្រឡាញ់ និង ខ្វល់ខ្វាយ នឹងនៅក្បែរយើងជានិច្ចដែរ ។ ទ្រង់បានសន្យាថា ៖

«‹ ខ្ញុំមិនចោលអ្នករាល់គ្នាឱ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ ។ ...

«‹ ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឱ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឱ្យនោះមិនមែនដូចជាលោកិយឱ្យទេ ។ កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬ ភ័យឡើយ › (យ៉ូហាន 14: 18, 27) » ។

---

*តើដោយរបៀបណាខ្លះដែលអ្នកអាចស្វែងរកការលួងលោមរបស់ព្រះអង្គសង្គ្រោះ និង សេចក្ដីសុខសាន្តនៅក្នុងការសាកល្បងរបស់អ្នកបាន ?*



**ដោយ អេរ៉ុន អិល វើស**
អ្នកពិនិត្យកម្មវិធីសិក្សាសាសនាចក្រ

# ជ្រក់ផ្លែត្រសក់, មើមឆៃថាវ និង ទីបន្ទាល់ ៖

## ការបំផុសគំនិតមកពីខ្សែជីវិត និង ការបង្រៀនរបស់ ឡូរែនសូ ស្នូ

*នៅពេលអ្នកសិក្សាពីការបង្រៀនរបស់ប្រធាន ឡូរែនសូ ស្នូ ក្នុងឆ្នាំនេះ នោះអ្នកនឹងស្គាល់លោកថាជាព្យាការី អ្នកមើលឆុត និង ជាអ្នកទទួលវិវរណៈ ដែលផ្ដល់ការណែនាំយ៉ាងសំខាន់ទាក់ទងនឹងពេលបច្ចុប្បន្ននេះ ។*

បើសិនអ្នកធ្លាប់ឃើញរូបភាពរបស់ ឡូរែនសូ ស្នូ ដែលជាប្រធានទីប្រាំនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះអ្នកប្រហែលជាចាំពីពុកចង្កាពណ៌សដ៏វែង និង ទឹកមុខសប្បុរសរបស់លោក ។ ហើយបើសិនអ្នកបានសំឡឹងមើលរូបភាពនោះមួយសន្ទុះ អ្នកអាចនឹងឃើញនូវកែវភ្នែកដ៏ទៀយហត់—តែមិនកើតទុក្ខរបស់ប្រធាន ស្នូ ដែលមានវ័យចំណាស់តែពោរពេញដោយកម្លាំង និង ពន្លឺ ។

អ្នកអាចនឹងធ្លាប់បានឮថា ប្រធាន ស្នូ ត្រូវបានបំផុសដើម្បីបង្រៀនអំពីដង្វាយមួយភាគក្នុងដប់ ហើយអ្នកនឹងនឹកឡើងវិញពីការអាននូវអ្វីមួយអំពីបទពិសោធន៍ដ៏ពិសិដ្ឋដែលលោកបានមាននៅក្នុងព្រះវិហារបរិសុទ្ធ សលត៍លេក ។

ប៉ុន្តែតើអ្នកបានដឹងទេថា អ្វីទៅដែលបាននាំឱ្យមានបទពិសោធន៍នៅព្រះវិហារបរិសុទ្ធរបស់លោក ហើយតើអ្វីទៅជាលទ្ធផល ? តើអ្នកចាប់អារម្មណ៍ចង់ដឹងពីដំណើររឿងអំពីវិវរណៈដែលលោកបានទទួលអំពីដង្វាយមួយភាគក្នុងដប់ឬទេ ?

ចុះភ្នែក និង ទឹកមុខរបស់លោកវិញយ៉ាងដូចម្ដេចដែរ ? មន្ត្រីម្នាក់ដែលជឿលើសាសនាផ្សេង បន្ទាប់ពីបានជួបប្រធាន ស្នូ ហើយបានសរសេរថា ៖ « ទឹកមុខរបស់លោកគឺមានអំណាចនៃសេចក្ដីសុខសាន្ដ វត្តមានរបស់លោកគឺជាការអធិស្ឋាននៃសេចក្ដីសុខសាន្ដ ។ នៅក្នុងជម្រៅនៃក្រសែភ្នែកដ៏ស្រទន់របស់លោកមិនគ្រាន់តែជា ‹ កន្លែងអធិស្ឋានដ៏ស្ងៀមស្ងាត់ប៉ុណ្ណោះទេ › តែថែមទាំងជាគេហដ្ឋានខាងវិញ្ញាណផងដែរ ។ ... អារម្មណ៍ដ៏ចម្លែកបំផុតបានគ្របដណ្ដប់លើខ្ញុំ ថាខ្ញុំ ‹ បានឈរនៅទីបរិសុទ្ធ › » ។[1] តើអ្នកចង់ដឹងពីដំណើរផ្សងព្រេង, ការសាកល្បង, ជ័យជំនះ, ទុក្ខព្រួយ, អំណរ និង វិវរណៈដែលរួមផ្សំគ្នាដើម្បីបង្កើតឱ្យមានទឹកមុខបែបនេះឬទេ ?

នៅឆ្នាំនេះ បងប្អូនស្រីនៃសមាគមសង្គ្រោះ និង អ្នកកាន់បព្វជិតភាពមិលគីស្សាដែក នឹងសិក្សាអំពី*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរែនសូ ស្នូ* ។ ពេលអ្នករៀនពីការបង្រៀនរបស់ប្រធាន ស្នូ ហើយពិភាក្សាការបង្រៀននោះនៅព្រះវិហារ



ខាងឆ្វេង ៖ ផ្ទៃខាងក្រោយ © ARTBEATS រូបភាពដោយ ចន វីឡាដ ខ្លាសុន© IRI ខាងស្ដាំ ៖ រូបភាពដោយ រ៉ូប៊េត ខាស៊ី

## ព័ត៌មានជីវប្រវត្តិ

ឡូរ៉េនសូ ស្នូ កើតនៅ ថ្ងៃទី 13 ខែ មេសា ឆ្នាំ 1814 នៅ ក្រុង ម៉ែនថោ រដ្ឋ អូហៃអូ ស.អ.រ ។ ឪពុកម្ដាយរបស់លោក គឺ រ៉ូស្សេតា និង អូលីវើរ ស្នូ បានចិញ្ចឹមលោក និង បងប្អូនបង្កើតទាំងប្រាំមួយនាក់របស់លោកនៅក្នុងគេហដ្ឋានមួយដែលបានឧទ្ទិសសម្រាប់សេចក្ដីជំនឿ ការខិតខំធ្វើការងារ ការបម្រើ និង ការអប់រំ ។ គោលការណ៍គ្រឹះទាំងឡាយនេះ បានរៀបចំលោកឱ្យឱបក្រសោបដំណឹងល្អដែលបានស្ដារឡើងវិញ ។ នៅក្នុងខែ មិថុនា ឆ្នាំ 1836 លោកបានចូលជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅក្នុងទីក្រុង ឃើតឡង់ រដ្ឋ អូហៃអូ ដោយឥទ្ធិពលនៃការបំផុសគំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធ និង ការជម្រុញដ៏ទន់ភ្លន់ខ្លះៗរបស់បងស្រីលោកឈ្មោះ អេលីស្សា ដែលបានចូលជាសមាជិកនៃសាសនាចក្រហើយនោះ ។ មិនបានមួយឆ្នាំផង លោកបានហៅឱ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។

12 ឆ្នាំបន្ទាប់មក លោកបានបម្រើបេសកកម្មជាច្រើនផ្សេងទៀតនៅក្នុងសហរដ្ឋ ហើយលោកបានក៏បានដឹកនាំពួកអ្នកត្រួសត្រាយបរិសុទ្ធថ្ងៃចុងក្រោយមួយក្រុមទៅជ្រលងភ្នំ សតល៍ លេក ។ លោកគឺជាអ្នកផ្សព្វផ្សាយសាសនាដ៏លះបង់, ស្វាហាប់, បម្រើនៅប្រទេស អ៊ីតាលី, កោះហាវ៉ៃ និង សហរដ្ឋប៉ែកខាងលិច ។ លោកត្រូវបានតែងតាំងជាសាវកនៅថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 1849 ។ លោកក៏បានធ្វើជាអ្នកដឹកនាំសាសនាចក្រនៅក្នុងតំបន់ផ្សេងៗជាច្រើនទៀត រួមទាំងការបម្រើច្រើនជាង 5 ឆ្នាំ ជាប្រធានទីមួយនៃព្រះវិហារបរិសុទ្ធ សតល៍ លេក ។ នៅថ្ងៃទី 10 ខែ តុលា ឆ្នាំ 1898 លោកត្រូវបានញែកចេញជាប្រធាននៃសាសនាចក្រ ។ លោកបានទទួលមរណៈភាពនៅថ្ងៃទី 10 ខែ តុលា ឆ្នាំ 1901 នៅក្នុងទីក្រុង សតល៍ លេក រដ្ឋ យូថាហ៍ ។



និង ទៅគេហដ្ឋាន នោះអ្នកនឹងស្គាល់លោកកាន់តែច្រើនថែមទៀត មិនមែនស្គាល់តែរូបដ៏សង្ហារបស់គាត់នៅលើគំនូរចាស់មួយសន្លឹកនេះទេ ។ អ្នក នឹងស្គាល់លោកថា ជាបុរសនៃព្រះ—ជាព្យាការី អ្នកមើលឆុត និង ជាអ្នកទទួលវិវរណៈ ដែលផ្ដល់ការណែនាំយ៉ាងសំខាន់ទាក់ទងនឹងពេលបច្ចុប្បន្ននេះ ។

ដើម្បីធ្វើឱ្យបំណងរបស់អ្នកកើនឡើង នេះគឺជាគំរូមួយចំនួននៃការបង្រៀន និង ដំណើររឿងដែលអ្នកនឹងឃើញនៅក្នុងកម្មវិធីសិក្សាឆ្នាំនេះ ។ នៅក្នុងកថាខណ្ឌខាងក្រោមនេះ ជំពូក និង លេខទំព័រ សំដៅលើ *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរ៉េនសូ ស្នូ* ។

អ្នកអាចនឹកចាំពីសុន្ទរកថា ដ៏គួរឱ្យចាប់អារម្មណ៍មួយនៃសន្និសីទទូទៅដែល អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រៀបធៀបពីដំណើរការនៃការផ្លាស់ប្រែចិត្តជឿទៅនឹងដំណើរការនៃការធ្វើជ្រក់ផ្លែត្រសក់ ។[2] អែលឌើរ បែដណា មិនមែនជាសាវកទីមួយដែលធ្វើការប្រៀបធៀបនេះនោះទេ ។ ប្រធាន ស្នូ បានចែកចាយការយល់ដឹងស្រដៀងគ្នានេះកាលពី 150 ឆ្នាំមុនថា ៖

« សូមដាក់ផ្លែត្រសក់មួយនៅក្នុងក្រឡទឹកខ្មេះ ហើយវាមានប្រតិកម្មតិចតួចកើតលើត្រសក់នោះនៅមួយម៉ោងដំបូង និង នៅ 12 ម៉ោងដំបូងផងដែរ ។ សូមពិនិត្យមើលវា នោះអ្នកនឹងឃើញថាមានប្រតិកម្មតិចតួចកើតឡើងលើសំបកត្រសក់ ព្រោះវាត្រូវការពេលយូរដើម្បីក្លាយជាជ្រក់ ។ មនុស្សម្នាក់ដែលបានទទួលបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រនេះ បានទទួលរងនូវឥទ្ធិពលមួយលើគាត់ តែមិនមានឥទ្ធិពលមកលើរូបគាត់ភ្លាមៗដូចជាត្រសក់ជ្រក់នោះទេ ។ វាមិនបានបង្កើតជាច្បាប់ប្រាជ្ញកប្រជា និង កាតព្វកិច្ចនៅក្នុងខ្លួនគាត់អំឡុងពេល 12 ទៅ 24 ម៉ោងដំបូងឡើយ គាត់ត្រូវតែនៅក្នុងសាសនាចក្រ រហូតដល់គាត់បានឆ្អែតដោយព្រះវិញ្ញាណដ៏ពិត គឺដូចជាផ្លែត្រសក់ត្រាំនៅក្នុងទឹកខ្មេះអញ្ចឹងដែរ ។[3]

នៅពេលប្រធាន ស្នូ បាននិយាយអំពីការផ្លាស់ប្រែចិត្តជឿ នោះលោកបាននិយាយពីបទពិសោធន៍ ។ ជានិច្ចជាកាលលោកបានប្រាប់ពីព្រឹត្តិការណ៍ពីរ—ព្រឹត្តិការណ៍មួយកើតមុនលោកចូលសាសនាចក្រ ហើយមួយទៀតកើតឡើងបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់របស់លោក—ថា បានជួយលោកឱ្យប្រែក្លាយទៅជា « ឆ្អែតដោយដោយព្រះវិញ្ញាណដ៏ពិត » ។ អ្នកអាចអានដំណើររឿងពីបទពិសោធន៍ទាំងនោះនៅក្នុងទំព័រ 1, 3, 59, និង 61–62 ។

« ហេតុអ្វីបានជាមនុស្ស[ម្នាក់] ត្រូវបានហៅដើម្បីធ្វើជាប្រធានលើមនុស្សជាច្រើន ? » ពេលមួយ ប្រធាន ស្នូ ត្រូវបានគេសួរសំណួរនេះ ។ « តើនេះជារបៀបមួយដើម្បីទទួលបានឥទ្ធិពលមួយ ហើយ

ពីខាងឆ្វេង ៖ រចនារូបភាពដោយ ប្រែន ខល, រូបភាពដោយ រ៉ូប៊េត ខាស៊ី, រចនាលម្អរូបភាពនៃបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ





*ប្រធាន ស្នូ បានបង្រៀនថា ការបង់ដង្វាយមួយភាគក្នុងដប់បាននាំមកនូវពរជ័យជាច្រើន ។ ដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់ដើម្បីកសាងការិយាល័យមួយដូចជាការិយាល័យដែលបានបង្ហាញនៅទីនេះ (ទីក្រុង សលត៍ លេក ទស្សនវត្ថុឆ្នាំ 1880) ។ ខាងឆ្វេង ៖ ដើម្បីរៀបចំទទួលមិត្តភក្តិខ្លះៗ ប្រធាន ស្នូបានធ្វើទម្រដើងទានពីមើមឆៃថាវដើម្បីបំភ្លឺគេហដ្ឋានរបស់លោក ។*

បន្ទាប់មកប្រើឥទ្ធិពលនោះដោយផ្ទាល់សម្រាប់ការពង្រីកអំណាចរបស់ខ្លួនលោកឬ ? ទេ តែផ្ទុយទៅវិញ គាត់ត្រូវបានហៅដើម្បីធ្វើមុខតំណែងបែបនោះនៅក្នុងគោលការណ៍ដូចគ្នានឹងបព្វជិតភាពដែលត្រូវបានប្រទានឱ្យព្រះរាជបុត្រានៃព្រះ គឺថាគាត់គួរតែធ្វើការបូជា ។ សម្រាប់ខ្លួនគាត់ឬ ? ទេ ប៉ុន្តែគឺសម្រាប់ជាប្រយោជន៍របស់មនុស្សដែលគាត់ធ្វើជាអធិបតី ។ … គឺដើម្បីក្លាយជាអ្នកបម្រើបងប្អូនរបស់គាត់ មិនមែនធ្វើជាចៅហ្វាយរបស់ពួកគេទេ ហើយដើម្បីធ្វើការសម្រាប់ប្រយោជន៍ និង សុខុមាលភាពរបស់ពួកគេ » ។ [4]

ក្នុងនាមជាអ្នកដឹកនាំសាសនាចក្រមួយរូប ប្រធាន ស្នូ បានអនុវត្តគោលការណ៍នេះ ហើយពេលខ្លះលោកបានបង្កើតវិធីជាច្រើនដើម្បីធ្វើបែបនោះ ។ តួយ៉ាង មានពេលមួយនោះ លោកបានប្រើ មើមឆៃថាវ កម្រាលពូក និង ស្បូវដើម្បីបំផុសវិញ្ញាណរបស់ពួកបរិសុទ្ធដែលរងទុក្ខមួយក្រុម ។ ដំណើររឿងនេះមាននៅក្នុងជំពូកទី 7 ។ ដើម្បីអានបន្ថែមទៀតពីការបង្រៀនរបស់លោក អំពីថ្នាក់ដឹកនាំនៅក្នុងសាសនាចក្រ សូមមើលជំពូកទី 18 ។

ប្រធាន ស្នូ គឺជាអ្នកដឹកនាំដែលពោរពេញដោយអំណាច កែច្នៃ និង មានប្រសិទ្ធភាព ពីព្រោះ លោកបានដឹងថា តើនរណាជាអ្នកដឹកនាំដ៏ពិត ។ លោកបានបង្រៀនថា « ឥឡូវនេះកិច្ចការដ៏អស្ចារ្យកំពុងត្រូវបានសម្រេច—គឺការប្រមូលនៃប្រជាជនពីគ្រប់ប្រជាជាតិលើផែនដីដែលមិនមាននៅក្នុងដួងចិត្តរបស់បុគ្គលណាម្នាក់ ឬ ក្រុមណាមួយ ប៉ុន្តែគឺវាមានប្រភពមកពីព្រះអម្ចាស់ដ៏មានព្រះចេស្ដារ » ។ [5] នៅក្នុងឆ្លើយតបចំពោះការប្រមូលផ្ដុំនៃសមាជិកសាសនាចក្រ ដែលផ្ដល់កិត្តិយសដល់លោកក្នុងបុណ្យគម្រប់ខួបកំណើតទី 85ឆ្នាំរបស់លោក នោះលោកបានមានប្រសាសន៍ថា

« ទោះជាយ៉ាងណា ខ្ញុំទទួលអារម្មណ៍ថា អ្វីៗដែលខ្ញុំបានសម្រេចនោះគឺមិនមែនមកពីឡូរែនស្នូ ស្នូ ទេ ហើយបទពិសោធន៍ទាំងឡាយដែលបាននាំខ្ញុំមកកាន់មុខតំណែងជាប្រធាននៃសាសនាចក្រ—នោះគឺមិនមែនជាឡូរែនស្នូ ស្នូ ផងដែរ ប៉ុន្តែគឺមកពីព្រះអម្ចាស់បានធ្វើវា » ។ [6]

លោកបានបង្រៀនសេចក្ដីពិតនេះនៅពេញអស់ទាំងនៃការបម្រើរបស់លោក ប៉ុន្តែលោកត្រូវបានរំឭកអំពីតំណែងនេះជាការពិសិដ្ឋ និង តាមរបៀបផ្ទាល់ខ្លួនពីមុនលោកបានក្លាយជាប្រធាននៃសាសនាចក្រ ។ លោកបានក្លាយជាសាវកច្បងនៅក្នុងសាសនាចក្រ នៅពេល ប្រធាន វិលហ្វឺដ វូឌ្រុហ្វ ទទួលមរណៈភាពកាលពីថ្ងៃទី 21 ខែ កញ្ញា ឆ្នាំ 1898 ។ ដោយគិតពិចារណាពីខ្លួនរបស់លោកថា មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីរែកពន់ទំនួលខុសត្រូវនេះ លោកបានទៅក្នុងបន្ទប់មួយតែម្នាក់ឯងក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ដើម្បីអធិស្ឋាន ។ លោកបានទូលអង្វរសុំការណែនាំ ប៉ុន្តែគ្មានបានទទួលចម្លើយចំពោះការអធិស្ឋានរបស់លោកឡើយ ដូច្នេះបន្ទាប់ពីនោះមក លោកបានចេញពីបន្ទប់ ហើយចូលទៅសាលធំ ។ នៅទីនោះហើយដែលលោកបានទទួលចម្លើយ ។ ព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញបានឈរនៅពីមុខលោក កំពស់ប្រហែលជាបីហ្វីត (1 ម៉ែត្រ) ពីឥដ្ឋ ហើយមានបន្ទូលប្រាប់លោកពីរបៀបដើម្បីបន្ដទៅមុខក្នុងនាមជាថ្នាក់ដឹកនាំរបស់សាសនាចក្រ ។ ដើម្បីសិក្សាបន្ថែមទៀតអំពីបទពិសោធន៍នេះ សូមមើលជំពូកទី 20 ។

ប្រធាន ស្នូ ត្រូវបានគេស្គាល់យ៉ាងច្បាស់អំពីការទទួលវិវរណៈមួយ ស្ដីពីច្បាប់ដង្វាយមួយភាគក្នុងដប់ ។ សម្រាប់សមាជិកនៃសាសនាចក្រក្នុងឆ្នាំ 1899 វិវរណៈនេះបានចាប់ផ្ដើមដោយការថ្លែងយ៉ាងម៉ឺងម៉ាត់ថា ៖ « ឥឡូវនេះដល់ពេលសម្រាប់ពួក



*ឡូរែនសូ ស្នូ បានមានបទពិសោធន៍ដ៏ពិសិដ្ឋដែលបានឃើញព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញនៅក្នុងព្រះវិហារបរិសុទ្ធ សតល៍ លេក ។*



បរិសុទ្ធគ្រប់រូបដែលមានជំនឿ ដើម្បីរៀបចំសម្រាប់អនាគត និង ដើម្បីឈរជើងឱ្យមាំនៅលើគ្រឹះដ៏ត្រឹមត្រូវ ដើម្បីធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ និង ដើម្បីបង់ដង្វាយមួយភាគក្នុងដប់របស់ខ្លួនឱ្យបានពេញលេញហើយ ។ នោះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់មកដល់អ្នករាល់គ្នា » ។[7]

ពួកបរិសុទ្ធថ្ងៃចុងក្រោយបានឆ្លើយតបយ៉ាងស្មោះត្រង់ចំពោះការទូន្មានរបស់ព្យាការីពួកគេ ហើយជាលទ្ធផលព្រះអម្ចាស់បានប្រទានពរដល់ពួកគេម្នាក់ៗ និង ដល់ពួកគេទាំងអស់គ្នា ។ ឥទ្ធិពលនៃវិវរណៈនោះបានបន្តរហូតមកដល់សព្វថ្ងៃនេះ នៅពេលដែលសមាជិកនៃសាសនាចក្រទូទាំងពិភពលោកបានទទួលពរជ័យខាងវិញ្ញាណ និងខាងសាច់ឈាមតាមរយៈការគោរពតាមច្បាប់ដង្វាយមួយភាគក្នុងដប់នេះ ។ ដើម្បីអានអំពីបទពិសោធន៍ដែលដឹកនាំដល់វិវរណៈនេះ និង ពរជ័យទាំងឡាយដែលបានទទួល សូមមើលជំពូកទី 12 ។

ដូចជាព្យាការីគ្រប់រូបដែរ ប្រធាន ស្នូ បានថ្លែងទីបន្ទាល់ដ៏មានអំណាចអំពីព្រះយេស៊ូវគ្រីស្ទ ។ លោកបានបង្រៀនថា ៖ « យើងទាំងអស់គ្នាពឹកផ្អែកលើព្រះយេស៊ូវគ្រីស្ទ លើការយាងមកលើផែនដីរបស់ទ្រង់ដើម្បីបើកផ្លូវឱ្យយើងទទួលសេចក្ដីសុខសាន្តសុភមង្គល និង ភាពលើកតម្កើង ។ ហើយបើទ្រង់មិនបានបំពេញកិច្ចការនេះទេ នោះយើងមិនអាចត្រូវបានសង្គ្រោះនៅក្នុងពរជ័យ និង ឯកសិទ្ធទាំងឡាយដែលធានាចំពោះយើងនៅក្នុងដំណឹងល្អឡើយ » ។ [8] លោកបានថ្លែងទីបន្ទាល់អំពីកំណើតរបស់ព្រះអង្គសង្គ្រោះ, ការបម្រើក្នុងជីវិតរមែងស្លាប់, ដង្វាយធួន, ទំនាក់ទំនងផ្ទាល់ទៅនឹងការស្ដារឡើងវិញនៃសាសនាចក្ររបស់ទ្រង់ និង ការយាងមកជាលើកទីពីរ ។ សម្រាប់ពាក្យពេចន៍បន្ថែមទៀតនៃទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ សូមមើល ជំពូកទី 24 ។

ពិតមែនហើយ អត្ថបទខ្លីមួយនេះ អាចផ្ដល់ព័ត៌មានស្ដួចស្ដើងអំពីខ្សែជីវិត និង

ការបម្រើរបស់ប្រធាន ស្ន តែប៉ុណ្ណោះ ។ នៅក្នុងការសិក្សារបស់អ្នកអំពី*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរ៉េនសូ ស្នូ*នោះអ្នកនឹងដឹងពីដំណើររឿងដ៏បំផុសគំនិតជាច្រើនទៀត, រួមទាំងដំណើររឿងពីឱកាសនៃការបង្រៀនដំបូងរបស់លោកក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា, ភាពអស្ចារ្យដ៏ពោរពេញរបស់គាត់នៅពេលត្រូវបានហៅឱ្យបម្រើនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់, អារម្មណ៍របស់លោកពេលធ្វើដំណើរលើកប៉ាល់នៅលើមហាសមុទ្រអាតាឡង់ទិចអំឡុងពេលព្យុះសង្ឃរាដ៏សាហាវ និង ឧទាហរណ៍ចំនួនបួនអំពីអំណាចនៃបព្វជិតភាពដែលជួយសង្គ្រោះដល់មនុស្ស ឱ្យរួចពីសេចក្ដីស្លាប់ (រួមទាំងខ្លួនលោក ឡូរ៉េនសូ ស្នូ ផ្ទាល់) ។ អ្នកអាចរៀនច្រើនពីការបង្រៀនរបស់លោកពីប្រធានបទផ្សេងៗជាច្រើន រួមទាំង សាមគ្គីភាព, ការបន្ទាបខ្លួន, សេចក្ដីសញ្ញា, កិច្ចការព្រះវិហារបរិសុទ្ធ, ទំនាក់ទំនងគ្រួសារ, ការពុះពារសម្រាប់ភាពល្អឥតខ្ចោះ, បព្វជិតភាព, សមាគមសង្គ្រោះ និង សេចក្ដីអំណរនៃការចែកចាយដំណឹងល្អ ។

បើអ្នកបានឆ្លៀតពេលដើម្បីអាន និង ពិចារណាពីដំណើររឿងមួយចំនួន និង ការបង្រៀនដែលបានរៀបរាប់នៅក្នុងអត្ថបទនេះ—ឬ សូម្បីតែ អ្នកប្ដេជ្ញាថា អ្នកនឹងអានដំណើររឿងនោះនៅពេលណាមួយឆាប់ៗនេះ—នោះអ្នកទទួលការអះអាងថា ប្រធាន ស្នូ នឹងពេញចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នក ។ លោករៀនពេញមួយជីវិតរបស់លោក ហើយលោកបានបង្រៀនថា យើងគួរតែ « ខំប្រឹងប្រែងដោយខ្លួនយើងផ្ទាល់ » ដូច្នេះយើងអាច « រីកលូតលាស់ក្នុងគោលការណ៍ទាំងឡាយនៃសេចក្ដីពិត » និង « បង្កើនចំណេះដឹងនៃស្ថានសួគ៌ » ។ [9] លោកបានជម្រុញថា « សូមឱ្យគ្រប់ថ្ងៃ ឬ សប្ដាហ៍ដែលបានកន្លងទៅថ្មីៗនេះ ថាវាគួរតែជាបទពិសោធន៍ល្អបំផុតដែលយើងអាចមាន ថាយើងគួរតែអភិវឌ្ឍខ្លួនរបស់យើងបន្ដិចម្ដងៗជារៀងរាល់ថ្ងៃ ក្នុងចំណេះដឹង និង ប្រាជ្ញា និង ក្នុងសមត្ថភាពដើម្បីសម្រេចសេចក្ដីល្អ » ។ [10]

សូមឱ្យជីវិតរបស់អ្នកឆ្នាំនេះរីកចម្រើនតាមរយៈការសិក្សារបស់អ្នកអំពី*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរ៉េនសូ ស្នូ* ។ នៅពេលអ្នកសិក្សា នោះអ្នកអាចមានបទពិសោធន៍មួយស្រដៀងនឹងមន្ត្រីល្អម្នាក់ដែលបានជួបប្រធាន ស្នូ ដោយផ្ទាល់នោះ ។ លើសពីការមើលឃើញនូវទឹកមុខដ៏សប្បុរស និង កែវភ្នែកដ៏ស្ងៀមស្ងាត់ នោះអ្នកក៏អាចទទួលអារម្មណ៍ថា អ្នកឈរនៅទីបរិសុទ្ធ—មិនមែនដោយសារអ្នកស្គាល់ ឡូរ៉េនសូ ស្នូ ទេ ប៉ុន្តែដោយសារអ្នកខិតកាន់តែជិតព្រះវរបិតាសួគ៌របស់អ្នក និង ព្រះយេស៊ូវគ្រីស្ទ ដែលលោកគឺជាសាក្សីម្នាក់ ។ ■

**កំណត់ចំណាំ**

1. ផ្ទៃខាងក្រោម ដោយការគោរព ដកស្រង់ពី*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរ៉េនសូ ស្នូ* (ឆ្នាំ 2012) ទំព័រ 30 ។
2. សូមមើល ដេវីឌ អេ បែដណា « អ្នកត្រូវកើតជាថ្មីម្ដងទៀត » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2007 ទំព័រ 19–22 ។
3. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ* ទំព័រ 68 ។
4. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 219 ។
5. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 153 ។
6. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 148 ។
7. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 157 ។
8. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 280–81 ។
9. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 65 ។
10. *ការបង្រៀន ៖ ឡូរ៉េនសូ ស្នូ*ទំព័រ 103 ។

ព័ត៌មានលម្អិតមកពី រចនាលម្អរូបភាពនៃបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ*ការយាងមកជាលើកទីពីរ*ដោយ ហ្រ្គេន រ៉ូមនី ខ្លាសុន © IRI

**លក្ខណៈពិសេសៗនៃ*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរ៉េនសូ ស្នូ***

សៀវភៅនេះជាការបន្ថែមលើបណ្ណាល័យសិក្សាផ្ទាល់ខ្លួន និង គ្រួសាររបស់អ្នកនៃ*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ* ។ ឥឡូវនេះមានសៀវភៅ 11ក្បាលដែលចេញជាឈុតហើយ ដែលការយល់ដឹងប្រកបដោយការបំផុសគំនិតលើប្រធានបទជាច្រើននៃដំណឹងល្អ ។ នេះគឺជាចំណុចសំខាន់ៗមួយចំនួននៃសៀវភៅនេះ ៖

- សេចក្ដីថ្លែងការណ៍ដ៏បំផុសគំនិតមកពីប្រធាន ឡូរ៉េនសូ ស្នូ មានប្រធានបទនៃដំណឹងល្អច្រើនជាង 75 ប្រធានបទ ។
- រូបគំនូរ និង រូបភាពថ្មីៗ បានមកពី ខ្សែជីវិតរបស់ ឡូរ៉េនសូ ស្នូ ដែលសមាជិកភាគច្រើនមិនធ្លាប់បានឃើញសោះ ។
- ជំនួយ នៃការបង្រៀន និង ការសិក្សាបីយ៉ាង ក្នុងជំពូកនិមួយៗ ៖ សំណួរដែលធ្វើឱ្យមានការគិត ព្រះគម្ពីរដែលទាក់ទងនឹងប្រធានបទក្នុងជំពូក និង ការបង្រៀនដែលជួយដើម្បីកែលម្អការចូលរួម និង ការពិភាក្សាក្នុងថ្នាក់រៀន ។
- សេចក្ដីណែនាំបីទំព័រដើម្បីជួយសមាជិកទាំងឡាយពង្រីកការសិក្សារបស់ពួកគេពី សៀវភៅ និង បង្រៀនដោយការបំផុសគំនិតនៅឯគេហដ្ឋាន ឬ ព្រះវិហារ ។




សៀវភៅនេះក៏មាននៅលើអ៊ីនធើរណែតផងដែរនៅគេហទំព័រ LDS.org និង Gospel Library នៅក្នុងកម្មវិធីរបស់ app (ជាភាសាអង់គ្លេស) នៅគេហទំព័រ mobile.lds.org ។




# ការស្គាល់ប្រធាន ឡូរ៉េនសូ ស្នូ

**ដោយ គ្រីស្ទស្តូហ្វើ ឌី ហ្វូស**

នៅឆ្នាំនេះ សៀវភៅសិក្សាសម្រាប់ថ្នាក់សមាគមសង្គ្រោះ និង ថ្នាក់បព្វជិតភាពមិលគីស្សាដែក ផ្ដោតលើខ្សែជីវិត និង ការបង្រៀនរបស់ប្រធាន ឡូរ៉េនសូ ស្នូ (ឆ្នាំ 1814–1901) ។ ដោយសារតែអាយុនៃក្រុមរបស់អ្នក ប្រហែលជាមិនអាចប្រើប្រាស់សៀវភៅនេះ នោះ មិនមានន័យថា អ្នកមិនអាចរៀនព័ត៌មានបន្ថែមពីលោកឡើយនោះទេ ។ ប្រធាន ស្នូ បានដឹកនាំនៅក្នុងជីវិតមួយដ៏អស្ចារ្យដែលពោរពេញដោយការលំបាក និង ជោគជ័យ ។

## ពានរង្វាន់សម្រាប់ដំណឹងល្អ

ដំបូងឡើយ ឡូរ៉េនសូ ស្នូ បានឮពីសាសនាចក្រតាំងពីលោកនៅក្មេង ។ មុនដំបូងលោកពុំមានបំណងប្រាថ្នា ដើម្បីជ្រមុជទឹកឡើយ សូម្បីតែបងស្រីរបស់លោក គឺ អេលីស្សា (គឺជា អេលីស្សា អ័រ ស្នូ ដែលជាអ្នកនិពន្ធទំនុកតម្កើងជាច្រើនរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយបានបម្រើជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ) ដែលបានទទួលយក និងធ្វើតាមដំណឹងល្អទាំងស្រុង ។ ទោះបីជាយ៉ាងណាក៏ដោយ លោកបានឃើញថាគោលលទ្ធិរបស់សាសនាចក្រគឺគួរឱ្យចាប់អារម្មណ៍ណាស់ ។ នៅពេលប្រធាន ឡូរ៉េនសូ បានចាប់ផ្ដើមចូលរៀនមហាវិទ្យាល័យនៅទីក្រុង អូប៊ើលីន រដ្ឋ អូហៃអូ ជាញឹកញាប់លោកបានចែកចាយសេចក្ដីជំនឿរបស់សាសនាចក្រជាមួយនិស្សិតដែលកំពុងបំពាក់បំប៉នដើម្បីក្លាយជាមន្ត្រីរបស់ពួកប្រូតេស្តង់ ។ ទោះបីជាលោកមិនទាន់តាំងចិត្តដើម្បីជ្រមុជទឹកក៏ដោយ លោកបានបង្ហាញដំណឹងល្អយ៉ាងល្អដែលធ្វើឱ្យនិស្សិតជាច្រើននៅ អូប៊ើលីន បានព្រមទទួលយកសេចក្ដីពិតដែលមានរបស់សាសនាចក្រដែលបានស្ដារឡើងវិញ ។

លោកបានធ្វើជាអ្នកផ្សព្វផ្សាយសាសនាដ៏ពូកែពីមុនលោកបានទទួលយកដំណឹងល្អទៅទៀត ហើយវាមិនជាការចម្លែកនោះទេ ដែល ឡូរ៉េនសូ បានក្លាយជាអ្នកដែលមានការលះបង់ ចំពោះកិច្ចការផ្សព្វផ្សាយបន្ទាប់ពីលោកបានជ្រមុជទឹក ។ អំឡុងពេលដែលលោកបានក្លាយជាសមាជិកនៃសាសនាចក្រថ្មីៗ នោះលោកត្រូវបានហៅឱ្យបម្រើបេសកកម្មពេញម៉ោងជាច្រើនលើកច្រើនគ្រា ។ ដំបូងលោកបានបម្រើនៅក្នុង រដ្ឋ អូហៃអូ បន្ទាប់មក មិសសួរី, ខាន់តាក់គី និង អិលលីណោយ ស.អ.រ ។ បន្ទាប់មកលោកត្រូវបានបញ្ជូនទៅចក្រភពអង់គ្លេស ដើម្បីជួយរៀបចំសាសនាចក្រនៅប្រទេស អង់គ្លេស ។ ខណៈពេលដែលលោកបម្រើនៅទីនោះ លោកបានថ្វាយព្រះគម្ពីរមរមនជាច្រើនក្បាលដល់ ម្ចាស់ក្សត្រី វីចតូរីយ៉ា និង ព្រះអម្ចាស់ អាល់ប៊ើត ។ ក្រោយមកលោកបានបម្រើបេសកកម្មនៅក្នុងប្រទេស អ៊ីតាលី, ស្វីសស៊ើលែន ហើយទីបញ្ចប់នោះគឺនៅលើកោះមួយ ដែលសព្វថ្ងៃនេះត្រូវគេហៅថា កោះ ហាវ៉ៃ ។

## អព្ភូតហេតុនៅសមុទ្រ

នៅពេលអែលឌើរ ស្នូ បានចាកចេញពីប្រទេស អង់គ្លេស ដើម្បីត្រលប់ទៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ វិញ នោះលោកបាននាំសមាជិកមួយក្រុមធំដែលទើបតែជ្រមុជទឹករួចថ្មីៗមកជាមួយលោក ។ ពួកគេទាំងអស់គ្នាបានកក់សំបុត្រធ្វើដំណើរតាមកប៉ាល់ *ស្វានតុន* ហើយរៀបចំសម្រាប់ការធ្វើដំណើរដ៏ឆ្ងាយទៅកាន់ទ្វីបអាមេរិកប៉ែកខាងជើង ។



*នេះជារឿងមួយចំនួន ដែលអ្នកប្រហែលជាមិនដែលបានដឹងអំពី ប្រធានទីប្រាំនៃសាសនាចក្រនោះទេ ។*

ទោះបីជានាយនាវារបស់កប៉ាល់ *ស្វាទគុន* មិនមានចិត្តកំណាញ់ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយនៅលើកប៉ាល់របស់គាត់ក្ដី ក៏គាត់មិនសូវរាក់ទាក់ដែរ ។ គាត់តែងតែនៅឆ្ងាយពីពួកបរិសុទ្ធទាំងនោះ ។ ប៉ុន្តែប្រហែលជាពីរសប្ដាហ៍បន្ទាប់ពីការធ្វើដំណើរលើសមុទ្រ នោះមានអ្វីមួយបានកើតឡើង ។ អ្នកបម្រើក្នុងកប៉ាល់ម្នាក់របស់នាយនាវាមានរបួសយ៉ាងធ្ងន់ធ្ងរដោយគ្រោះថ្នាក់មួយ ។ គ្មាននរណាម្នាក់សង្ឃឹមថា អ្នកបម្រើនោះអាចនឹងរស់រហូតដល់ពេលព្រឹកនោះឡើយ ។

ប៉ុន្តែមានស្ត្រីដ៏ស្មោះត្រង់ម្នាក់ ដែលបានថែរក្សាអ្នកបម្រើដែលជិតស្លាប់នោះបានផ្ដល់យោបល់មួយ ។ នាងបានប្រាប់អ្នកបម្រើនោះថា អែលឌើរ ឡូរ៉េនសូ ស្នូ អាចផ្ដល់ការប្រសិទ្ធពរមួយដល់គាត់ ហើយថា ការប្រសិទ្ធពរនោះ នឹងជួយសង្គ្រោះជីវិតរបស់គាត់ ។ អ្នកបម្រើនោះ—ដែលកំពុងធ្វើការដើម្បីចិញ្ចឹមភរិយា និង កូនទាំងពីររបស់គាត់ដែលកំពុងរស់នៅប្រទេសអាល្លឺម៉ង់—បានយល់ព្រមមួយរំពេច ។

នៅកណ្ដាលអាធ្រាតនោះ គេបានដាស់ អែលឌើរ ស្នូ ហើយសុំឱ្យលោកទៅបន្ទប់បុរសដែលជិតស្លាប់នោះ ។ នៅពេលទៅដល់ លោកបានជួបនាយនាវានោះ ។ នាយនាវាបានថ្លែងអំណរគុណដែលលោកបានអញ្ជើញមក ប៉ុន្តែបានបង្ហាញពីភាពអស់សង្ឃឹមចំពោះស្ថានការណ៍នោះ ។ អែលឌើរ ស្នូ អាចមើលឃើញថា នាយនាវានោះបានយំ ។

លោកបានចូលទៅក្នុងបន្ទប់ ហើយបានដាក់ដៃលើក្បាលរបស់អ្នកបម្រើនោះ ហើយផ្ដល់ការប្រសិទ្ធពរបព្វជិតភាពមួយដល់គាត់ ។ បន្ទាប់ពី អែលឌើរ ស្នូ បានបញ្ចប់ការប្រសិទ្ធពរភ្លាម ស្រាប់តែអ្នកបម្រើនោះក្រោកអង្គុយ ហើយងើបចេញពីគ្រែ ។ អ្នកបម្រើនោះបានជាសះស្បើយទាំងស្រុង ហើយគាត់បានត្រឡប់ទៅធ្វើការរបស់គាត់វិញនៅថ្ងៃបន្ទាប់ ។

## តម្លៃនៃព្រលឹងទាំងឡាយ

ការព្យាបាលអ្នកបម្រើនៅលើកប៉ាល់*ស្វាទគុនបានធ្វើឱ្យមានការផ្លាស់ប្ដូរយ៉ាងច្រើនក្នុងការធ្វើដំណើរនោះ ។* នាយនាវាម្នាក់នោះ ចាប់ផ្ដើមចំណាយពេលនៅជាមួយពួកបរិសុទ្ធកាន់តែច្រើនតាមដែលគាត់អាច ហើយគាត់ថែមទាំងរៀនដំណឹងល្អ ហើយចូលរួមការប្រជុំរបស់សាសនាចក្រ ។ ពលទាហានជើងទឹកផ្សេងទៀតមានការភ្ញាក់ផ្អើល ។ នៅពេលកប៉ាល់ដល់ចំណត នោះក្រុមនាវិកបានលាពួកបរិសុទ្ធដោយក្ដីស្រឡាញ់ ។ តាមរយៈអំណាចនៃបព្វជិតភាព នោះមិនគ្រាន់តែអាចសង្គ្រោះជីវិតរបស់មនុស្សម្នាក់តែប៉ុណ្ណោះទេ គឺមានមនុស្សដទៃជាច្រើនទៀតដែលបានទទួលមួយចំណែកនៃអំណាច និង សេចក្ដីស្រឡាញ់របស់ព្រះ ។ នៅទីបំផុតអ្នកបម្រើនោះ និង សមាជិកជាច្រើននៃក្រុមនាវិកនោះបានជ្រមុជទឹក ។

មានព្រឹត្តិការណ៍ដ៏អស្ចារ្យជាច្រើនបានកើតឡើងនៅក្នុងជីវិតរបស់ប្រធាន ឡូរ៉េនសូ ស្នូ ។ ដូច្នេះ នៅឆ្នាំនេះខណៈពេលដែលមជ្ឈឹមវ័យសិក្សាអំពី*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ឡូរ៉េនសូ ស្នូ*ហេតុអ្វីអ្នកមិនសិក្សាវាផង ? នៅថ្ងៃអាទិត្យ ឬ នៅពេលអ្នកទំនេរ អ្នកអាចអានការបង្រៀនមួយចំនួនរបស់ប្រធាន ស្នូ ។ អ្នកអាចនឹងចែកចាយការពិភាក្សាដំណឹងល្អជាមួយគ្រួសារបានច្រើនថែមទៀត ហើយតាមរបៀប នេះ អ្នកនឹងស្គាល់បុរសដ៏អស្ចារ្យម្នាក់នេះដែលបានក្លាយជាព្យាការីរបស់ព្រះ ។ ■



*បានព្យាបាលអ្នកបម្រើរបស់នាយនាវា ពេលធ្វើដំណើរត្រឡប់ទៅទ្វីបអាមេរិកខាងជើងវិញ ។*

*បានថ្វាយព្រះគម្ពីរមរមនជាច្រើនក្បាលដល់ ម្ចាស់ក្សត្រី វិចតូរីយ៉ា និង ព្រះអម្ចាស់ អាល់ប៊ើត ។*

រចនារូបភាពដោយ ជូយ៉ាង ម៉េង ឆាង និង ជេមីរ៉េត ម៉ៃរឡៃ; MAP © ISTOCKPHOTO/THINKSTOCK។

**ដោយ អែលឌើរ**
**នែល អិល អាន់ឌើរសិន**
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*



# គារវភាពចំពោះព្រះគឺជាដើមចមនៃ ប្រាជ្ញា

*ប្រាជ្ញារបស់លោកិយគឺមានតម្លៃបំផុត នៅពេលវាឱនក្បាលចុះចូលយ៉ាងរាបទាបទៅនឹងប្រាជ្ញារបស់ព្រះ ។*

យើងរស់នៅក្នុងពិភពលោកមួយដែលពោរពេញដោយព័ត៌មានដ៏លើសលប់ ។ ប្រហែលជានិមិត្តសញ្ញានៃពិភពលោកនេះគឺជាគេហទំព័រ Wikipedia ដ៏អស្ចារ្យ ដែលជាវចនានុក្រមអត្ថាធិប្បាយនៅតាមអ៊ិនធើរណែតដ៏ធំបំផុត ។ ដើម្បីជួយឱ្យយល់ពីវិសាលភាពរបស់វា ដូចនៅក្នុងឆ្នាំ 2012 នេះគ្រាន់តែភាសាអង់គ្លេសវាមានពាក្យច្រើនជាង 2.5 កោដិពាក្យ ហើយមានអត្ថបទច្រើនជាង 22 លានអត្ថបទដែលមានប្រហែលជា 284 ភាសា ។ មានភាសាច្រើនជាង 70 ភាសារបស់គេហទំព័រ Wikipedia ដែលយ៉ាងហោចណាស់មាន10000 អត្ថបទក្នុងភាសានិមួយៗ ។ មានអត្ថបទច្រើនជាង 4 លានអត្ថបទជាភាសាអង់គ្លេស ។ [1]

ព័ត៌មានដ៏ច្រើនលើសលប់របស់យើងគឺជាភស្តុតាងចំពោះកំណើននៃការប្រើប្រាស់គេហទំព័រនៃបណ្ដាញសង្គម ដូចជា Facebook ដែលបានបង្កើតឡើងក្នុងឆ្នាំ 2004 ហើយមានអ្នកប្រើប្រាស់ដ៏សកម្មរហូតដល់ច្រើនជាង 1 កោដិនាក់ទូទាំងពិភពលោកនៅក្នុងឆ្នាំ 2012[2] ឬ គេហទំព័រ YouTube ដែលចាប់ផ្ដើមប្រើប្រាស់ក្នុងឆ្នាំ 2005 ដែលមានវីដេអូវគ្គខ្លីៗមួយចំនួនដែលបានរាយការណ៍ថា ត្រូវបានគេទស្សនាច្រើនជាង 100 លានដង ។

ជាមួយនឹងការកើនឡើងនូវព័ត៌មានដ៏ច្រើនលើសលប់នេះ យើងពិតជាត្រូវការប្រាជ្ញាយ៉ាងខ្លាំង ប្រាជ្ញាដើម្បីរៀបចំ និង ដឹងពីរបៀបដើម្បីអនុវត្តអ្វីដែលយើងកំពុងរៀន ។ ធី. អេស អេលីយុត ជាអ្នកមានជំនឿលើសាសនាគ្រីស្ទានម្នាក់បានសរសេរអត្ថបទជាច្រើនឆ្នាំកន្លងទៅ ដែលនិយាយមកកាន់ពិភពលោកយើងសព្វថ្ងៃនេះថា ៖

*ឱ ពិភពនៃរដូវផ្ការីក និង ស្លឹកឈើជ្រុះអើយ ឱ ពិភពនៃកំណើត និង មរណាអើយ !*
*ពិភពនៃគំនិត និង សកម្មភាពដែលមិនចេះចប់*
*ការប្រឌិតឡើងដ៏គ្មានទីបញ្ចប់ ការពិសោធន៍ដ៏មិនចេះចប់មិនចេះហើយ*
*ភាពគ្មានទីបញ្ចប់នេះនាំមកនូវចំណេះដឹងនៃការបង្កើតជាចលនា ប៉ុន្តែមិនបានបង្កើតជាភាពស្ងប់ស្ងាត់នោះទេ*
*ជាចំណេះដឹងនៃការនិយាយស្ដី ប៉ុន្តែមិនមែនជាចំណេះដឹងនៃការស្ងាត់ស្ងៀមនោះទេ*
*ជាចំណេះដឹងនៃពាក្យសំដី ហើយបដិសេធដំណឹងល្អ ។*
*ចំណេះដឹងខាងលោកិយទាំងអស់របស់យើង នាំយើងឱ្យកាន់តែបដិសេធចំណេះដឹងខាងវិញ្ញាណរបស់យើង*
*ការបដិសេធទាំងអស់របស់យើងនាំឱ្យយើងដើរទៅរកសេចក្ដីស្លាប់*
*ដើរទៅរកសេចក្ដីស្លាប់ តែមិនដើរទៅរកព្រះឡើយ ។*
*តើជីវិតខាងវិញ្ញាណនៅឯណា បើយើងផ្ដោតចិត្តតែលើជីវិតខាងលោកិយនោះ ?*
*តើប្រាជ្ញាខាងព្រះនៅឯណា បើយើងផ្ដោតចិត្តតែលើចំណេះដឹងខាងលោកិយនោះ ?*
*តើចំណេះដឹងខាងព្រះនៅឯណា បើយើងផ្ដោតចិត្តតែលើព័ត៌មានខាងលោកិយនោះ ?*
*ពេលវេលាកន្លងទៅអស់ម្ភៃសតវត្សន៍*
*នាំយើងឱ្យកាន់តែឃ្លាតឆ្ងាយពីព្រះ ហើយខិតទៅរករឿងឥតប្រយោជន៍* [3]



តើអ្នកនៅត្រង់ចំណុចណាលើជញ្ជីងនៃប្រាជ្ញា ? មានមនុស្សខ្លះគិតថាវាទាក់ទងនឹងស្ត្រីវ័យក្មេង ដែលរំភើបចំពោះអាពាហ៍ពិពាហ៍របស់នាងដែលនឹងមកដល់ឆាប់ៗ ដែលបាននិយាយដាក់ឪពុកម្ដាយនាងថា « អ៊ំ កូនរៀបការហើយ ។ ខ្ញុំផុតទុក្ខហើយ » ។ ហើយម្ដាយរបស់នាងបានខ្សឹបប្រាប់ឪពុកនាងថា « ចា៎ស ! មែនហើយ ប៉ុន្តែនាងមិនដឹងថា ផុតទុក្ខមួយណានោះទេ » ។

កាលណាខ្ញុំកាន់តែរៀនអំពីប្រាជ្ញារបស់ព្រះ នោះខ្ញុំកាន់តែជឿថា ខ្ញុំគ្រាន់តែនៅត្រង់ចំនុចចាប់ផ្ដើមនៃប្រាជ្ញាតែប៉ុណ្ណោះ ។ វាធ្វើឱ្យខ្ញុំមានការបន្ទាបខ្លួន នៅពេលខ្ញុំដឹងថា តើខ្ញុំត្រូវរៀនប៉ុណ្ណាទៀត ។ ថ្ងៃនេះ ខ្ញុំសង្ឃឹមថា យើងបង្កើនបំណងប្រាថ្នារបស់យើងដើម្បីទទួលបានប្រាជ្ញា ហើយជាពិសេសនោះ គឺប្រាជ្ញារបស់ព្រះ ។

## ពរជ័យទាំងឡាយនៃប្រាជ្ញា

ខ្ញុំចង់បញ្ជាក់ពីគោលការណ៍មួយចំនួនអំពីប្រាជ្ញា ។ ទីមួយ នៅក្នុងសម័យនៃព័ត៌មាន និង ចំណេះដឹងរបស់យើង នោះយើងត្រូវស្វែងរកប្រាជ្ញា ។ ប្រាជ្ញាមានច្រើនសណ្ឋាន និង មានលក្ខណៈផ្សេងៗពីគ្នា ។ ប្រាជ្ញាដែលទទួលបានភ្លាមៗ នាំមកនូវពរជ័យជាច្រើន ។ ប្រាជ្ញាលើផ្នែកអ្វីមួយ នោះវាមិនអាចផ្ទេរទៅផ្នែកមួយផ្សេងទៀតបានទេ ។ ហើយនៅទីបញ្ចប់ ក្នុងករណីជាច្រើនប្រាជ្ញារបស់លោកិយត្រូវបានគេឱ្យតម្លៃ នោះ គឺមានតម្លៃបំផុត នៅពេលវាចុះចូលយ៉ាងរាបទាបទៅនឹង ប្រាជ្ញារបស់ព្រះតែប៉ុណ្ណោះ ។

ព្រះគម្ពីរបានរៀបរាប់ពីប្រាជ្ញាពីរប្រភេទ ៖ ប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះ ។ ប្រាជ្ញារបស់លោកិយមានទាំងចំណុចវិជ្ជមាន និង អវិជ្ជមាន ។ នៅក្នុងការរៀបរាប់ដ៏ងងឹតងងល់បំផុតនោះ វាអាចពិពណ៌នាបានថា ជាចំណែកនៃសេចក្ដីពិតដែលលាយឡំជាមួយនឹងប្រាជ្ញា និង ឧបាយកល ដើម្បីសម្រេចនូវគោលបំណងនៃភាពអត្តានិយម ឬ បំណងអាក្រក់ទាំងឡាយ ។

ឧទាហរណ៍មួយមកពីព្រះគម្ពីរមរមន គឺបុរសម្នាក់ឈ្មោះ អាំលិចៃ ។ ព្រះគម្ពីរប្រាប់ថា « ត្បិតមានបុរសម្នាក់ ហៅថា អាំលិចៃ គាត់ជាមនុស្សប្រកបដោយកលល្បិច មែន*ហើយជាមនុស្សមានប្រាជ្ញាស្របតាមប្រាជ្ញានៃលោកិយ* ... [បានទាក់ទាញ] មនុស្សជាច្រើនទៅតាមគាត់ » ។ ព្រះគម្ពីរបានបន្តរៀបរាប់ពីអាំលិចៃទៀតថាជា « មនុស្សទុច្ចរិត ... [ដែល]មានបំណង[ចង់] បំផ្លាញសាសនាចក្រនៃព្រះចោល » (អាលម៉ា 2:1–2, 4 សេចក្ដីបញ្ជាក់ត្រូវបានបន្ថែម) ។ យើងមិនចាប់អារម្មណ៍ពីប្រាជ្ញាបែបនេះទេ ។

មានប្រាជ្ញារបស់លោកិយមួយប្រភេទទៀត ដែលមិនអាក្រក់ណាស់ណាទេ ។ តាមពិតទៅគឺវាមានភាពវិជ្ជមាន ។ ប្រាជ្ញានេះគឺជាចំណេះដឹងដែលទទួលបានតាមរយៈការសិក្សា ការគិតពិចារណា ការអង្កេត និង ការខិតខំធ្វើការ ។ វាពិតជាមានតម្លៃ និង មានប្រយោជន៍សម្រាប់អ្វីៗដែលយើងធ្វើ ។ ចំពោះមនុស្សល្អ និង ត្រឹមត្រូវ ចំណេះដឹងទាំងនោះកើតមានមកតាម បទពិសោធន៍នៅក្នុងជីវិតរមែងស្លាប់របស់យើង ។

អ្នកនឹងចងចាំពីយោបល់មួយរបស់អ្នកនិពន្ធជនជាតិអាមេរិកឈ្មោះ ម៉ាក ធ្វេន ថា ៖ « កាលពីខ្ញុំអាយុ 14 ឆ្នាំ ឪពុករបស់ខ្ញុំជាមនុស្សគ្មានការរៀនសូត្រទេ ហើយខ្ញុំមិនចង់នៅក្បែរគាត់សោះ ។ ប៉ុន្តែនៅពេលខ្ញុំឈានដល់អាយុ 21ឆ្នាំ ខ្ញុំមានការភ្ញាក់ផ្អើលពីអ្វីជាច្រើនដែលគាត់បានរៀនក្នុងរយៈពេល 7ឆ្នាំ » ។ [4] បើសិនជាយើងជាអ្នកអង្កេត បើសិនជាយើងជាមនុស្សចេះគិតគូរ នោះពេលវេលាដែលកន្លងទៅអាចបង្រៀនយើងច្រើនណាស់ ។

ខ្ញុំបានចាំពីពេលមួយដែលខ្ញុំបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ។ ខ្ញុំបានធ្វើដំណើរពីសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ទៅ ទីក្រុង ប្រេសស្តុន រដ្ឋ អៃដាហូ ស.អា.រ ជាកន្លែងដែលជីដូនរបស់ខ្ញុំឈ្មោះ ម៉ារី ខែលលើរ បានរស់នៅទីនោះ ។ កាលនោះគាត់មានអាយុ 78 ឆ្នាំ ហើយមានភាពជរាណាស់ ។ គាត់បានចែកឋានពីរឆ្នាំក្រោយមក ។ គាត់គឺជាស្ត្រីដ៏អស្ចារ្យម្នាក់ ហើយខ្ញុំដឹងថា បើសិនខ្ញុំស្ដាប់តាម ហើយរៀនពីបទពិសោធន៍របស់គាត់ នោះខ្ញុំអាចរៀនពីប្រាជ្ញាដែលនឹងជួយខ្ញុំឱ្យឆ្លងកាត់នូវបទពិសោធន៍ក្នុងឆាកជីវិតខ្ញុំ ។

*យើងអាចឆ្លងផុតពីបទពិសោធន៍ដ៏សោហ្មងជាច្រើនដែលកើតមាននៅក្នុងជីវិតរបស់មនុស្សមួយចំនួន ដោយការទទួលនូវប្រាជ្ញាតាំងពីនៅក្មេង ។*

យើងអាចឆ្លងផុតនូវបទពិសោធន៍ដ៏សោហ្មងជាច្រើនដែលកើតមាននៅក្នុងជីវិតរបស់មនុស្សមួយចំនួន តាមរយៈ ការទទួលនូវប្រាជ្ញាកាលពីនៅក្មេងនោះ—ដែលជាប្រាជ្ញាដែលលើសពីអាយុរបស់យើងទៀតនោះ ។ សូមស្វែងរកប្រាជ្ញានេះ—សូមគិតពិចារណា សូមអង្កេតដោយយកចិត្តទុកដាក់ សូមគិតអំពីអ្វីដែលអ្នកមានបទពិសោធន៍នៅក្នុងជីវិតនេះ ។

យើងអាចរៀនពីប្រាជ្ញានៅក្នុងជំនាញជាក់លាក់ និង ការស្វែងរកផ្ទាល់ខ្លួនរបស់យើង ។ ខ្ញុំសូមផ្ដល់ដល់អ្នកនូវឧទាហរណ៍ចំនួនពីរ ។

លោកវេជ្ជបណ្ឌិត ដេវ៉ន ស៊ី ហែល គឺជាគ្រូពេទ្យនៅក្នុងទីក្រុង សតល៍ លេក ដែលចម្រើនវ័យធំឡើងនៅក្នុងទីក្រុង អៃដាហូ ហ្វល រដ្ឋ អៃដាហូ ។ ខ្ញុំមានភាពអស្ចារ្យ ចំពោះចំណេះដឹងនឹងប្រាជ្ញារបស់គាត់ នៅពេលមានបញ្ហាអំពីជំងឺដែលបានកើតឡើងនៅតំបន់ត្រូពិក ។ វាមិនគ្រាន់តែដោយសារចំណេះដឹងរបស់លោកវេជ្ជបណ្ឌិត ហែល តែប៉ុណ្ណោះទេ វាមានទាំងការយល់ដឹងរបស់គាត់ពីរបៀបដើម្បីអនុវត្តចំណេះដឹងនោះផងដែរ ដោយរៀបតាមលំដាប់លំដោយនៃព័ត៌មានមួយចំនួន និង ការវិភាគប្រៀបធៀបនូវព័ត៌មានទាំងនោះ ។ វាគឺជាពរជ័យមួយដើម្បីមាននូវប្រាជ្ញាខាងវេជ្ជសាស្ត្របែបនោះសម្រាប់អ្នកផ្សព្វផ្សាយសាសនាជុំវិញពិភពលោក ។

ឧទាហរណ៍ទីពីរ ៖ នៅពេលកូនប្រុសច្បងរបស់យើងចាប់ផ្ដើមចូលរៀននៅបឋមសិក្សានៅក្នុងស្រុកកំណើតរបស់យើងនៅក្នុងទីក្រុង តាមប៉ា រដ្ឋ ហ្លរីដា ស.អា.រ នោះយើងបានអន្ទះសារដើម្បីជួបជាមួយ



គ្រូមត្តេយ្យរបស់គាត់ គឺលោកស្រី ជូឌីស ក្រេប៉ែល ។ គាត់ជាស្ត្រីម្នាក់អាយុ 50 ឆ្នាំ ហើយមានសម្ថភាពពិសេសជាមួយក្មេងតូចៗ ។ គាត់ដឹងពីរបៀបដើម្បីជម្រុញទឹកចិត្តពួកគេ ដឹងពីពេលដែលត្រូវសរសើរពួកគេ និងដឹងពីពេលដែលត្រូវតឹងរឹងជាមួយពួកគេ ។ គាត់មានចំណេះដឹងដើម្បីបង្រៀនពួកគេ ហើយ គាត់មានចំណេះជាច្រើនទៀត ។ យើងបានខិតខំដើម្បីយកកូនម្នាក់ៗរបស់យើងឱ្យចូលរៀនថ្នាក់មត្តេយ្យរបស់គាត់ ។

មនុស្សទាំងពីរនេះ ឆ្លុះបញ្ចាំងពីប្រាជ្ញាដ៏ចាំបាច់នៅក្នុងពិភពលោក ។ ប្រាជ្ញារបស់ពួកគាត់ គឺជាជំនួយមួយដល់មនុស្សជាច្រើន ហើយវាអាចធ្វើឱ្យពួកគាត់ទទួលបានភាពជោគជ័យនៅក្នុងអាជីពរបស់ពួកគាត់ ។

ទោះបីជាយ៉ាងណាក៏ដោយ យើងគួរតែដឹងពីព្រំដែននៃប្រាជ្ញានេះ ។ ប្រាជ្ញាលើជំនាញអ្វីមួយអាចនឹងមិនមានប្រយោជន៍លើប្រាជ្ញានៃជំនាញ ទៀតបានឡើយ ។ ឧទាហរណ៍ ខ្ញុំប្រហែលជាមិនចង់ឱ្យលោកស្រី ក្រេប៉ែល ធ្វើរោគវិនិច្ឆ័យពីជំងឺនៅតំបន់ត្រូពិកឡើយ ហើយខ្ញុំប្រហែលជាមិនចង់ឱ្យលោកវេជ្ជបណ្ឌិត ហែល បង្រៀនថ្នាក់សាលាមត្តេយ្យរបស់កូនៗខ្ញុំដែរ ។

អ្វីដែលសំខាន់ជាងនេះ គឺប្រាជ្ញាដែលនាំមកនូវភាពជោគជ័យនៅក្នុងពិភពលោកនេះ ត្រូវតែមានឆន្ទៈដើម្បីពឹងផ្អែកលើប្រាជ្ញានៃព្រះ ហើយសូមកុំគិតថាវាអាចជំនួសប្រាជ្ញារបស់ព្រះបាននោះឡើយ ។

*សូម*ចងចាំថា ៖ ប្រាជ្ញាទាំងអស់គឺមិនត្រូវបានបង្កើតមកស្មើគ្នានោះទេ ។

ទំនុកតម្កើងបានសរសេរថា « ឯសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃប្រាជ្ញា » ។ (ទំនុកតម្កើង 111:10) ។ អ្វីដែលព្រះគម្ពីរចង់មានន័យនោះគឺថាជា « គារវភាពដ៏ខ្លាំង » [5] ចំពោះ ព្រះអម្ចាស់គឺជាដើមចមនៃប្រាជ្ញា ។ គារវភាពដ៏ខ្លាំងនោះបានមកដោយសារព្រះវរបិតាសួគ៌របស់យើង « មានគ្រប់ប្រាជ្ញា និងគ្រប់ចេស្ដា ទាំងនៅលើស្ថានសួគ៌ និង នៅលើផែនដីផង » (ម៉ូសាយ 4:9) ។ ប្រាជ្ញារបស់ទ្រង់គឺល្អឥតខ្ចោះ ។ វាបរិសុទ្ធ ។ វាគ្មានភាពអត្មានិយមទេ ។

នៅក្នុងកាលៈទេសៈជាច្រើន ប្រាជ្ញានេះនឹងប្រឆាំងប្រាជ្ញារបស់លោកិយ មានន័យថាប្រាជ្ញារបស់ព្រះ និង ប្រាជ្ញារបស់លោកិយនឹងមានទិសដៅបញ្ច្រាសគ្នា ។

តើអ្នកចាំពីព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងព្រះគម្ពីរអេសាយដែរឬទេ ?

« ពីព្រោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គំនិតអញ មិនមែនដូចជាគំនិតរបស់ឯងរាល់គ្នាទេ ឯផ្លូវរបស់ឯងរាល់គ្នាក៏មិនមែនជាផ្លូវរបស់អញដែរ ។

« ត្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះអស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯងហើយគំនិតរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នាយ៉ាងនោះដែរ » (អេសាយ 55:8–9) ។

ប្រាជ្ញារបស់ព្រះនឹងមិនមករកយើងដោយសារតែយើងមានសិទ្ធទទួលឡើយ តែយើងត្រូវមានឆន្ទៈដើម្បីស្វែងរកប្រាជ្ញាទាំងនោះវិញ ។ « តែបើអ្នករាល់គ្នាណាមួយខ្វះ*ប្រាជ្ញា*មានតែ*សូម* ដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ ដោយសទ្ធា ឥតបន្ទោសផង

*ប្រាជ្ញាដែលនាំមកនូវភាពជោគជ័យនៅក្នុងពិភពលោកត្រូវតែមានឆន្ទៈដើម្បីពឹងផ្អែកលើប្រាជ្ញានៃព្រះ ហើយសូមកុំគិតថាវាអាចជំនួស ប្រាជ្ញារបស់ព្រះបាននោះឡើយ ។*

នោះទ្រង់នឹងប្រទានឲ្យ » (យ៉ាកុប 1:5 សេចក្ដីបញ្ជាក់ត្រូវបានបន្ថែម) ។

ប្រាជ្ញារបស់ព្រះគឺជាអំណោយខាងវិញ្ញាណមួយ ។ « *ចូរកុំស្វែងរកទ្រព្យសម្បត្តិឡើយ ប៉ុន្តែរកប្រាជ្ញាវិញ* ហើយមើលចុះ សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះនឹងបានបើកបង្ហាញដល់អ្នក ហើយខណៈនោះអ្នកនឹងបានទៅជាអ្នកមាន » (គ. និង ស. 6:7 សេចក្ដីបញ្ជាក់ត្រូវបានបន្ថែម) ។

ការស្វែងរកប្រាជ្ញារបស់ព្រះគឺតាមរយៈការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិទាំងឡាយជានិច្ច ។

ជាទូទៅ អំណោយខាងវិញ្ញាណនៃប្រាជ្ញាបានមកដោយសន្សឹមៗ នៅពេលដែលយើងស្វែងរកប្រាជ្ញានោះដោយសេចក្ដីស្មោះត្រង់ និងដោយការឧស្សាហ៍ព្យាយាម ។ « យើងនឹងប្រទានដល់កូនចៅមនុស្សមួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ ... នោះមានពរហើយដល់អស់អ្នកណាដែលប្រុងស្ដាប់តាមសិក្ខាបទទាំងឡាយរបស់យើង ត្បិតពួកគេនឹងមាន*ប្រាជ្ញា*ត្បិតចំពោះអ្នកណាដែលបានទទួលនោះយើងនឹងឲ្យថែមទៀត » នីហ្វៃទី 2 28:30 សេចក្ដីបន្ថែមត្រូវបានបញ្ជាក់) ។

យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា ៖ « កិច្ចការរបស់ព្រះគឺមានសារៈសំខាន់បំផុត ហើយយើងអាចស្វែងយល់កាលណាទាំងនោះបានតាមតែរយៈ ពេលវេលា និង បទពិសោធន៍ និង ការគិតប្រកបដោយការយកចិត្តទុកដាក់ និង ការពិចារណា និង ភាពហ្មត់ចត់ប៉ុណ្ណោះ » ។ [6] វាពុំចាំបាច់មានតម្រូវការច្រើនទេ ក្នុងការស្វែងរកប្រាជ្ញារបស់ព្រះនោះ ។

នៅទីបំផុត ប្រភពនៃប្រាជ្ញារបស់ព្រះ គឺខុសគ្នាពីប្រភពប្រាជ្ញារបស់លោកិយ ។ ប្រាជ្ញារបស់ព្រះអាចរកបាននៅក្នុងព្រះគម្ពីរ, នៅក្នុងការបង្រៀនទាំងឡាយរបស់ព្យាការី (ដូចជាអំឡុងពេលសន្និសីទទូទៅ) ពិតមែនហើយ ក៏អាចរកឃើញនៅក្នុងការអធិដ្ឋានរបស់យើងដែរ (សូមមើល គ. និង ស. 8:1–2) ។ ហើយជានិច្ចជាកាលប្រាជ្ញានេះ*តែងតែ*ប្រទានដល់យើងដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ។ សាវកប៉ុលបានមានប្រសាសន៍ថា ៖

« ត្បិតបើមិនមែនជាព្រះវិញ្ញាណ ដែលនៅក្នុងខ្លួនមនុស្សទេ នោះតើមានអ្វីនឹងស្គាល់សណ្ឋានមនុស្សនោះបាន ? ហើយបើមិនមែនជាព្រះវិញ្ញាណនៃព្រះនោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ ។ ...

« ហើយយើងក៏និយាយពីសេចក្ដីនោះឯងមិនមែនដោយពាក្យសំដីដែល*ប្រាជ្ញាមនុស្ស*បានបង្រៀនទេ គឺដោយពាក្យសំដីដែលព្រះវិញ្ញាណបង្រៀនវិញ » (កូរិនថូសទី 1 2:11, 13សេចក្ដីបញ្ជាក់ត្រូវបានបន្ថែម) ។

ជាមួយនឹងប្រាជ្ញារបស់ព្រះ នោះយើងអាចឃើញលើសពីកាលៈទេសៈបច្ចុប្បន្នរបស់យើងពីព្រោះដូចដែលព្រះគម្ពីរបានប្រាប់ « ព្រះវិញ្ញាណទ្រង់ ... មានព្រះបន្ទូលអំពីរឿងទាំងឡាយតាមដែលមាននៅពេលនេះ ហើយអំពីរឿងទាំងឡាយតាមដែលនឹងមាននៅពេលខាងមុខ » (យ៉ាកុប 4:13) ។

ប្រាជ្ញារបស់ព្រះ គឺជាប្រាជ្ញាដ៏សក្តិសមនៃការចេះគិតគូរដោយស្មោះត្រង់របស់យើង ។

*ប្រាជ្ញារបស់ព្រះអាចរកបាននៅក្នុងព្រះគម្ពីរ, នៅក្នុងការបង្រៀនរបស់ព្យាការីទាំងឡាយ (ដូចជាអំឡុងពេលសន្និសីទទូទៅ) ពិតមែនហើយ ក៏អាចរកបាននៅក្នុងការអធិស្ឋានរបស់យើងផងដែរ ។*

## ប្រាជ្ញា និង ដង្វាយមួយភាគក្នុងដប់

ប្រហែលជាចំណុចសំខាន់បំផុតគឺថា គ្មានប្រាជ្ញាទាំងអស់ណាដែលបង្កើតឲ្យបានស្មើគ្នាឡើយ ។ យើងត្រូវតែរៀនថា នៅពេលមានភាពផ្ទុយគ្នា រវាង ប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះ នោះយើងត្រូវតែបន្ទន់បំណង របស់យើងដើម្បីធ្វើតាម ប្រាជ្ញារបស់ព្រះ ។

យើងគឺជាបុត្រា និង បុត្រីទាំងឡាយរបស់ព្រះ ។ យើងគឺជាវិញ្ញាណនៅក្នុងជីវិតរមែងស្លាប់ហើយ យើងកំពុងស្ថិតនៅក្នុងបេសកកម្មមួយ ។ យើងគឺជាអ្នកបានឧទ្ទិសដើម្បីរៀនពីប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះមិនត្រូវមានការភាន់ច្រឡំថា ប្រាជ្ញាណាសំខាន់ជាងប្រាជ្ញាណាឡើយ ។

ខ្ញុំសូមចែកចាយពីបទពិសោធន៍មួយពីពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ថ្លៃថ្នូរម្នាក់ នៅក្នុងទីក្រុង សៅ ប៉ូឡូ ប្រទេស ប្រេស៊ីល ។ គាត់ប្រាប់ពីការពុះពាររបស់គាត់រវាងការបង់ដង្វាយ ឬ បង់ថ្លៃឈ្នួលសាលារៀន ។ នេះគឺជាពាក្យសម្ដីរបស់គាត់ ៖

« សាកលវិទ្យាល័យ ... មិនអនុញ្ញាតឲ្យប្រលងឡើយ ចំពោះនិស្សិតទាំងឡាយណាដែលជំពាក់ [ឬ អ្នកដែលមិនបង់ថ្លៃឈ្នួលសាលារៀនរបស់ពួកគេ] ។

« ខ្ញុំបានចាំពីពេលមួយ ពេលដែលខ្ញុំ ... មានបញ្ហាលំបាកខ្លាំងខាងផ្នែកហិរញ្ញវត្ថុ ។ នៅថ្ងៃព្រហស្បតិ៍មួយ នៅពេលដែលខ្ញុំបានបើកប្រាក់ខែរបស់ខ្ញុំ ។ នៅពេលដែលខ្ញុំចាត់ចែងថវិកាប្រចាំខែរបស់ខ្ញុំ នោះខ្ញុំចាប់អារម្មណ៍ថា គ្មានប្រាក់គ្រប់គ្រាន់ដើម្បីបង់ [ទាំង] ដង្វាយមួយភាគក្នុងដប់ និង ថ្លៃសាកលវិទ្យាល័យរបស់ខ្ញុំ ។ ខ្ញុំត្រូវតែជ្រើសរើស ថាត្រូវបង់ថ្លៃសាលា ឬ បង់ដង្វាយមួយភាគក្នុងដប់ ។ ការប្រលងរៀងរាល់ពីរខែម្ដង នឹងចាប់ផ្ដើមនៅសប្ដាហ៍បន្ទាប់ ហើយបើសិនខ្ញុំមិនបានប្រលងទេ នោះខ្ញុំនឹងអត់បានរៀន ។ ខ្ញុំមានអារម្មណ៍ច្របូកច្របល់យ៉ាងខ្លាំង ។ ... ដួងចិត្តរបស់ខ្ញុំឈឺចាប់ » ។

នេះគឺជាការប្រកួតប្រជែងផ្ទាល់រវាងប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះ ។ ទោះបីជាយ៉ាងណាក៏ដោយអ្នកគឺជាមនុស្សដ៏ល្អ និង សុចរិត បើសិនជាអ្នកស្មោះត្រង់ជាមួយខ្លួនឯង នោះអ្នកនឹងឃើញនៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងមានការពិបាកចិត្ត នៅពេលដែលអ្នកដឹងថាការប្រកួតប្រជែងនេះវានឹងកើតឡើងចំពោះ អ្នកនៅពេលខាងមុខ ។

ខ្ញុំសូមបកទៅនិយាយរឿងរបស់គាត់វិញ ។ ដំបូង គាត់បានបង់ដង្វាយមួយភាគក្នុងដប់របស់គាត់នៅថ្ងៃអាទិត្យ ។ នៅថ្ងៃច័ន្ទបន្ទាប់គាត់បានរៀបរាប់ពីអ្វីដែលបានកើតឡើង ៖

« ជិតដល់ម៉ោងចេញពីធ្វើការទៅហើយ ស្រាប់តែនាយករបស់ខ្ញុំបានដើរសំដៅមកកាន់ខ្ញុំ ហើយបានប្រគល់ ការបញ្ជាទិញចុងក្រោយឱ្យខ្ញុំធ្វើនៅថ្ងៃនោះ ។ ... ភ្លាមនោះ គាត់ឈប់មួយភ្លែត ហើយបានសួរខ្ញុំថា ‹ តើការសិក្សានៅមហាវិទ្យាល័យរបស់អ្នកយ៉ាងម៉េច ដែរ ? › [គាត់រៀបរាប់ថា នាយកនោះជាមនុស្សប៉ិនចំអន់ឱ្យគេណាស់ ហើយអ្វីដែលគាត់អាចនិយាយនោះគឺត្រឹមតែពាក្យថា ៖] ‹ អត់មានបញ្ហាអីទេ ! ›»

បន្ទាប់មកគាត់បានចេញទៅ ។ ភ្លាមនោះលេខារបស់គាត់បានដើរចូលមកក្នុងបន្ទប់នោះ ។ នាងបាននិយាយថា « លោកនាយកបានមានប្រសាសន៍ថា ចាប់ពីថ្ងៃនេះទៅ ក្រុមហ៊ុននឹងបង់លុយសម្រាប់ការសិក្សា និងសៀវភៅរបស់ឯងពេញតែម្ដង ។ មុនពេលអ្នកចេញពីធ្វើការ សូមទៅតុរបស់ខ្ញុំ ហើយសូមប្រាប់ខ្ញុំពីតម្លៃសាលា ដូច្នេះថ្ងៃស្អែកខ្ញុំអាចចេញជាមូលទានប័ត្រឱ្យអ្នក » ។ [7]

បើសិនជាអ្នកគិត មើលទៅ នោះអ្នកនឹងឃើញថាអ្នកបានជួបប្រទះនូវការសាកល្បងបែបនេះជាច្រើនដងពេញមួយជីវិតរបស់អ្នក ។ តើអ្នកនឹងដាក់ទីទុកចិត្តរបស់អ្នកនៅឯណា ? សូមស្ដាប់ការព្រមានដោយផ្ទាល់របស់ព្រះអម្ចាស់ចំពោះយើង ៖

« ឱ អំពើមោឃៈ និង ភាពទន់ខ្សោយ និង ការឆ្កួតលីលានៃមនុស្សលោកអើយ ! កាលណាគេបានរៀនសូត្រ [ពីប្រាជ្ញារបស់លោកិយ] គេ *ស្មានថាគេឆ្លាតវៃ*ហើយគេមិនស្ដាប់តាមពាក្យដំបូន្មាននៃព្រះឡើយ ព្រោះគេបានទុកមួយអន្លើដោយគិតស្មានថាគេបានដឹងខ្លួនគេដោយសព្វគ្រប់ហើយ [ប្រាជ្ញារបស់លោកិយ] ហេតុដូច្នោះហើយ*ប្រាជ្ញា*របស់គេគឺជាសេចក្ដីឆ្កួតលីលា ហើយមិនផ្ដល់ប្រយោជន៍អ្វីដល់ពួកគេឡើយ ។ ហើយពួកគេនឹងត្រូវវិនាសទៅ ។

« ប៉ុន្តែដែលបានរៀនសូត្រ [ពីប្រាជ្ញារបស់លោកិយ] គឺជាការល្អវិញ បើសិនជាគេស្ដាប់តាមពាក្យដំបូន្មាននៃព្រះ » (នីហ្វៃទី 2 9:28–29 សេចក្ដីបន្ថែមត្រូវបានបញ្ជាក់) ។

ឥឡូវនេះមកពី ប៉ុលវិញម្ដង ៖

« តើអ្នកប្រាជ្ញានៅឯណា ? ... ព្រះទ្រង់បានធ្វើឱ្យប្រាជ្ញារបស់លោកិយនេះទៅជាសេចក្ដីល្ងង់ល្ងើវិញទេតើ ? (កូរិនថូស 1 1:20) ។

« កុំឱ្យអ្នកណាបញ្ឆោតខ្លួនឡើយ ។ បើអ្នកណាក្នុងពួកអ្នករាល់គ្នាស្មានថា ខ្លួនមានប្រាជ្ញាក្នុងលោកិយនេះ ត្រូវឱ្យអ្នកនោះត្រឡប់ជាល្ងង់ល្ងើវិញ ដើម្បីឱ្យមានប្រាជ្ញាឡើង ។

« ពីព្រោះ*ប្រាជ្ញារបស់លោកិយនេះ*ជាសេចក្ដីល្ងង់ល្ងើនៅចំពោះព្រះ » (កូរិនថូសទី 1 3:18–19 សេចក្ដីបន្ថែមត្រូវបានបញ្ជាក់) ។

ការសាកល្បងគឺមានជានិច្ច ទោះជាយើងនឹងអនុញ្ញាតឱ្យប្រាជ្ញារបស់ព្រះធ្វើជាការនាំផ្លូវដល់យើង នៅពេលប្រាជ្ញារបស់ព្រះមាន

*សូមគិតអំពីប្រាជ្ញារបស់ព្រះលើហិរញ្ញវត្ថុផ្ទាល់ខ្លួន ។ យើងចំណាយប្រាក់ឱ្យបានត្រឹមត្រូវដោយបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ ហើយបង់ដោយសទ្ធាចំពោះដង្វាយផ្សេងៗទៀតរបស់យើង ។*



ទិសដៅ ផ្ទុយពីប្រាជ្ញារបស់លោកិយក៏ដោយ ។

អាំម៉ូន បានទូញយំថា « ព្រោះពួកគេពុំស្វែងរកប្រាជ្ញា [ប្រាជ្ញារបស់ព្រះ] ហើយពួកគេក៏មិនចង់ឲ្យប្រាជ្ញាដឹកនាំគេដែរ » (ម៉ូសាយ 8:20) ។ នៅពេលគិតដល់អស់អ្នកដែលមានឆន្ទៈដើម្បីឲ្យប្រាជ្ញារបស់ព្រះដឹកនាំពួកគេ នោះខ្ញុំនឹកដល់មិត្តម្នាក់របស់ខ្ញុំនៅប្រទេសចិនដីគោក ឈ្មោះ ស្យេ យីង ដែលធ្វើការលះបង់យ៉ាងអស្ចារ្យដើម្បីចូលជាសមាជិកនៃសាសនាចក្រ ហើយបម្រើបេសកកម្មមួយនៅក្នុងទីក្រុង ញូវ យក ។ ខ្ញុំគិតពីកូនស្រីពីរនាក់របស់ខ្ញុំ ពួកគេទាំងពីរមានប្រាជ្ញាណាស់ដោយបានបញ្ចប់សញ្ញាប័ត្រអនុបណ្ឌិត តែបានជ្រើសរើសពរជ័យធ្វើជាម្ដាយ និងសម្រាប់កូនៗវិញ ។ ខ្ញុំគិតអំពីមិត្តម្នាក់ដែលមកពី អាមេរិកខាងត្បូង ដែលបានចាកចោលការងារដ៏មានប្រាក់ចំណេញច្រើន នៅពេលគាត់បានដឹងថាថៅកែរបស់គាត់មានការគេចពន្ធខុសច្បាប់នោះ ។ អ្នកទាំងអស់នោះបានដាក់ប្រាជ្ញារបស់ព្រះនៅលើប្រាជ្ញារបស់លោកិយ ។

គួរឲ្យស្ដាយណាស់ ប្រាជ្ញារបស់លោកិយអាចបោកបញ្ឆោតមនុស្សដែលមានសមត្ថភាពបាន ។ យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍បែបនេះថា ៖ « មានអ្នកមានប្រាជ្ញាទាំងប្រុស និងស្រីដ៏អស្ចារ្យជាច្រើននៅក្នុងចំណោមពួកយើង ដែលមានប្រាជ្ញាខ្ពស់ពេកដើម្បីទទួលការបង្រៀន ហេតុដូច្នោះហើយពួកគេនឹងស្លាប់ក្នុងភាពល្ងង់ខ្លៅរបស់ពួកគេ ហើយនៅក្នុងដំណើររស់ឡើងវិញ នោះពួកគេនឹងឃើញពីកំហុសរបស់ពួកគេ » ។ [8]

**ប្រាជ្ញា និង ហិរញ្ញវត្ថុ**

ដោយមានការលំបាកជាច្រើននៅក្នុងសេដ្ឋកិច្ចរបស់យើង ខ្ញុំសូមលើកយកបញ្ហានៃហិរញ្ញវត្ថុផ្ទាល់ខ្លួនមកពិភាក្សា ។ នៅក្នុងលក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្នរបស់យើង យើងទាំងអស់គ្នាមានការងាយស្រួលដើម្បីបន្ទាបខ្លួន និង ងាយបង្រៀន—ប៉ុន្តែសូមគិតត្រឡប់ទៅកាលពីពីរបីឆ្នាំមុន ។

លោកិយបង្រៀនថា បើសិនយើងចង់បានអ្វីមួយ នោះយើងគួរតែបានអ្វីដែលយើងចង់បាននោះ ។ យើងមិនគួររង់ចាំនោះទេ ។ បំណុលអាចឲ្យយើងមានទូវអ្វីៗទាំងនោះក្នុងពេលឥឡូវនេះ ។ បំណុលនោះអាចកើតមានតាមរយៈ កាតឥណទាន ឬ អាចមកតាមរយៈការខ្ចីប្រាក់យ៉ាងច្រើនពីធនាគារដោយដាក់បញ្ចាំផ្ទះដែលយើងមាន ។ យើងអាចដាក់បញ្ចាំអ្វីដែលយើងមាន សូម្បីតែការអប់រំរបស់យើង ។ តម្លៃនៃការខ្ចីប្រាក់នឹងកើនឡើងជានិច្ច ហើយយើងនឹងចម្រើនឡើង ។ ប្រាជ្ញារបស់លោកិយគឺថា ចំនួនទឹកប្រាក់ដែលបង់សងប្រាក់ចម្ចីប្រចាំខែ នោះវាសំខាន់ជាងចំនួនសរុបនៃប្រាក់ចម្ចី ។ កាតព្វកិច្ចដើម្បីបង់សងប្រាក់កម្ចីរបស់យើង គឺអាស្រ័យសមត្ថភាពរបស់យើង ហើយបើយើងធ្វើមិនបាន នោះជម្រើសចុងក្រោយរបស់យើង គឺ ការក្ស័យធន ។

ឥឡូវនេះសូមគិតអំពីប្រាជ្ញារបស់ព្រះលើបញ្ហាហិរញ្ញវត្ថុផ្ទាល់ខ្លួន ដែលតែងតែបង្រៀនជាប់ជានិច្ចដោយព្យាការី ។ គ្រឹះសំខាន់នោះគឺ ភាពខ្លួនទីពឹងខ្លួន និង ការងារ ។ យើងចំណាយប្រាក់ឲ្យបានត្រឹមត្រូវ ដោយបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ ហើយបង់ដោយសទ្ធាចំពោះដង្វាយផ្សេងៗទៀតរបស់យើង ។ យើងចាយវាយតិចជាងប្រាក់ចំណូលរបស់យើង ហើយយើងត្រូវធ្វើការបែងចែករវាងអ្វីដែលជាតម្រូវការចាំបាច់ និង ការចង់បានរបស់យើង ។ យើងគួរតែចៀសវាងពីបំណុលលើកលែងតែសម្រាប់អ្វីដែលជាសេចក្តីត្រូវការចាំបាច់បំផុតប៉ុណ្ណោះ ។ យើងរស់នៅតាមថវិការបស់យើង ។ យើងសន្សំប្រាក់មួយចំនួន ។ យើងស្មោះត្រង់នៅក្នុងគ្រប់កាតព្វកិច្ចទាំងអស់របស់យើង ។

កាលពី 14ឆ្នាំមុន ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី (ឆ្នាំ 1910–2008) បានព្រមានថា ៖ « ខ្ញុំសូមផ្ដល់យោបល់ថា វាដល់ពេលសម្រាប់យើងរៀបចំផ្ទះរបស់យើងឲ្យមានរបៀបរៀបរយហើយ ។ « ត្បិតមានប្រជាជនយើងជាច្រើន កំពុងរស់នៅយ៉ាងផុតផើយជាមួយនឹងចំណូលរបស់ពួកគេ ។ តាមពិតទៅមានអ្នកខ្លះរស់នៅដោយប្រាក់កម្ចី ។ ... មានការព្រមានជាមុនពីអាកាសធាតុដែលមានព្យុះ ដែលយើងត្រូវតែប្រុងស្ដាប់តាមឲ្យបានកាន់តែច្បាស់ » ។ [9]

*មានអ្វីៗជាច្រើនដែលយើងអាចរៀនពីប្រាជ្ញាក្នុងពេលឥឡូវនេះ ។ ខ្ញុំសូមសន្យានឹងអ្នកថាពរជ័យរបស់ព្រះអម្ចាស់នឹងមានមកដល់អ្នកនៅពេលអ្នកស្វែងរកប្រាជ្ញា—ដែលជាប្រាជ្ញារបស់ព្រះ ។*

បីបួនឆ្នាំកន្លងទៅ នៅពេលភាពរីកចម្រើនរបស់យើងមានកម្រិតខ្ពស់បំផុត ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖

« បងប្អូនប្រុសស្រី សូមចៀសវាងពីទស្សនៈដែលថា ភាពឆើតឆាយកន្លងទៅបានក្លាយជាភាពចាំបាច់នៅពេលបច្ចុប្បន្ននេះឡើយ ។ វាមិនចាំបាច់ឡើយ លុះត្រាយើងធ្វើឲ្យវាចាំបាច់ ។ មានមនុស្សជាច្រើនបានធ្លាក់ទៅក្នុងបំណុលយូរអង្វែងដោយសារមានការផ្លាស់ប្ដូរកើតឡើង ៖ មនុស្សជាច្រើនបានធ្លាក់ខ្លួនឈឺ ឬ ពិការ, ក្រុមហ៊ុនបិទទ្វារ ឬ ដួលរលំ, បាត់បង់ការងារ, គ្រោះធម្មជាតិបានកើតឡើងដល់យើង ។ ដោយមានហេតុផលជាច្រើន នោះការបង់សងប្រាក់បំណុលដែលមានចំនួនច្រើនពេក មិនអាចសង្ឃឹម ។ បំណុលរបស់យើងក្លាយជាដាវដ៏មុតស្រួចដែលព្យួរលើក្បាលរបស់យើងហើយគំរាមកំហែងដើម្បីបំផ្លាញយើង ។

« ខ្ញុំសុំដម្រុញអ្នកឲ្យចាយវាយទៅតាមចំណូលរបស់អ្នក ។ បុគ្គលម្នាក់មិនអាចចំណាយប្រាក់ច្រើនជាងអ្វីដែលគាត់រកបាន ហើយនៅមានប្រាក់សងគេទៀតនោះទេ ។ ខ្ញុំសូមសន្យាថា អ្នកនឹងរីករាយជាង កាលពីមុនពីការខ្វល់ខ្វាយជាប់រហូតនូវ របៀបដើម្បីបង់សងប្រាក់បន្ត ទៀត លើបំណុលដែលមិនចាំបាច់នោះ ។ [10]

តើអ្នកបានឃើញពីរបៀបដែលប្រាជ្ញារបស់ព្រះអាចធ្វើការប្រកួតប្រជែងជាមួយប្រាជ្ញារបស់លោកិយដែរឬទេ ? ជម្រើសគឺវាមិនច្បាស់លាស់ទេ នៅពេលអ្វីៗទាំងអស់មើលទៅ




រីកចម្រើននោះ ។ សមាជិកជាច្រើននៃសាសនាចក្របានប្រាថ្នាថា ពួកគេគួរតែបានស្ដាប់ដោយយកចិត្តទុកដាក់កាលពីពេលមុននោះ ។

នេះគឺជាប្រាជ្ញារបស់ព្រះ ។

ខ្ញុំផ្ដល់យោបល់ដល់អ្នកថា សូមដកយកបញ្ហាមួយចំនួនដែលអ្នកជួបប្រទះចេញ ។ សូមគូសបន្ទាត់មួយនៅចំកណ្ដាលក្រដាសនោះ ។ សូមធ្វើបញ្ជីនៃប្រាជ្ញារបស់លោកិយនៅផ្នែកខាងឆ្វេង និង ប្រាជ្ញារបស់ព្រះនៅផ្នែកខាងស្ដាំ ។ សូមសរសេរពីបញ្ហាទាំងឡាយណាដែលមានការប្រកួតប្រជែងគ្នា ។

តើអ្នកនឹងជ្រើសរើសយកមួយណា ?នៅក្នុងកណ្ឌទី 45នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ដែលបានប្រាប់ពីព្រឹត្តិការណ៍ដែលឆ្ពោះទៅរកការយាងមកជាលើកទីពីរនៃព្រះអង្គសង្គ្រោះ នោះព្រះអម្ចាស់បានប្រាប់ម្ដងទៀតនូវរឿងអំពីស្ត្រីព្រហ្មចារីដប់នាក់ ហើយបានបន្សល់នូវបន្ទូលទាំងនេះថា ៖ « ត្បិតពួកអ្នកណាដែលមានប្រាជ្ញា ហើយបានទទួលសេចក្ដីពិត ហើយបានទទួលយកព្រះវិញ្ញាណបរិសុទ្ធទុកជាអ្នកណែនាំរបស់ខ្លួន ហើយដែលពុំត្រូវគេបញ្ឆោត—យើងប្រាប់អ្នកជាប្រាកដថា ពួកគេនឹងពុំត្រូវកាប់បោះចោលទៅក្នុងភ្លើងឡើយ ប៉ុន្តែនឹងធន់នៅថ្ងៃនោះវិញ » (គ. និង ស. 45:57) ។ សូមឱ្យយើងស្វែងរកប្រាជ្ញារបស់ព្រះ ។ នៅទូទាំងពិភពលោក យើងកំពុងមានភាពលំបាកខាងសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ននេះ ហើយវាបាននាំឱ្យមានកង្វល់នៅពេលយើងដាក់ផែនការសម្រាប់ការងារ, អាជីព និង ប្រាក់ចំណូល ។ ប៉ុន្តែមានពេលជាច្រើនដែលល្អៗ និង រីកចម្រើននៅថ្ងៃខាងមុខ ។ មានអ្វីៗជាច្រើនដែលយើងអាចរៀនពីប្រាជ្ញាក្នុងពេលឥឡូវនេះ ។ ខ្ញុំសូមសន្យានឹងអ្នកថា ពរជ័យរបស់ព្រះអម្ចាស់នឹងមានមកដល់អ្នកនៅពេលអ្នកស្វែងរកប្រាជ្ញា—ដែលជាប្រាជ្ញារបស់ព្រះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៃពិធីចែកសញ្ញាប័ត្រដែលបានធ្វើឡើងនៅថ្ងៃទី 10 ខែ មេសា ឆ្នាំ 2009 នៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់–រដ្ឋ អៃដាហូ ។ សម្រាប់អត្ថបទទាំងមូលជាភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័រ http://web.byui.edu/DevotionalsAndSpeeches* ។

***សូមដកយកបញ្ហាមួយចំនួនដែលអ្នកជួបប្រទះចេញ ។ សូមគូសបន្ទាត់មួយនៅចំកណ្ដាលក្រដាសនោះ ។ សូមធ្វើបញ្ជីនៃប្រាជ្ញារបស់លោកិយនៅផ្នែកខាងឆ្វេង និង ប្រាជ្ញារបស់ព្រះនៅផ្នែកខាងស្ដាំ ។ សូមសរសេរពីបញ្ហាទាំងឡាយណាដែលមានការប្រកួតប្រជែងគ្នា ។***

**កំណត់ចំណាំ**

1. សូមមើល អែនដ្រូ លី *The Wikipedia Revolution* (ឆ្នាំ 2009) ទំព័រ xv–xvi សូមមើលផងដែរនូវគេហទំព័រ http://en.wikipedia.org/wiki/Wikipedia:Size_comparisons; http://wikimediafoundation.org/wiki/FAQ/en; http://en.wikipedia.org/wiki/History_of_Wikipedia ។
2. សូមមើល រ៉ាមូណា អ៊ីមើសុន “Facebook Users Expected to Pass 1 Billion in August: iCrossing,” *The Huffington Post,* ថ្ងៃទី 14 ខែ មករា ឆ្នាំ 2012, www.huffingtonpost.com/2012/01/13/facebook-users-Å-billion-icrossing_n_1204948.html ។
3. « Choruses from ‹ The Rock,›» នៅក្នុង *T. S. Eliot: The Complete Poems and Plays, ឆ្នាំ 1909–1950* (ឆ្នាំ 1980) ទំព័រ 96 ។
4. *Mark Twain Laughing: Humorous Anecdotes by and about Samuel L. Clemens,* បោះពុម្ពដោយ ភី អ៊ិម ស្ប្រាល (ឆ្នាំ 1985) ទំព័រ xxii ។
5. សូមមើល ម៉ារ៉ុន ដី រ៉មនី “Converting Knowledge into Wisdom,” *Ensign* ខែ កក្កដា ឆ្នាំ 1983 ទំព័រ 5 ។
6. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* (ឆ្នាំ 2007) ទំព័រ 267 ។
7. នៅក្នុង ហ្គរដុន ប៊ី ហ៊ិងគ្លី “We Walk by Faith,” *លីអាហូណា* ខែ កក្កដា ឆ្នាំ 2002 ទំព័រ 81–82 ។
8. *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ 202 ។
9. ហ្គរដុន ប៊ី ហ៊ិងគ្លី “To the Boys and to the Men,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1998 ទំព័រ 53 ។
10. ថូម៉ាស អេស ម៉នសុន « ពិតចំពោះសេចក្ដីជំនឿ » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2006 ទំព័រ 19 ។

# ការបង្រៀនក្នុងផ្ទះ
## ដែលប្រកបដោយអត្ថន័យ

*វិធីបួនយ៉ាងដែលយើងបង្រៀនកូនចៅរបស់យើងអំពីមេរៀនសំខាន់ៗនៃជីវិត*

**ដោយ ដារែន អ៊ី ស្មីត**

ការចាប់យកឱកាសចំពោះពេលបង្រៀនទាំងឡាយ ជាមួយកូនប្រាំបីនាក់របស់យើង ពិតជាពិបាក ហើយក៏ផ្ដល់ជាប្រយោជន៍ផងដែរ ។ ដោយការដឹងថា « ផ្ទះសំបែងគឺជាទីកន្លែងដំបូង និងមានអានុភាពបំផុតសម្រាប់ក្មេង ដើម្បីនឹងរៀនអំពីមេរៀនជីវិត » [1] ប្រពន្ធរបស់ខ្ញុំ និងខ្ញុំបានព្យាយាមធ្វើឱ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីជួយកូនរបស់យើងរៀនមេរៀនទាំងនោះ ។ ទាំងនេះគឺជាគោលការណ៍ខ្លះៗដែលជាជំនួយដ៏ធំចំពោះយើង ។

## ចូរធ្វើ*កិច្ចការ*ដ៏ល្អបំផុតទាំងឡាយ

កាលដែលកូនរបស់យើងចូលប្រឡូកក្នុងសកម្មភាពកាន់តែច្រើនៗ ការដាក់អាទិភាពក៏កាន់តែចាំបាច់ទៅៗផងដែរ ។ អែលឌើរ ដាល្លិន អេក. អូក នៃកូរ៉ុមសាវកដប់ពីរនាក់បានបង្រៀនថា ៖ « មិនមែនគ្រាន់តែអ្វីដែលល្អគឺជាមូលហេតុគ្រប់គ្រាន់ដើម្បីធ្វើនោះទេ ។ … មានអ្វីៗជាច្រើនដែលប្រសើរជាងការគ្រាន់តែល្អ ហើយរឿងទាំងនេះគួរតែជារឿងដែលបញ្ជាឱ្យផ្ដោតយកចិត្តទុកដាក់ជាចម្បងនៅក្នុងជីវិតរបស់យើង » ។ គាត់បានមានប្រសាសន៍ទៀតថា ៖ « មាតាបិតាគប្បីគួរខ្នះខ្នែងដើម្បីរក្សាពេលវេលាសម្រាប់ការអធិស្ឋានជាក្រុមគ្រួសារ ការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ រាត្រីជួបជុំក្រុមគ្រួសារ ហើយនិងការជួបជុំដ៏មានតម្លៃឯទៀត និងពេលវេលាផ្ទាល់ ម្នាក់ទល់នឹងម្នាក់ ដែលចងចំណងក្រុមគ្រួសារមួយជាមួយគ្នា ហើយជួសជុលគោលតម្លៃរបស់កូនៗ ទៅលើអ្វីៗដែលមានតម្លៃដ៏អស់កល្បជានិច្ច ។ មាតាបិតាគប្បីបង្រៀនពីសារៈសំខាន់នៃដំណឹងល្អ តាមរយៈអ្វីៗដែលពួកគាត់ធ្វើចំពោះកូនៗរបស់ខ្លួន » ។ [2]

នេះត្រូវបានបង្ហាញថាជាដំបូន្មានដ៏ល្អសម្រាប់ក្រុមគ្រួសាររបស់យើង។ ព្រោះតែខ្ញុំ ហើយនិងភរិយាបានរៀបចំសកម្មភាពឱ្យកូនៗយើង នៅខាងក្រៅផ្ទះ គឺជារឿងរ៉ាវនៃការសញ្ជឹងគិត និងការអធិស្ឋាន សកម្មភាពខ្លះដែលយើងបានគិតថាសំខាន់ បែរទៅជាមិនសំខាន់ចាំបាច់វិញ ។ ជាពិសេស ខ្ញុំមានចិត្តភ្ញាក់ផ្អើលនៅពេលខ្ញុំបានសួរកូនៗរបស់យើង ប្រសិនបើពួកគេចង់ចូលរួមក្នុងក្រុម កីឡាបាល់បោះដោយមានខ្ញុំធ្វើជាអ្នកបង្ហាត់របស់ពួកគេ ។ ចម្លើយរបស់គេគឺ « ខ្ញុំមិនចង់ឱ្យប៉ាធ្វើជាអ្នកបង្ហាត់ទេ ព្រោះយើងមានតារាងបោះនៅខាងមុខផ្ទះហើយ ហើយយើងចង់ឱ្យប៉ាលេងជាមួយយើង ហើយនៅពេលយើងមានការប្រកួតជាមួយអ្នកជិតខាងរបស់យើងដែរ ។ យើងអាចលេងបាល់បានកាន់តែច្រើនទៀតផង ! »

## សិក្សា និង អនុវត្តតាមព្រះគម្ពីរ

មានទូវភាពខុសគ្នាដ៏ធំរវាង*ការអាន*ព្រះគម្ពីរ និង*ការសិក្សា*ព្រះគម្ពីរ ។ ព្យាការីបុរាណឈ្មោះយ៉ូស្វេបានបង្រៀនថា ជោគជ័យក្នុងការសិក្សាព្រះគម្ពីរបានមក នៅពេលយើង « គឺត្រូវជញ្ជឹងគិតទាំងយប់ទាំងថ្ងៃ » ហើយ « ប្រព្រឹត្តិតាម*អស់ទាំងសេចក្ដីដែលកត់ទុក* ក្នុងគម្ពីរនេះឯង » (យ៉ូស្វេ 1:8; ការបញ្ជាក់បានបញ្ចូលបន្ថែម) ។ ក្នុងកំឡុងពេលការសិក្សាព្រះគម្ពីរជាក្រុមគ្រួសាររបស់យើង យើងទទួលបានជោគជ័យដ៏ច្រើនបំផុត នៅពេលយើងផ្ដល់ពេលវេលាដល់កូនៗរបស់យើង ដើម្បីនឹងសញ្ជឹងគិតអំពីសំណួរច្បាស់លាស់នានា រួចហើយផ្ដល់នូវការអញ្ជើញឱ្យ « អនុវត្តតាមអ្វីៗទាំងអស់ដែលបានសរសេរចុះ » ។

រាត្រីមួយយើងកំពុងតែបរិភោគបង្អែម និងអានព្រះគម្ពីរមរមនអំពីការធ្លាក់ចុះរបស់សាសន៍នីហ្វៃ ។ ខ្ញុំត្រូវបានបំផុសគំនិតឱ្យសួរកូនៗអំពីមូលហេតុអ្វី ដែលពួកគេគិតថាសាសន៍នីហ្វៃបានត្រឡប់ទៅជាទុច្ចរិត ។ កូនស្រីអាយុប្រាំមួយឆ្នាំឈ្មោះសេឡេស បានគិតថា សាសន៍នីហ្វៃ និងសាសន៍លេមិនបានឈប់ធ្វើការ អធិស្ឋានប្រចាំថ្ងៃរបស់ពួកគេឡើយ ។ យើងទាំងអស់គ្នាបានយល់ស្របថា ការធ្លាក់ចុះរបស់សាសន៍នីហ្វៃបានចាប់ផ្ដើមជាមួយនឹងការភ្លេចនូវ ការអធិស្ឋាន ដែលសមាជិកក្រុមគ្រួសារ



ឯទៀតបានគិតថាជាទង្វើដ៏តូចតាចមួយ ។ ក្នុងមួយពព្រិចភ្នែកនោះគំនិតមួយបានផុសឡើងចំពោះខ្ញុំ ឱ្យអញ្ជើញកូនៗអធិស្ឋានដោយមានគំនិតហើយអារម្មណ៍កាន់តែហ្មត់ចត់ជាងមុន ។

ថ្ងៃបន្ទាប់មក ខ្ញុំបានសួរពួកគេអំពីការអធិស្ឋានរបស់គេ ។ រឿងនេះបានផ្ដល់ដល់ពួកគេនូវឱកាស ដើម្បីនឹងចែករំលែកបទពិសោធន៍របស់ពួកគេ ហើយបាន ផ្ដល់ដល់ខ្ញុំ នូវឱកាសដើម្បីនឹងចែករំលែកទីបន្ទាល់នៃការអធិស្ឋានរបស់ខ្ញុំថែមទៀត ។ ពុំមែនរាល់បទពិសោធន៍នៃការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ មានលទ្ធផលវិជ្ជមានបែបនេះនោះឡើយ ប៉ុន្ដែនៅពេលយើងបានផ្ដល់នូវការពិភាក្សា និងការអញ្ជើញទាំងឡាយដើម្បីនឹងអនុវត្តជាផ្នែកនៃការសិក្សារបស់យើង ព្រះគម្ពីរនឹងកាន់តែមានអត្ថន័យថែមទៀត ។

## ជួយកូនៗឱ្យមានទំនួលខុសត្រូវ

យើងបានរកឃើញអំណាចដ៏ធំ ក្នុងការផ្ដល់ធុរៈនានា ដល់កូនៗរបស់យើង ហើយទុកឱ្យពួកគេ ស្វែងរកសេចក្ដីលំអិតសម្រាប់ខ្លួនគេផ្ទាល់ ។ នៅពេលយើងទុកឱ្យកូនៗរបស់យើងចូលរួម និងជួយធ្វើការសម្រេចចិត្តជា

*ក្នុងកំឡុងពេលសិក្សាព្រះគម្ពីររបស់យើង យើងបានទទួលជោគជ័យបំផុត គឺនៅពេលយើងផ្ដល់ពេលវេលាដល់កូនៗរបស់យើង ដើម្បីនឹងជញ្ជឹងគិតពីសំណួរទាំងឡាយ ហើយផ្ដល់នូវការអញ្ជើញឱ្យពួកគេអនុវត្តតាម ។*

ក្រុមគ្រួសារខ្លះ នោះពួកគេនឹងក្លាយទៅជាអ្នកចូលរួមដ៏សកម្មជាងមុន ។ ពួកគេក៏អភិវឌ្ឍន៍នូវការវិនិច្ឆ័យចំពោះកម្មសិទ្ធិ និងទំនួលខុសត្រូវ ហើយហេតុនោះរៀន « ប្រព្រឹត្តអ្វីៗជាច្រើន តាមបំណងចិត្តរបស់ខ្លួន ហើយនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន » (គ. និង ស. 58:27) ។ ខាងក្រោមនេះគឺជារឿងខ្លះដែលបានជួយកូនៗរបស់យើងឱ្យកាន់តែមានទំនួលខុសត្រូវ ៖

- សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ជួយពួកគេរៀបចំមេរៀនព្រះគម្ពីរ ឬទេពកោសល្យនៃជម្រើសផ្ទាល់របស់ ពួកគេ ។
- អនុញ្ញាតពួកគេឱ្យជ្រើសរើសទំនុកតម្កើងសម្រាប់សមាជិកគ្រប់រូបច្រៀង នៅក្នុងកំឡុងពេលការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ រួចហើយចាត់កូនម្នាក់ឱ្យអធិស្ឋាន ។
- អនុញ្ញាតឱ្យពួកគេជួយរៀបចំផែនការនិងមានទំនួលខុសត្រូវចំពោះផ្នែកនៃការធ្វើដំណើរជាក្រុមគ្រួសារមួយ ។
- ប្រារព្ធការប្រឹក្សាជាក្រុមគ្រួសារជាមួយពួកគេអំពីរឿងរ៉ាវផ្នែកលុយកាក់ ហើយអនុញ្ញាតឱ្យពួកគេធ្វើការសម្រេចចិត្តអំពីការចាយវាយ ។

រូបថតដោយ ក្រូឌី ប៊ើល © IRI



- បង្រៀនពួកគេអំពីរបៀបធ្វើការងារណាមួយ ហើយផ្ដុកឱ្យគេចាត់ចែងលើការងារនោះ សម្រាប់រយៈពេលមួយសប្ដាហ៍ ។
- ធ្វើគម្រោងការបម្រើជាក្រុមគ្រួសារប្រចាំខែ ហើយអនុញ្ញាតឱ្យពួកគេសម្រេចចិត្តថា តើអ្នកណាម្នាក់ដែលក្រុមគ្រួសារត្រូវជួយ ។
- អនុញ្ញាតឱ្យគេផ្លាស់ប្ដូរវេនគ្នា ក្នុងការជ្រើសនរណាម្នាក់ ដើម្បីនឹងទៅសួរសុខទុក្ខក្នុងថ្ងៃអាទិត្យណាត់ទុកណាមួយនោះ ។
- អនុញ្ញាតឱ្យពួកគេជ្រើសយកសកម្មភាពជាក្រុមគ្រួសារ សម្រាប់រាត្រីណាមួយក្នុងកំឡុងខែ ។

## ណែនាំពួកគេ

មានពេលវេលាខ្លះ នៅពេលដែលប្រពន្ធរបស់ខ្ញុំហើយនិងខ្ញុំបានអារម្មណ៍ដូចជាអ្នកគង្វាលចៀម កៀងប្រមូលកូនៗរបស់យើងសម្រាប់ការអធិស្ឋានឬការសិក្សាព្រះគម្ពីរ ។ ប៉ុន្តែក្នុងពេលវេលាខ្លះទៀត ខ្ញុំមានអារម្មណ៍នៃវិញ្ញាណដ៏ផ្អែមល្ហែមជ្រៀតចូលមក នៅពេលដែលយើង ពិតជាបានឃ្វាល និងថែទាំហ្វូងចៀមដ៏តូចរបស់យើង ។ ប្រសិនបើយើងមិនប្រុងប្រយ័ត្នទេ យើងអាចបាត់បង់នូវឱកាសនៃការគង្វាលចៀមទាំងនេះ ។

ឱកាសបែបនេះមួយ បានមកដល់ នៅពេលខ្ញុំកំពុងតែយកកូនៗរបស់យើងចូលដេក ។ កូនប្រុសម្នាក់របស់ខ្ញុំបានសួរថា « ប៉ា តើមានអ្វីខ្លះល្បួងប៉ា ? »

ខ្ញុំបានភ្ញាក់ផ្អើលនឹងសំណួរនោះណាស់ ។

រួចហើយគេបាននិយាយថា « យើងកំពុងតែនិយាយអំពីអ្វីដែលល្បួងយើង ហើយយើងឆ្ងល់ថា តើមានអ្វីខ្លះ ដែលល្បួងប៉ា » ។

ខ្ញុំបានដឹងថា ពេលនេះគឺជាពេលដ៏ល្អបំផុតដើម្បីនឹងបង្រៀនពួកគេ ប៉ុន្តែខ្ញុំបាននឿយហត់យ៉ាងខ្លាំងពី ការខំធ្វើការពេញមួយថ្ងៃ ។ ខ្ញុំគ្មានបំណងចំពោះការសន្ទនាដ៏ជ្រៅជ្រះជាមួយក្មេងប្រុសពីរនាក់ ក្នុងពេលអាធ្រាតបែបនេះ ជា ពិសេសក្នុងរាត្រីរៀនសូត្រឡើយ ។

ប៉ុន្តែ រឿងរបស់ព្រះសង្គ្រោះនៅឯអណ្ដូងទឹកបានផុសឡើងក្នុងគំនិតរបស់ខ្ញុំ ។ សូម្បីតែបន្ទាប់ពីការដើរ 30 ម៉ៃ (48 គ.ម.) ឬច្រើនជាង ទ្រង់បានចំណាយពេលបង្រៀនស្ត្រីសាសន៍ សាម៉ារីដែរ (សូមមើលយ៉ូហាន 4) ។ ខ្ញុំបានសម្រេចចិត្តថា ពេលនេះគឺជាឱកាសមួយនៃឱកាសដែលមាននៅ « អណ្ដូងទឹក » នោះហើយ ខ្ញុំក៏អង្គុយចុះហើយ បានសួរពួកគេប្រសិនបើពួកគេគិតថា គឺជាអំពើបាបមួយដោយត្រូវបានល្បួង ។ មានការសញ្ជឹងគិតមួយរយៈ រួចហើយយើងបានចាប់ផ្ដើមនិយាយ និងស្ដាប់គ្នាទៅវិញទៅមក ។ ខ្ញុំបានបង្រៀនពួកគេអំពីការប្រឈមមុខរបស់ព្រះអង្គសង្គ្រោះជាមួយសាតាំង (សូមមើលម៉ាថាយ 4) ហើយបានថ្លែងទីបន្ទាល់របស់ខ្ញុំអំពីព្រះពរដែលមកពីការទប់ទល់នឹងសេចក្ដីល្បួង ។

គឺជាគ្រាដ៏ពិសេសមួយ ក្នុងនាមជាមាតាបិតា ។ យើងបានចូលសម្រាន្តយឺតជាងពេលសព្វដង ប៉ុន្តែសេចក្ដីអំណរដែលខ្ញុំបានមានពិសោធន៍ ពិតជាសក្ដិសមនឹងពលិកម្មជាងការចូលសម្រាន្តទៅទៀត ។

« ឱកាសដ៏ចាំបាច់មួយរបស់យើង គឺដើម្បីនឹងឆ្លើយតបចំពោះកូនណាម្នាក់ នៅពេលពួកគេសាកសួរដោយចិត្តស្មោះថា ពួកគេមិន*តែងតែ*សុំ ថាពួកគេមិន*តែងតែ*ចង់ចេះចង់ដឹង ថាពួកគេមិន*តែងតែ*ស្ដាប់តាមនោះឡើយ » អែលឌើររីឆាដ អិល. អ៊ីវែនស៍ (1906–71) នៃកូរ៉ុមសាវកដប់ពីរនាក់ ។ « ហើយជាញយៗ យើងធ្វើទំនាក់ទំនងជាមួយពួកគេតាម*លក្ខខណ្ឌ*របស់ពួកគេ*ពេលវេលា*របស់ពួកគេ ហើយពុំមែនតាម*លក្ខខណ្ឌ*របស់យើង និងក្នុង *ពេលវេលា*របស់យើងឡើយ ។ ...ប្រសិនបើពួកគេអាចទុកចិត្តយើងជាមួយនឹងសំណួរដ៏តូចតាចរបស់ពួកគេ ពួកគេប្រហែលជាទុកចិត្ត យើងនៅពេលក្រោយ ជាមួយនឹងសំណួរដែលកាន់តែសំខាន់ៗឯទៀត ។ [3]

## បានជ្រើសរើស និងជួយដោយព្រះអម្ចាស់ ។

ទំនួលខុសត្រូវដើម្បីមើលថែកូនចៅរបស់ព្រះអម្ចាស់ គឺជាទំនួលខុសត្រូវដ៏ធ្ងន់មួយ ។ នៅពេលណាខ្ញុំមានអារម្មណ៍ថានៅមានចន្លោះខ្វះខាតក្នុងនាមឪពុកម្នាក់ ខ្ញុំរំលឹកខ្លួនខ្ញុំអំពីអ្វីដែល អែលឌើរ នៀល អេ. មែកស្វែល (1926–2004) នៃកូរ៉ុមសាវកដប់ពីរនាក់បាននិយាយក្នុងគ្រា មួយថា ៖ « ព្រះអម្ចាស់អង្គនោះដែលបានដាក់តារាចំគន្លងសហសវត្សរ៍ មុននឹងវាបានលេចមកលើក្រុង បេថ្លេហិមនៅ ក្នុងការប្រារព្ធនៃការប្រសូតនៃព្រះរាជបុត្រ ដែលបានអនុវត្តឡើងដោយការយកចិត្តទុក ស្មើរគ្នា ចំពោះការដាក់យើងរាល់គ្នាម្នាក់ៗចំនឹងគន្លងរបស់មនុស្សលោកដើម្បីឱ្យយើងអាច ប្រសិនបើ យើងនឹងបំភ្លឺសភាពនៃជីវិតផ្ទាល់ខ្លួនរបស់យើង ដើម្បីឱ្យពន្លឺរបស់យើងមិនត្រឹមតែអាចដឹកនាំអ្នកដទៃ ប៉ុណ្ណោះទេ ប៉ុន្តែកំដៅពួកគេទៀតផង » ។ [4]

សេចក្ដីថ្លែងការណ៍នេះ លើកស្ទួយខ្ញុំ នៅពេលខ្ញុំបាក់ទឹកចិត្ត ។ វាជួយខ្ញុំ និងភរិយាខិតខំអស់ពីសមត្ថភាពរបស់យើងក្នុងនាមជាមាតាបិតា ក្នុងការដឹងថា កូនៗរបស់យើងត្រូវបានដាក់នៅក្នុង « គន្លង » របស់យើងសម្រាប់មូលហេតុមួយ ហើយថា ព្រះវរបិតា សួគ៌ទុកចិត្ត យើង ។

សូមឱ្យទ្រង់ប្រទានពរដល់ក្រុមគ្រួសាររបស់អ្នក ក្នុងពេលអ្នករៀនដំណឹងល្អជាមួយគ្នា ជួយកូនៗរបស់ អ្នកឱ្យមានទំនួលខុសត្រូវ ហើយឈោងចាប់យកឱកាសដ៏មានតម្លៃនានា ដើម្បីនឹងបង្រៀន ។ ■

**កំណត់ចំណាំ**

1. ដាវិឌ អូ ម័កឃេ នៅក្នុង *សៀវភៅសិក្សាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ* (1968), iii ។
2. ដាល្លិន អេក អូក « ល្អ ល្អជាង ប្រសើរ » *លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ 2007 ទំព័រ 104 105 ។
3. រីឆាដ អិល អ៊ីវែនស៍ « The Spoken Word » *Ensign* ខែ ឧសភាឆ្នាំ 1971, ទំព័រ 12 ។
4. នៀល អេ មែកស្វែល *That My Family Should Partake* (1974) ទំព័រ 86 ។



# តម្លៃនៃការសិក្សាអប់រំ

ការអប់រំគឺជាផ្នែកដ៏សំខាន់នៃដំណឹងល្អ និងនៃការរៀបចំខ្លួនដើម្បីនឹងចូលរួមនៅក្នុងសង្គម ហើយផ្គត់ផ្គង់សម្រាប់ខ្លួនឯង និងក្រុមគ្រួសារខ្លួន។ [1] អែលឌើរ គ្រែក អេ. ខាដុននៃពួកចិតសិបនាក់និយាយ អំពីសារៈសំខាន់នៃការអប់រំនៅក្នុង ទំព័រ 54–55 នៃទស្សនាវដ្ដីនេះ ។

គាត់សរសេរថា « នៅក្នុងពិភពលោកដែលកាន់តែស្មុគស្មាញនេះ ការអប់រំគឺជាការបានទទួលដ៏សំខាន់បំផុតនៃជីវិត » ។ « ហើយថ្វីបើវាជាពិតដែលថា ការទទួលការអប់រំកាន់តែច្រើននឹងនាំឆ្ពោះទៅរកឱកាសដើម្បីទទួលបាន រង្វាន់ជាច្រើនផ្នែកសាច់ឈាមក្តី ក៏ជាតម្លៃកាន់តែធំនៃចំណេះវិជ្ជាដែលជាឱកាសដែលផ្ដល់ដល់យើងនូវ អនុភាពកាន់តែខ្លាំង ក្នុងការសម្រេចបាននូវគោលបំណងរបស់ព្រះអម្ចាស់ផងដែរ »

*សៀវភៅដើម្បីកម្លាំងនៃយុវជន*ចែងថា ៖ « ការអប់រំរបស់អ្នកត្រូវតែមានបន្ថែមនូវការរៀនសូត្រខាងវិញ្ញាណដែរ ។ ចូរសិក្សាព្រះគម្ពីរ និងប្រសាសន៍របស់ពួកព្យាការីនាថ្ងៃចុងក្រោយ ។ ចូលរៀននៅថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ។ បន្តរៀនអំពីផែនការនៃព្រះវរបិតាសួគ៌ពេញមួយជីវិតរបស់អ្នក ។ ការរៀនសូត្រខាងវិញ្ញាណនេះនឹងជួយអ្នកឱ្យរកឃើញចម្លើយចំពោះឧបសគ្គទាំងឡាយនៃជីវិត ហើយនឹងអញ្ជើញភាពជាដៃគូពីព្រះវិញ្ញាណបរិសុទ្ធ ។ [2]

## យោបល់ទាំងឡាយសម្រាប់បង្រៀនយុវវ័យ

- សូមអានផ្នែកនៃការអប់រំនៅក្នុងសៀវភៅ *សម្រាប់កម្លាំងរបស់យុវវ័យ* ។ ចែកចាយបទពិសោធន៏វិជ្ជមានរបស់អ្នក អំពីសាលារៀន និងការសិក្សារដំណឹងល្អ ។ វានឹងអនុញ្ញាតឱ្យអ្នកពិភាក្សាបទដ្ឋាននេះជាមួយកូនជំទង់របស់អ្នក ហើយឆ្លើយនឹងសំណួរនានា ណា មួយដែលពួកគេមាន។
- ជួយកូនជំទង់របស់អ្នកឱ្យដាក់គោលដៅធ្វើការងារ និងផ្នែកអប់រំ ផ្អែកលើទេពកោសល្យ និងចំណាប់ អារម្មណ៍របស់គេ ។ ជួយពួកគេឱ្យស្វែងរកដំណាក់ការនានា ដើម្បីចាប់ផ្ដើមអនុវត្តតាមគោលដៅទាំងនេះ ។
- សូមគិតពិចារណាដើម្បីធ្វើនូវរាត្រីជួបជុំក្រុមគ្រួសារមួយ ស្ដីអំពីសារៈសំខាន់នៃការអប់រំ (ធនធានដ៏ល្អ មួយគឺជាអត្ថបទដែលថ្លែងដោយ អែលឌើរ ដាល្លិន អេច. អូកស៍ និងគ្រីស្ទិន អិម. អូកស៍ « ការរៀនសូត្រ និងពួកបរិសុទ្ធថ្ងៃចុងក្រោយ » *Liahona,* ខែមេសា ឆ្នាំ 2009, 26–31) ។
- សូមចូលទៅ youth.lds.org ហើយចុចត្រង់ « ដើម្បីកម្លាំងនៃយុវជន » ក្រោមមិនុយ យុវវ័យ ។ នៅក្រោម « ការអប់រំ » អ្នកនឹងរកឃើញនូវវគ្គគម្ពីរទាំងឡាយអំពីការអប់រំ វីឌអូ (សូមមើលឧទាហរណ៍ « Surfing or Seminary? » ) ប៉ុស្ដិ៍កម្មវិធីវិទ្យុសំណួរ និង ចម្លើយ ហើយនិងអត្ថបទទាំងឡាយ រួមជាមួយ សន្ទរកថារបស់ពួកអ្នកដឹកនាំទូទៅ ។

## យោបល់ទាំងឡាយដើម្បីបង្រៀនកូនចៅ

វាជារឿងគួរឱ្យសប្បាយដែលរៀនអ្វីថ្មីៗ ប៉ុន្ដែការរៀនក៏អាចជារឿងពិបាកដែរ ។ ទស្សនាវដ្ដីខែនេះ មានរួមជាមួយរឿងដែលហៅថា « ត្រៀមដើម្បីនឹងអាន » (ទំព័រ 66 ។ សាច់រឿងនេះពិពណ៌នាអំពីក្មេងស្រីម្នាក់ដែលមានជម្ងឺលំបាកអាន ដែលគាត់ពិបាកនឹងការអានឱ្យឮៗ ហើយនិងអំពីរបៀបដែលកុមារក្នុងបឋមសិក្សាលើកទឹកចិត្តនាងឱ្យខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ នាង ។ សូមគិតអំពីការអានរឿងនេះជាមួយកូនៗរបស់អ្នក ហើយពិភាក្សាគ្នា នូវសំណួរទាំងឡាយ ដូចខាង ក្រោម ៖

- តើម៉ារីបានមានអារម្មណ៍ដូចម្ដេច នៅពេលនាងកំពុងតែខិតខំធ្វើរឿងមួយដែលពិបាកនឹងធ្វើ ? តើហេតុអ្វីវាសំខាន់នឹងបន្តនូវការអប់រំ ថ្វីបើវាពិបាកក្ដី ?
- តើក្មេងៗឯទៀតបានធ្វើដូចម្ដេច ដើម្បីជួយដាកម៉ារី ? តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីជួយអ្នកដទៃឱ្យរៀននៅក្នុងផ្ទះ នៅព្រះវិហារ ហើយនិងនៅសាលារៀន ? ■

### ព្រះគម្ពីរស្ដីពីការរៀនសូត្រ

សុភាសិត 4:7 ។

នីហ្វៃទី2 9:28–29

អាលម៉ា 37:35

គោលលទ្ធិ និងសេចក្ដីសញ្ញា 88:77–80។

**កំណត់ចំណាំ**

1. *ដើម្បីកម្លាំងនៃយុវជន* (កូនសៀវភៅ ឆ្នាំ 2011) 6 ។
2. *ដើម្បីកម្លាំងនៃយុវជន* 8 ។



# យុវនារី និង
# ការសម្រេចចិត្តដើម្បីបម្រើបេសកកម្ម




នៅក្នុង សន្និសីទទូទៅខែ តុលា ឆ្នាំ 2012 ប្រធាន ថូម៉ាស អេស. ម៉នសុនបានប្រកាសថា ៖ « យុវនារីដែលមានសមត្ថភាព មានភាពសក្ដិសមដែលមានបំណងចង់បម្រើ អាចលើកទឹកចិត្តឱ្យបម្រើបេសកកម្មចាប់ពីអាយុ 19 ជំនួសឱ្យអាយុ 21 ឆ្នាំ » ។ លោកបានមានប្រសាសន៍ថា ទោះបីជាយុវនារី « មិននៅក្រោមការបញ្ជាឱ្យបម្រើដូចគ្នានឹងយុវជននោះទេ » ពួកគេ « នឹងចូលរួមចំណែកយ៉ាងមានតម្លៃក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ហើយយើងសូមស្វាគមន៍ចំពោះការបម្រើរបស់ពួកគេ » ។[1]

តើបងប្អូនស្រីម្នាក់សម្រេចចិត្តដើម្បីបម្រើដោយរបៀបណា? ដំណើររឿងខាងក្រោមនិយាយពីរបៀបដែលបងប្អូនស្រីត្រូវបានដឹកនាំដោយព្រះវិញ្ញាណក្នុងការសម្រេចចិត្តលើផ្លូវដ៏ត្រឹមត្រូវរបស់ពួកគេ ។

*របៀបដែលយុវនារីនៅក្មេងទាំងនេះបានអនុវត្តតាមពាក្យទូន្មានរបស់ព្យាការីទាក់ទងនឹងការបម្រើបេសកកម្មពេញម៉ោង ។*

### ការខកខានទំនាក់ទំនង

កាលពីខ្ញុំនៅក្មេង បើមាននរណាម្នាក់សួរខ្ញុំ ថាតើខ្ញុំនឹងបម្រើបេសកកម្មទេ នោះខ្ញុំនឹងឆ្លើយថា អត់ទេ ។ ដួងចិត្តរបស់ខ្ញុំបានទោរទន់ទៅរកគំនិតនោះនៅពេលដែលខ្ញុំធំឡើង ដោយព្រោះខ្ញុំបានឃើញបងប្រុសបង្កើតរបស់ខ្ញុំបានបម្រើ ។ ប៉ុន្តែខ្ញុំពិតជាមិនចង់គិតអំពីបេសកកម្មថា ជាអ្វីដែលខ្ញុំនឹងធ្វើនោះឡើយ ។

នៅពេលខ្ញុំអាយុ 21 ឆ្នាំ ខ្ញុំបានចាប់ផ្ដើមឆ្ងល់ថា តើខ្ញុំគួរតែបម្រើបេសកកម្មឬទេ ពីព្រោះខ្ញុំមិនធ្លាប់បានអធិស្ឋានឱ្យខ្លាំងក្លាអំពីបេសកកម្មឡើយ ។ នៅវេលាមកដល់ ខ្ញុំបានចាប់ផ្ដើមទទួលអារម្មណ៍ដូចជាខកខានមិនបានធ្វើអ្វីមួយ ។ ខ្ញុំបានប្រាប់ម្ដាយខ្ញុំអំពីអារម្មណ៍នោះ ហើយគាត់បានឱ្យយោបល់ថា ខ្ញុំគួរពិចារណាអំពីបេសកកម្មម្ដងទៀត ។ គាត់បាននិយាយថា កាលពីគាត់នៅអាយុស្របាលខ្ញុំ គាត់បានទទួលអារម្មណ៍នៃការរំជួលចិត្តដូចដែលខ្ញុំទទួលបទពិសោធន៍ដែរ ។ ការបម្រើបេសកកម្មគឺជាចម្លើយសម្រាប់គាត់ ដូច្នេះវាប្រហែលអាចជាចម្លើយសម្រាប់ខ្ញុំផងដែរ ។

ខ្ញុំមានការភ័យខ្លាចក្នុងការអធិស្ឋានអំពីបេសកកម្ម ។ ពីមុន មូលហេតុមួយដែលខ្ញុំមិនធ្លាប់គិតពិចារណាអំពីបេសកកម្មនោះគឺថា ខ្ញុំបានគិតថា ខ្ញុំគ្មានភាពរឹងមាំគ្រប់គ្រាន់ដើម្បីបម្រើបេសកកម្មទេ ។ ខ្ញុំត្រូវទុកការលួងលោមរបស់ខ្ញុំចោល ហើយប្រហែលជាត្រូវរៀនភាសាថ្មី ។ លើសពីនេះ ខ្ញុំគិតថា ខ្ញុំមិនចេះដំណឹងល្អច្បាស់លាស់ គ្រប់គ្រាន់ដើម្បីបង្រៀនទេ ។ ប៉ុន្តែនៅ ពេលខ្ញុំបានអធិស្ឋានដោយមានគោលបំណងនោះ ខ្ញុំទទួលអារម្មណ៍ថាការភ័យខ្លាចរបស់ខ្ញុំបានរលាយបាត់សូន្យឈឹង ។ ចម្លើយដែលខ្ញុំបានទទួលនោះគឺមានអនុភាពជាខ្លាំង ៖ ព្រះអម្ចាស់ស្រឡាញ់ខ្ញុំ ហើយទ្រង់ចង់ឱ្យខ្ញុំបម្រើបេសកកម្ម ។

ខ្ញុំមានការភ្ញាក់ផ្អើលដោយសារទំនុកចិត្តដែលខ្ញុំបានទទួលបន្ទាប់ពីខ្ញុំបានទទួលចម្លើយរបស់ខ្ញុំ ។ បន្ទាប់ពីនោះមក ខ្ញុំពុំដែលមានអារម្មណ៍ថា ភ័យខ្លាច ឬ អារម្មណ៍មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីបម្រើឡើយ ។ ផ្ទុយទៅវិញ ខ្ញុំមានចិត្តរំភើបដើម្បីចែកចាយដំណឹងល្អ ហើយខ្ញុំចាប់ផ្ដើមបំពេញទម្រង់បែបបទបេសកកម្មរបស់ខ្ញុំ ។ មិនយូរប៉ុន្មានខ្ញុំត្រូវបានហៅបម្រើទៅ បេសកកម្ម វិសាលដ្ឋានព្រះវិហារបរិសុទ្ធ ទីក្រុងសលត៍ លេក រដ្ឋ យូថាហ៍ ។

រ៉េបេកា យែលលើរ ម៉នសុន

### ជីវិតជាអ្នកផ្សព្វផ្សាយសាសនាម្នាក់

កាលខ្ញុំអាយុ 17 ឆ្នាំ មានមនុស្សចាប់ផ្ដើមសួរខ្ញុំថាតើខ្ញុំនឹងបម្រើបេសកកម្មទេ ។ ខ្ញុំមិនទាន់បានសម្រេចចិត្តនៅឡើយទេ ដូច្នេះខ្ញុំតែងតែពន្យាពេលរហូត ។

ប៉ុន្តែ នៅពេលខួបកំណើតគំរប់ខួបទី 21 ឆ្នាំ របស់ខ្ញុំបានមកដល់ នោះខ្ញុំបានចាប់ផ្ដើមគិតអំពីបេសកកម្ម ។ ខ្ញុំបានអានពររបស់លោកអយ្យកោ ពិភាក្សាជាមួយឪពុកម្ដាយរបស់ខ្ញុំ និង បានអធិស្ឋាន ។

បំណងប្រាថ្នានេះមិនធ្លាប់មានទេ ខ្ញុំមិនធ្លាប់ទទួលអារម្មណ៍ថាខ្ញុំត្រូវតែទៅបម្រើឡើយ ។ ខ្ញុំបានគិតពីពាក្យទូន្មានរបស់ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី (ឆ្នាំ 1910–2008) ដែលបានមានប្រសាសន៍ថា ខណៈពេលដែលស៊ីស្ទើរជាអ្នកផ្សព្វផ្សាយសាសនាត្រូវបានស្វាគមន៍ នោះពួកគេ « មិននៅក្រោមកាតព្វកិច្ចដើម្បីបម្រើបេសកកម្មទេ » ។[2]

ខាងឆ្វេង ៖ រចនាឡើងដោយ រ៉ូប៊ើត ខាស៊ី ខាងស្ដាំ ៖ ផ្លាកឈ្មោះរបស់អ្នកផ្សព្វផ្សាយ ដោយ ដេវីដ ស្តូក © IRI





**វិញ្ញាណនៃវិវរណៈ**

« នៅពេលការជ្រើសរើសមួយធ្វើឡើង នោះនឹងមានការផ្លាស់ប្ដូរមួយនៅក្នុងជីវិតរបស់យើង ... ហើយនៅពេលយើងរស់នៅតាមសំឡេងរបស់ព្រះវិញ្ញាណ ហើយស្វែងរកការដឹកនាំរបស់ទ្រង់ នោះយើងអាចប្រាកដថាយើងនឹងទទួលការណែនាំ ដែលយើងត្រូវការដើម្បីសម្រេចគោលដៅរបស់យើង ។ ព្រះអម្ចាស់នឹងមិនចោលយើង ដោយមិនជួយយើងឡើយ » ។

**អែលឌើរ ដាល្លិន អេក. អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « វិវរណៈ » នៅក្នុង *Brigham Young University 1981–82 Fireside and Devotional Speeches*** (ឆ្នាំ 1982) ទំព័រ 26 ។

ខ្ញុំក៏ត្រូវបានរំឭកនូវព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាថា ៖ « បើសិនជាអ្នករាល់គ្នាមានបំណងចង់បម្រើព្រះ នោះអ្នករាល់គ្នាត្រូវបានហៅឱ្យធ្វើកិច្ចការនោះហើយ » (កណ្ឌទី 4:3) ។

ខគម្ពីរនោះបានជួយខ្ញុំឱ្យសម្រេចចិត្តថាមិនបម្រើបេសកកម្មទេ ។ នៅពេលខ្ញុំទូលដល់ព្រះអម្ចាស់ក្នុងការអធិស្ឋានពីការសម្រេចចិត្តរបស់ខ្ញុំ នោះខ្ញុំទទួលអារម្មណ៍នៃភាពសុខសាន្ត និង ការបញ្ជាក់ថាមានរបៀបជាច្រើនដែលខ្ញុំអាចក្លាយជាអ្នកផ្សព្វផ្សាយសាសនាដោយមិនបាច់ត្រូវបម្រើពេញម៉ោង ។ ចាប់តាំងពីនោះមកខ្ញុំបានឃើញថា ខ្ញុំអាចចែកចាយទីបន្ទាល់របស់ខ្ញុំតាមរបៀបជាច្រើន—តាមរយៈការសន្ទនាអំពីសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ពេលដែលខ្ញុំទៅបង្រៀនសួរសុខទុក្ខ ឬ ធ្វើកិច្ចការពង្សប្រវត្តិ និងព្រះវិហារបរិសុទ្ធ ។ ខ្ញុំបានបូជាដួងចិត្តរបស់ខ្ញុំចំពោះកិច្ចការនេះ ដោយព្យាយាមរស់នៅតាមដំណឹងល្អ និង ធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ។

អាមី ស៊ីម៉ូន

## ចូរមានចិត្តក្លាហាន

នៅដើមឆ្នាំ 2010 ខ្ញុំមានអារម្មណ៍ច្របូកច្របល់ជាមួយនឹងការលំបាកខ្លះៗ ហើយបានដើរកម្សាន្តដើម្បីឱ្យបានស្រឡះដួងចិត្តរបស់ខ្ញុំ ។ នៅពេលខ្ញុំកំពុងដើរនោះ ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណខ្សឹបប្រាប់ថា ខ្ញុំមិនគួរព្រួយបារម្ភពីអតីតកាលឡើយ ផ្ទុយទៅវិញខ្ញុំគួរតែគិតអំពីអនាគតរបស់ខ្ញុំ ។ នៅពេលដែលខ្ញុំបានពិនិត្យឡើងវិញពីគោលដៅនៃការបញ្ចប់ការសិក្សារបស់ខ្ញុំ នោះខ្ញុំត្រូវបានបំផុសគំនិតឱ្យគិតអំពីការបម្រើបេសកកម្ម ។ ពីមុនខ្ញុំមិនធ្លាប់បានគិតអំពីបេសកកម្មសោះ ប៉ុន្តែនៅពេលគំនិតនោះមកដល់ នោះនាំឱ្យមានការរំភើបចិត្ត និង បំណងដើម្បីបម្រើ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំចង់ទុកពេលបន្តិចទៀត ដើម្បីគិតអំពីការសម្រេចចិត្តដ៏ធំបែបនោះ ។

ពីរបីខែក្រោយមក ខ្ញុំត្រូវបានបំផុសគំនិតកាន់តែខ្លាំងដើម្បីបម្រើបេសកកម្ម ។ នៅពេលដែលខ្ញុំនៅតែមានអារម្មណ៍បំផុសគំនិតពី បំណងប្រាថ្នា និង ការរំភើបចិត្តដដែរ ដែលខ្ញុំបានទទួលនោះការសង្ស័យ និង ការភ័យខ្លាចក៏បានមកដំណាលគ្នាផងដែរ ។ ខ្ញុំបានដឹងថាស្ត្រីត្រូវបានលើកទឹកចិត្តឱ្យបម្រើ បើសិនពួកគេមានបំណង តែពុំមែនជាកាតព្វកិច្ចដើម្បីបម្រើនោះទេ ។ អំឡុងពេលនេះ ខ្ញុំបានទទួលការប្រសិទ្ធពរបព្វជិតភាពដោយបានប្រាប់ខ្ញុំថា ព្រះអម្ចាស់នឹងសព្វព្រះហរទ័យទោះបីជាខ្ញុំជ្រើសរើសធ្វើមួយណាក៏ដោយ ។

នៅរដូវក្ដៅបន្ទាប់នោះ ខ្ញុំមានមិត្តរួមថ្នាក់ម្នាក់ដែលបានបម្រើបេសកកម្ម ។ គាត់បាននិយាយថា គាត់ពីមុនក៏មានអារម្មណ៍ភ័យខ្លាចផងដែរ ហើយសូម្បីតែបន្ទាប់ពីគាត់សម្រេចចិត្តដើម្បីបម្រើក្ដី ។ គាត់បានជួយខ្ញុំឱ្យយល់ថា ព្រះវិញ្ញាណមិនមានព្រះបន្ទូលតាមរយៈការសង្ស័យ និង ការភ័យខ្លាចឡើយ (សូមមើលធីម៉ូថេទី 2 1:7) ។ នៅពេលយើងជជែកគ្នា នោះព្រះវិញ្ញាណបានរំជួលចិត្តខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំបានត្រឡប់ទៅបន្ទប់ខ្ញុំវិញ ហើយអានសំបុត្រមួយមកពីមិត្តរបស់ខ្ញុំដែលកំពុងបម្រើបេសកកម្ម ។ សំបុត្រនោះបានលើកទឹកចិត្តខ្ញុំឱ្យអានគម្ពីរយ៉ូស្វេ 1:9ហើយខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណជម្រុញឱ្យខ្ញុំមើលខនោះ ។

ព្រះបន្ទូលនោះបានចាក់ក្នុងព្រលឹងខ្ញុំ ៖ « ចូរឱ្យមានកម្លាំង និង ចិត្តក្លាហានចុះ កុំឱ្យខ្លាចឡើយ ក៏កុំឱ្យស្រយុតចិត្តផង ត្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង » ។ ខ្ញុំទទួលអារម្មណ៍ថា ព្រះអម្ចាស់កំពុងមានព្រះបន្ទូលមកខ្ញុំដោយផ្ទាល់ ។ ខ្ញុំដឹងថា ខ្ញុំអាចបម្រើបេសកកម្ម ។ ខ្ញុំមិនត្រូវភ័យខ្លាចឡើយ—ខ្ញុំនឹងមិនធ្វើកិច្ចការនោះតែឯងឡើយ ព្រះអម្ចាស់នឹងគង់នៅជាមួយខ្ញុំ ។

មួយខែក្រោយមក ខ្ញុំបានទទួលការហៅរបស់ខ្ញុំទៅកាន់បេសកកម្ម ភ្វីលីពីន អ៊ីឡូយឡូ ដែលមានខគម្ពីរយ៉ូស្វេ 1:9 ជាប្រធានបទសម្រាប់បេសកកម្មនោះ ។

គ្រីស្ទាន ទីក្លូល ដែននើរ

## បេសកកម្មមួយផ្សេងទៀត

ខ្ញុំបានរៀបផែនការពេញមួយជីវិតរបស់ខ្ញុំដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ ប៉ុន្តែ នៅពេលខ្ញុំទៅរៀននៅមហាវិទ្យាល័យ ព្រិកហាំ យ៉ង់ (រដ្ឋ យូថាយ៍ ស.រ.អា) នោះខ្ញុំចាប់ផ្ដើមមានអារម្មណ៍ច្របូកច្របល់ ។ តើខ្ញុំអាចដឹងដោយរបៀបណា ថាខ្ញុំពិតជាត្រូវបម្រើបេសកកម្មនោះ ? ខ្ញុំបានចំណាយពេលមួយឆ្នាំមុនខួបកំណើតគំរប់ 21 ឆ្នាំរបស់ខ្ញុំដោយទូលអង្វរ



ព្រះវរបិតាសួគ៌ឱ្យប្រាប់ខ្ញុំ បើសិនខ្ញុំគួរតែទៅបម្រើ ។ បន្ទាប់មក សាស្ត្រាចារ្យសាសនាម្នាក់របស់ខ្ញុំបាននិយាយអ្វីមួយដែលបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំថា ៖ « ព្រះអម្ចាស់មិនអាចបើកឡានដែលទុកចតចោលបានឡើយ » ។ ខ្ញុំបានសម្រេចចិត្តដើម្បីធ្វើតាម ។

ខ្ញុំបានបំពេញទម្រង់បែបបទបេសកកម្មរបស់ខ្ញុំ បានទទួលការបម្រើ ទិញសម្លៀកបំពាក់អ្នកផ្សព្វផ្សាយ ហើយបើកឡានពី រដ្ឋ យូថាយ៍ ទៅផ្ទះ នៅ ខារ៉ូលីណា ប៉ែកខាងជើង—គឺអំឡុងពេលទាំងអស់នៃ ការរៀបចំសម្រាប់បេសកកម្មរបស់ខ្ញុំដោយមានការអធិស្ឋាន សិក្សា និង តមអាហារយ៉ាងអស់ពីចិត្ត ។

បន្ទាប់ពីខ្ញុំបានទៅផ្ទះនៅ ខារ៉ូលីណា ប៉ែកខាងជើង នោះមានយុវជនម្នាក់ដែលខ្ញុំបានស្គាល់នៅសាលារៀនបានមកសួរសុខទុក្ខខ្ញុំ ហើយយើងបានជជែកគ្នាត្រង់ៗអំពីទំនាក់ទំនងរបស់យើង ។

ការអធិស្ឋានត្រង់របស់ខ្ញុំ និង ទូលអង្វរម្ដងទៀត ប៉ុន្តែខ្ញុំបន្តទទួលអារម្មណ៍ថាព្រះអម្ចាស់ទុកចិត្តខ្ញុំ ឱ្យខ្ញុំធ្វើការសម្រេចដោយផ្ទាល់ខ្លួនខ្ញុំ ។ ខ្ញុំទទួលអារម្មណ៍ថាទទួលបន្ទុកនៃការទទួលខុសត្រូវ ប៉ុន្តែក៏ទទួលបាននូវការបញ្ជាក់ដ៏ផ្អែមល្ហែមនៅពេលដែលខ្ញុំជ្រើសរើសដោយសេចក្តីជំនឿ នោះព្រះអម្ចាស់នឹងគាំទ្រការសម្រេចចិត្តរបស់ខ្ញុំ ។

ដប់ថ្ងៃមុនពេលខ្ញុំចាកចេញទៅ នោះមិត្តរបស់ខ្ញុំបានសុំខ្ញុំរៀបការ ។ ខ្ញុំបានពន្យាបេសកកម្មរបស់ខ្ញុំ ហើយទុកពេលសម្រាប់ខ្ញុំគិត ។ នៅពេលខ្ញុំបានសម្រេចចិត្តដើម្បីភ្ជាប់ពាក្យ នោះព្រះវិញ្ញាណបានបញ្ជាក់ដល់គូដណ្ដឹងរបស់ខ្ញុំ និង ខ្ញុំ ថានោះគឺត្រឹមត្រូវហើយ ។

ទោះបីខ្ញុំមិនបានបម្រើបេសកកម្មពេញម៉ោង នោះការរៀបចំសម្រាប់បេសកកម្មបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំ ។ ការខិតកាន់តែជិតព្រះអម្ចាស់បានជួយខ្ញុំប្រែក្លាយជាមនុស្សដែលទ្រង់ត្រូវការខ្ញុំ ដើម្បីនៅសម្រាប់បេសកកម្មរបស់ខ្ញុំ គឺធ្វើជាភរិយា និង ម្ដាយ ។
ខាស៊ី វែនដល

## បទពិសោធន៍ទាំងឡាយនៃជីវិត

ខ្ញុំមានពរជ័យជាមួយនឹងទីបន្ទាល់ដ៏រឹងមាំ និង ក្ដីស្រឡាញ់ចំពោះដំណឹងល្អតាំងពីខ្ញុំនៅក្មេង ប៉ុន្តែខ្ញុំមិនបាននឹកចាំនៅពេលមួយដែលខ្ញុំបានដឹងថា ការបម្រើបេសកកម្មនោះគឺជាការត្រឹមត្រូវឡើយ ។ ខ្ញុំគ្រាន់តែដឹងថា ខ្ញុំនឹងទៅ ។ ខ្ញុំបានដាក់គោលដៅតាំងពីក្មេងដើម្បីរស់នៅតាមរបៀបដែលសក្តិសមដើម្បីខ្ញុំអាចបម្រើបេសកកម្ម ។

នៅពេលខ្ញុំចាប់ផ្ដើមរៀបចំបែបបទបេសកកម្មរបស់ខ្ញុំ ខ្ញុំបានតមអាហារ អធិស្ឋាន និង ចូលរួមព្រះវិហារបរិសុទ្ធ ។ នៅពេលខ្ញុំធ្វើការរៀបចំនេះជាមួយប៊ីស្សពរបស់ខ្ញុំ នោះខ្ញុំបន្តទទួលអារម្មណ៍សុខសាន្ត ដែលខ្ញុំធ្លាប់បានទទួលពេញមួយជីវិតរបស់ខ្ញុំ អំពីការបម្រើបេសកកម្ម ។

ដំណើរការនោះមានការលំបាកណាស់ពេលនោះ ៖ ភ្លាមនោះ ការចំណាយហាក់បីដូចជាមានការឡើងតម្លៃ ហើយសាលារៀន និង ការងារបានប្រែជាតម្រូវឱ្យចំណាយពេលច្រើន ។ ខ្ញុំរៀននៅមហាវិទ្យាល័យដែលឆ្ងាយពីគ្រួសាររបស់ខ្ញុំ ហើយវាហាក់បីដូចជា មិត្តភក្តិរបស់ខ្ញុំបានរៀបការអស់ហើយ ។ វាគួរឱ្យភ័យខ្លាចដើម្បីដឹងថាមនុស្សដែលខ្ញុំខ្វល់ខ្វាយ នឹងបន្តផ្លាស់ប្ដូរនៅពេលខ្ញុំចេញទៅឆ្ងាយ ។

ពីព្រោះខ្ញុំគ្មានការណ៍ខាងវិញ្ញាណណាដែលអស្ចារ្យដែលបញ្ជាក់ពីការសម្រេចចិត្តរបស់ខ្ញុំដើម្បីបម្រើឡើយ វាងាយស្រួលនឹងសង្ស័យ នៅពេលដែលជួបការលំបាក ។ ប៉ុន្តែព្រះអម្ចាស់បានប្រទានពរខ្ញុំបន្ទាប់ពីខ្ញុំបានទទួលការហៅបម្រើទៅកាន់បេសកកម្ម ឈីលី សាន់ទីអាហ្គោ ប៉ែកខាងកើត ដើម្បីអភិវឌ្ឍសេចក្តីស្រឡាញ់ចំពោះមនុស្សនៅក្នុងបេសកកម្មរបស់ខ្ញុំ ទោះបីពីមុនខ្ញុំបានចេញបេសកកម្មក៏ដោយ ។ ឥឡូវនេះ ខ្ញុំមានបទពិសោធន៍នៃជីវិតដែលមានទីបន្ទាល់ថា បេសកកម្មគឺជាជម្រើសដ៏ល្អសម្រាប់ខ្ញុំ ។
ម៉ាដែលែន ប៉ៃលី ■

**កំណត់សម្គាល់**

1. ថូម៉ាស អេស. ម៉នសុន « សូមស្វាគមន៍មកកាន់សន្និសីទ » *លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 4–5 ។
2. ហ្គរដុន ប៊ី.ហ៊ិងគ្លី « ជូនចំពោះប៊ីស្សពទាំងឡាយនៃសាសនាចក្រ » *ការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោក*ខែ មិថុនា ឆ្នាំ 2004 ទំព័រ 27 ៕

**ការឆ្លើយនឹងសំណួរទាំងឡាយ**

តើសមាជិកគ្រប់រូបទាំងអស់នៃពួកបរិសុទ្ធថ្ងៃចុងក្រោយតម្រូវឱ្យបម្រើបេសកកម្មឬ ? មិនមែនទេ ! កិច្ចការផ្សព្វផ្សាយសាសនាគឺជាការស្ម័គ្រចិត្ត ។ យុវជនត្រូវបានរំពឹងទុកដើម្បីបម្រើ យុវនារីត្រូវបានស្វាគមន៍ ហើយរៀមច្បង និង គូស្វាមីភរិយារៀបការរួចត្រូវបានលើកទឹកចិត្តដើម្បីបម្រើបើសិនពួកគេអាចធ្វើទៅបាន ។ យុវជនអាចចាប់ផ្ដើមបម្រើនៅអាយុ 18 ឆ្នាំ ហើយបម្រើសម្រាប់រយៈពេលពីរឆ្នាំ ។ យុវនារីអាចចាប់ផ្ដើមបម្រើនៅអាយុ 19 ឆ្នាំ ហើយបម្រើសម្រាប់រយៈពេល18 ខែ ។ រៀមច្បង និង គូស្វាមីភរិយាដែលរៀបការរួចដែលចូលនិវត្តន៍ អាចបម្រើក្នុងរយៈពេលផ្សេងៗគ្នាតាមការចាត់តាំង ចាប់ពីរយៈពេល 6 ខែ ដល់ 23 ខែ ។

សមាជិកសាសនចក្រចាត់ទុកថាវាជា ឯកសិទ្ធិមួយដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សដទៃ និង ព្រះអម្ចាស់ ដោយធ្វើតាមការណែនាំរបស់ទ្រង់ថា ៖ « ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ » (ម៉ាថាយ 28:19) ។

សម្រាប់ព័ត៌មានបន្ថែម សូមមើល គេហទំព័រ mormon.org/faq ហើយ សូមចុចលើ ប្រធានបទអំពី អ្នកផ្សព្វផ្សាយសាសនា ។

# តើបេសកកម្មអ្វីដែល

សម្រាប់ព័ត៌មានបន្ថែមអំពីឱកាសបម្រើជាអ្នកផ្សព្វផ្សាយសាសនារៀមច្បង សូមជួបអ្នកដឹកនាំបព្វជិតភាពរបស់អ្នក និង សូមចូលទៅកាន់គេហទំព័រ lds.org/service/missionary-service ។





# ល្អបំផុតនោះ ?

*ទោះបីជាកាលៈទេសៈអ្នកយ៉ាងដូចម្ដេចក្ដី នោះឱកាសបម្រើជាអ្នកផ្សព្វផ្សាយសាសនា
រៀមច្បងអាចមានសម្រាប់អ្នក ។*

| | បេសកកម្មពេញម៉ោង | បេសកកម្មបម្រើសាសនាចក្រ | អ្នកស្ម័គ្រចិត្តរយៈពេលយូរ |
|---|---|---|---|
| **តើអ្នកណាខ្លះអាចបម្រើបាន ?** | អ្នកផ្សព្វផ្សាយសាសនារៀមច្បង ស៊ីស្ទើររៀមច្បង | អ្នកផ្សព្វផ្សាយសាសនារៀមច្បង បងប្អូនប្រុសរៀមច្បង បងប្អូនស្រីរៀមច្បង | សមាជិកគ្រប់គ្នា |
| **តើត្រូវតែជាសមាជិកដែលមានភាពស័ក្ដិសមដើម្បីចូលព្រះវិហារបរិសុទ្ធឬ ?** | បាទ | ចាស៎ ! | ទេ |
| **ចំនួនម៉ោងនៃការតាំងចិត្តបម្រើ** | ច្រើនជាង 32 ម៉ោងក្នុងមួយសប្ដាហ៍ | នៅចន្លោះពី 8 និង 32 ម៉ោងក្នុងមួយសប្ដាហ៍ | តិចជាង 8 ម៉ោងក្នុងមួយសប្ដាហ៍ |
| **រយៈពេលនៃការតាំងចិត្តបម្រើ** | 6–23 ខែ | 6–24 ខែ (អាចបម្រើយូរជាងនេះដោយមានការអនុម័តពីប្រធានស្តេក) | រយៈពេលប៉ុន្មានក៏បាន |
| **ស្ថានភាពការងារ** | ចូលនិវត្តន៍ | អាចចូលនិវត្តន៍ ឬ នៅតែធ្វើការ | អាចចូលនិវត្តន៍ ឬ នៅតែធ្វើការ |
| **ទីតាំង** | ឆ្ងាយពីផ្ទះ | ជិតផ្ទះ ឬ នៅផ្ទះ | នៅផ្ទះ |
| **ហិរញ្ញវត្ថុ** | ត្រូវតែអាចមានប្រាក់គ្រប់គ្រាន់ទៅកន្លែងដែលបេសកកម្មបានហៅ ។ ត្រូវតែអាចបង់ថ្លៃផ្ទះ (រហូតដល់ 1400 ដុល្លារ ស.រ.អា ក្នុងមួយខែ សម្រាប់អ្នកផ្សព្វផ្សាយសាសនាគូរស្វាមីភរិយា ធានារ៉ាប់រង សុខភាព និង ធ្មេញ ការធ្វើដំណើរក្នុងបេសកកម្ម ការចំណាយទាំងឡាយផ្ទាល់ខ្លួន | ត្រូវតែអាចមានប្រាក់គ្រប់គ្រាន់ទៅកន្លែងដែលបេសកកម្មបានហៅ ។ ត្រូវតែអាចបង់ថ្លៃផ្ទះ ធានារ៉ាប់រងសុខភាព និង ធ្មេញ ការធ្វើដំណើរ ការចំណាយទាំងឡាយផ្ទាល់ខ្លួន | ត្រូវតែផ្ដល់ប្រាក់សម្រាប់ការចំណាយផ្ទាល់ខ្លួន |

ថតរូបដោយ រ៉ូប៊ើត ខាស៊ី

# ការចែករំលែកពន្លឺរបស់ខ្ញុំ

វាគឺជាថ្ងៃចម្លែកមួយសម្រាប់ប៉ែកខាងត្បូងនៃរដ្ឋកាលីហ្វញ៉ា ស.ហ.អ ដែលមានផ្គរលាន់ផ្លេកបន្ទោរ ភ្លៀងធ្លាក់ជោគជាំ ហើយនិងកំដៅឡើងក្ដៅយ៉ាងខ្លាំង ។ ខ្ញុំបានទន្ទឹងរង់ចាំឱ្យដល់ថ្ងៃឈប់សម្រាក ហើយមើលកុន នៅក្នុងផ្ទះដែលមានម៉ាស៊ីនត្រជាក់របស់ខ្ញុំ ។ ប៉ុន្តែក្នុងពេលខ្ញុំទើបតែដាក់ខ្លួនអង្គុយចុះ ខ្ញុំបានមានអារម្មណ៍ថាខ្ញុំត្រូវតែទូរស័ព្ទទៅមិត្តរបស់ខ្ញុំឈ្មោះ ស្បេរិល ។

នៅពេលខ្ញុំបានទូរស័ព្ទទៅ ហើយបានជ្រាបដឹងថានៅផ្ទះរបស់នាងបានដាច់ភ្លើងតាំងពីព្រឹកនោះមកម្ល៉េះ ។ នាងបានព្រួយបារម្ភអំពីគ្រឿងម្ហូបដែលដាក់ក្លាស់សេនៅក្នុងទូរទឹកកកហើយថាទឹកដោះគោរបស់គាត់នឹងត្រូវជួមដូច្នេះ ហើយយើងបានយកគ្រឿងម្ហូបរបស់គាត់ចូលទៅក្នុងទូទឹកកករបស់ខ្ញុំ

រាត្រីបន្ទាប់ ស្បេរិល និងខ្ញុំបានឈរនៅពីមុខផ្ទះរបស់គាត់ ។ ផ្ទះនីមួយៗនៅខាងផ្លូវរបស់នាងមានភាពងងឹតទាំងស្រុង នៅពេលដែលនៅម្ខាងទៀតនៃផ្លូវមានពន្លឺភ្លើង ។ ជាពិសេស មានផ្ទះមួយដែលបានទាក់ទាញអារម្មណ៍របស់ខ្ញុំជាខ្លាំង ។ គឺជាផ្ទះទល់មុខនោះ ផ្ទះបានជះរស្មីដោយពន្លឺភ្លើង កាលដែលមនុស្សបានអង្គុយនៅលើរានហាលខាងមុខ និយាយគ្នា សើចក្អាកក្អាយដោយសប្បាយរីករាយ ។

នៅប៉ុន្មានថ្ងៃបន្ទាប់មក ខ្ញុំពុំអាចបំភ្លេចរូបភាពពីគំនិតរបស់ខ្ញុំឡើយ ។ ផ្ទុយទៅវិញ ហាក់ដូចជាលេចធ្លោឡើង ៈ ភាពងងឹតទាំងស្រុងនៅលើផ្លូវម្ខាង ហើយពន្លឺភ្លើងភ្លឺចិញ្ចែងចិញ្ចាចនៅលើផ្លូវម្ខាងទៀត ដែលមានមនុស្សអង្គុយក្នុងភាពងងឹត នៅពេលដែលអ្នកជិតខាងរបស់ខ្លួនរីករាយនឹងពន្លឺភ្លើង ។

រូបភាពដែលបានធ្វើឱ្យខ្ញុំងឿងឆ្ងល់ថា តើខ្ញុំជាញយៗដូចជាមនុស្សដែលនៅលើផ្លូវមានពន្លឺភ្លើងដែរឬទេ—ដែលរីករាយនឹងពន្លឺនៃដំណឹងល្អ នៅពេលដែលអ្នកឯទៀតអង្គុយនៅក្នុងភាពងងឹតនោះ ។ ខ្ញុំបានស្រមៃឃើញខ្លួនខ្ញុំអង្គុយនៅលើរានហាលរបស់ខ្ញុំ ជាមួយមិត្តភក្តិពីរបីនាក់របស់ខ្ញុំនៅព្រះវិហារ រីករាយនឹងពន្លឺនៃដំណឹងល្អដោយមិនចែករំលែកវាជាមួយនឹងអ្នកដទៃ ។

មនុស្សគ្រប់រូបនៅក្នុងផែនដីបានកើតមកជាមួយនឹងពន្លឺ—ពន្លឺរបស់ព្រះគ្រីស្ទ ។ ជាសមាជិកនៃ

*ក្នុងពេលខ្ញុំឈរក្នុងទីងងឹត ខ្ញុំបានងឿងឆ្ងល់ថា តើខ្ញុំជាញយៗដូចជាមនុស្សដែលនៅលើផ្លូវមានពន្លឺភ្លើងដែរឬទេ—ដែលរីករាយនឹងពន្លឺនៃដំណឹងល្អ នៅពេលដែលអ្នកឯទៀតអង្គុយនៅក្នុងភាពងងឹតនោះ ។*



សាសនាចក្រ យើងមានសិទ្ធិដើម្បីនឹងបន្ថែមទៅលើពន្លឺនោះ ដោយការចែករំលែក ដំណឹងល្អ ។ ព្រះអម្ចាស់បានបង្រៀនថា ៖

« មើលចុះ តើមនុស្សអុជទៀន ហើយដាក់នៅក្រោមថាំងឬ ? « ទេ ប៉ុន្តែដាក់នៅលើជើងទៀនវិញ នោះទើបនឹងឱ្យពន្លឺដល់អ្នកដែលនៅក្នុងផ្ទះទាំងអស់គ្នា

« ដូច្នេះ ចូរឱ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខប្រជាជននេះ ដើម្បីឱ្យគេអាចឃើញការល្អរបស់អ្នករាល់គ្នា ហើយសរសើរដំកើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅលើស្ថានសួគ៌ » (នីហ្វៃទី 3 12:15–16) ។

ជាសមាជិកនៃសាសនាចក្រ យើងមានការទទួលខុសត្រូវដើម្បីនឹងធ្វើឱ្យទីបន្ទាល់របស់យើងអំពីព្រះគ្រីស្ទជះពន្លឺឡើងសម្រាប់ឱ្យមនុស្សគ្រប់រូបមើលឃើញ—ជាពិសេសចំពោះអស់អ្នកស្ថិតនៅក្នុងភាពងងឹតខាងវិញ្ញាណ ។ បន្ទាប់ពីបទពិសោធន៍នេះ ខ្ញុំបានសម្រេចចិត្តនឹងធ្វើជាមនុស្សម្នាក់ដែលព្រះវរបិតាអាចទុកចិត្ត ឱ្យចាកចេញពីរានហាលដ៏កក់ក្ដៅរបស់ខ្ញុំ ហើយកាន់ពន្លឺនៃដំណឹងល្អទៅដល់អ្នកជិតខាងរបស់ខ្ញុំ ដែលស្ថិត នៅក្នុងភាពងងឹត ។ ■

ដូលរេស សូបេស្ដី មកពីកាលីហ្វូញ៉ា ស.ហ.អ

# ការអធិស្ឋានដំបូងរបស់ខ្ញុំអំពីការនិមិត្តដំបូង

នៅពេលខ្ញុំបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក គឺដោយព្រោះតែបញ្ហាខ្លះរបស់ខ្ញុំត្រូវបានដោះស្រាយនៅពេលខ្ញុំកំពុងតែទទួលមេរៀនការពិភាក្សារបស់អ្នកផ្សព្វផ្សាយសាសនា ។ គឺពុំមែនដោយព្រោះតែខ្ញុំបានអធិស្ឋានហើយបានទទួលទីបន្ទាល់ថាព្រះគម្ពីរគម្ពីរមរមនពិត ឬថាយ៉ូសែបស្ម៊ីធ បានឃើញព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទទេ ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានអញ្ជើញខ្ញុំឱ្យអធិស្ឋានអំពីអ្វីៗទាំងនេះ ប៉ុន្តែខ្ញុំមិនដែលអធិស្ឋានសោះឡើយ ។ ខ្ញុំគ្រាន់តែជឿនូវអ្វីដែលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនដល់ខ្ញុំប៉ុណ្ណោះ

បីខែក្រោយពីការជ្រមុជទឹករបស់ខ្ញុំ បងស្រីម្នាក់បានឈរឡើងនៅលើវេទិកាឡើងនិយាយក្នុងព្រះវិហារ ហើយបានចែកចាយទីបន្ទាល់គាត់អំពីព្រះគម្ពីរមរមន និងយ៉ូសែប ស្ម៊ីធ ។ គាត់បានស្នើសុំឱ្យសមាជិកគ្រប់រូបឱ្យសញ្ជឹងគិតនឹងសំណួរនេះ ៖ « តើយើងពិតជាបានអធិស្ឋានអំពីភាពពិតដ៏ពេញលេញនៃព្រះគម្ពីរមរមន និងអំពីបទពិសោធន៍ដែលយ៉ូសែបស្ម៊ីធហើយឬនៅ ? » សំណួរនេះបានប៉ះដល់ដួងចិត្តរបស់ខ្ញុំយ៉ាងធ្ងន់ ហើយខ្ញុំបានគិតដោយខ្លួនឯងថា « ខ្ញុំមិនដែលអធិស្ឋាន អំពីអ្វីៗទាំងនេះទេឬ ប៉ុន្តែខ្ញុំគប្បីនិងខ្ញុំត្រូវតែអនុវត្ត » ។

ខ្ញុំត្រូវបានទាក់ទាញចិត្តដើម្បីនឹងបញ្ចេញសកម្មភាព ដោយព្រោះតែសេចក្ដីជំនឿរបស់ខ្ញុំនៅពេលនោះ នៅខ្សោយហើយទីបន្ទាល់របស់ខ្ញុំអំពីព្រះគម្ពីរនៅរាក់នៅឡើយ ។ យប់នោះខ្ញុំបានអធិស្ឋានទៅព្រះវរបិតាខ្ញុំ អំពីយ៉ូសែប ស្ម៊ីធ និងភាពពិតដ៏ពេញលេញនៃព្រះគម្ពីរមរមន ។

ខ្ញុំមិនបានមានអារម្មណ៍អ្វីសោះ ក្នុងគ្រាដំបូងដែលខ្ញុំបានអធិស្ឋាន ឬនៅក្នុងគ្រាទីពីរទៀតផង ។ ដោយមិនបាក់ទឹកចិត្ត ខ្ញុំបានបើកព្រះគម្ពីរទៅប្រវត្តិរបស់យ៉ូសែបស្ម៊ីធ 1:14–17 ត្រង់ចំណុចដែលពិពណ៌នាអំពីរបៀបដែលយ៉ូសែប បានចូលទៅក្នុងព្រៃ ដើម្បីធ្វើការអធិស្ឋានដោយផ្ទាល់ ។

« ខ្ញុំបានឃើញបង្គោលពន្លឺមួយនៅចំលើក្បាលខ្ញុំមានរស្មីចែងចាំងលើសជាងសុរិយាទៅទៀត ដែលចុះសន្សឹមៗមកចំលើរូបខ្ញុំ ។

« ខ្ញុំបានរួចពីខ្មាំងសត្រូវដែលបានចងខ្ញុំទុក ។ ... កាលពន្លឺនោះស្ថិតចំលើរូបខ្ញុំ ខ្ញុំបានឃើញតួអង្គពីរ » ។

កាលខ្ញុំបានអានពាក្យទាំងនេះរួចហើយ ខ្ញុំបានចាប់ផ្ដើមរញ្ជួយហាក់ដូចជារលកអគ្គីសនីបានចូលយ៉ាងពាសពេញក្នុងខ្លួនរបស់ខ្ញុំទាំងមូល ។ មួយរំពេចនោះខ្ញុំបានដឹងថាយ៉ូសែបស្ម៊ីធ ពិតជាបានឃើញព្រះវរបិតាសួគ៌ ហើយព្រះរាជបុត្រាសំណប់ របស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំបានដឹងថា យើងមានព្រះគម្ពីរមរមនពីព្រោះវាត្រូវបានបកប្រែតាមរយៈព្យាការីរបស់ទ្រង់ ។

ខ្ញុំមានអំណរគុណថា ព្រះវរបិតាសួគ៌បានប្រទានដល់ខ្ញុំនូវសាក្សីនេះនៃភាពពិតដ៏ពេញលេញនៃទស្សនទិមិត្តទីមួយ ។ ខ្ញុំបានយល់ដឹងថា ប្រសិនបើដំណឹងល្អមិនត្រូវបានសាងឡើងវិញទេ ខ្ញុំនឹងមិនដែលដឹងអំពីព្រះដ៏ប្រោសលោះរបស់ខ្ញុំឡើយ ។ ខ្ញុំដឹងថាភាពពេញលេញនៃដំណឹងល្អគឺពិត ហើយខ្ញុំដឹងថាខ្ញុំនឹងទទួលសេចក្ដីសន្យាទាំងឡាយរបស់ព្រះ ប្រសិនបើខ្ញុំនឹងស៊ូទ្រាំរហូតដល់ទីបញ្ចប់ ។ ■

ជីង-ជួន ឆិន មកពីតៃវ៉ាន់



# តើខ្ញុំអាចទទួលបានពរដូចម្តេច ?

ជាច្រើនឆ្នាំកន្លងមក ខ្ញុំបានទៅធ្វើការបង្រៀនតាមផ្ទះជាមួយបងប្រុសម្នាក់ ឈ្មោះបងប្រុស ស្វាហ្វ ទៅមន្ទីពេទ្យដើម្បីផ្តល់ពរនៃបព្វជិតភាពដល់ប្រពន្ធរបស់គាត់មុននឹងទទួលការវះកាត់ ។ បងស្រីស្វាហ្វ បានស្នាក់នៅក្នុងបន្ទប់ជាមួយស្ត្រីម្នាក់មានឈ្មោះថា អ៊ែនី ឡេដបាជាអ្នកមានជម្ងឺរ៉ាំរ៉ៃជាមួយ ដែលជាជម្ងឺមហារីកផ្តាច់ជីវិតដែលនឹងគ្មានសង្ឃឹមថានឹងអាចរស់នៅបានយូរតទៅទៀតឡើយ ។

ខ្ញុំបានឈោងទៅវែកបើកវាំងននរវាងគ្រែមន្ទីរពេទ្យទាំងពីរ មុននឹងការចាប់ផ្តើមឱ្យពរ ប៉ុន្តែខ្ញុំបានឈប់ ។ ដោយមិនចង់ទុកអ៊ែនី នៅតែម្នាក់ឯង ខ្ញុំបានពន្យល់នូវអ្វីដែលយើងរៀបចំនឹងធ្វើ ហើយបើសួរប្រសិនបើ គាត់ចង់ធ្វើជាសាក្សីនៃការប្រសិទ្ធពរ ។ គាត់បានឆ្លើយថាគាត់ចង់មើល ។ ស្វាមីរបស់គាត់ ដែលបានស្លាប់ទៅ បានធ្វើជាគ្រូគង្វាលនៃសាសនាចក្រមួយទៀត ហើយថាគាត់មានចិត្តចង់ដឹងអំពីអ្វីដែលយើងជឿ ។ បងប្រុសស្វាហ្វ និងខ្ញុំបានបន្តធ្វើការប្រសិទ្ធពរ នៅពេលដែលអ៊ែនី បានស្តាប់

ពីរបីថ្ងៃក្រោយមក មុននឹងបងស្រីស្វាហ្វបានចេញពីមន្ទីរពេទ្យត្រឡប់ទៅផ្ទះវិញ អ៊ែនីបានសួរប្រសិនបើ គាត់អាចទទួលពរបព្វជិតភាពដែរ ។ បងប្រុសស្វាហ្វ និងខ្ញុំបានត្រឡប់ទៅមន្ទីរពេទ្យវិញ ដោយចិត្តរីករាយ នឹងផ្តល់ការប្រសិទ្ធពរដល់គាត់ ។ អ៊ែនី មិនបានជាជម្ងឺមហារីករបស់គាត់ទេ ប៉ុន្តែសុខភាពរបស់គាត់បានធូរស្បើយជាច្រើន ។



*ខ្ញុំបានឈោងទៅវែកបើក វាំងនន រវាង គ្រែមន្ទីរពេទ្យទាំងពីរ មុននឹងការចាប់ផ្តើម ប្រសិទ្ធពរ ប៉ុន្តែខ្ញុំបាន ឈប់ ដោយមិនចង់ទុក អ៊ែនី ឱ្យនៅតែម្នាក់ឯង ។*

គាត់បានមានបំណងចង់រៀនថែមទៀតអំពីដំណឹងល្អដូច្នេះហើយ ខ្ញុំបានស្នើសុំពួកអ្នកផ្សព្វផ្សាយ សាសនាឱ្យទៅមន្ទីរពេទ្យដើម្បីបង្រៀនគាត់ ។ គាត់បានស្តាប់ដល់សារដំណឹងល្អជាមួយដួងចិត្តបើកចំហរហើយបានជ្រើសទទួលបុណ្យជ្រមុជទឹក ។ រៀងរាល់សប្តាហ៍បន្ទាប់ពីបុណ្យជ្រមុជទឹករបស់គាត់ យើងបានទៅមន្ទីរពេទ្យដើម្បីទៅយកអ៊ែនី ទៅ ព្រះវិហារនៅក្នុងកៅអីមានកង់របស់គាត់ ។

ពីព្រោះអ៊ែនីមានជម្ងឺ គឺពិបាកនឹងដឹកជូនគាត់ណាស់ ប៉ុន្តែមិនយូរក្រោយមក បានរកឃើញរបៀបផ្ទាល់ របស់គាត់ ដើម្បីនឹងបម្រើព្រះអម្ចាស់ ។ យើងបានយកអង្គុលីលេខមួយឱ្យគាត់ ហើយគាត់បានចំណាយពេលជាច្រើនម៉ោង រៀងរាល់ថ្ងៃនៅក្នុងមន្ទីរពេទ្យធ្វើកិច្ចការពង្សប្រវត្តិ ។ អ៊ែនី បានរស់នៅបីឆ្នាំលើសពីកំណត់ពេល ហើយបានរៀបចំឈ្មោះក្រុមគ្រួសារទាំងឡាយ សម្រាប់ព្រះវិហារមុនគាត់បានទទួលមរណៈ ។

បន្ទាប់ពីមរណភាពរបស់អ៊ែនី បងស្រីស្វាហ្វបានធ្វើបុណ្យជំនួសជូនតាស្ត្ររបស់អ៊ែនី ជាច្រើននាក់ ។

តាមដែលខ្ញុំដឹង អ៊ែនី គឺជាសមាជិកនៃក្រុមគ្រួសារតែម្នាក់របស់នាង ដែលចូលរួមក្នុងសាសនាចក្រ ។ ក្រុមគ្រួសារដែលនៅរស់របស់គាត់មិនដែលមានចិត្តសោមនស្សអំពីការចូលរួមរបស់គាត់ជាមួយសាសនាចក្រទេ ប៉ុន្តែខ្ញុំជឿថាសមាជិកក្រុមគ្រួសារដែលបានស្លាប់របស់គាត់ មានអំណរគុណចំពោះការងារជំនួស ដែលត្រូវបានធ្វើសម្រាប់ពួកគេ ។

យើងមិនដែលដឹង ប្រសិនបើមនុស្សដែលយើងជួបនឹងទទួលដំណឹងល្អឬអត់នោះទេ ។ ខ្ញុំមានអំណរគុណដែលខ្ញុំអាចមើលឃើញគ្រាប់ពូជ—ដែលបានដាំនៅក្នុងដួងចិត្តរបស់អ៊ែនី បន្ទាប់ ពីគាត់បានធ្វើជាសាក្សីនៃការប្រសិទ្ធពរបព្វជិតភាព—បានលូតលាស់ឡើងហើយបានផ្តល់ជាពរដល់ កូនចៅរាប់រយនាក់របស់ព្រះវរបិតាសួគ៌ ។ ■

អាត គ្រេតឌីរ៍ មកពីក្រុងញូវយ៉ក ស.ហ.អ

# បំណងប្រាថ្នានៃបុណ្យខួបរបស់ខ្ញុំ

ខ្ញុំបានទទួលដំណឹងល្អកាលមានអាយុ 18 ឆ្នាំ ខ្ញុំបានយល់ដឹងថា ខ្ញុំបានភ្លក់ផ្លែឈើដ៏ផ្អែមបំផុត ជាងផ្លែឈើទាំងអស់ ។ ខ្ញុំមានអារម្មណ៍នៃសេចក្ដីអំណរដ៏ធំ ប៉ុន្តែខ្ញុំបានគិតអំពីសមាជិកក្រុមគ្រួសាររបស់ខ្ញុំ ដែលបានវង្វេងបាត់ បង់ ។ ខ្ញុំមានអារម្មណ៍ទុក្ខសោកក្រៃលែង ដោយព្រោះខ្ញុំគឺជាសមាជិកនៃសាសនាចក្រតែម្នាក់ឯង នៅក្នុងក្រុម គ្រួសាររបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងអំពីរបៀបបើកភ្នែក និងត្រចៀកអ្នកឯទៀតចំពោះការពិតទេ ។

ខ្ញុំបានខិតខំជាច្រើនលើកច្រើនគ្រា ដើម្បីនឹងបញ្ចុះបញ្ចូលក្រុមគ្រួសាររបស់ខ្ញុំ ឱ្យស្ដាប់ពួកអ្នកផ្សព្វផ្សាយសាសនា ។ ប៉ុន្តែកាលណាខ្ញុំកាន់តែខិតខំ ពួកគេកាន់តែមានចិត្តរុញរា

ខ្ញុំបានស្រងាកចិត្តយ៉ាងខ្លាំង ដូច្នេះហើយខ្ញុំបានគិតថាមិនចង់ទៅព្រះវិហារទៀតឡើយ ។ ប៉ុន្តែខ្ញុំបានអធិស្ឋាន នោះវគ្គនៃព្រះគម្ពីរបានផុសឡើងនៅក្នុងគំនិតរបស់ខ្ញុំ ៖ « ហើយបន្ទាប់ការនេះ [អ្នក] មិនទទួលស្គាល់យើងទៀត នោះប្រសើរជាងបើអ្នកមិនដែលបានស្គាល់យើងសោះ » (នីហ្វៃទី 2 31:14) ។ ខ្ញុំបានខំអធិស្ឋាន អានព្រះគម្ពីរ ទៅចូលរួមការប្រជុំសាសនាចក្រ ហើយបានផ្ដោតចិត្តទៅលើពរទាំងឡាយនៅក្នុងជីវិតរបស់ខ្ញុំ ។ ជាលទ្ធផល ការឈឺចាប់ចាប់ផ្ដើមរសាយបាត់ទៅ ។

កាលដែលបុណ្យខួបរបស់ខ្ញុំចូលមកដល់ ខ្ញុំបានមានអារម្មណ៍បំផុសគំនិតឱ្យធ្វើពិធីបុណ្យខួប នៅក្នុងផ្ទះរបស់ខ្ញុំ ហើយខ្ញុំគប្បីអញ្ជើញមិត្តភក្ដិក្នុងសាសនាចក្រទាំងអស់របស់ខ្ញុំ រួមជាមួយពួកអ្នកផ្សព្វផ្សាយសាសនាទៀតផង ។ ខ្ញុំចង់ឱ្យក្រុមគ្រួសាររបស់ខ្ញុំមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសមាជិកទាំងឡាយនៃសាសនាចក្រ ដែលចំពោះរូបខ្ញុំ ពួកគេហាក់ដូចជាមនុស្សដ៏រីករាយបំផុតនៅក្នុងពិភពលោក ។ ចំពោះខ្ញុំ ពិធីជប់លៀងហាក់ដូចជារាត្រីជួបជុំគ្រួសារ ។



*កាលដែលបុណ្យខួបរបស់ខ្ញុំចូលមកដល់ ខ្ញុំបានមានអារម្មណ៍បំផុសគំនិតឱ្យធ្វើពិធីបុណ្យខួប នៅក្នុងផ្ទះរបស់ខ្ញុំ ហើយខ្ញុំគប្បីអញ្ជើញមិត្តភក្ដិសាសនាចក្រទាំងអស់របស់ខ្ញុំ រួមជាមួយពួកអ្នកផ្សព្វផ្សាយសាសនាទៀតផង ។*

បន្ទាប់ពីថ្ងៃនោះមក អ្វីៗបានផ្លាស់ប្ដូរ ។ ពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានស្វាគមន៍ចូលផ្ទះរបស់យើង ហើយបានក្លាយទៅជាមិត្តដ៏ល្អប្រសើរ ជាមួយនឹងក្រុមគ្រួសាររបស់ខ្ញុំ ។ ថ្ងៃមួយ ឪពុករបស់ខ្ញុំបានប្រកាសថាគាត់ចង់ឱ្យក្រុមគ្រួសាររបស់យើងទាំងអស់គ្នា ស្ដាប់ពួកអ្នកផ្សព្វ ផ្សាយសាសនា ហើយទៅព្រះវិហារ ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

បីឆ្នាំបន្ទាប់ពីបុណ្យជ្រមុជទឹករបស់ខ្ញុំ ក្រុមគ្រួសាររបស់ខ្ញុំគ្រប់រូប បានទទួលបុណ្យជ្រមុជទឹក ។ នៅឯកម្មវិធីបុណ្យជ្រមុជទឹក ម្ដាយរបស់ខ្ញុំបានថ្លែងទីបន្ទាល់របស់គាត់ ហើយឪពុករបស់ខ្ញុំបានអរគុណ ពួកអ្នកផ្សព្វផ្សាយសាសនា ។ សមាជិកវួដមានចិត្តអស្ចារ្យចំពោះការប្រែចិត្តជឿរបស់ពួកគេ ។

តើវាបានកើតឡើងយ៉ាងដូចម្ដេច ? ទឹកភ្នែកទាំងអស់ដែលខ្ញុំបានសម្រក់ និងគោលដៅទាំងឡាយដែលខ្ញុំបានទទួលហើយ ។ ប៉ុន្តែដ៏សំខាន់បំផុត នោះដួងចិត្តរបស់ឪពុកខ្ញុំ ត្រូវបានបន្ទន់ដោយសេចក្ដីស្រឡាញ់ និងមិត្តភាពនៃ ពួកអ្នកផ្សព្វផ្សាយសាសនា និងសមាជិកវួដ ។ សមាជិកទាំងអស់គឺជាពួកអ្នកផ្សព្វផ្សាយសាសនាពីព្រោះតែគំរូនៃការអនុវត្តតាមដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំមានអំណរគុណចំពោះពួកគេ និងចំពោះផែនការណ៍របស់ព្រះវរបិតាសួគ៌ ដែលអនុញ្ញាតឱ្យក្រុមគ្រួសារ នៅជាមួយនឹងគ្នាជានិរន្ដ ។ ■

អាន់ជេលីកា ខាបូណោល ឌីកាល ប្រទេសហ្វិលីពីន



**ដោយអែលឌើរ**
**ម៉ៃកុល ធី រីងវូដ**
នៃពួកចិតសិបនាក់

# សេចក្ដីជំនឿ សេចក្ដីសង្ឃឹម ហើយនឹងទំនាក់ទំនង

*សេចក្ដីប្រាថ្នា ជំនឿ ហើយនិង សេចក្ដីសង្ឃឹមគប្បី បំផុតចិត្តរបស់យើង ឱ្យបង្កើតទំនាក់ទំនង ដែលនាំ ឆ្ពោះទៅ រកអាពាហ៍ពិពាហ៍ ។*

តើអ្នកបានធ្វើបញ្ជីវិជ្ជមាន និងអវិជ្ជមានឬទេ ? » សំណួរដែលកូនប្រុសជំទង់របស់ខ្ញុំបានសួរនៅក្នុងសម្លេងភ្ញាក់ផ្អើល បានយោងទៅលើបញ្ជីដែលគេបានរកឃើញនៅក្នុងកំណត់សារមួយរបស់ខ្ញុំ ។ វាមិនគ្រាន់តែជាបញ្ជីវិជ្ជមាន និងអវិជ្ជមានប៉ុណ្ណោះទេ វាគឺជាបញ្ជីដែលខ្ញុំបានធ្វើ 30 ឆ្នាំកន្លងមក មុននឹងខ្ញុំបានសុំប្រពន្ធរបស់ខ្ញុំរៀបការ ។ ខ្ញុំមិនដឹងថាតើមានបុរសប៉ុន្មាននាក់ដែលបានធ្វើបញ្ជីដូចរូបខ្ញុំឡើយ ប៉ុន្តែនៅពេលខ្ញុំបានសញ្ជឹងគិតអំពី គំនិតនៃអាពាហ៍ពិពាហ៍ជានិសិត្សអាយុ 24 ឆ្នាំម្នាក់ វាហាក់ដូចជាគំនិតល្អមួយ ។

ខ្ញុំមិនចាំនូវសំណួរឯទៀតពីកូនប្រុសរបស់ខ្ញុំអំពីការផ្ដើមទំនាក់ទំនងជាដៃគូក្នុងថ្ងៃនោះទេ កូនខ្ញុំមានចិត្តដក់ជាប់នឹងបញ្ជីនោះជាខ្លាំ ។ ខ្ញុំនៅតែអាចមើលឃើញគេដោយភ្នែករបស់ខ្ញុំ ស្រែកប្រកាសដល់បងប្អូនរបស់គេ « ប៉ា បានធ្វើបញ្ជីអំពីម៉ាក់ ! ចូរមកមើល ! » តែ ពេលដែលខ្ញុំមើលត្រឡប់ទៅក្រោយវិញ ខ្ញុំអាចគិតឃើញអំពីសំណួរជាច្រើនដែលគេ*អាច*នឹងសួរ ។

*តើប៉ាស្រឡាញ់ម៉ាក់ឬទេ ?* សំណួរនេះគប្បីជាសំណួរដំបូងរបស់គាត់ ។ ចម្លើយរបស់ខ្ញុំគឺថា ពិតមែនហើយ នោះគឺជាមូលហេតុដែលខ្ញុំបានធ្វើបញ្ជី ។ ខ្ញុំពិតជាស្រឡាញ់ភរិយាខ្ញុំ ហើយខ្ញុំ*បានប្រាថ្នា*ចង់ឱ្យគាត់មានភាពរីករាយណាស់ ។ បញ្ជីគឺមិនត្រឹមតែសម្រាប់មើលថាបើខ្ញុំអាចធ្វើឱ្យភរិយាខ្ញុំរីករាយ ជាជាងអំពីថា ប្រសិនបើ ខ្ញុំស្រឡាញ់នាងឬអត់នោះ ។

*តើប៉ាសប្បាយរីករាយជាមួយគ្នាឬទេ ?* សារជាម្ដងថ្មីទៀត ចម្លើយរបស់ខ្ញុំពិតជាថា ពិតមែនហើយ នោះគឺជាមូលហេតុដែលខ្ញុំបានធ្វើបញ្ជី ។ វាគឺជារបៀបមួយដើម្បីសង្កេតមើល ប្រសិនបើ*សេចក្ដីសង្ឃឹម*របស់ខ្ញុំ ថានាងនឹងតែងតែរីករាយក្អាកក្អាយជាមួយនឹងខ្ញុំ នឹងក្លាយទៅជាភាពពិតជាក់ស្ដែង ។

*តើអ្នកមិនគិតថានាងគឺជានារីត្រូវឬទេ ?* ប្រហែលនេះគឺជាសំណួរដ៏គួរឱ្យអស្ចារ្យជាងគេ ។ ខ្ញុំត្រូវតែបានឆ្លើយថាពិតមែនហើយ; ខ្ញុំបាន *ជឿ* នាងគឺជា « នារីនោះហើយ » ប៉ុន្តែខ្ញុំចង់ដឹងយ៉ាងពិតប្រាកដថា ជំនឿរបស់ខ្ញុំនឹងបំផុសសកម្មភាពនៅក្នុងផ្នែករបស់ខ្ញុំ ដើម្បីនឹងធ្វើឱ្យអ្វីៗមាន ចលនា ។

ខ្ញុំមិនគិតថាខ្ញុំពិតជាយល់ដឹងដ៏ពេញលេញក្នុងពេលនោះ ថាការបង្រៀននៃប្រធានបេសកកម្មរបស់ខ្ញុំអំពីសេចក្ដីជំនឿ និងសមាសភាគរបស់វា ដែលជាសេចក្ដីប្រាថ្នា ជំនឿ ហើយនឹងសេចក្ដីសង្ឃឹមមានឥទ្ធិពលទៅលើការផ្ដើមទំនាក់ទំនងជាដៃគូររបស់ខ្ញុំឡើយ ។ ជាមួយនឹងទិដ្ឋភាពកាន់តែច្បាស់លាស់អំពីពេលវេលា ខ្ញុំមានអំណរគុណចំពោះប្រធានអេហ្វ. រេហកគិនស៍ ចំពោះអនុភាពរបស់គាត់មកលើរូបខ្ញុំ ។ ខ្ញុំនៅតែមានកំណត់ត្រា ដែលខ្ញុំបានកត់ជាអ្នកផ្សព្វផ្សាយ

រូបថតដោយ អ៊ែន ប៊្រីគីនស៍





សាសនាអាយុ 20 ឆ្នាំម្នាក់ កាលដែលប្រធានបេសកកម្មដ៏ក្មេងម្នាក់របស់ខ្ញុំបានបើកព្រះគម្ពីរហើយបានពន្យល់អំពី កត្តាទាំងឡាយនៃសេចក្ដីជំនឿ ដែលក្រោយបានក្លាយទៅជាផ្នែកដ៏សំខាន់បំផុតនៃការសម្រេចជីវិតរបស់ខ្ញុំ ។

## ការបង្រៀនរបស់អាល់ម៉ាអំពីសេចក្ដីជំនឿ

ក្នុងចំណោមអ្វីៗដេលប្រធាន ហាកគិនស៍ បានចែកចាយអំពីការបង្រៀនរបស់អាល់ម៉ា អំពីសេចក្ដីជំនឿទៅកាន់ចំណោមអ្នកក្រីក្រពួកសូរាំ ។ អាល់ម៉ា បានរកឃើញនូវសេចក្ដីត្រូវការ ដើម្បីនឹងមានអនុភាពនៃសេចក្ដីជំនឿ ដែលគាត់បានពិពណ៌នាថាជា*សេចក្ដីប្រាថ្នា* សូមមើល អាល់ម៉ា 32:27) ។ សេចក្ដីប្រាថ្នាចំពោះអ្វីដែលនឹងកើតឡើង គឺជាអនុភាពដ៏ខ្លាំងក្លាសម្រាប់យើងដើម្បីនឹងបោះជំហានយ៉ាងចាំបាច់ដើម្បីនឹងបង្កើនសេចជំនឿរបស់យើង ។

អនុភាពទីពីរនៃសេចក្ដីជំនឿគឺជាអ្វីដែលអាល់ម៉ា បានបង្រៀនថាមកពីសេចក្ដីប្រាថ្នានោះគឺជា ៈ*ជំនឿ ។* គាត់បានបង្រៀនពួកសូរាំឱ្យបណ្ដោយឱ្យសេចក្ដីប្រាថ្នារបស់គេមានចលនានៅក្នុងខ្លួនពួកគេរហូតដល់ ពួកគេបានជឿតាមរបៀបមួយ ដែលពួកគេអាចទុកកន្លែងមួយសម្រាប់ពាក្យសំដីរបស់គាត់ នៅក្នុងដួងចិត្តរបស់ពួកគេ (សូមមើលវគ្គទី 27) ។
ការផ្ដួបបញ្ចូលនៃសេចក្ដីប្រាថ្នា និងជំនឿនេះចាប់ផ្ដើមរីកឡើងនៅក្នុងដួងចិត្តរបស់យើង យើងនឹងដឹងថាវាជាគ្រាប់ពូជល្អ ។ វាចាប់ផ្ដើមពង្រីកព្រលឹងរបស់យើងនឹងបំភ្លឺយោបល់របស់យើង ។ វាចាប់ផ្ដើមមានរសជាតិឆ្ងាញ់ ។ (សូមមើលខទី 28) ។

*សេចក្ដីសង្ឃឹម*គឺជាអនុភាពដ៏សំខាន់មួយទៀតនៃសេចក្ដីជំនឿ ។ អាល់ម៉ាបានប្រាប់ពួកសូរាំ ដែលមានចិត្តរាបទាបថា សេចក្ដីជំនឿគឺពុំមែនជាដំរិះដ៏ឥតខ្ចោះនៃអ្វីៗទាំងឡាយនោះឡើយ ។ វាគឺជា « *សេចក្ដីសង្ឃឹម*ទៅលើអ្វីៗដែលមើលមិនឃើញ ហើយដែលពិត » (អាល់ម៉ា 32:21; ការបញ្ជាក់បានបញ្ចូលបន្ថែម) ។ មរមនក៏បានបង្រៀនថា សេចក្ដីសង្ឃឹមថាជាអនុភាពចាំបាច់នៃសេចក្ដីជំនឿដូចគ្នាដែរ នៅពេលគាត់ បាននិយាយទៅកាន់មរ៉ូណៃ « តើធ្វើដូចម្ដេចឱ្យអ្នករាល់គ្នាបានសេចក្ដីជំនឿ លើកលែងតែអ្នករាល់គ្នា នឹងមានសេចក្ដីសង្ឃឹម ? » (មរ៉ូណៃ 7:40) ។ សេចក្ដីសង្ឃឹមអាចត្រូវបានពិពណ៌នាថា ជាសមត្ថភាពដើម្បីនឹងមើលឃើញអ្វីៗថាល្អប្រសើរ ក្នុងពេលអនាគត ។ [1] បញ្ជីរបស់ខ្ញុំ គឺជាមធ្យោបាយរបស់ខ្ញុំដើម្បីនឹងសម្លឹងទៅក្នុងអនាគត ជាមួយនឹងភ្នែកនៃសេចក្ដីជំនឿ ដូចជាអ័ប្រាហាំ ដោយសម្រេចថា « មានសុភមង្គល និងសេចក្ដីសុខសាន្ត » (គម្ពីរអ័ប្រាហាំ 1:2) សម្រាប់ខ្ញុំដើម្បីនឹងរៀបការទៅនឹងប្រពន្ធរបស់ខ្ញុំ ។

ការមាន*សេចក្ដីប្រាថ្នា*អនុភាពនៃសេចក្ដីជំនឿខ្ញុំបានត្រូវការ*ជំនឿ* ហើយនិង*សេចក្ដីសង្ឃឹម*ដើម្បីនឹងបំពេញសេចក្ដីជំនឿរបស់ខ្ញុំ ហើយខ្ញុំត្រូវការបញ្ចេញសកម្មភាព ដោយសុំ ឱ្យរ៉ូសសាលី រៀបការជាមួយខ្ញុំ ។ បញ្ជី—ការសម្ដែងនូវសេចក្ដីប្រាថ្នា ជំនឿ ហើយនិងសេចក្ដីសង្ឃឹម—គឺសំខាន់ក្រៃលែង ក្នុងការផ្ដល់ជាសេចក្ដីក្លាហានដើម្បីនឹងបញ្ចេញសកម្មភាព ចាំបាច់ដើម្បីបំពេញសេចក្ដីជំនឿរបស់ខ្ញុំ ។ យ៉ាកុប បានបង្រៀនសេចក្ដីជំនឿដោយគ្មានប្រព្រឹត្តតាមទេ នោះក៏ស្លាប់នៅតែឯង (សូមមើល យ៉ាកុប 2:17) ។ គ្មានចំនួនសេចក្ដីប្រាថ្នាជំនឿ ឬសេចក្ដីសង្ឃឹមណានឹងបានជួយខ្ញុំឱ្យរកឃើញសុភមង្គល និងសេចក្ដីសុខណា ដែលខ្ញុំបានរកឃើញនៅក្នុងអាពាហ៍ពិពាហ៍ ប្រសិនបើចុណ្ណភាគទាំងនោះ មិនបាននាំខ្ញុំឱ្យសួរ សំណួរដ៏ធំនោះ ។ (គួរឱ្យសោកស្ដាយ កាលដែលខ្ញុំសុំនាងរៀបការលើកដំបូង ចម្លើយរបស់រ៉ូសាលីគឺទេ ប៉ុន្តែនោះគឺជារឿងសម្រាប់គ្រាផ្សេងទៀត ។ នៅក្នុងកាលៈទេសៈទាំងឡាយបែបនេះ—នៅពេលអ្វីៗមិនកើតឡើងតាមគម្រោងឬពេលវេលា—សេចក្ដីជំនឿនៅតែមានមុខនាទីដ៏សំខាន់នៅក្នុងជីវិតរបស់យើង) ។ វាតម្រូវឱ្យមានការតស៊ូ និងការអត់ធ្មត់ខ្លះចំពោះយើងទាំងពីរនាក់ ហើយយើងក្រោយមកបានរៀបការ នៅក្នុងថ្ងៃធ្លាក់ព្រិល ក្នុងខែធ្នូ ឆ្នាំ 1982 ។

សេចក្ដីជំនឿគឺសំខាន់ក្រៃលែងនៅក្នុងអ្វីៗទាំងអស់ដែលយើងធ្វើ រួមជាមួយនឹងការដើរលេងជាដៃគូ និងការផ្ដើមទំនាក់ទំនងជាដៃគូ ។ សេចក្ដីប្រាថ្នា ជំនឿ ហើយនិងសេចក្ដីសង្ឃឹមថា ពិតជាមានសុភមង្គល និងសេចក្ដីសុខសាន្តដ៏ធំ កំពុងតែរង់ចាំយើង ជម្រុញយើងឱ្យបញ្ចេញសកម្មភាព ដើម្បីបង្កើតទំនាក់ទំនងដែលនាំទៅអាពាហ៍ពិពាហ៍ ។ តើអ្នក*ប្រាថ្នា*ដើម្បីអនុវត្តតាមគម្រោងនៃសុភមង្គលឬទេ ? តើអ្នក*ជឿ ថា*ការអនុវត្តតាមគម្រោងនឹងនាំទៅកាន់សុភមង្គល និងសេចក្ដីសុខសាន្តដ៏ធំឬទេ ? (សូមជឿខ្ញុំចុះ នៅពេលខ្ញុំប្រាប់អ្នកថា ការអនុវត្តតាមគម្រោងនិងអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារ បរិសុទ្ធនាំទៅកាន់សុភមង្គល និងសេចក្ដីសុខសាន្តដ៏ធំនោះ) ។ តើអ្នកសង្ឃឹមចំពោះអាពាហ៍ពិពាហ៍ដ៏រីករាយឬទេ ? តើសេចក្ដីសង្ឃឹមរបស់អ្នកឱ្យអ្នកមើលឃើញខ្លួនអ្នក នៅក្នុងទីកន្លែងកាន់តែល្អប្រសើរនាអនាគតឬទេ ? ប្រសិនបើចម្លើយរបស់អ្នកចំពោះសំណួរទាំងនេះគឺ ពិតមែន នោះអ្នកត្រូវតែបំពេញសេចក្ដីជំនឿរបស់ អ្នក ដោយបញ្ចេញសកម្មភាព ។ សូមសួរនរណាម្នាក់ឱ្យដើរលេងជាដៃគូនឹងអ្នក ! ទទួលការអញ្ជើញចេញទៅដើរលេងជាដៃគូ ! ធ្វើឱ្យខ្លួនអ្នកនៅក្នុងស្ថានភាពមួយ ដែលអាចនាំទៅនឹងការជួបនឹងពួកអ្នកមជ្ឈិមវ័យវ័យក្មេងដែលមានបំណងដូចអ្នក ។ និយាយសង្ខេបទៅ ស្វែងរកផ្លូវដែលនាំទៅសុភមង្គល និងសេចក្ដីសុខសាន្តដ៏ធំ ។





## គំរូនៃសេចក្តីជំនឿរបស់យ៉ូសែប ស៊្មីធ

ចូរយើងសម្លឹងមើលទៅយ៉ូសែប ស៊្មីធទុកជាគំរូនៃសេចក្តីជំនឿ និងការបង្ហាញនូវអនុភាពនៃសេចក្តីប្រាថ្នា ជំនឿ ហើយនិងសុភមង្គល ។

យ៉ូសែបចង់រកឃើញសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទពិត ។ សេចក្តីប្រាថ្នារបស់គាត់គឺខ្លាំងដ៏ម្ល៉េះនោះ ដែលវានាំគាត់បើកទៅអានវគ្គគម្ពីរមួយ ដែលជាកន្លែងគាត់បានអានថា « តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ » (យ៉ាកុប 1:5) ។ គាត់បានសញ្ជឹងគិតអំពីវគ្គគម្ពីរនេះ ។ គាត់*បានប្រាថ្នា*ចង់បានប្រាជ្ញា ហើយគាត់*បានជឿ*ថាគាត់នឹងទទួលវាបាន ប្រសិន គាត់ទូលសុំដល់ព្រះ ។ គាត់បានធ្វើតាមបំណងរបស់គាត់ ៖ គាត់បានអធិស្ឋាន ហើយបានទូលសុំដល់ព្រះ ។ ឥឡូវនេះ ចូរគិតអំពីបទពិសោធន៍នេះ មួយស្របក់សិន ។ យ៉ូសែបបានមានសេចក្តីប្រាថ្នាចង់ដឹងការពិត ។ គាត់បានជឿតាមពាក្យសំដីរបស់យ៉ាកុប ។ គាត់បានសង្ឃឹមចំពោះចម្លើយមួយ ។ ប៉ុន្តែប្រសិនបើគាត់បានឈប់ត្រង់នោះ យើងនឹងមិនទៅទីនេះថ្ងៃនេះទេ ។ ការអនុវត្តសេចក្តីជំនឿមានន័យថា គាត់បានចូលទៅក្នុងព្រៃហើយអធិស្ឋាន ។ ខ្ញុំជឿថា នៅពេលយ៉ូសែប បានចូលទៅក្នុងព្រៃដើម្បីអធិស្ឋាន គាត់បានជឿជាក់ថា គាត់នឹងដើរចេញមក វិញជាមួយនឹងចម្លើយមួយ ។ គាត់មិនបានគិតថានឹងឃើញព្រះវរបិតាសួគ៌ ហើយព្រះយេស៊ូវគ្រីស្ទទេ ប៉ុន្តែពិតជាជឿថានឹងបានចម្លើយមួយ ។ ឱគំរូនៃសេចក្តីជំនឿដ៏ធំក្រៃលែងអើយ ! គាត់បានមានចំណង់ គាត់បានជឿ គាត់បានសង្ឃឹម ហើយគាត់បានបញ្ចេញសកម្មភាព ។

សេចក្តីជំនឿរបស់ក្មេងប្រុសអាយុ 14 ឆ្នាំបានផ្លាស់ប្តូរពិភពលោក ។ ព្រោះតែការអធិស្ឋានរបស់យ៉ូសែប នៅក្នុងព្រៃពិសិដ្ឋ ស្ថានសួគ៌បានបើកទ្វារ ហើយព្រះអម្ចាស់បានមានបន្ទូលម្តងទៀតមកកាន់កូនចៅរបស់ទ្រង់តាមរយៈព្យាការីម្នាក់ ។

## ការបង្ហាញសេចក្តីជំនឿគឺគម្ពីជាឱកាសមួយរបស់អ្នក

ព្រះអម្ចាស់បន្តមានបន្ទូលតាមរយៈព្យាការីរបស់ទ្រង់ទាពេលសព្វថ្ងៃនេះ ។ គ្រាន់តែជាងមួយឆ្នាំកន្លះមុននេះ ប្រធានថូម៉ាស អេស. ម៉នសុន បានមានប្រសាសន៍ថា ៖

« មានទូវចំណុចដ៏សំខាន់ ដែលជាពេលវេលាដើម្បីគិតយ៉ាងហ្មត់ចត់អំពីអាពាហ៍ពិពាហ៍ហើយស្វែងរក ដៃគូ ដែលអ្នកនឹងចំណាយភាពអស់កល្បជានិច្ចជាមួយនឹងគ្នា ។ ប្រសិនបើអ្នកជ្រើសដោយឈ្លាសវៃ ហើយប្រសិនបើអ្នកប្តេជ្ញាចិត្តនឹងចង់បានជោគជ័យក្នុងអាពាហ៍ពិពាហ៍ គ្មានអ្វីទៅក្នុងជីវិតនេះ ដែលនាំមកដល់អ្នកនូវសុភមង្គលដ៏ធំឡើយ ។

« នៅពេលអ្នករៀបការ ... អ្នកនឹងប្រាថ្នាចង់រៀបការនៅក្នុងដំណាក់របស់ព្រះអម្ចាស់ ។ ចំពោះអ្នកកាន់បព្វជិតភាព គ្មានជម្រើសណាទៀតឡើយ ។ ចូរប្រុងប្រយ័ត្ន កុំឱ្យអ្នកបំផ្លាញនូវលក្ខណៈសម្បត្តិរបស់អ្នក ដើម្បីនឹងរៀបការឡើយ ។ អ្នកអាចរក្សាការផ្តើមទំនាក់ទំនងជាដៃគូរបស់អ្នក នៅក្នុងចំណងត្រឹមត្រូវក្នុងពេលកំពុងតែស្ថិតនៅក្នុង ពេលដ៏ល្អប្រិមប្រិយនៅឡើយ » ។[2]

បំណងប្រាថ្នា ជំនឿ ហើយនិងសេចក្តីសង្ឃឹមរបស់អ្នក ប្រហែលជាមិនបានសម្តែងនៅក្នុងទ្រង់ទ្រាយនៃបញ្ជីណាមួយ ដូចជាបញ្ជីរបស់ខ្ញុំនោះឡើយ ប៉ុន្តែអ្នកបង្ហាញគុណភាពទាំងនេះ វានឹងជួយអ្នកឱ្យបញ្ចប់សេចក្តីជំនឿរបស់អ្នក ដោយការអនុវត្តតាមព្យាការីរបស់ព្រះអម្ចាស់ ដើម្បីស្វែងរកដៃគូ ដែលអ្នកនឹងអាចរកឃើញសុភមង្គលដ៏ធំបាន ។ បំណងប្រាថ្នា ជំនឿ ហើយនឹងសេចក្តីសង្ឃឹមរបស់អ្នកក៏នឹងជួយអ្នកឱ្យជ្រើសដោយឈ្លាសវៃដែរ ។

ពរជ័យនៃការជ្រើសដើម្បីទទួលបាន និងថែទាំអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច នឹងនាំយើងទៅកាន់ការពិសោធន៍ផ្លែឈើនៃដំណឹងល្អ ដូចដែលអាល់ម៉ាបានពិពណ៌នាថា « មានតម្លៃ ... មានរសជាតិផ្អែមលើអ្វីៗដែលផ្អែម ហើយ ... ឥតខ្ចោះលើអ្វីៗដែលឥតខ្ចោះ » ។ គាត់បានបន្តទៀតថា « អ្នករាល់គ្នានឹងទទួលទាន [ផ្លែនេះ] រហូតដល់អ្នករាល់គ្នាបានឆ្អែតឆ្អន់ ដើម្បីកុំឱ្យអ្នករាល់គ្នាឃ្លាន ហើយកុំឱ្យអ្នករាល់គ្នាស្រេកទៀតឡើយ » (អាល់ម៉ា 32:42) ។ ជាជាងការភ័យខ្លាចអំពីអនាគត ចូរអនុវត្តសេចក្តីជំនឿដែលនឹងឱ្យអ្នកគោងចាប់យកសេចក្តីសន្យាទាំងឡាយ របស់ព្រះអម្ចាស់ ។ ■

**កំណត់ចំណាំ**

1. សូមមើល ជិន្នីស អេហ្វ វ៉ាសម៉ូសិន « What Faith Is » នៅក្នុង លែរី អ៊ី ដល និងឆាលស៍ ឌី ធេត ជូញ៉ែរ បានកែសម្រួល *ការអធិប្បាយអំពីសេចក្តីជំនឿ នៅក្នុងចិន្តភាពព្រះគម្ពីរសាស្ត្រ* (1990), 164 ។
2. ថូម៉ាស អេស ម៉នសុន « អំណាចបព្វជិតភាព » *លីអាហូណា* ខែឧសភា ឆ្នាំ 2011, 67–68 ។



**ដោយអែលឌើរ**
**ហ្វ៊ូន អេ យូសេដា**
នៃពួកចិតសិបនាក់

# ព្រះគម្ពីរមរមន—ចូរចែកចាយវា

*ខ្ញុំបានដឹងថាព្រះគម្ពីរមរមនពិត ពីព្រោះតែចំណុចបីយ៉ាងដែលខ្ញុំមានក្នុងអារម្មណ៍នៅពេលខ្ញុំអាន*

នៅពេលខ្ញុំមានអាយុ 18 ឆ្នាំ ខ្ញុំបានរស់នៅក្នុងក្រុងលីម៉ា ប្រទេសប៉េរូ ជាទីកន្លែងដែលខ្ញុំបានកើតមក និងធំឡើង ។ ក្នុងពេលនោះ ឪពុករបស់ខ្ញុំបានជួបមិត្តដ៏ល្អម្នាក់ដែលគាត់មិនបានជួបជាយូរណាស់មកហើយ ។

ឪពុករបស់ខ្ញុំពេញចិត្ត ដោយព្រោះតែមិត្តរបស់គាត់បានភ្ញាក់ផ្អើលដែលមិត្តរបស់គាត់មើលទៅក្មេងជាងមុន ហើយមានសម្លៀកបំពាក់ស្អាតបាត ។ គាត់បានសួរមិត្តរបស់គាត់ នូវអ្វីដែលបានកើតឡើងដល់គាត់ ដែលបង្កើតចំពោះការប្រែក្លាយនេះ ។ « តើអ្នកទើបតែចាប់លេខឆ្នោតត្រូវឬ ? » គាត់បានសួរ ។ មិត្តបានឆ្លើយតបថា « គឺមកពីបុព្វហេតុដែលល្អប្រសើរជាងនោះទៅទៀត ។ ឥឡូវនេះ ខ្ញុំគឺជាសមាជិកសាសនាចក្រមរមន ហើយខ្ញុំចង់ចែកចាយដំណឹងល្អជាមួយអ្នក និងគ្រួសាររបស់អ្នក » ។



*អែលឌើរយូសេដា (រូបទីពីរពីខាងស្ដាំ) ជាមួយនឹងក្រុមគ្រួសារនៅក្នុងក្រុងលីម៉ា ប្រទេសប៉េរូ មិនយូរប៉ុន្មានក្រោយពីគាត់បានចូលរួមក្នុងសាសនាចក្រ ។*

រូបថតនៃក្រោមគ្រួសារ រូបរបស់អែលឌើរយូសេដា រចនារូបភាពដោយប្រៃអិន ខល

ឪពុករបស់ខ្ញុំបានគិតថា មិត្តរបស់គាត់កំពុងតែលេងនឹងគាត់ ដូច្នេះគាត់បាននិយាយថា « យល់ព្រម ប្រសិនបើសំឡាញ់ចង់បញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាឱ្យមក សូមធ្វើចុះ » ។ ប៉ុន្តែបុរសនេះនិយាយពិត ហើយនៅក្នុងអំឡុងពីរបីថ្ងៃ ពួកអ្នកផ្សព្វផ្សាយសាសនាបានមក ហើយគោះទ្វាររបស់យើង ។ នោះគឺជាការចាប់ផ្ដើមនូវបទពិសោធន៍ដ៏អស្ចារ្យ ។

ពួកសាសនាទូតបានបង្រៀនយើងអំពីព្រះគម្ពីរមរមន ហើយបានទុកព្រះគម្ពីរមរមនមួយក្បាលឱ្យយើងអាន ។ ការណ៍នេះកើតឡើងក្នុងរដូវក្ដៅ ហើយខ្ញុំបានដើរលេងវិស្សមកាលអស់ពីរខែ បន្ទាប់ពីបានបញ្ចប់ឆ្នាំទី មួយនៅឯសកលវិទ្យាល័យ ។ ខ្ញុំបានយកសៀវភៅចេញមកពេលរសៀលនោះ បន្ទាប់ពីការពិភាក្សា ហើយបានចាប់ផ្ដើមអានវា ។

ពីទំព័រមួយទៅទំព័រមួយខ្ញុំបានអាន ហើយអានទៀត ហើយខ្ញុំមិនអាចឈប់សោះ ។ នេះពិតជាបទពិសោធន៍ដ៏មានឥទ្ធិពលក្រៃលែង ចេញពីព្រះគម្ពីរមរមន ។ ខ្ញុំចូលចិត្តអានហើយបានអានសៀវភៅមរមនជាច្រើន ប៉ុន្តែព្រះគម្ពីរនេះខុសប្លែកពីគេ ។ ខ្ញុំបានដក់ចិត្តជាប់នឹងសៀវភៅនោះ ហើយបន្ទាប់ពីខ្ញុំបានអានជាច្រើនម៉ោង ម្ដាយរបស់ខ្ញុំបាននិយាយថា « ហ្វ៊ន បិទភ្លើងទៅ ! បងប្អូនប្រុសរបស់ឯងត្រូវការដេក » ។ ហើយខ្ញុំបាននិយាយថា « បាទ សូមចាំបន្តិចសិន » ហើយខ្ញុំបានបន្តអាន ។ ព្រមទាំងបន្ទាប់ពីការអានជាច្រើនម៉ោងមក ខ្ញុំមិនឃ្លាន មិនស្រេក ហើយនិងគ្មានបំណងចង់ដេកឡើយ ។

មុននឹងខ្ញុំបានបញ្ចប់ព្រះគម្ពីរនោះ ខ្ញុំបានដឹងថា ព្រះគម្ពីរនេះពិសេស ។ ខ្ញុំបានមានទីបន្ទាល់ ដោយព្រោះតែចំណុចបីយ៉ាង ដែលខ្ញុំបានពិសោធន៍ ក្នុងពេលខ្ញុំកំពុងតែអានព្រះគម្ពីរនោះជាលើកដំបូង ។

ចំណុចទីមួយដែលបានកើតឡើងចំពោះខ្ញុំក្នុងអំឡុងម៉ោងទាំងនោះ គឺជាអារម្មណ៍ដ៏មានជម្រៅនៃសេចក្ដីសុខសាន្ត ដែលខុសពីអ្វីៗដែលខ្ញុំបានដកពិសោធន៍ពីមុនមក ។ អារម្មណ៍នៃសន្តិភាពគឺនៅជាមួយនឹងខ្ញុំជាច្រើនម៉ោង ។

ការណ៍ទីពីរ ខ្ញុំបានដកពិសោធន៍គឺក្នុងពេលខ្ញុំកំពុងតែអាន គឺជាអារម្មណ៍នៃសេចក្ដីអំណរ ។ វាពុំមែនអារម្មណ៍សុភមង្គលដែលខ្ញុំធ្លាប់មានពីមុន នៅពេលដែលខ្ញុំនៅជាមួយនឹងមិត្តភ័ក្ដទាំងឡាយ របស់ខ្ញុំ ឬនៅពេលខ្ញុំបានទិញអ្វីមួយដែលខ្ញុំពិតជាពេញចិត្តឡើយ ។ វាពុំមែនជាអារម្មណ៍នៃសុភមង្គលទេ វាគឺជាអារម្មណ៍នៃសេចក្ដីអំណរ ។ កាលដែលខ្ញុំកំពុងតែអាន ខ្ញុំបានចាប់ផ្ដើមយំហើយខ្ញុំបានយល់ដឹងថា « ពុទ្ធោអើយ ខ្ញុំពិតជារីករាយណាស់ ! »

ហើយចំណុចទីបីដែលខ្ញុំបានដកពិសោធន៍នោះគឺជាការបំភ្លឺ ។ នៅពេលខ្ញុំបានចាប់ផ្ដើមអានដំបូង វាពិតជាពិបាកនឹងយល់ដោយព្រោះតែវាមានពាក្យពេចន៍ដូចជា *នីហ្វៃ*ហើយនិង*ដង្វាយធួន*ដែលខ្ញុំមិនដែលឮពីមុន ។ ប៉ុន្តែបន្ទាប់ពីពីរបីម៉ោងនៃការអាន ចិត្តគំនិតបានបើកចំហរ ហើយវាហាក់ដូចជាមានពន្លឺនៅក្នុងចិត្តគំនិតរបស់ខ្ញុំ ហើយខ្ញុំអាចយល់កាន់តែច្រើនឡើងៗ ក្នុងពេលដែលខ្ញុំបានបន្តអានព្រះគម្ពីរនោះ ។



ខ្ញុំបានរៀនក្រោយមកថា បទពិសោធន៍ទាំងបីនោះ គឺជារបៀបខ្លះដែលព្រះវិញ្ញាណបើកបង្ហាញដល់យើង ។ ខ្ញុំបានទទួលព្រះវិញ្ញាណ ហើយខ្ញុំបានត្រៀមរួចជាស្រេចដើម្បីនឹងទទួលបុណ្យជ្រមុជទឹក ប៉ុន្តែខ្ញុំគប្បីរង់ចាំសមាជិកក្រុមគ្រួសារទាំងអស់របស់ខ្ញុំ ទទួលទីបន្ទាល់ផ្ទាល់ខ្លួនសិន ។ ទីបំផុត ក្នុងថ្ងៃទី 6 ខែមេសា ឆ្នាំ 1972 ម្ដាយខ្ញុំ ប្អូនស្រីខ្ញុំ ហើយនិងខ្ញុំបានទទួលបុណ្យជ្រមុជទឹក ។ ឪពុកម្ដាយ បងប្អូនពីរនាក់ទៀតបានមានវត្តមាននៅទីនោះ ហើយយកចិត្តទុកដាក់នឹងអ្វីដែលយើងកំពុងតែឆ្លងកាត់ ហើយពីរបីខែក្រោយមក ពួកគេបានទទួលបុណ្យជ្រមុជទឹកដែរ ។

សាសនាចក្រ និងដំណឹងល្អបានចូលមកក្នុងជីវិតរបស់ខ្ញុំ នៅក្នុងគ្រាដ៏ត្រឹមត្រូវ ។ នៅក្នុងឆ្នាំដំបូងនៃសកលវិទ្យាល័យ ខ្ញុំបានសេពគប់នឹងមនុស្សគ្រប់ប្រភេទ ហើយមានគំនិតថ្មីៗ និងមានរបៀបនៃការរស់នៅខុសពីអ្វីៗដែលខ្ញុំធ្លាប់មានពីមុនមក ។ តម្លៃជាច្រើនដែលខ្ញុំបានរៀននៅក្នុងសាសនាចក្រកាលនៅវ័យកុមារ ត្រូវបានសាកល្បង ដោយផ្លាស់ទូវគំនិតថ្មីៗ ដែលខ្ញុំធ្លាប់ដឹងពីមុន ។

នេះគឺពិបាកចំពោះរូបខ្ញុំ ពីព្រោះខ្ញុំបានស្មុគស្មាញ ។ មានទូវអ្វីៗថ្មីថ្មោងជាច្រើន ដែលខ្ញុំដឹងថាមិនត្រូវ ប៉ុន្តែវាហាក់ដូចជារឿងធម្មតាចំពោះអ្នកឯទៀត ។ ហើយដំរិះដែលខ្ញុំមានគឺមិនគ្រប់គ្រាន់ចំពោះខ្ញុំ ដើម្បីនឹងការពារតម្លៃទាំងឡាយរបស់ខ្ញុំឡើយ ។

បន្ទាប់ពីខ្ញុំបានទទួលបុណ្យជ្រមុជទឹក ការត្រឡប់ទៅសកលវិទ្យាល័យគឺខុសពីមុន ។ ឥឡូវនេះ ខ្ញុំមានពាក្យពេចន៍ខ្លះចង់ឆ្លើយតបជាមួយសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃ ។ ខ្ញុំអាចនិយាយដោយចិត្តក្លាហានថា « ទេ ! សូមអរគុណ ខ្ញុំមិនគិតថានោះគឺសម្រាប់ខ្ញុំឡើយ » ។ ហើយឥឡូវនេះ ខ្ញុំបានដឹងអំពីមូលហេតុដែលខ្ញុំត្រូវតែនិយាយបែបនោះ ។ សាសនាចក្រ និងព្រះគម្ពីរមរមនបានមកចំពេលវេលាសម្រាប់ខ្ញុំ ។ ខ្ញុំពិតជាមានអំណរគុណ ពីព្រោះការណ៍ទាំងនេះបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំ ។

ខ្ញុំបានពរពីព្រោះតែការសម្រេចចិត្តរបស់ខ្ញុំនឹងចូលរួមក្នុងសាសនាចក្រ ។ ខ្ញុំបានជួបមិត្តដ៏ល្អវិសេសរបស់ខ្ញុំនៅក្នុងសាសនាចក្រ ។ ខ្ញុំធ្លាប់ជាមនុស្សមានការអៀនខ្មាស់ច្រើន ហើយខ្ញុំចង់តែនៅតែម្នាក់ឯង សិក្សា អានសៀវភៅរបស់ខ្ញុំ ហើយខ្ញុំពេញចិត្តនឹងខ្លួនខ្ញុំ ។ ប៉ុន្តែនៅពេលសាសនាចក្របានចូលមកក្នុងជីវិតរបស់ខ្ញុំ ខ្ញុំបានរៀនដឹងអំពីមិត្តដ៏ពិតម្នាក់មានគុណសម្បត្តិបែបណា ។ ខ្ញុំបានជួបនឹងយុវនារីដ៏ស្រស់ស្អាតម្នាក់ នៅក្នុងសាសនាចក្រ ដែលក្រោយមកបានក្លាយទៅជាប្រពន្ធរបស់ខ្ញុំ ។ ខ្ញុំបានរកឃើញអ្នកដឹកនាំបព្វជិតភាព ហើយសមាជិកទាំងឡាយដែលយកចិត្តទុកដាក់នឹងខ្ញុំ។ នៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ខ្ញុំបានរកឃើញអ្វីដែលខ្ញុំត្រូវការ ។

មានមនុស្សជាច្រើន ដែលនឹងរកឃើញនូវអ្វីដែលពួកគេត្រូវការនៅក្នុងសាសនាចក្រ ។ កុំភ័យខ្លាចនឹងបើកមាត់របស់អ្នក និយាយទៅកាន់មិត្តភក្តិរបស់អ្នកហើយនិយាយថា « ខ្ញុំជឿទៅលើការណ៍នេះ ។ ខ្ញុំចង់ចែកចាយការណ៍នេះជាមួយអ្នក » ។ ជួនកាលអ្នកស្ដាប់ពួមនុស្សវ័យកណ្ដាលនិយាយអំពីអ្វីដែលត្រូវ និងខុស ប៉ុន្តែនៅពេលអ្នកមានមិត្តមានអាយុប្រហាក់ប្រហែលអ្នកដែលនិយាយពាក្យប្រាំដែលៗ អ្នកធ្វើតាមអ្នកនោះ ។ ដោយមូលហេតុ សំឡេងនៃមិត្តភក្តិរបស់យើង បន្លឺសូរខ្លាំងជាងសំឡេងរបស់មនុស្សដែលមានវ័យកណ្ដាល ។ ដូច្នេះហើយ ចូរធ្វើជាគំរូដ៏ល្អ ពីព្រោះអ្នកមិនដឹងថា ហ៊ូន យូសេដា នឹងរង់ចាំនៅទីនោះ ។ អ្នកនឹងមិនដឹងទេ លើកលែងតែអ្នកបើកមាត់របស់អ្នក ហើយនិយាយថា « ហ៊ូន ខ្ញុំចង់អញ្ជើញអ្នកទៅ ព្រះវិហាររបស់ខ្ញុំ ។ ខ្ញុំចង់ឱ្យអ្នកអានព្រះគម្ពីរនេះ » ។ ប្រសិនបើអ្នកធ្វើការណ៍ដ៏ងាយស្រួលនោះ អ្នកនឹងអាចផ្លាស់ប្ដូរជីវិតជាច្រើនរូប ។ ■



*បន្ទាប់ពីការចូលរួមក្នុងសាសនាចក្រ អែលឌើរយូសេដា បានមានឱកាសជាច្រើនដើម្បីនឹងចែកចាយ ទីបន្ទាល់របស់គាត់អំពីព្រះគម្ពីរមរមន ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក្នុងប្រទេសប៉េរូ ។ ខាងឆ្វេង ខាងលើ ៖ អែលឌើរយូសេដា (ខាងស្ដាំ) ឈរជាមួយក្រុមគ្រួសារប្រែចិត្តជឿដែលគាត់បានបង្រៀន ។ ខាងឆ្វេង ខាងក្រោម ៖ អែលឌើរយូសេដា (ជួរខាងក្រោយ ខាងស្ដាំ) ជួបជុំគ្នាជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ខាងក្រៅអគារនៃព្រះវិហារ ។*

មួយបន្ទាត់ម្ដងៗ

# គោលលទ្ធិ និង សេចក្ដីសញ្ញា 87:8

*ផ្ទៃរឿងម៉្យតឆលឆ្នាំនេះបង្រៀនយើងអំពីទីកន្លែងដើម្បីនឹងឈរសម្រាប់សុវត្ថិភាព ។*

៨ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ រហូតដល់ថ្ងៃនៃព្រះអម្ចាស់មកដល់; ត្បិតមើលចុះ ថ្ងៃនោះនឹងមកដល់យ៉ាងឆាប់រហ័ស ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះមែន ។ អាម៉ែន ៕



### ចូរឯងឈរឡើង

« ព្រះអម្ចាស់អញ្ជើញយើងឱ្យ ‹ ចូលមកក្បែរយើង ហើយយើងនឹងចូលមកក្បែរឯង ចូរខំប្រឹងប្រែងស្វែង រកយើងហើយឯងនឹងរកយើងឃើញ › ។ កាលដែលយើងធ្វើដូច្នេះ យើងនឹងបានទទួលអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ក្នុងជីវិតរបស់យើង ដោយផ្ដល់ដល់យើងនូវសេចក្ដី ប្រាថ្នា និងសេចក្ដីក្លាហាន ដើម្បីនឹងឈរយ៉ាងរឹងមាំ នៅក្នុងទីកន្លែងសុច្ចរិតភាព — ‹ ឈរ ... ក្នុងទីកន្លែងបរិសុទ្ធ ហើយកុំរើឡើយ ›» ។

ប្រធាន ថូម៉ាស អេស ម៉នសុន « Stand in Holy Places » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 86 ។

### ថ្ងៃរបស់ព្រះអម្ចាស់

*ថ្ងៃរបស់ព្រះអម្ចាស់*—ការយាងមកលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ

### ចូរកុំរើឡើយ

នេះគឺជារបៀបខ្លះដើម្បីបញ្ជាក់ថា អ្វីនឹងមិនត្រូវផ្លាស់ប្ដូរកន្លែងឡើយ ៖

- *ជាយុថ្កាមួយ*—« សេចក្ដីសង្ឃឹម ... ជាយុថ្កាមួយដល់ព្រលឹងមនុស្ស » (អេធើរ12:4)។
- *គ្រឹះយ៉ាងរឹងមាំ*—« គឺនៅលើសលានៃព្រះដ៏ប្រោសលោះនៃយើង គឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដែលកូនសង់គ្រឹះរបស់កូន ... ដែលជាគ្រឹះដ៏ខ្ជាប់ខ្ជួនមួយ » (ហេលេមិន5:12) ។
- *ជំហរដ៏រឹងមាំ*—អ្នកមិនអាចមានជើងម្ខាងនៅក្នុងក្រុងស៊ីយ៉ូន ហើយជើងម្ខាងទៀតនៅក្នុងលោកីយឡើយ « អ្នកនោះជាមនុស្សមានចិត្តពីរ ចេះតែសាវ៉ាក្នុងគ្រប់ទាំងផ្លូវ » (យ៉ាកុប 1:8) ។
- *គង់ស្តេក*—ពហុស្តេកនៃគង់ស៊ីយ៉ូនជួយសាសនាចក្រឱ្យមានជំហរខ្ពស់ហើយរឹងមាំនៅពេលផ្ដល់ជម្រកដល់យើងរាល់គ្នា ៖ « ការប្រមូលគ្នាមកលើដែនដីស៊ីយ៉ូន និងមកលើស្តេកទាំងឡាយរបស់នាង អាចបានទៅជាទីការពារនិងជាជ្រកពីព្យុះសង្ឃរា » (គ. និង ស. 115:6) ។

### វានឹងមកដល់យ៉ាងឆាប់រហ័ស

« យើងគប្បីរកមើលសញ្ញាទាំងឡាយ [នៃការយាងមកទីពីរ] យើងគប្បីរស់នៅដោយចិត្តស្មោះស្ម័គ្រ ស្របតាមសក្តានុពលរបស់យើង ។ ... ប៉ុន្តែយើងមិនត្រូវតែឈរគាំងតែមួយកន្លែង ពីព្រោះតែព្រឹត្តិការណ៍នោះ និងព្រឹត្តិការណ៍ទាំងឡាយជុំវិញវាស្ថិតនៅពីមុខរបស់យើង ត្រង់ទីកន្លែងណាមួយនោះឡើយ ។ យើងមិនអាចឈប់រស់នៅឡើយ ។ ពិតហើយ យើងគប្បីរស់នៅឱ្យកាន់តែពេញលេញ ជាជាងតាមរបៀបដែលយើងបានរស់នៅពីមុនៗ » ។

អែលឌើរ ជេហ្វ្រី អ. ហូលែនដ៏នៃកូរ៉ុមសាវកដប់ពីរនាក់ « នេះគឺជាគ្រាកាន់កាប់ ត្រួតត្រាដ៏ធំផុត » *លីអាហូណា*ខែកក្កដា ឆ្នាំ 2007, 19–20 ។

### នៅក្នុងទីកន្លែងបរិសុទ្ធនានា

« តើ... ‹ ទីកន្លែងបរិសុទ្ធ › គឺជាអ្វី ? ពិតហើយ ទីកន្លែងទាំងនោះ មានរួមជា *ព្រះវិហារបរិសុទ្ធ*និងសេចក្ដីសញ្ញារបស់វាបានរក្សាគោរពដោយស្មោះស្ម័គ្រ ។ ពិតហើយ ទីកន្លែងទាំងនោះមានរួមជា*គេហដ្ឋាន*ជាទីកន្លែងដែលកូនៗត្រូវបានចិញ្ចឹមបីបាច់ ហើយឪពុកម្ដាយត្រូវបានគោរព ។ ពិតហើយ ទីកន្លែងបរិសុទ្ធមានរួមជា*ទីតាំងនៃកាតព្វកិច្ចរបស់យើង*បានចាត់តាំងដោយអ្នកមាន សិទ្ធិអំណាច រួមជាមួយនឹងបេសកកម្ម និងការហៅដោយចិត្តស្មោះ បំពេញនៅក្នុងសាខា វួដ និងស្តេក » ។

អែលឌើរ ដាលឡិន ហ. អូកស៍នៃ កូរ៉ុមសាវកដប់ពីរនាក់ « ការរៀបចំសម្រាប់ការយាងមកលើកទីពីរ » *លីអាហូណា*ខែឧសភាត ឆ្នាំ 2004, 10; ការបញ្ជាក់បានបញ្ចូលបន្ថែម ។

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅទំព័រនេះពុំមែនមានន័យថា វាពន្យល់ដ៏ទូលំទូលាយពីខគម្ពីរដែលបានជ្រើសរើសនោះទេ វាគ្រាន់តែជាចំណុចចាប់ផ្ដើមមួយ សម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ ។*

# បាវចនាម្ជ័តឆល ឆ្នាំ 2013








## ការឈរនៅ ទីខ្ពស់

ដោយ ដេវីឌ អេល បេក
ប្រធានយុវជនទូទៅ

បាវចនាម្ជ័ឆលឆ្នាំ 2013 ត្រូវបានដកចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា 87:8 ៖ « ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ រហូតដល់ថ្ងៃនៃព្រះអម្ចាស់មកដល់ » ។ សំណួរដែលខ្ញុំសង្ឃឹមថា យុវជនគ្រប់រូប នឹងគិតពិចារណានៅពេញមួយឆ្នាំខាងមុខនេះគឺ *តើខ្ញុំកំពុងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយដែរឬទេ ?*

នៅពេលខ្ញុំបានជួបនឹងយុវជនក្លាហាននៅទូទាំងពិភពលោក ខ្ញុំបានធ្វើជាសាក្សីដោយផ្ទាល់ អំពីរបៀបដែលអ្នករាល់គ្នារាប់ពាន់នាក់ កំពុងធ្វើកិច្ចការនេះតាមមធ្យោបាយផ្សេងៗគ្នារួចជាស្រេចទៅហើយ ។ អ្នករាល់គ្នាឈរនៅក្នុងទីដែលបរិសុទ្ធបំផុត រៀងរាល់ពេលដែលអ្នកចូលក្នុងព្រះវិហារបរិសុទ្ធ ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់អ្នកស្លាប់ ។ ខ្ញុំលើកទឹកចិត្តអ្នកឱ្យឆ្លៀតឱកាសជារៀងរាល់ពេលដែលអ្នកមានដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយមានភាពសក្ដិសមដើម្បីធ្វើដូច្នោះជានិច្ច ។ ជារៀងរាល់ថ្ងៃ នៅពេលអ្នកបំពេញសៀវភៅកាតព្វកិច្ចចំពោះព្រះរបស់អ្នក នោះអ្នកឈរនៅក្នុងទីបរិសុទ្ធ ហើយស្ថិតនៅក្នុងកន្លែងមួយដើម្បីលើកតម្កើងដល់អ្នកដទៃ ។ អ្នកឈរនៅក្នុងទីបរិសុទ្ធ នៅពេលអ្នករៀបចំ ប្រសិទ្ធពរ និង ចែកសាក្រាម៉ង់ជារៀងរាល់ថ្ងៃអាទិត្យ ។ អ្នកឈរនៅក្នុងទីបរិសុទ្ធ នៅពេលអ្នកចែកចាយដំណឹងល្អ និង នៅពេលអ្នកធ្វើកិច្ចការជាអ្នកបម្រើដែល—ជាអ្នកបម្រើម្នាក់តែងតែមានសមត្ថភាព មានឆន្ទៈ និង សក្ដិសមដើម្បីបម្រើ និង ពង្រឹងដល់អ្នកដទៃ ។

ក្នុងនាមជាអ្នកកាន់បព្វជិតភាពអើរ៉ុន អ្នកត្រូវបានប្រគល់ឱ្យនូវភារៈដើម្បីព្រមាន, ដាស់តឿន, ពន្យល់, បង្រៀន និង អញ្ជើញមនុស្សទាំងអស់ឱ្យមករកព្រះគ្រីស្ទ (សូមមើល គ. និង ស. 20:59) ។ ប្រធាន ហារ៉ូលដ៍ ប៊ី លី (ឆ្នាំ 1899–1973) បានមានប្រសាសន៍ថា ៖ « អ្នកពុំអាចលើកស្ទួយព្រលឹងរបស់អ្នកផ្សេងឡើងបានទេ ទាល់តែអ្នកឈរនៅលើទីខ្ពស់ជាងអ្នកនោះសិន ។ ... អ្នកពុំអាចផ្ដល់ពន្លឺដល់ ព្រលឹងរបស់អ្នកដទៃបានទេ ទាល់តែព្រលឹងរបស់អ្នកមានពន្លឺជាមុនសិន » ។ [1] យុវជនទាំងឡាយ នេះមានន័យថា អ្នកគួរតែបន្តធ្វើកិច្ចការដើម្បីពង្រឹងដល់ទីបន្ទាល់របស់អ្នក ហើយតែងតែមានឆន្ទៈដើម្បីចែកចាយទីបន្ទាល់នោះជានិច្ច ។

អ្នកមានការទទួលខុសត្រូវដ៏ពិសិដ្ឋមួយ ដើម្បីធ្វើជាឧបករណ៍មួយនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។ នៅពេលអ្នកអធិស្ឋាន និង សិក្សាព្រះគម្ពីរ ព្យាយាមដើម្បីរក្សាបទបញ្ញត្តិ ហើយស្ដាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណ នោះអ្នកនឹងស្វែងរកឃើញថាខ្លួនអ្នកស្ថិតនៅក្នុងទីកាន់តែខ្ពស់ ។ ជាលទ្ធផល នៅគ្រប់កន្លែងណាក៏ដោយដែលអ្នកនៅ នោះអាចក្លាយជាទីបរិសុទ្ធមួយ ។ បន្ទាប់មក នៅពេលមានស្ថានភាពអ្វីមួយកើតឡើង នោះអ្នកនឹងមានកម្លាំង ក្លាហាន និង សមត្ថភាពដើម្បីជួយលើកស្ទួយដល់អ្នកដទៃ ។ អ្នកនឹងមានអំណាច និង ការការពារ ដែលព្រះអម្ចាស់សន្យាដល់អស់អ្នកណា ដែលឈរនៅក្នុងទីបរិសុទ្ធ ។

ខ្ញុំចូលចិត្តអ្វីដែលប្រធាន ថូម៉ាស អេស. ម៉នសុន បានមានប្រសាសន៍អំពីការសន្យាទាំងនេះ នៅពេលលោកអះអាងនឹងយើងនៅពេលយើងខិតទៅជិតព្រះអម្ចាស់ ថា « យើងនឹងមានព្រះវិញ្ញាណរបស់ទ្រង់នៅក្នុងជីវិតរបស់យើង ដែលផ្ដល់ដល់យើងនូវបំណងប្រាថ្នា និង ភាពក្លាហាន ដើម្បីឈររឹងមាំ និង មុតមាំនៅក្នុងសេចក្ដីសុចរិត—ដើម្បី ‹ ... ឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ › (គ. និង ស. 87:8) ។

« នៅពេលមានការផ្លាស់ប្ដូរកើតឡើងនៅជុំវិញយើង ហើយក្រមសីលធម៌នៃសង្គមបន្តរងនូវការខ្ទេចខ្ទាំ នៅចំពោះមុខយើងគ្រប់គ្នា នោះសូមឱ្យយើងចងចាំនូវការសន្យាដ៏មានតម្លៃរបស់ព្រះអម្ចាស់ ចំពោះអ្នកទាំងឡាយណាដែលទុកចិត្តលើទ្រង់ថា ៖ ‹ កុំឱ្យភ័យខ្លាចឡើយ ត្បិតយើងនៅជាមួយនឹងឯង កុំឱ្យស្រយុតចិត្តឱ្យសោះ ពីព្រោះយើងជាព្រះនៃឯង យើងនឹងចម្រើនកម្លាំងដល់ឯង អើ យើងនឹងជួយឯង › (អេសាយ 41:10) » ។ [2] ■

**កំណត់សំគាល់**

1. ហារ៉ូលដ៍ ប៊ី. លី « Stand Ye in Holy Places » *Ensign,* ខែកក្កដា ឆ្នាំ 1973 ទំព័រ 123 ។
2. ថូម៉ាស អេស ម៉នសុន « Stand in Holy Places » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 86 ។

រចនារូបភាពដោយ ឌេ ល្វីក






« ចូរអ្នករាល់គ្នាឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ ... »
(សូមមើល គ. និង ស. 87:8) ។



# **ទីបរិសុទ្ធ** នៅក្នុងជីវិតរបស់អ្នក

**ដោយ អេលលែន អេស ដាល់ថុន**
ប្រធានយុវនារីទូទៅ

បាវចនាម៉ូឆលឆ្នាំនេះ អញ្ជើញអ្នកឱ្យបោះជំហានដើរចេញពីពិភពលោក ហើយដើរចូលទៅក្នុងនគរនៃព្រះ ។ ដូចដែលប្រធាន ប៊យ ឃេ ផាកកឺ ជាប្រធាននៃកូរ៉ុមនៃសាវកដប់ពីរនាក់ បានបង្រៀនថា យើងរស់នៅក្នុងដែនដីរបស់មារសត្រូវ ។[1] « ចូរអ្នកឈរនៅក្នុងទីបរិសុទ្ធ » គឺជាកូនសោដើម្បីនៅរស់រានមានជីវិត ។

បាវចនានេះ អញ្ជើញឱ្យមានសំណួរសំខាន់ៗថា ៖ តើទីបរិសុទ្ធគឺជាអ្វី ? តើកន្លែងណាជាទីបរិសុទ្ធ ? តើយើងអាចឈរនៅក្នុងទីបរិសុទ្ធដោយរបៀបណា ? តើយើងអាចធ្វើឱ្យទីកន្លែងដែលយើងរស់នៅជាប្រចាំ កាន់តែបរិសុទ្ធបានដោយរបៀបណា ? នៅពេលអ្នកស្វែងរកចម្លើយចំពោះសំណួរទាំងនេះ ចម្លើយរបស់អ្នក នឹងដឹកនាំការទំនាក់ទំនងរបស់អ្នក ដឹកនាំជម្រើសរបស់អ្នកចំពោះសកម្មភាពទាំងឡាយ និង ដឹកនាំការស្លៀកពាក់ ការនិយាយស្ដី និង សកម្មភាពរបស់អ្នក ។

អ្នកបានតាំងចិត្តដើម្បីពង្រឹងដល់គេហដ្ឋាន និង គ្រួសាររបស់អ្នក ។ ចូរព្យាយាមធ្វើឱ្យគេហដ្ឋានរបស់អ្នកក្លាយជាទីបរិសុទ្ធ មានពេញទៅដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ អ្នកអាចគាំទ្រដល់ការអធិស្ឋានជាគ្រួសារ និង ការសិក្សាព្រះគម្ពីរជាគ្រួសារ ។

បន្ទប់របស់អ្នក អាចជាទីបរិសុទ្ធមួយ ដែលអញ្ជើញព្រះវិញ្ញាណ ។ បើព្យាការីទៅមើលបន្ទប់របស់អ្នក តើគាត់នឹងមើលឃើញវាជាទីបរិសុទ្ធមួយឬទេ ? ចុះអ្នកវិញ ?

យើងអាចឈរនៅក្នុងទីបរិសុទ្ធ នៅពេលយើងទៅព្រះវិហារ ។ ព្រះគម្ពីរបង្រៀនថា វួដ និង ស្តេកនៃស៊ីយ៉ូន គឺជាកន្លែងបរិសុទ្ធ ដែលនឹង « ជាទីកាពារ និង ជាទីជ្រកកោនពីព្យុះសង្ឃរា » (គ. និង ស. 115:6) ។

ទីបរិសុទ្ធបំផុតនៅលើផែនដី គឺព្រះវិហារបរិសុទ្ធ ។ ប្រធាន ថូម៉ាស អេស. ម៉នសុន បានមានប្រសាសន៍ថា ៖ « មិត្តវ័យក្មេងរបស់ខ្ញុំ ដែលជាយុវវ័យអើយ សូមឱ្យមានព្រះវិហារបរិសុទ្ធក្នុងកែវភ្នែករបស់អ្នកជានិច្ច ។ សូមកុំធ្វើអ្វីដែលនឹងរារាំងអ្នកមិនឱ្យចូលក្នុង ព្រះវិហារបរិសុទ្ធ ហើយទទួលពរជ័យដ៏ពិសិដ្ឋ និង អស់កល្បជានិច្ច នៅទីនោះឡើយ ។ ខ្ញុំសូមសរសើរចំពោះអ្នកទាំងឡាយដែលបានចូលទៅព្រះវិហារបរិសុទ្ធជាទៀងទាត់ ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់អ្នកស្លាប់រួចហើយនោះ » ។[2] ចូរមានភាពសក្តិសមជានិច្ច ដើម្បីមានបណ្ណចូលព្រះវិហារបរិសុទ្ធសុពលភាព ទោះជាព្រះវិហារបរិសុទ្ធនៅឆ្ងាយក្តី ។

ទីណាដែលអ្នកនៅ ទីនោះមានព្រះវិញ្ញាណគង់នៅ នោះវាអាចជាទីបរិសុទ្ធមួយ ។ ប្រធាន ហារ៉ូលដ៍ ប៊ី. លី (ឆ្នាំ 1899–1973) បានបង្រៀនថា ទីបរិសុទ្ធ វាទាក់ទងច្រើនទៅនឹង *របៀប* ដែលមនុស្សម្នាក់រស់នៅ ជាជាង *ទីកន្លែង* ដែលមនុស្សម្នាក់រស់នៅ ។[3] បើអ្នករស់នៅសក្តិសមមានព្រះវិញ្ញាណបរិសុទ្ធជាដៃគូជាប្រចាំ នោះអ្នកឈរនៅក្នុងទីបរិសុទ្ធមួយហើយ ។

គ្រប់ព្រះវិហារបរិសុទ្ធ មានពាក្យឆ្លាក់ថា « បរិសុទ្ធចំពោះព្រះអម្ចាស់ » ។ សូមព្យាយាមដើម្បីឈរនៅក្នុងទីបរិសុទ្ធជានិច្ច ។ នៅពេលអ្នករស់នៅតាមបទដ្ឋានអធិស្ឋានជារៀងរាល់ថ្ងៃ ហើយអានព្រះគម្ពីរ—ជាពិសេសព្រះគម្ពីរមរមន—នោះអ្នកនឹងទទួលអារម្មណ៍ភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះអម្ចាស់ផ្ទាល់ បានសន្យានឹងអ្នកថា « ត្បិតយើងប្រាប់អ្នកជាប្រាកដថា ការណ៍ដ៏ធំនោះកំពុងតែរង់ចាំអ្នក » (គ. និង ស. 45:62) ។ ខ្ញុំយល់ស្រប ហើយថ្លែងទីបន្ទាល់ថា នេះគឺជាការពិត ! ■

**កំណត់ចំណាំ**

1. សូមមើល ប៊យ ឃេ. ផាកកឺ « How to Survive in Enemy Territory » *Liahona,* ខែតុលា ឆ្នាំ 2012 ទំព័រ 34–37; *New Era,* ខែមេសា ឆ្នាំ 2012 ទំព័រ 2–5 ។
2. ប្រធាន ថូម៉ាស អេស ម៉នសុន « The Holy Temple—a Beacon to the World » *Liahona,* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 93 ។
3. សូមមើល *Doctrine and Covenants Student Manual: Religion 324 and 325,* កំណែថ្មីលើកទី 2 ។ (Church Educational System manual, ឆ្នាំ2001) 196 ។



**ដោយ អ័ដាម ស៊ី អូលសុន**
ទស្សនាវដ្ដីសាសនាចក្រ

# អ្វីដែលអាហ្គុង បានរៀន មកពីការវាយសី

*យុវវ័យឥណ្ឌូណេស៊ី បានរៀនថា ការមានក្ដីសង្ឃឹម ជួយការពារគាត់កុំឱ្យព្រមចុះចាញ់ ។*

វាជាថ្ងៃក្តៅសើមដូចធម្មតានៅក្នុងទីក្រុងចាកាតា ប្រទេសឥណ្ឌូណេស៊ី ហើយដំណក់ញើសបានស្រក់ ចេញពីថ្ងាសរបស់ អាហ្គុង នៅពេលគាត់កំពុងរង់ចាំឱ្យគូប្រកួតរបស់គាត់វាយកូនសីមក ។ ការប្រកួតវាយសី ជិតនឹងបញ្ចប់ ហើយយុវជនអាយុ 15 ឆ្នាំ មានអារម្មណ៍ថាត្រូវបានលើកទឹកចិត្តក្នុងការយកជ័យជំនះ ។

បន្ទាប់ពីវាយសីទៅវិញទៅមកមួយសន្ទុះ នោះគូប្រកួតរបស់គាត់បានវាយសីដែលធ្វើឱ្យ អាហ្គុង ពុំអាចឈោងយកបាន ។ ដោយសារមិនព្រមចុះចាញ់នៅក្នុងពិន្ទុចុងក្រោយក្នុងការប្រកួត នោះ អាហ្គុង បានលោតទៅវាយសី ប៉ុន្តែលោតពុំដល់—ក៏ត្រូវរអិលនៅលើស៊ីម៉ង់ រលាត់ចេញឈាម

យើងមើលឃើញដោយងាយថា គាត់ស្រឡាញ់ការប្រកួតវាយសីនេះណាស់ ។ ប៉ុន្តែ អាហ្គុង ពុំសុបិនចង់ក្លាយជាអ្នកលេងវាយសីអាជីពនោះទេ ។ គាត់នឹងពុំចាំបាច់ត្រូវជ្រើសរើស រវាងការវាយសីនៅអូឡាំពិក និង ការបម្រើបេសកកម្មឡើយ ។ គាត់បានសារភាពថា គាត់ពុំជំនាញនៅក្នុងការលេងកីឡានោះទេ ។

ដូច្នេះ ចុះហេតុអ្វីបានជាយុវជនម្នាក់នេះ ព្យាយាមយ៉ាងខ្លាំងដោយស្នាមញញឹមដូច្នេះ ? សេចក្ដីសង្ឃឹម ។

គាត់និយាយថា « ខ្ញុំជឿថាខ្ញុំអាចលេងបានល្អជាងនេះ » ។

## មូលហេតុមួយចំពោះសេចក្ដីសង្ឃឹម

សេចក្ដីសង្ឃឹម គឺជាមូលហេតុ ដែលយើងធ្វើបានទូវរឿងជាច្រើន ។ យើងហាត់ប្រាណ ដោយសារតែយើងសង្ឃឹមថា យើងអាចមានកម្លាំងកាន់តែរឹងមាំ និង សុខភាពកាន់តែល្អ ។ យើង

រូបថត ដោយ អ័ដាម ស៊ី អូលសុន



ហាត់លេងឧបករណ៍តន្ត្រី ដោយសារតែយើងសង្ឃឹមថា យើងអាចរៀនលេងបានល្អ ។ អាហ៊ុង បានហាត់លេងវាយសី ដោយសារតែគាត់សង្ឃឹមថា គាត់អាចកាន់តែប៉ិនប្រសព្វ ។

អាហ៊ុង បាននិយាយថា « បើខ្ញុំគ្មានសង្ឃឹមថានឹងធ្វើបានល្អប្រសើរ ឬ ឈ្នះនោះទេ វាងាយស្រួល ដើម្បីនឹងព្រមចុះចាញ់ »

សេចក្ដីសង្ឃឹម គឺជាធាតុដ៏សំខាន់មួយ នៃផែនការនៃសុភមង្គល ។ សេចក្ដីសង្ឃឹមដែលថា យើងអាចត្រូវបានអភ័យទោសឱ្យ នាំយើងទៅកាន់ការប្រែចិត្ត ហើយព្យាយាមសារជាថ្មី បន្ទាប់ពីយើងបរាជ័យក្នុងការគោរពបទបញ្ញត្តិ ។

## ការវាយប្រហាររបស់សាតាំងទៅលើសេចក្ដីសង្ឃឹម

អាវុធដ៏ល្អបំផុតពីរយ៉ាងដែលសាតាំងបានប្រើប្រឆាំងនឹងយើង គឺ ភាពសង្ស័យ និង ការបាក់ទឹកចិត្ត ។ វាពុំអាចរារាំងផែនការរបស់ព្រះវរបិតាសួគ៌តាមរយៈការបញ្ឈប់ដង្វាយធួនបានទេ ។ ប៉ុន្តែវាអាចនៅតែព្យាយាមរារាំងឥទ្ធិពលសំអាតរបស់ដង្វាយធួននៅក្នុងជីវិតរបស់យើង បើវាអាចលួចយកសេចក្ដីសង្ឃឹមរបស់យើងថា យើងអាចត្រូវបានអភ័យទោស ។

អាហ៊ុង បាននិយាយថា « សាតាំងចង់ឱ្យយើងបាត់បង់ក្ដីសង្ឃឹម ពីព្រោះនៅពេលយើងចុះចាញ់ នោះវានាំឱ្យយើងចាកចេញឆ្ងាយពីព្រះវរបិតាសួគ៌ » ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលសាតាំង មានជោគជ័យក្នុងការបំបាក់ទឹកចិត្តយើង នោះមានវិធីជាច្រើនដើម្បីស្វែងរកសេចក្ដីសង្ឃឹមឡើងវិញ ។

## ការស្វែងរកសេចក្ដីសង្ឃឹម

នៅពេលយើងត្រូវការក្ដីសង្ឃឹមសម្រាប់ពេលអនាគត នោះយើងអាចក្រឡេកទៅមើលអតីតកាល ។ អាហ៊ុង ប្រើគំរូមួយមកពីសាលារៀន ដែលបានបង្រៀនគាត់អំពីមេរៀននេះ ។ គាត់និយាយថា « ខ្ញុំបានមើលឃើញថា បើខ្ញុំខិតខំសិក្សា នោះខ្ញុំអាចទទួលជោគជ័យក្នុងការប្រឡងរបស់ខ្ញុំ » ។ គាត់និយាយថា « ដោយសារតែបទពិសោធន៍នោះ ខ្ញុំមានក្ដីសង្ឃឹមថា បើខ្ញុំខិតខំហាត់ នោះខ្ញុំអាចរីកចម្រើនក្នុងការវាយសី » ។ « បទពិសោធន៍របស់ខ្ញុំ បានផ្ដល់ក្ដីសង្ឃឹមដល់ខ្ញុំ » ។

នៅពេលយើងត្រូវការក្ដីសង្ឃឹមទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចស្វែងរកវាឃើញ ទាំងនៅក្នុងបទពិសោធន៍កាលពីអតីតកាលរបស់យើង ជាមួយនឹងអំណាចនៃដង្វាយធួន (សូមមើល រ៉ូម 5:4) និង ទាំងបទពិសោធន៍ទាំងឡាយរបស់អ្នកដទៃទៀត រួមមានទាំងបទពិសោធន៍ ដែលអ្នកអាចស្ដាប់ឮនៅក្នុងការប្រជុំសាក្រាម៉ង់ មេរៀនសាលាថ្ងៃអាទិត្យ *លីអាហូណា*, ឬ បទគម្ពីរ (សូមមើល យ៉ាកុប 4:4–6) ។

នៅពេលយើងសិក្សាពាក្យសម្ដីដែលប្រកបដោយក្ដីសង្ឃឹមរបស់ព្យាការី ចូរអធិស្ឋានសុំអំណោយទាននៃសេចក្ដីសង្ឃឹមខាងវិញ្ញាណ ហើយរៀនស្គាល់អំណាចរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរស់នៅរបស់យើង នោះសេចក្ដីជំនឿរបស់យើងទៅលើទ្រង់ រីកចម្រើនឡើងក៏ដូចជាក្ដីសង្ឃឹមរបស់យើងថា ទ្រង់នឹងជួយយើងនៅពេលអនាគត ។[1]

## មិនត្រូវចុះចាញ់ឡើយ

អាហ៊ុង ដឹងថា គាត់នឹងពុំអាចក្លាយជាអត្តពលករជំនាញទេ ប៉ុន្តែគាត់ដឹងថា ដរាបណាគាត់បន្តព្យាយាម នោះគឺមានក្ដីសង្ឃឹមថា គាត់អាចរីកចម្រើន ។

គាត់បាននិយាយថា គាត់បានរៀនដឹងថា អំណាចដ៏មហិមានៃក្ដីសង្ឃឹម គឺដូចនេះថា ៖ « ដរាបណាអ្នកពុំចុះចាញ់ នោះគឺមានសេចក្ដីសង្ឃឹម » ។

នៅក្នុងជីវិត ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាប្រភពនៃក្ដីសង្ឃឹមតែមួយគត់ ។ ដោយសារតែដង្វាយធួន នោះយើងអាចប្រែចិត្ត នៅពេលយើងមានកំហុសណាមួយ ។ នោះក៏មានន័យផងដែរថា ដោយសារតែដង្វាយធួន នោះយើងពុំបរាជ័យក្នុងការសាកល្បងនៃជីវិតរបស់យើងនោះទេនៅពេលយើងធ្វើកំហុសមួយលើកលែងតែយើងចុះចាញ់ពុំព្យាយាមប្រែចិត្ត ហើយគោរពតាមប៉ុណ្ណោះ ។

នោះជាមូលហេតុដែល អាហ៊ុង បន្តអញ្ជើញឪពុករបស់គាត់ឱ្យមកព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ ។ នោះជាមូលហេតុដែលគាត់ព្យាយាម ឈរការពារអ្វីដែលត្រឹមត្រូវ ទោះបីជាមិត្តរបស់គាត់ពុំធ្វើដូច្នេះក្ដី ។ នោះជាមូលហេតុដែលគាត់ជិះកង់រាប់ម៉ោងទៅមកព្រះវិហារជាញឹកញាប់ សម្រាប់ថ្នាក់សិក្ខាសាលា ទៅសកម្មភាពម៉្យូឆល ការប្រជុំថ្ងៃអាទិត្យ ថ្នាក់ត្រៀមខ្លួនជាអ្នកផ្សព្វផ្សាយសាសនា និង ដើម្បីជួយសំអាតអគារសាលាប្រជុំ ។

អាហ៊ុង និយាយថា « វាពុំងាយស្រួលទេ ក្នុងការព្យាយាមដើម្បីក្លាយដូចជាព្រះយេស៊ូវនោះ » ។ « ពេលខ្លះ ខ្ញុំបាក់ទឹកចិត្ត ប៉ុន្តែខ្ញុំពុំចុះចាញ់ឡើយ ។ ដោយសារតែពលិកម្មរបស់ទ្រង់ សម្រាប់ខ្ញុំ នោះខ្ញុំមានសង្ឃឹមថា ខ្ញុំអាចបានល្អប្រសើរ » ។

ដោយសារតែដង្វាយធួន នោះគឺមានសេចក្ដីសង្ឃឹម ។ ហើយដោយសារតែសេចក្ដីសង្ឃឹម នោះដង្វាយធួន អាចផ្លាស់ប្ដូរជីវិតរស់នៅរបស់យើង ។ ■

### កំណត់ចំណាំ

1. ឌៀថើរ អេហ្វ អុជដូហ្វ « The Infinite Power of Hope » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 21–24 ។



## ការសន្យាមួយ អំពីសេចក្ដីសង្ឃឹម

« ដោយសារតែព្រះមានភាពស្មោះត្រង់ ហើយរក្សាការសន្យារបស់ទ្រង់កាលពីអតីតកាល នោះយើងអាចមានក្ដីសង្ឃឹមដោយទំនុកចិត្តថា ព្រះនឹងរក្សាការសន្យារបស់ទ្រង់ចំពោះយើង ក្នុងពេលបច្ចុប្បន្ន និង ពេលអនាគត » ។

**ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ « The Infinite Power of Hope » *Liahona,* ខែវិច្ឆិកា ឆ្នាំ 2008, ទំព័រ 23 ។**

# ការអប់រំ

*ចំណេះដឹងរីកចម្រើន ជួយយើងមានឱកាសដើម្បីមានឥទ្ធិពលកាន់តែខ្លាំងនៅក្នុងការសម្រេចនូវគោលបំណងទាំងឡាយរបស់ព្រះអម្ចាស់ ។*



យ៉ាកុបបានបង្រៀនដល់ប្រជាជននីហ្វៃ ដោយបំណងប្រាថ្នា និង ការបារម្ភយ៉ាងខ្លាំងចំពោះសុខុមាលភាពនៃព្រលឹងរបស់ពួកគេថា « អំពីការណ៍ទាំងឡាយដែលកំពុងកើតឡើង និង អំពីការណ៍ទាំងឡាយដែលនឹងកើតឡើង » (នីហ្វៃទី 2 6:4) ។ អ្នកទាំងនេះ គឺជាប្រជាជនរបស់លោក ហើយលោកស្រឡាញ់ពួកគេ ។ លោកបានបង្រៀនពួកគេអំពីខ្លួនពួកគេជានរណាពិត ហើយបង្រៀនអំពីការសន្យារបស់ព្រះអម្ចាស់អំពីពួកគេ ។ នៅពេលគាត់បានបង្រៀនពួកគេអំពីព្រះអង្គសង្គ្រោះ នោះគាត់បានប្រកាសថា ៖ « ឱ សេចក្ដីបរិសុទ្ធនៃព្រះរបស់យើងធំណាស់ហ្ន៎ ! ត្បិត*ទ្រង់ជ្រាបគ្រប់អស់ទាំងការណ៍* ហើយគ្មានការណ៍អ្វីដែលទ្រង់មិនជ្រាបនោះឡើយ » (នីហ្វៃទី 2 9:20; គូសបញ្ជាក់បន្ថែម) ។

នោះគឺជាការចងចាំដ៏មានតម្លៃ នៅពេលអ្នកពិចារណាអំពីសារៈសំខាន់នៃការអប់រំ ។ កាលពីច្រើនសតវត្សន៍មុន នៅផ្នែកម្ខាងទៀតនៃពិភពលោក ឪពុកអ័ប្រាហាំ « បានស្វែងរកព្រះពរទាំងឡាយខាងពួកអយ្យកោ » និង បានប្រាថ្នាចង់ « ធ្វើជាអ្នកដែលមានចំណេះដ៏ធំ ហើយចង់ធ្វើជាអ្នកដើរតាមសេចក្ដីសុចរិតកាន់តែខ្លាំងឡើង » (អ័ប្រាហាំ 1:2) ។

អ្នកទាំងអស់គ្នាគឺជាបុត្រា និង បុត្រីសំណប់នៃព្រះ [1] ហើយ « អ្នករាល់គ្នាគឺជាកូនចៅនៃពួកព្យាការី ហើយអ្នករាល់គ្នានៅ ... ក្នុងសេចក្ដីសញ្ញា ដែលព្រះវរបិតាទ្រង់បានធ្វើ ជាមួយនឹង [អ័ប្រាហាំ] » (នីហ្វៃ 2 20:25) ។ ដូចជាអ័ប្រាហាំ អ្នករាល់គ្នាមាននៅក្នុងខ្លួនអ្នកនូវសមត្ថភាពដើម្បី « មានចំណេះដ៏ធំ » ដូចជាអ្នកត្រូវបានបង្រៀននៅក្នុងរឿងទាំងឡាយ ដែល « ជាការចាំបាច់សម្រាប់អ្នកយល់ » (គ. និង ស. 88:78) ។

ព្រះអម្ចាស់ បានចង្អុលបង្ហាញថា ចំណេះដឹងដែលប្រាថ្នាចង់



ដោយអែលឌើរ
ក្រេហ្គ អេ. ខារដុន
នៃពួកចិតសិបនាក់



បាន រួមមាន « អំពីរបស់ទាំងឡាយនៅលើទាំងស្ថានសួគ៌ និង នៅលើផែនដី និង នៅក្រោមផែនដីផង របស់ទាំងឡាយ ដែលធ្លាប់មានមក របស់ទាំងឡាយ ដែលមានពេលនេះ របស់ទាំងឡាយដែលនឹងកើតមានឡើងនៅពេលឆាប់ៗ របស់ទាំងឡាយដែលនៅក្នុងផ្ទះ របស់ទាំងឡាយនៅស្រុកផ្សេង សង្គ្រាមទាំងឡាយ និង ការច្របូកច្របល់នៃសាសន៍ទាំងឡាយ និង សេចក្ដីជំនុំជំរះទាំងឡាយ ដែលនៅលើដែនដី និង ដំណឹងអំពីស្រុកទាំងឡាយ និង នគរទាំងឡាយផង » (គ. និង ស. 88:79) ។

ហេតុអ្វី? ហេតុអ្វីបានជាការទទួលការអប់រំមានសារៈសំខាន់ដល់ម្ល៉េះ ? ព្រះអម្ចាស់ផ្ទាល់ ផ្ដល់នូវការយល់ដឹងដ៏ល្អមួយថា ៖ « ដើម្បីឱ្យអ្នករាល់គ្នាអាចបានរៀបចំ នូវគ្រប់ទាំងអស់ក្នុងកាលយើងនឹងចាត់អ្នកម្ដងទៀត ឱ្យទៅដើម្បីដំកើងការហៅដែលយើងបានហៅអ្នករួចហើយនោះ និងបេសកកម្មដែលយើងបានអនុញ្ញាតដល់អ្នក » (គ. និង ស. 88:80) ។

នៅក្នុងពិភពលោកដែលមានការស្មុគស្មាញកំពុងតែកើនឡើងនេះ ការអប់រំ គឺជាតម្រូវការដ៏សំខាន់បំផុតក្នុងជីវិត ។ ហើយវាគឺជាការពិត ថាការអប់រំមានកាន់តែច្រើន នឹងនាំទៅរកឱកាសសម្រាប់រង្វាន់ខាងសាច់ឈាមកើនឡើង នៅពេលតម្លៃនៃចំណេះដឹងច្រើនកាន់តែកើនខ្លាំង គឺជាឱកាសដែលវាផ្ដល់ឱ្យយើងមានឥទ្ធិពលកាន់តែខ្លាំង នៅក្នុងការសម្រេចនូវគោលបំណងទាំងឡាយរបស់ព្រះអម្ចាស់ ។ ដូចដែលបានពន្យល់នៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ៖ « ការអប់រំ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ដើម្បីជួយអ្នកប្រែក្លាយកាន់តែដូចជាទ្រង់ ។ ទ្រង់សព្វព្រះទ័យចង់ឱ្យអ្នកអប់រំចិត្តរបស់អ្នក និងអភិវឌ្ឍជំនាញ និង ទេពកោសល្យទាំងឡាយរបស់អ្នក អំណាចរបស់អ្នកដើម្បីអនុវត្តឱ្យល្អប្រពៃ នៅក្នុងការទទួលខុសត្រូវនានារបស់អ្នក និងសមត្ថភាពរបស់អ្នក ដើម្បីមានអំណរចំពោះជីវិត » ។ [2]

ព្យាការីយ៉ូសែប ស៊្មីធ ក៏បានបង្រៀនផងដែរថា ៖ « នៅក្នុងចំណេះដឹង គឺមាននូវអំណាច ។ ព្រះមានអំណាចលើសអ្វីៗផ្សេងទៀតទាំងអស់ ដោយសារតែទ្រង់មានចំណេះដឹងកាន់តែអស្ចារ្យ » ។ [3]

សម្រាប់ជាមូលហេតុល្អ ការអប់រំជាផ្លូវការតម្រូវឱ្យអ្នកចំណាយពេលជាច្រើនឆ្នាំ ដើម្បីចូលរួមនៅក្នុងលំដាប់ជំនាញ និង មុខវិជ្ជាយ៉ាងទូលំទូលាយមួយ ដែលមុខវិជ្ជាមួយចំនួន អ្នកពុំធ្លាប់ស្គាល់ ឬ ដែលអ្នកពុំសូវចូលចិត្តសិក្សា ។ ទោះជាយ៉ាងនោះក្ដី អ្នកគួរតែឧស្សាហ៍ព្យាយាមនៅក្នុងការសិក្សារបស់អ្នក ត្បិតវានឹងពង្រីកនូវទស្សនៈរបស់អ្នក និង សមត្ថភាពគំនិតរបស់អ្នក ដើម្បីរៀនអំពីផ្នែកផ្សេងទៀតផងដែរ ។ ប្រាកដណាស់ បទពិសោធន៍របស់អ្នកនៅក្នុងលំដាប់ជំនាញ និង មុខវិជ្ជាមូលដ្ឋានគ្រឹះយ៉ាងទូលំទូលាយនោះ ផ្ដល់ជាឱកាសដល់អ្នក ដើម្បីស្គាល់ជំនាញ និង មុខវិជ្ជាទាំងឡាយ ដែលអ្នកមានចំណាប់អារម្មណ៍ពិត ។



នៅពេលអ្នកបន្តពង្រីកការអប់រំរបស់អ្នក ដោយចំណាប់អារម្មណ៍បែបនេះ នោះអ្នកនឹងមានឱកាសដើម្បីបន្តរៀននូវរឿងទាំងឡាយដែលអ្នកចូលចិត្តពិត ដែលកាន់តែជ្រៅជ្រះជាងនេះ ។

ប្រធាន ហែនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានចែកចាយដំបូន្មានដ៏មានតម្លៃដែលគាត់បានទទួលមកពីឪពុករបស់គាត់ ជាពេលដែលឪពុករបស់គាត់ បានប្រឹក្សាគាត់ឱ្យបន្តការសិក្សាថា « កូនចូលចិត្តណាស់ពេលកូនពុំចាំបាច់គិតពីអ្វីទាំងអស់តែនោះជាអ្វីដែលកូនគិត » ។[4] បងស្រី ខារដុន និង ខ្ញុំ បានទូន្មានកូនៗរបស់យើងឱ្យបន្តការសិក្សា រួចហើយមានអាជីពមួយ ដែលពួកគេចូលចិត្ត ដែលពួកគេចង់ « រំលងទៅចូលធ្វើការ » ។

យ៉ាកុប បានដាស់តឿនដល់ប្រជាជនរបស់គាត់ទាស់នឹង « ភាពទន់ខ្សោយ និង ការឆ្កួតលីលានៃមនុស្សលោកអើយ ! » ។ គាត់បានពន្យល់ថា « កាលណាគេបានរៀនសូត្រ គេស្មានថាគេឆ្លាតវៃ ហើយគេមិនស្ដាប់តាមពាក្យដំបូន្មាននៃព្រះឡើយ » ។ រួចហើយ គាត់បានបន្ថែមនូវសេចក្ដីពិតដ៏ថ្លៃថ្នូនេះថា ៖ « ប៉ុន្តែដែលបានរៀនសូត្រ គឺជាការល្អវិញ បើសិនជាគេស្ដាប់តាមពាក្យដំបូន្មាននៃព្រះ » (នីហ្វៃទី 2 9:28–29) ។

ចូររៀនសូត្រ ហើយស្ដាប់តាមពាក្យដំបូន្មាននៃព្រះ ។ ទ្រង់នឹងប្រទានពរ ហើយចម្រើនដល់អ្នកនៅក្នុងការសម្រេចនូវគោលបំណងរបស់ទ្រង់ ។ ■

**កំណត់ចំណាំ**

1. សូមមើល « គ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* ខែវិច្ឆិកា ឆ្នាំ 2010, ទំព័រ 129 ។
2. *ដើម្បីកម្លាំងនៃយុវជន* (កូនសៀវភៅ ឆ្នាំ 2011) 9 ។
3. *Teachings of Presidents of the Church: Joseph Smith* (2007), ទំព័រ 265 ។
4. នៅក្នុង ជីរ៉ាល់ដ៍ អិន. ឡាន់ « Elder Henry B. Eyring: Molded ដោយ ‹ Defining Influences ›» *Liahona* ខែមេសា ឆ្នាំ 1996, 28 ។

រូបថតដោយ រ៉ូប៊ើត កាស៊ី



# សូមបន្តអនុវត្ត

*ខ្ញុំចង់ឈប់ ។ តើការខិតខំទាំងអស់នេះ នឹងនាំឱ្យមានផលល្អឬទេ ?*

**ដោយវិលលីស ជែនសិន**

ខ្ញុំបានប្រាប់ម្ដាយខ្ញុំថា « ខ្ញុំពុំចង់រៀនព្យាណូតទៀតទេ » ។ ខ្ញុំបានរៀនអស់រយៈពេលជាច្រើនឆ្នាំហើយ ធុញទ្រាន់ក្នុងការហាត់រៀនទាំងអស់នោះណាស់ ។ ខ្ញុំត្រៀមខ្លួនឈប់រៀនរួចជាស្រេច ។ ខ្ញុំលេងមិនសូវល្អផង ។ ដោយសារតែខ្ញុំមានបញ្ហាក្នុងការស្ដាប់ឮខ្លះៗ ហើយត្រូវពាក់ឧបករណ៍ជំនួយការស្ដាប់ឮ នោះខ្ញុំពុំដែលចាត់ទុកខ្លួនខ្ញុំជាមនុស្សម្នាក់ ដែលមានទេពកោសល្យផ្នែកតន្ត្រីនោះឡើយ ។ វាត្រូវចំណាយពេលហាត់ច្រើនជានិច្ច ក្នុងការរៀនសាច់ភ្លេងនៃចម្រៀងមួយបទ ។

ម្ដាយរបស់ខ្ញុំពុំនិយាយច្រើនទេ ប៉ុន្តែបានប្រាប់ខ្ញុំដោយសាមញ្ញថា ខ្ញុំគួរតែបន្តហាត់រៀន រហូតដល់ខ្ញុំអាចលេងចម្រៀងទំនុកដំកើងបាន ។ បន្ទាប់ពីការរអ៊ូរទាំជាច្រើនរបស់ខ្ញុំ និង ការលើកទឹកចិត្តជាច្រើនរបស់ឪពុកម្ដាយ នោះខ្ញុំបានសម្រេចចិត្តថាមិនឈប់រៀនទេ ។

បន្ទាប់ពីអស់រយៈពេលជាច្រើនឆ្នាំមក និង ការធ្វើដំណើររាប់ពាន់ម៉ៃលទៅកាន់សាលាជំនុំនៅលើភ្នំនៃប្រទេសហ្គូតេម៉ាឡាប៉ែកកណ្ដាល ។ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ខ្ញុំបានចូលរួមនៅក្នុងសន្និសីទមណ្ឌលមួយ ។ ខ្ញុំបានទៅដល់មុន ហើយបានឃើញមានព្យាណូមួយនៅទីនោះ ដូច្នេះខ្ញុំបានអង្គុយលេងចម្រៀងទំនុកដំកើង ។ វួដ និង សាខាជាច្រើន មានព្យាណូតូចប្រើភ្លើង ដែលពិបាកលេង ដូច្នេះខ្ញុំរំភើបចិត្តណាស់ដើម្បីលេងព្យាណូធំពិតនោះ ។ ជាលទ្ធផល ខ្ញុំត្រូវបានសុំឱ្យលេងភ្លេងកំដរក្រុមជំនុំសម្រាប់សន្និសីទ

តើមានអ្វីខ្លះបានផ្លាស់ប្ដូរអាកប្បកិរិយារបស់ខ្ញុំ កាលពីវ័យក្មេង និង ពេលខ្ញុំជាអ្នកផ្សព្វផ្សាយសាសនា ? ខ្ញុំមានអារម្មណ៍ពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធតាមរយៈតន្ត្រី ។

ខណៈដែលកំពុងតែបម្រើបេសកកម្ម ខ្ញុំមានឱកាសជាច្រើន ដើម្បីប្រើជំនាញតន្ត្រីដែលខ្ញុំបានរៀន ។ ខ្ញុំបានរីករាយនឹងឱកាសជាច្រើនដើម្បីច្រៀង និង លេងព្យាណូ ហើយបានលេងភ្លេងស្ទើរតែរាល់សប្ដាហ៍នៅក្នុងការប្រជុំសាក្រាម៉ង់ ។ ខ្ញុំនឹងចងចាំ ជានិច្ចអំពីគ្រាដែលស្ដាប់សមាជិកហ្គូតេម៉ាឡាដ៏ស្មោះត្រង់ទាំងនោះច្រៀងទំនុកដំកើង ។ ខ្ញុំបានបង្រៀនសមាជិកនូវទំនុកដំកើងថ្មី ដែលពួកគេពុំដែលចេះ ។ ខ្ញុំបានបង្រៀនមេរៀនព្យាណូមូលដ្ឋានមួយចំនួន ។ ដៃគូរបស់ខ្ញុំ និងខ្ញុំនឹងច្រៀងចម្រៀងសម្រាប់អ្នកដែលយើងបង្រៀន ។ ទោះជាយើងច្រៀងមិនចំចង្វាក់ទំនុកក្ដី ក៏ព្រះវិញ្ញាណតែងតែគង់នៅទីនោះ ប៉ះដល់ដួងចិត្តនៃមនុស្សទាំងឡាយ ដែរ ។

ខ្ញុំបានដឹងថា វាពុំសំខាន់ថាអ្នកមានទេពកោសល្យអ្វីនោះទេ អ្នកនៅតែអាចរៀនអភិវឌ្ឍសមត្ថភាពខាងតន្ត្រីបានដែរ ។ ខ្ញុំនឹងពុំក្លាយជាអ្នកលេងព្យាណូចំណាត់ថ្នាក់ពិភពលោកទេ ហើយសមាជិកជាច្រើននៅហ្គូតេម៉ាឡា នឹងក៏ពុំក្លាយជាក្រុមចម្រៀងរោងឧបោសថនោះដែរ ។ ប៉ុន្តែនោះវាមិនសំខាន់ទេ ។ យើងនៅតែអាចរីករាយនឹងអារម្មណ៍ពីព្រះវិញ្ញាណតាមរយៈតន្ត្រី ។ ខ្ញុំមានអំណរគុណណាស់ដែលឪពុកម្ដាយរបស់ខ្ញុំ បានលើកទឹកចិត្តខ្ញុំឱ្យបន្តរៀនព្យាណូ ហើយខ្ញុំមានអំណរគុណដែលខ្ញុំបានបន្តហាត់រៀន ។ ■

**អភិវឌ្ឍជំនាញ និង ទេពកោសល្យរបស់អ្នក**

« ការអប់រំ គឺជាផ្នែកមួយដ៏សំខាន់នៃផែនការរបស់ព្រះវរបិតាសួគ៌ ដើម្បីជួយអ្នកឱ្យប្រែក្លាយកាន់តែដូចជាទ្រង់ ។ ទ្រង់សព្វព្រះទ័យឱ្យអ្នកអប់រំចិត្តរបស់អ្នក និង អភិវឌ្ឍជំនាញ និង ទេពកោសល្យទាំងឡាយរបស់អ្នក អំណាចរបស់អ្នកដើម្បីអនុវត្តឱ្យល្អប្រពៃនៅក្នុងការទទួលខុសត្រូវនានារបស់អ្នក និង សមត្ថភាពរបស់អ្នក ដើម្បីមានអំណរចំពោះជីវិត ។ ការអប់រំដែលអ្នកទទួលបាន នឹងមានតម្លៃចំពោះអ្នកក្នុងអំឡុងពេលជីវិតរមែងស្លាប់ និង ជីវិតខាងមុខ » ។

*ដើម្បីកម្លាំងនៃយុវជន* (កូនសៀវភៅ ឆ្នាំ 2011) 9 ។

រូបភាពដោយ ISTOCKPHOTO © BRIAN STEELE



# ឈរ
## នៅក្នុងទីបរិសុទ្ធ

*« ទីណាដែលអ្នកនៅ ទីនោះមានព្រះវិញ្ញាណគង់នៅ នោះវាអាចជាទីបរិសុទ្ធមួយ »* ។

(អេលែន អេស. ដាល់ថុន « សូមបន្តអនុវត្ត » *Liahona,* ខែមករា ឆ្នាំ 2013, 51;
*New Era,* ខែមករា ឆ្នាំ 2013, 7; សូមមើលផងដែរ គ. និង ស. 87:8) ។

រូបថតដោយ វៀលឌេន ស៊ី អាន់ឌើរសុន, រូបភាពផ្ទៃខាងក្រោយ © DIGITAL VISION/GETTY IMAGES

# ការមើលឃើញ សេចក្ដីល្អ នៅក្នុងខ្លួន ខែលី

ដោយ ខារីន ស្ដេស៊ី

*យើងពុំអាចមើលមុខគ្នាចំបានទេ ។ តើយើងអាចធ្វើជាមិត្តនឹងគ្នាបានឬទេ ?*

កាលនៅថ្នាក់ទីបួន ខ្ញុំបានរៀននៅក្នុងថ្នាក់ដែលល្អបំផុត ។ អ្វីៗគ្រប់យ៉ាងនៅក្នុងថ្នាក់គឺល្អឥតខ្ចោះ—លើកលែងតែ ខែលី (ឈ្មោះត្រូវបានផ្លាស់ប្ដូរ) ។ គាត់មានចិត្តអាក្រក់ចំពោះមនុស្សស្ទើរតែគ្រប់គ្នា រួមទាំងខ្ញុំផងដែរ ។ ខ្ញុំបានឃើញនាងរុញអ្នកដទៃនៅតាមទីធ្លាសាលា ហើយនាងធ្លាប់រុញខ្ញុំពីរបីដងដែរ ។ ខ្ញុំមកផ្ទះវិញយំដោយសារតែខ្ញុំមិនយល់ថា ហេតុអ្វីបានជានាងធ្វើបាបខ្ញុំ។

គ្មាននរណាម្នាក់ជាមិត្តរបស់នាងឡើយ ។ នាងមានតុមួយតែឯងសម្រាប់អាហារថ្ងៃត្រង់ គឺដោយសារតែគ្មាននរណាម្នាក់ចង់អង្គុយជិតនាងទេ ។ ខ្ញុំបានប្រាប់ម្ដាយខ្ញុំអំពីខែលី ហើយគាត់បានផ្ដល់នូវឱវាតនៃប្រាជ្ញាដែលផ្លាស់ប្ដូរជីវិតខ្ញុំខ្លះៗថា ៖ « ប្រហែលជានាងត្រូវការមិត្ត » ។

រឿងនេះធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល ។ តើខ្ញុំអាចធ្វើល្អនឹងមនុស្ស ដែលពុំចេះគិតមកហៅឈ្មោះខ្ញុំដោយការប្រមាថដោយរបៀបណាបាន ? ទោះជាយ៉ាងណា ខ្ញុំបានសម្រេចចិត្តដោយភាពស្ទាក់ស្ទើរ ដើម្បីធ្វើល្អចំពោះខែលី ហើយបានព្យាយាមដើម្បីយល់ពីនាង ។ នៅពេលខ្ញុំស្គាល់នាងកាន់តែច្រើន ខ្ញុំបានដឹងថា តាមពិត នាងជាមនុស្សល្អ ។ មិនយូរប៉ុន្មានខ្ញុំបានដឹងថា ជីវិតរបស់នាងគឺមានការលំបាកខ្លាំងដែលខ្ញុំនឹកស្មានមិនដល់ ។ នាងរស់នៅក្នុងគ្រួសារដែលលំបាក ហើយនាងមិនចង់និយាយអំពីពាក្យ « គ្រួសារ » ទេ

ថ្ងៃមួយ អំឡុងពេលអាហារថ្ងៃត្រង់ ខ្ញុំបានអង្គុយនៅជិតមិត្តនានារបស់ខ្ញុំ ។ ដោយសារខែលី កោងកាចចំពោះអ្នកដទៃ នោះមានក្មេងស្រីមួយចំនួនបានធ្វើអាក្រក់ដាក់នាងវិញ ។ ពួកគេបានចាប់ផ្ដើមចំអកឱ្យ ខែលី ដោយនិយាយពាក្យឮៗ ដែលនាងអាចស្ដាប់ឮ ។ ពួកគេនិយាយដូចជា « មកអង្គុយជិតយើងមក—មិនអាចទេ ! » « តើក្លិនអ្វីហ្នឹង ? អ៊ូ! ជាក្លិនខែលីទេតើ ! » ហើយ « ចេញឱ្យឆ្ងាយពីយើងទៅ ! » ខ្ញុំបានអង្គុយនៅទីនោះស្ដាប់ ។

បន្ទាប់មកខ្ញុំបានស្ដាប់ឮសម្លេងតូចមួយនៅក្នុងក្បាលខ្ញុំថា ៖ « ចូរធ្វើអ្វីមួយ » ។ ខ្ញុំបានក្រោកឈរឡើង ហើយមានក្រសែភ្នែករាប់គូរ ងាកបែរមកមើលខ្ញុំ ។ « ឈប់ ! » ខ្ញុំបាននិយាយ ។ « ហេតុអ្វីក៏អ្នករាល់គ្នានិយាយបែបនេះទៅគេដូច្នោះ ? សូមធ្វើល្អនឹងនាង ! » មនុស្សគ្រប់គ្នាបានស្ងាត់ ។ នៅពេលខ្ញុំអង្គុយចុះ ខ្ញុំបានមើលទៅខែលី ។ នាងបានងាកមកហើយមើលមកខ្ញុំដោយការអរគុណដ៏សុទ្ធចិត្ត ។

នៅថ្នាក់ទីប្រាំមួយ ជាខួបកំណើតអាយុ 12 ឆ្នាំរបស់ខ្ញុំ ហើយខ្ញុំចង់មានពិធីជប់លៀងជាមួយមិត្តភក្ដិមួយចំនួន ។ នៅពេលម្ដាយសួរខ្ញុំថា តើខ្ញុំចង់អញ្ជើញនរណាខ្លះទៀត ខ្ញុំបានស្ដាប់ឮសម្លេងតូចដដែលនោះនៅក្នុងក្បាលរបស់ខ្ញុំថា ៖ « អញ្ជើញខែលី » ។

ខ្ញុំបានប្រាប់ម្ដាយខ្ញុំថា « ខ្ញុំចង់អញ្ជើញខែលី » ។

« មែនឬ ? »

ខ្ញុំបានងក់ក្បាល ។ បន្ទាប់ពីពិធីជប់លៀងខួបកំណើត មិត្តរបស់ខ្ញុំ និង ខ្ញុំ រួមទាំងខែលី បានក្លាយជាមិត្តល្អនឹងគ្នា ដែលយើងបានជួបជុំគ្នាជារៀងរាល់ថ្ងៃសុក្រ សម្រាប់រយៈពេលបីខែចុងក្រោយនៅសាលារៀន ។ ខែលីមកចូលរួមរាល់ពេល ។ យើងបានក្លាយជាមិត្តសម្លាញ់ ។

ឥឡូវខ្ញុំបានរៀននៅថ្នាក់ទីប្រាំបី ហើយបានផ្លាស់ទៅរដ្ឋផ្សេង ប៉ុន្តែខ្ញុំបានទំនាក់ទំនងជាមួយខែលីដែលជាមិត្តសម្លាញ់ម្នាក់របស់ខ្ញុំ ជាញឹកញាប់ ។ ពេលខ្លះមិត្តរបស់ខ្ញុំ បានសួរថាហេតុអ្វីបានជាយើងក្លាយជាមិត្តយ៉ាងជិតស្និតដូច្នេះ ។

ខ្ញុំបាននិយាយថា « នៅថ្នាក់ទីបួន នាងបានធ្វើបាបខ្ញុំ ហើយយើងបានស្អប់គ្នាយ៉ាងខ្លាំង » ។

« មែនហើយ បន្ទាប់មកតើអ្នកបានក្លាយជាមិត្តដ៏ល្អនឹងគ្នាដោយរបៀបណា ? »

« ខ្ញុំបានស្វែងរកសេចក្ដីល្អដែលនៅក្នុងខ្លួននាង ។ មនុស្សគ្រប់គ្នា មានសេចក្ដីល្អខ្លះៗក្នុងខ្លួនពួកគេ ហើយខ្ញុំបានទៅរកនាង » ។ ■





សាក្សីពិសេស



# តើខ្ញុំអាចទទួលបាន ទីបន្ទាល់មួយដោយរបៀបណា ?

**ដោយ អែលឌើរ រ៉ូប៊ើត ឌី ហែល**
នៃកូរ៉ុមនៃពួកសាវក ដប់ពីរនាក់

*សមាជិកនៃកូរ៉ុមនៃពួក ដប់ពីរនាក់ គឺជា សាក្សីពិសេសរបស់ ព្រះយេស៊ូវគ្រីស្ទ ។*



ការទទួលបានទីបន្ទាល់មួយ ចាប់ផ្ដើមជាមួយនឹងការសិក្សា



និង ការអធិស្ឋាន



បន្ទាប់មក រស់នៅតាមដំណឹងល្អដោយការអត់ធ្មត់ និង តស៊ូខ្ជាប់ខ្ជួន



រួចហើយអញ្ជើញ និង រង់ចាំព្រះវិញ្ញាណ ។



ជីវិតរបស់យ៉ូសែប ស្ម៊ីធ គឺជាគំរូដ៏ល្អមួយ អំពីដំណើរការនេះ ។

*ចេញមកពី « Receiving a Testimony of the Restored Gospel of Jesus Christ »* Liahona, *ខែវិច្ឆិកា ឆ្នាំ 2003 ទំព័រ 28 ។*

រូបភាពដោយ ប្រាត ធៀរ

# ផែនការមួយសម្រាប់គ្រួសាររបស់យើង



*« ក្រុមគ្រួសារអាចរួមរស់ជានិរន្តន៍ តាមផែនការព្រះបិតា »*
(សៀវភៅចម្រៀងកុមារ *188*) ។

**ដោយ ម៉ារីស្សា វីដឌីសុន**
ទស្សនាវដ្ដីសាសនាចក្រ
ផ្អែកទៅលើដំណើររឿងពិតមួយ



ទៅពេលទូរស័ព្ទរោទិ៍ឡើង ខ្ញុំកំពុងតែអង្គុយនៅលើគ្រែរបស់ម៉ាក់ និង ប៉ា ដោយការនឹករលឹកដល់ពួកគាត់ជាខ្លាំង ។

« ហ្អេ៎! លេវី ។ ស្មានទៅមើល ថាជាអ្វី ? » លោកប៉ាបាននិយាយ ។ « ប្អូនស្រីរបស់កូន ណូវ៉ា បានកើតហើយកាលពីថ្ងៃមិញ ! »

ខ្ញុំអាចប្រាប់បានថា ប៉ាសប្បាយចិត្ត ប៉ុន្តែសម្លេងរបស់គាត់ ហាក់ដូចជាចម្លែក—គាត់ដូចជាមានការបារម្ភ ។

« តើនាងមានទម្ងន់ប៉ុន្មាន ? » ខ្ញុំបានសួរ ដោយងឿងឆ្ងល់ថា តើខ្ញុំពិតជាចង់ដឹងចម្លើយឬទេ ។

គាត់បាននៅស្ងៀមមួយសន្ទុះ ។ គាត់បាននិយាយថា « នាងតូចមានទម្ងន់តិចជាងពីរផោន [0.9 គីឡូក្រាម] ។ ឥឡូវគាត់មានសម្លេងកាន់តែបារម្ភ ។ ណូវ៉ា ត្រូវកើតនៅក្នុងរដូវបុណ្យគ្រីស្ទម៉ាស់ ប៉ុន្តែឥឡូវនៅខែកញ្ញានៅឡើយ ។ ប៉ាបានបន្តថា « នាងតូច តែមិនអីទេ » ។ « លេវី ចូរកូនកុំភ្លេចអធិស្ឋានសម្រាប់នាងផងណា ។ ហើយអធិស្ឋានសម្រាបយើងទាំងអស់គ្នាផងដែរ ដើម្បីយើងអាចទុកចិត្តថា ព្រះវរបិតាសួគ៌ ដឹងពីអ្វីដែលល្អបំផុតសម្រាប់គ្រួសាររបស់យើង » ។

បន្ទាប់ពីខ្ញុំបានដាក់ទូរស័ព្ទចុះ ខ្ញុំបានចូលទៅផ្ទះបាយ ហើយបានយកកញ្ចប់សណ្ដែកដែលម៉ាក់ បំរុងនឹងធ្វើស៊ុបមក ។ កញ្ចប់នោះ មានទម្ងន់ស្មើរតែស្មើនឹងទម្ងន់របស់ណូវ៉ាក្នុងពេលឥឡូវនេះ ។ ខ្ញុំបានកាន់នៅក្នុងដៃរបស់ខ្ញុំ ដោយព្យាយាមគិតអំពីទារកតូចដែលទម្ងន់ប្រហាក់ប្រហែលនោះ ។

ខ្ញុំបានគិត ដោយចាំអំពីអ្វីដែលខ្ញុំបានរៀនអំពីជីវិតមុនផែនដី និង ផែនការនៃសេចក្ដីសង្គ្រោះថា « វិញ្ញាណរបស់នាងទើបតែនៅជាមួយនឹងព្រះវរបិតាសួគ៌ » ។ ខ្ញុំបានដឹងថា ទោះជាណូវ៉ាស្លាប់ នោះយើងនឹងជួបនាងម្ដងទៀត ដោយសារយើងទាំងអស់គ្នាបានផ្សាភ្ជាប់នឹងគ្នាជាគ្រួសារ ។ ប៉ុន្តែខ្ញុំក៏សង្ឃឹមថា នាងនឹងនៅជាមួយយើងលើផែនដីនេះ ។

ក្នុងរយៈពេលប៉ុន្មានខែក្រោយនេះ ម៉ាក់ និង ប៉ា

រូបគំនូរដោយ ដេន ប៊ឺនស៊ិន



បានទៅមន្ទីរពេទ្យច្រើនដងណាស់ ។ លោកតា និង លោកយាយ បានមកផ្ទះរបស់យើង ដើម្បីជួយមើលថែខ្ញុំ និង ប្អូនប្រុស និង ប្អូនស្រីតូចរបស់ខ្ញុំ ។ សមាជិកក្នុងវួដបានតមអាហារ និង អធិស្ឋានសម្រាប់គ្រួសាររបស់យើង ហើយមានស្ត្រីចិត្តល្អជាច្រើនរូប មកពីសមាគមសង្គ្រោះ បានយកអាហារពេលល្ងាចមកឱ្យយើងពេលខ្លះ ។ មនុស្សគ្រប់គ្នាចង់ដឹងថា តើណូរ៉ា សុខសប្បាយឬទេ ។

នាល្ងាចមួយ ម៉ាក់ និង ប៉ា បានហៅយើងទាំងអស់គ្នាទៅបន្ទប់ទទួលភ្ញៀវ ។ ពួកគាត់បានប្រាប់យើងថា ប៉ានឹងទៅជាមួយប៊ីស្សព ដើម្បីប្រសិទ្ធពរឱ្យណូរ៉ា ។ បន្ទាប់ពីប៉ាចេញទៅដោយស្លៀកពាក់អាវធំ និង ក្រវ៉ាត់ក នោះម៉ាក់បានប្រមូលយើងទាំងអស់គ្នានៅជុំវិញសាឡុងដើម្បីអធិស្ឋាន ។

ម៉ាក់បានអធិស្ឋានថា « សូមប្រទានពរដល់ប៉ានៅពេលគាត់ផ្ដល់ពរជ័យបព្វជិតភាពដល់ណូរ៉ា » ។ សម្លេងរបស់គាត់ឮកាន់តែតិចទៅៗ ។ « ហើយសូមអនុញ្ញាតឱ្យនាងអាចមកផ្ទះ និង មានសុខភាពល្អ បើនោះជាព្រះទ័យរបស់ទ្រង់ » ។

នៅពេលយើងអធិស្ឋាន ខ្ញុំអាចទទួលអារម្មណ៍ព្រះវិញ្ញាណបរិសុទ្ធ មានពេញក្នុងបន្ទប់ ព្រមជាមួយនឹងភាពសុខសាន្ត និង ក្ដីស្រឡាញ់ ។ វាហាក់បីដូចជាព្រះវរបិតាសួគ៌ កំពុងតែប្រាប់ខ្ញុំថា មិនថាមានអ្វីបានកើតឡើងចំពោះណូរ៉ាទេ វាគឺជាចំណែកនៃផែនការរបស់ទ្រង់ទាំងអស់ ។

ក្រោយមកនៅយប់នោះ ប៉ាបានមកផ្ទះ ហើយប្រាប់យើងថា មានអ្វីមួយដ៏អស្ចារ្យបានកើតឡើងនៅក្នុងមន្ទីរពេទ្យ ។ តាមធម្មតា បន្ទប់ណូរ៉ា មានឮសូរសម្លេងអ៊ូអែខ្លាំង ។ តែងតែមានម៉ាស៊ីន និង ម៉ូនីទ័រយ៉ាងច្រើន ព្រមទាំងកន្ទឹងរោទិ៍ និង ពន្លឺពិល ហើយមានពេទ្យ និង វេជ្ជបណ្ឌិត ប្រញាប់ប្រញាល់មកជួយដល់ទារកតូចៗនៅទីនោះជានិច្ច ។ ប៉ុន្តែនៅពេលប៉ា និង ប៊ីស្សពបានទៅដល់ទីនោះ អ្វីៗជាច្រើនមានភាពខុសប្លែក ។ ម៉ាស៊ីនទាំងអស់បានស្ងាត់ ។ គ្រូពេទ្យអង្គុយនៅជិតទារក អាន ឬ មើលថែពួកគេ ។ ប៉ា និង ប៊ីស្សព អាចផ្ដល់ប្រសិទ្ធពរដល់ណូរ៉ា ដោយគ្មានការរំខាន ។

ខ្ញុំមិនដឹងថា តើណូរ៉ា នឹងធំឡើងនៅទីនេះលើផែនដី ឬ ក៏ត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌ក្នុងពេលឆាប់ៗនេះទេ ។ ប៉ុន្តែខ្ញុំដឹងថា ព្រះវរបិតាសួគ៌ បានស្ដាប់ឮ និង ឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ហើយខ្ញុំមានអារម្មណ៍សុខសាន្ត នៅពេលខ្ញុំចាំថា ទ្រង់មានផែនការមួយសម្រាប់សមាជិក *គ្រប់រូប*ក្នុងគ្រួសារខ្ញុំ ។ ■

សូមមករុករកកន្លែងសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រ !

# ផ្ទះ2កន្លែង ដែលយ៉ូសែប ស្ម៊ីធ បានរស់នៅ

**ដោយ ជេន ភិនប៉ូវ៉ាហ្វ** ទស្សនាវដ្ដីសាសនាចក្រ

ប៉ាលម៉ៃរ៉ា នូវយ៉ោក គឺជាកន្លែងដែល **ការស្ដារឡើងវិញ** នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានចាប់ផ្ដើម កាលពី 193 ឆ្នាំកន្លងទៅ ។ លូកា, វ៉ាឆែល និង ជូលៀ អេស. បានទៅទស្សនាកន្លែងពិសេសនេះ ដើម្បីរៀនច្រើនទៀតអំពីកន្លែងដែលព្យាការីយ៉ូសែប ស្ម៊ីធបានរស់នៅ និង របៀបដែលលោកបានជួយស្ដារសាសនាចក្រឡើងវិញនៅលើផែនដី ។

## ផ្ទះឈើ

ផ្ទះឈើនេះត្រូវបានសង់ឡើង ឱ្យដូចជាផ្ទះដែលយ៉ូសែប បានរស់នៅកាលពីអាយុ 12 ឆ្នាំ ដល់ 19 ឆ្នាំ ។

**1.** *យ៉ូសែប មានបងប្អូនប្រុសប្រាំនាក់ និង បងប្អូនស្រីបីនាក់ ។ នេះគឺជាផ្ទះតូចដែលមានមនុស្ស 11 នាក់ !*



**2.** *ក្រុមគ្រួសារ បានជួបជុំគ្នានៅតុកន្លែងផ្ទះបាយ ដើម្បីអានព្រះគម្ពីរបរិសុទ្ធជាញឹកញាប់ ។ នៅពេលលោកមានអាយុ 14 ឆ្នាំ យ៉ូសែប បានអាន យ៉ាកុប 1:5 ៖ « តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ » ។ លោកមានសំណួរសំខាន់មួយដើម្បីសួរដល់ព្រះ ។*



រូបថត ដោយ រ៉ូប៊ើរ វ៉េលជុន *THE ANGEL MORONI APPEARS TO JOSEPH SMITH*, ដោយ ថម ឡូវែល © 2003 IRI



**3.** ទាព្រឹកនិទារឃរដូវមួយក្នុងឆ្នាំ 1820 យ៉ូសែប បានដើរទៅព្រៃមួយ ដែលនៅជិតផ្ទះឈើរបស់លោក ហើយបានអធិស្ឋានសួរអំពីព្រះវិហារណាមួយ ដែលលោកគួរតែចូលរួម ។ ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ បានលេចមក ហើយបានប្រាប់លោកថា កុំឱ្យចូលរួមក្នុងព្រះវិហារណាមួយឡើយ ។ ព្រះយេស៊ូវ បានមានបន្ទូលថា យ៉ូសែប នឹងជួយនាំឱ្យមានសាសនាចក្ររបស់ព្រះអម្ចាស់នៅលើផែនដីវិញ ។



**4.** កូនប្រុសទាំងប្រាំមួយនាក់នៅក្នុងគ្រួសារ បានដេកនៅបន្ទប់ខាងលើមួយ ។ នាយប់មួយ នៅពេលយ៉ូសែប មានអាយុ 17 ឆ្នាំ ទេវតាម៉ូរ៉ូណៃ បានលេចមកបីដង ហើយបានប្រាប់លោកអំពីផ្ទាំងចំណារមាស ដែលយ៉ូសែប នឹងបកប្រែ ហើយបោះពុម្ពជាព្រះគម្ពីរមរមន ។



បួនឆ្នាំក្រោយមក យ៉ូសែប បានទទួលផ្ទាំងចំណារនោះ ។

## គ្រោងផ្ទះ

នៅពេលយ៉ូសែប មានអាយុ 19 ឆ្នាំ គ្រួសាររបស់លោក បានផ្លាស់ទៅផ្ទះថ្មី ។ លោកបានរស់នៅទីនោះ នៅពេលលោកបានទទួលផ្ទាំងចំណារមាស មកពីភ្នំកូម៉ូរ៉ា ។

**6.** បងប្អូនស្រីរបស់យ៉ូសែប សូហ្វ្រូនា និង ខាធើរីន ដេកនៅក្នុងបន្ទប់តូចនេះ ។ មានយប់មួយ យ៉ូសែប បានរុំផ្ទាំងចំណារនៅក្នុងក្រណាត់ ហើយដាក់លាក់នៅចន្លោះក្មេងស្រីទាំងពីរនាក់ ពេលពួកគេកំពុងដេក ។

**5.** មានមនុស្សមួយចំនួនបានមកព្យាយាមលួចផ្ទាំងចំណារមាស ។ យ៉ូសែប បានលាក់វានៅក្រោមឥដ្ឋខាងមុខកន្លែងអាំងភ្លើងនេះ ។







# ព្រះយេស៊ូវគ្រីស្ទ និង ការនិមិត្តដំបូង



ការនិមិត្តដំបូង នៅពេលយ៉ូសែប ស្ម៊ីធ បាន ឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ នោះគឺជាការចាប់ផ្ដើមនៃការត្រឡប់មកនៃ សាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទនៅលើ ផែនដី ។

យ៉ូសែប ស្ម៊ីធ បានរៀនមកពីការនិមិត្តដំបូង ថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ គ្រីស្ទ គឺជាតួអង្គពីរដាច់ដោយឡែកពីគ្នា ។

គ្រាមួយក្នុងចំណោមគ្រាទាំងបី ដែលបាន កត់ត្រានៅក្នុងបទគម្ពីរថា ព្រះវរបិតាសួគ៌ បានណែនាំឱ្យស្គាល់បុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:17) ។ នៅគ្រាផ្សេងមួយ ទៀតគឺនៅពេលព្រះអង្គសង្គ្រោះ បានយាង ទៅជួបនឹងពួកសាសន៍នីហ្វៃ និង នៅពេល ទ្រង់បានទទួលបុណ្យជ្រមុជទឹក (សូមមើល នីហ្វៃ 11:7; ម៉ាថាយ 3:17)

ការនិមិត្តដំបូង ដោយ ហ្គារី អិល ខេប ហាមថតចម្លង

# ទំព័ររបស់កុមារ



ខារ៉ូលីណា អិល. អាយុ 11 ឆ្នាំ មកពី វ៉េនេហ្ស៊ុយអេឡា បានធំឡើងនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយតែងតែចង់ទៅព្រះវិហារបរិសុទ្ធ ការ៉ាកាស វ៉េនេហ្ស៊ុយអេឡា ។ នៅក្នុងខែមិនា ឆ្នាំ 2012 គាត់បានទៅទស្សនាព្រះវិហារបរិសុទ្ធជាលើកទីមួយ ។ វាបានធ្វើឱ្យគាត់រីករាយខ្លាំងណាស់ ។



នៅពេលខ្ញុំទៅព្រះវិហារបរិសុទ្ធ ខ្ញុំមានក្ដីសប្បាយជាមួយប៉ារបស់ខ្ញុំ និង បងប្រុសរបស់ខ្ញុំ រ៉ាយអិន ខណៈដែលម្ដាយរបស់ខ្ញុំ និង មិត្តរបស់គាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំមានគារវភាពណាស់ នៅពេលខ្ញុំនៅក្នុងបន្ទប់រង់ចាំក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំមានចិត្តរំភើបណាស់ ដើម្បីនៅក្នុងដំណាក់របស់ព្រះវរបិតាសួគ៌ និង ដើម្បីទទួលអារម្មណ៍នៃក្ដីស្រឡាញ់ និង ព្រះទ័យល្អរបស់ទ្រង់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំស្រឡាញ់ដំណាក់របស់ព្រះអម្ចាស់ ។

**ចច អិម. អាយុ 6 ឆ្នាំ កូស្តា រីកា**



នេះគឺជាគំនូរមួយនៃព្រះវិហារបរិសុទ្ធអាសិុនស្យ៊ែអន ប៉ារ៉ាហ្គាយ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដោយសារតែមិនយូរប៉ុន្មានទៀតទេ យើងនឹងត្រូវបានផ្សារភ្ជាប់ជាគ្រួសារដ៏អស់កល្បជានិច្ចហើយ ។ ខ្ញុំសូមថ្វាយអំណរគុណដល់ព្រះវរបិតាសួគ៌ ចំពោះការប្រទានគ្រួសារមួយដល់ខ្ញុំ ។

**អាន់ជីឡូ អិន. អាយុ 5 ឆ្នាំ ប៉ារ៉ាហ្គាយ**





ខ្ញុំមានគ្រួសារដ៏ពិសេសមួយ ។ ព្រះវិហារមានចម្ងាយរយៈពេលប្រាំមួយម៉ោងពីផ្ទះយើង ប៉ុន្តែយើងទៅនៅពេលយើងអាច ។ ឪពុករបស់ខ្ញុំប្រសិទ្ធពរសាក្រាម៉ង់សម្រាប់យើងជារៀងរាល់ថ្ងៃអាទិត្យ ហើយម្ដាយរបស់ខ្ញុំបង្រៀនខ្ញុំនៅក្នុងថ្នាក់អង្គការបឋមសិក្សា ។ យើងទៅព្រះវិហារបរិសុទ្ធរ៉េស៊ីហ្វេ ប្រេស៊ីល មួយឆ្នាំម្ដង ។ ខ្ញុំនឹងទៅបេសកកម្ម នៅពេលខ្ញុំគ្រប់អាយុ ។ ខ្ញុំសិក្សាគម្ពីរ ហើយអធិស្ឋានជារៀងរាល់ថ្ងៃ ។ ខ្ញុំបានព្យាយាមដើម្បីធ្វើឱ្យ ព្រះវរបិតាសួគ៌សព្វព្រះទ័យ ដោយការធ្វើជាក្មេងល្អ ។ ខ្ញុំស្រឡាញ់ដំណឹងល្អខ្លាំងណាស់ ។

**ខេវិន អិល អាយុ 8 ឆ្នាំ ប្រទេសប្រេស៊ីល**



ប្អូនស្រីតូចរបស់ខ្ញុំ អូមេកា និង ខ្ញុំ ចូលចិត្តទៅមើលព្រះវិហារបរិសុទ្ធ ។ នៅពេលវួដរបស់យើង ទៅទស្សនាព្រះវិហារបរិសុទ្ធម៉ុនទើរ៉េ មិុកស៊ីកូ យើងបានចេញដំណើរនៅពាក់កណ្ដាលអធ្រាត្រ ហើយធ្វើដំណើររយៈពេលប្រាំមួយម៉ោង ដើម្បីទៅដល់ទីនោះ ។ ខ្ញុំដឹងថា ព្រះវិហារបរិសុទ្ធ គឺជាកន្លែងដែលធ្វើឱ្យក្រុមគ្រួសារមានភាពអស់កល្បជានិច្ច ។ មិនយូរប៉ុន្មានយើងនឹងផ្លាស់ទៅ តូស្តឡា ហ្គូទីរ៉េហ្ស ។ នៅទីនោះមានព្រះវិហារបរិសុទ្ធមួយ ហើយយើងនឹងអាចទៅទស្សនាកាន់តែញឹកញាប់ ។ ខ្ញុំមានអំណរគុណចំពោះព្រះវិហារបរិសុទ្ធ ។

**ហេលិម អិន. អាយុ 4 ឆ្នាំ ប្រទេសមិុកស៊ីកូ**



**សូលីទី អេស. អាយុ 6 ឆ្នាំ ប្រទេសប្រេស៊ីល**



នៅពេលខ្ញុំចូលទៅក្នុងព្រះវិហារបរិសុទ្ធគ្វិតស្សាទីណានហ្គូ ហ្គូតេម៉ាឡា ខ្ញុំមានអារម្មណ៍សេចក្ដីសុខសាន្តយ៉ាងខ្លាំង ។ អំឡុងពេលការឧទ្ទិសឆ្លង ខ្ញុំមានអារម្មណ៍រីករាយខ្លាំងណាស់ ។ ប្រសាសន៍ទាំងឡាយ បានចាក់ទម្លុះចូលក្នុងជម្រៅបេះដូងរបស់ខ្ញុំ ។

**ចូអាន ជី. អាយុ 11 ឆ្នាំ ហ្គូតេម៉ាឡា**





# ត្រៀមខ្លួនជារួច

ដោយ មើរលី បូរិន

ផ្អែកទៅលើដំណើររឿងពិតមួយ

*« ព្រះទ្រង់មិនបានប្រទានឱ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាច » (ធីម៉ូថេទី 2 1:7)* ។

ម៉ារី មានចិត្តរសាប់រសល់អង្គុយរំកិលទៅមុខទៅក្រោយនៅលើកៅអីរបស់នាង នៅពេលនាងស្ដាប់ក្មេងដទៃទៀតនៅក្នុងថ្នាក់អង្គការបឋមសិក្សា ផ្លាស់វេណគ្នាអានបទគម្ពីរ ។ នាងមិនចង់ឱ្យដល់វេណនាងឡើយ

ម៉ារី អសមត្ថភាពក្នុងការរៀន ដែលហៅថាភាពកំណត់នៃខួរក្បាល ។ នៅពេលនាងមើលអក្សរនៅលើក្រដាសមួយសន្លឹក អក្សរទាំងនោះហាក់ដូចលាយឡំច្របូកច្របល់គ្នា ។ នៅពេលនាងអានឮៗ សំដីរបស់នាងនិយាយឃឺតៗ ហើយពេលខ្លះ

រូបភាពគំនូរដោយ អេរ៉ែន លូត

# ស្រេចដើម្បីអាន



ខុសលំដាប់ ។ ជាញឹកញាប់ នាងអានទូវពាក្យដែលគ្មាននៅក្នុងក្រដាសសោះ ។

ពេលជិតដល់វេណ ម៉ារី នោះធ្វើឱ្យនាងកាន់តែភ័យ ។ នៅពេលដល់វេណនាង ម៉ារី ពុំទទួលយកបានទេ ។

នាងបាននិយាយភ្លាម នៅពេលនាងលោតចុះពីកៅអីថា « ខ្ញុំត្រូវទៅបន្ទប់ទឹក » ធ្វើឱ្យគម្ពីររបស់នាងធ្លាក់ទៅលើកំរាលឥដ្ឋ ។ ម៉ារី រត់ចេញទៅតាមទីធ្លាសាលទៅកាន់បន្ទប់ទឹក ។ នាងសប្បាយចិត្តដែលវាគ្មានមនុស្សនៅទីនោះ ។ នាងបានឈរនៅកាច់ជ្រុងនោះ ហើយបានយំ ។

ប៉ុន្មាននាទីក្រោយមក នាងបានឮបងស្រី ស៊្មីធ ហៅឈ្មោះនាង នៅពេលនាងចូលទៅក្នុងបន្ទប់ទឹក ។ « ម៉ារី មានរឿងអ្វីហ្នឹង ? »

ម៉ារី គ្មានពាក្យអ្វីត្រូវនិយាយទេ ។ នាងមានការខ្មាស់អៀនខ្លាំងណាស់ ។ គ្មានកុមារណាផ្សេងទៀត ដែលមានបញ្ហានេះទេ ។ « ខ្ញុំពុំអាចអានបានទេ ! » នាងបានយំ នៅពេលនាងទម្លាក់មុខចុះផ្ទប់នឹងដៃរបស់នាង ។

« ប្អូនពុំអាចអានបានឬ ? » បងស្រី ស៊្មីធបានសួរដោយឆ្ងល់ ។ « ខ្ញុំបានឃើញប្អូនឡើងនិយាយនៅក្នុងថ្នាក់កុមារ ។ ខ្ញុំដឹងថា ប្អូនអាចអានបាន » ។

ម៉ារី គ្រវីក្បាល ។ « ខ្ញុំទន្ទេញការឡើងនិយាយរបស់ខ្ញុំ ។ ខ្ញុំបានហាត់និយាយម្តងហើយម្តងទៀត ដូច្នេះខ្ញុំពុំចាំបាច់ត្រូវអានវានៅចំពោះមុខអ្នកដទៃទេ ។ ខ្ញុំពុំអាចអានឮៗបានទេ ហើយនៅពេលខ្ញុំអាន ខ្ញុំនឹងអានខុសច្រើនណាស់ ។ ខ្ញុំពុំចង់ឱ្យក្មេងដទៃទៀត សើចចំអកដាក់ខ្ញុំនោះទេ » ។

បងស្រីស៊្មីធបាននិយាយថា « អូ ! ម៉ារី ខ្ញុំសុំអភ័យទោស ។ ខ្ញុំនឹងពុំហៅប្អូនឱ្យអានឮៗទៀតទេ ទាល់តែខ្ញុំដឹងថា ប្អូនបានត្រៀមខ្លួនជាស្រេចដើម្បីអាន » ។ « ហើយខ្ញុំមិនជឿថា មាននរណាម្នាក់នៅក្នុងថ្នាក់របស់យើង នឹងសើចចំអកឱ្យប្អូននោះដែរ ។ ពួកគេជាមិត្តរបស់ប្អូន » ។

ម៉ារីបានខ្សឹបប្រាប់ថា « ក្មេងៗនៅសាលារៀនសើចចំអកឱ្យខ្ញុំ » ។

បងស្រីស៊្មីធបានជូតទឹកភ្នែកឱ្យម៉ារី ។ គាត់បាននិយាយថា « តោះត្រឡប់ទៅថ្នាក់វិញ ។ ប្អូននឹងដឹង » ។

ពួកគេបានដើរត្រឡប់ទៅថ្នាក់រៀនវិញជាមួយគ្នា ។ មិត្តរបស់ម៉ារី ឈ្មោះ បេតស៊ី បានអង្គុយនៅកៅអីជិតនឹងម៉ារី រៀបទំព័រគម្ពីររញ្ជៀវញ្ជៀឱ្យម៉ារីវិញ ។ ម៉ារី បានអង្គុយចុះ ហើយ បេតស៊ី បានហុចគម្ពីររបស់នាងឱ្យទៅនាងវិញ ។

បងស្រី ស៊្មីធបានសួរ « តើនរណានឹងចង់អានបន្ទាប់មកទៀត ? »

កុមារាម្នាក់ក្នុងថ្នាក់បាននិយាយថា « ដល់វេណរបស់ម៉ារី » ។

ម៉ារី ស្ទាក់ស្ទើរ ប៉ុន្តែនាងបានមើលទៅមិត្តក្នុងថ្នាក់របស់នាង ហើយឃើញពួកគេញញឹមដោយរួសរាយ ។ បងស្រី ស៊្មីធ បានងក់ក្បាលហើយញញឹមផងដែរ ។ ម៉ារី ភិតភ័យ ប៉ុន្តែនាងបានរកឃើញកន្លែងដែលនាងត្រូវអាន ហើយបានចាប់ផ្តើមអាន ។

នាងអានយឺតៗ ។ នាងបានអានខុសខ្លះៗ ប៉ុន្តែនៅពេលនាងទាក់ នោះបេតស៊ី បានខ្សឹបដោយស្ងាត់ស្ងៀមប្រាប់នូវពាក្យត្រឹមត្រូវដាក់ត្រចៀកម៉ារី ។ ម៉ារី ពុំអានបានល្អដូចជាកុមារផ្សេងទៀតនៅក្នុងថ្នាក់នាងទេ ប៉ុន្តែគ្មាននរណាម្នាក់សើចចំអក ឬមើលងាយនាងទេ។ បន្ទាប់មក ដល់វេណរបស់កុមារផ្សេងទៀត ហើយមេរៀនក៏បានបន្តទៅទៀត ។

នៅពេលពួកគេដើរទៅបន្ទប់ថ្នាក់កុមារ បន្ទាប់ពីថ្នាក់រៀនចប់ នោះបងស្រី ស៊្មីធ បានខ្សឹបប្រាប់ម៉ារីថា គាត់មានមោទនភាពចំពោះនាង ។ ម៉ារី សប្បាយចិត្ត ដែលនាងពុំចាំបាច់ត្រូវលាក់អំពីរឿងការពិបាកអានរបស់នាងទៀតឡើយ ។ នាងបានគិតថា « ខ្ញុំនឹងបន្តហាត់រៀន » ។ ហើយនាងបានញញឹម ដោយដឹងថា នាងមានមិត្តល្អនៅព្រះវិហារ ដើម្បីជួយគាំទ្រដល់នាង ។ ■

អ្នកអាចប្រើមេរៀន និង សកម្មភាពនេះ ដើម្បីរៀនសូត្របន្ថែមទៀតពីបាវចនាថ្នាក់កុមារសម្រាប់ខែនេះ

# ព្រះវរបិតាសួគ៌ ស្រឡាញ់ខ្ញុំ ហើយទ្រង់មានផែនការមួយសម្រាប់ខ្ញុំ

ក្លិននំឃុកគីដុត ឈ្ងុយពេញអាកាស នៅពេលណាថានែល បានជួយលោកយាយ យកនំពីក្នុងថាសដុតនំ ។ លោកយាយ ញញឹមដាក់គាត់ ។ លោកយាយបានសួរ ។ « នរណាស្រឡាញ់ចៅ ? »

ណាថានែល បានគិតអំពីរបៀបដែលលោកយាយតែងតែធ្វើនំឃុកគីដែលគាត់ពេញចិត្ត ហើយតែងតែមានក្រដាសនៅក្នុងដៃ ដោយសារគាត់ដឹងថា ណាថានែល ចូលចិត្តគូររូប ។ គាត់បានឆ្លើយថា « គឺលោកយាយ » ។

លោកយាយមានប្រសាសន៍ថា « ត្រឹមត្រូវហើយ » ។ « យាយបានស្គាល់ចៅយូរជាងគេឯងទាំងអស់ ក្រៅពីម៉ាក់ និង ប៉ារបស់ចៅ ។ ប៉ុន្តែមានអ្នកដែលស្គាល់ចៅច្រើនជាងយាយទៅទៀត » ។

ណាថានែល បានសួរ ។
« នរណាទៅយាយ ? »

លោកយាយមានប្រសាសន៍ថា « អ្នកដែលស្រឡាញ់ចៅមុនពេលចៅមកកាន់ផែនដី » ។

ណាថានែល បាននិយាយថា « អូ៎ ! »
« យាយចង់មានន័យថា ជាព្រះវរបិតាសួគ៌ » ។

លោកយាយមានប្រសាសន៍ថា « ចាស៎ » រួចឱប ណាថានែល ។

ណាថានែលញញឹម ។ ដោយដឹងថា គាត់មានអ្នកស្រឡាញ់ នោះធ្វើឱ្យគាត់មានអារម្មណ៍កក់ក្ដៅនៅខាងក្នុងខ្លួន ។

នៅឆ្នាំនេះ ក្នុងពេលវេលាចែកចាយ ចៅនឹងរៀនច្រើនអំពីសេចក្ដីពិតដ៏អស្ចារ្យថា ចៅគឺជាកូនរបស់ព្រះ ។ ព្រះវរបិតាសួគ៌ ស្គាល់ និង ស្រឡាញ់ចៅ ។ ទ្រង់មានផែនការមួយ ដើម្បីជួយចៅឱ្យត្រឡប់ទៅរស់នៅជាមួយទ្រង់នៅថ្ងៃណាមួយ ។ ■



រូបភាពលំអរដោយ ប៊េកគី ហ្វូសុន ខាងឆ្វេង ៖ រូបភាពដោយ ភីលីស លុច



## ចម្រៀង និងព្រះគម្ពីរ

- « ខ្ញុំជាកូនរបស់ព្រះ » (*សៀវភៅចម្រៀងកុមារ*, ទំព័រ 58)
- រ៉ូម 8:16

# ហត្ថកម្មធ្វើផ្កាយព្រិល

1. បត់ក្រដាសទំហំ 8 x 8 អ៊ិញ (20 x 20 សម) ជាពីរ ។ រួចហើយបត់វាជាពីរជាន់ ។
2. ប្រើគំរូដើម្បីកាត់ចេញជាផ្កាយព្រិលកុមារា ឬ កុមារី ។ កាត់ផ្នែកពណ៌លឿងចេញ ។
3. ប្រើគូល័រឡេទ្រ ឬ ខ្មៅដៃ ដើម្បីផាត់ពណ៌រូបភាពនៅលើផ្កាយព្រិល ។ អ្នក អាចផាត់ពណ៌រូបភាពទីមួយៗខុសៗគ្នា ដើម្បីបង្ហាញនូវស្នាដៃពិសេសអំពីខ្លួនអ្នក ។
4. នៅចំកណ្ដាលផ្កាយព្រិល ចូរសរសេរថា « ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ » ដើម្បីរំឭកខ្លួនអ្នកថា ព្រះវរបិតាសួគ៌ស្គាល់អ្វីៗទាំងអស់អំពីអ្នក ហើយថា ទ្រង់ស្រឡាញ់អ្នកយ៉ាងខ្លាំង ។






## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

- ដូចជាផ្កាយព្រិលដែលមានទំហំ និងទ្រង់ទ្រាយខុសៗគ្នា នោះកុមារទាំងឡាយមានគុណសម្បត្តិពិសេស ដែលធ្វើឱ្យកុមារម្នាក់ៗពិសេសរៀងៗខ្លួន ។ បន្ទាប់ពីការធ្វើផ្កាយព្រិល អ្នកអាចផ្លាស់វេណគ្នាហុចផ្កាយព្រិលរបស់សមាជិកគ្រួសារម្នាក់ៗជុំវិញ ដោយប្រាប់អំពីចរិតលក្ខណៈពិសេសអំពីបុគ្គលនោះ ហើយបង្ហាញសេចក្ដីស្រឡាញ់ ។ បន្ទាប់មក សូមប្រាប់បុគ្គលម្នាក់ៗថា ព្រះវរបិតាសួគ៌ ស្គាល់ ហើយស្រឡាញ់ពួកគេ ។
- អ្នកក៏អាចហុចកញ្ចក់ទៅជុំវិញ ហើយឱ្យសមាជិកគ្រួសារម្នាក់ៗ មើលទៅក្នុងកញ្ចក់ នៅពេលអ្នកពិភាក្សាអំពីគោលគំនិតទាំងនេះថា ៖ អ្នកគឺជាកូនរបស់ព្រះ ។ ព្រះវរបិតាសួគ៌របស់អ្នកស្រឡាញ់អ្នកខ្លាំងណាស់ ។ អ្នកបានរស់នៅស្ថានសួគ៌ជាមួយទ្រង់ មុនពេលអ្នកមកកាន់ផែនដី ។ នោះគឺជាមូលហេតុដែលយើងហៅទ្រង់ថាជាព្រះវរបិតាសួគ៌ ។ ទ្រង់ចង់ឱ្យអ្នកបានរីករាយ ហើយត្រឡប់ទៅកាន់ទ្រង់នៅថ្ងៃមួយ ។ តើអ្នក ដឹងថាព្រះវរបិតាសួគ៌ស្រឡាញ់អ្នកដោយរបៀបណា ?





សម្រាប់កុមារតូចៗ

# ទីបន្ទាល់របស់អ៊ីវលីនអំពីព្រះវិហារបរិសុទ្ធ

**ដោយ មិចឈី បារបូសា និង ម៉ារីស្សា វីដឌីសុន**

ផ្អែកទៅលើដំណើររឿងពិតមួយ



អ៊ីវលីន ចូលចិត្តមកថ្នាក់អង្គការបឋមសិក្សា ។ នាងតែងតែលើកដៃអធិស្ឋាន ។ នាងក៏ចូលចិត្តជួយដល់គ្រូបង្រៀនរបស់នាងផងដែរ ។



ប៉ុន្តែថ្ងៃនេះ គឺជាលើកដំបូងដែលអ៊ីវលីនឡើងនិយាយ ។ នៅពេលនាងដើរទៅខាងមុខបន្ទប់ នាងចាប់ផ្ដើមបុកពោះ ។ បន្ទាប់មកបេះដូងរបស់នាងចាប់ផ្ដើមលោតកាន់តែញាប់ ។ ក្ដុក-ក្ដាក់ ។ ក្ដុក-ក្ដាក់ ។ ក្ដុក-ក្ដាក់



នៅពេលនាងទៅឈរនៅខាងមុខថ្នាក់ អីវីលីន បាននិយាយថា « សួស្ដី » ។ « ខ្ញុំឈ្មោះ អីវីលីន ។ គ្រួសាររបស់ខ្ញុំទើបតែទៅព្រះវិហារបរិសុទ្ធ ដូច្នេះយើងអាចរស់នៅជាមួយគ្នាជានិរន្តរ៍ » ។



អីវីលីន បានប្រាប់កុមារថ្នាក់អង្គការបឋមសិក្សាអំពីសម្លៀកបំពាក់ពណ៌ស ដែលនាងបានពាក់ ។ ព្រះវិហារបរិសុទ្ធ ក៏ស្អាតខ្លាំងណាស់ផងដែរ ។ នាងបានប្រាប់ពួកគេថា នាង និង ឪពុកម្ដាយរបស់នាង និង បងស្រី បានផ្សារភ្ជាប់ជាមួយគ្នាជានិរន្តន៍ ។

រូបភាពគំនូរដោយ ខាធី ម៉ាក់គី



អ៊ីវលីន បាននិយាយថា « ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ស្រឡាញ់យើង » ។ « ទ្រង់បានអនុញ្ញាតឱ្យយើងទៅព្រះវិហារបរិសុទ្ធ ដើម្បីអាចនៅជាមួយក្រុមគ្រួសារយើងជានិរន្តន៍ » ។

អ៊ីវលីន បានត្រឡប់មកអង្គុយចុះវិញ ។ នាងមានអារម្មណ៍សប្បាយចិត្ត ។ មានអារម្មណ៍ដូចជាពន្លឺដ៏កក់ក្ដៅ កំពុងតែបំភ្លឺនៅក្នុងរាងកាយរបស់នាង ។ នាងសប្បាយចិត្ត ដែលនាងបានទៅព្រះវិហារបរិសុទ្ធ ។ ■

# ទីបន្ទាល់អំពីព្រះវិហារបរិសុទ្ធ

អ៊ីវលីន បាននិយាយអំពី ការផ្សារភ្ជាប់របស់នាងទៅនឹងគ្រួសារនៅក្នុងព្រះវិហារបរិសុទ្ធ ។ ចូរមើលថា តើអ្នកអាចរកឃើញវត្ថុមួយចំនួន នៅក្នុងបន្ទប់របស់អ៊ីវលីន ដែលនាងបាននិយាយអំឡុងពេលនាងឡើងនិយាយក្នុងថ្នាក់អង្គការកុមារឬទេ ។ តើអ្នកអាចរកវត្ថុដែលលាក់កំបាំងដទៃទៀតបានដែរឬទេ ?



# ព័ត៌មានអំពីសាសនាចក្រ

*សូមមើល news.lds.org សម្រាប់ព័ត៌មាន និងព្រឹត្តិការណ៍ច្រើនទៀត ។*

## ការជួយយុវវ័យឱ្យក្លាយជាអ្នករៀន និង គ្រូបង្រៀនដ៏មានឥទ្ធិពល

**ដោយ ម៉ៃឃល បាបើរ**

អ្នកបង្កើតកម្មវិធីសិក្សាសម្រាប់ ការិយាល័យផ្នែកបព្វជិតភាព

*កម្មវិធីសិក្សាថ្មីរបស់យុវវ័យ* Come, Follow Me: Learning Resources for Youth *(ចូរមកតាមខ្ញុំចុះ ៖ ធនធានសិក្សាសម្រាប់យុវវ័យ) សង្កត់ធ្ងន់លើវិធីបួនយ៉ាងដែលឪពុកម្ដាយ គ្រូបង្រៀន និង អ្នកដឹកនាំទាំងឡាយអាចជួយយុវវ័យយ៉ាងមានប្រសិទ្ធភាព ដើម្បីប្រែចិត្តជឿ លើដំណឹងល្អ ។*

នៅក្នុងដំណើររឿងអំពីភាពជាយុវវ័យរបស់ព្រះយេស៊ូវគ្រីស្ទក្នុងព្រះគម្ពីរ យើងដឹងថាព្រះអង្គសង្គ្រោះដែលមានព្រះជន្ម 12 ព្រះវស្សា គេបានឃើញ « ទ្រង់គង់នៅកណ្ដាលពួកអាចារ្យ ក្នុងព្រះវិហារ កំពុងតែស្ដាប់ ហើយនឹងសួរគេ ។

« ពួកអស់អ្នកដែលឮទ្រង់ក៏អស្ចារ្យក្នុងចិត្តពីប្រាជ្ញា ហើយនឹងពាក្យចម្លើយរបស់ទ្រង់ » (ការបកប្រែនៃ យ៉ូសែប ស៊្មីធ លូកា 2:46–47 [នៅក្នុង លូកា 2:46 កំណត់សម្គាល់ *គ*]) ។

តាំងពីនៅយុវវ័យម្ល៉េះ ព្រះអង្គសង្គ្រោះបានចូលរួមយ៉ាងសកម្មនៅក្នុងការសិក្សា និង បង្រៀនដំណឹងល្អ ។ នៅក្នុងព្រះវិហារបរិសុទ្ធ ព្រះអង្គសង្គ្រោះបានបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អ ដល់អស់អ្នកដែលចាត់ទុកថាមានចំណេះដឹង និង បទពិសោធន៍ច្រើនជាងទ្រង់ទៅទៀត ។ ពីព្រោះ ទ្រង់បានយល់ថា ការសិក្សា និង ការបង្រៀនដំណឹងល្អគឺជាផ្នែកមួយនៃ « កិច្ចការរបស់ព្រះវរបិតា » (លូកា 2:49) ហើយមានសារៈសំខាន់ចំពោះបេសកកម្មដ៏ទេវភាពនៅលើផែនដីនេះ ។

ដោយគ្មានសង្ស័យ ព្រះយេស៊ូវគ្រីស្ទគឺជាអ្នករៀន និង គ្រូបង្រៀនដំណឹងល្អដ៏អស្ចារ្យម្នាក់ សូម្បីតែទ្រង់នៅវ័យក្មេងក៏ដោយ មិនត្រឹមតែប៉ុណ្ណោះ ទ្រង់បានរីកចម្រើនខាងសមត្ថភាពរបស់ទ្រង់ដើម្បីយល់ និង បង្រៀនគោលលទ្ធិ ។ ព្រះគម្ពីរបានប្រាប់យើងថា ទ្រង់ « បានព្រះគុណថែមលើព្រះគុណជាបន្តបន្ទាប់មក រហូតដល់ទ្រង់បានទទួលនូវភាពពោរពេញ » (គ. និង ស. 93:13) ។ សព្វថ្ងៃនេះ នៅពេលដែលយុវវ័យនៅតែ



*ព្រះគ្រីស្ទនៅភូមិអេម៉ោស ដោយ វលធើ រេន © IRI*



***ការរៀបចំខាងវិញ្ញាណ—ការសិក្សា ការអធិស្ឋាន និង តមអាហារ—អាចជួយទាំងគ្រូបង្រៀន និង អ្នករៀនឱ្យទទួលឥទ្ធិពលពីព្រះវិញ្ញាណ ។***

បន្តជីវិតពួកគេឱ្យស្របទៅនឹងអ្វីដែលពួកគេដឹងថាជាការពិត នោះពួកគេអាចប្រែចិត្តជឿយ៉ាងពិតប្រាកដដល់ព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ហើយបង្កើនប្រាជ្ញា « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ » (នីហ្វៃទី 2 28:30) ។

នៅក្នុងសេចក្ដីណែនាំសម្រាប់សៀវភៅ កម្មវិធីសិក្សាថ្មីរបស់យុវវ័យ នោះ គណៈប្រធានទីមួយបានថ្លែងថា « អ្នកត្រូវបានហៅដោយព្រះអម្ចាស់ដើម្បីជួយយុវវ័យឱ្យប្រែចិត្តជឿចំពោះដំណឹងល្អ » ។[1] នៅពេលយើងសិក្សា និង ធ្វើតាមការបម្រើរបស់ព្រះអង្គសង្គ្រោះ នោះយើងនឹងអាចគាំទ្រដល់យុវវ័យរបស់យើងយ៉ាងមានប្រសិទ្ធភាពនៅក្នុងដំណើររបស់ពួកគេ ដើម្បីរៀន រស់នៅ និង បង្រៀនដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដូចជាព្រះអង្គសង្គ្រោះដែរ នោះយើងអាចរៀបចំខ្លួនយើងខាងព្រលឹងវិញ្ញាណ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់យុវវ័យរបស់យើង លើកទឹកចិត្តពួកគេស្វែងរកសេចក្ដីពិតនៃដំណឹងល្អ និង អញ្ជើញពួកគេឱ្យប្រែចិត្តជឿនៅពេលពួកគេធ្វើកិច្ចការនោះដោយសេចក្ដីជំនឿ ។

## រៀបចំខាងព្រលឹងវិញ្ញាណ

ពីមុនពេលចាប់ផ្ដើម ការបម្រើនៃជីវិតរមែងស្លាប់របស់ទ្រង់ នោះព្រះអង្គសង្គ្រោះបានរៀបចំអង្គទ្រង់ខាងព្រលឹងវិញ្ញាណតាមរយៈការសិក្សា អធិស្ឋាន និង តមអាហារយ៉ាងសំភី ។ ទ្រង់ត្រូវបាន « នាំដោយព្រះវិញ្ញាណទៅឯទីរហោស្ថានដើម្បីទៅជាមួយព្រះ » ហើយ « តមអាហារអស់សែបសិបថ្ងៃ និង សែបសិបយប់ » (យ៉ូសែប ស្ម៊ីធ ម៉ាថាយ 4:1–2 [នៅក្នុងម៉ាថាយ 4:1 កំណត់សម្គាល់ *ខ*]) ។ នៅចុងបញ្ចប់នៃការតមអាហាររបស់ទ្រង់ នោះព្រះអង្គសង្គ្រោះបានជួបនឹងការសាកល្បងជាបន្តបន្ទាប់ពីមារសត្រូវ ។ ការសិក្សាព្រះគម្ពីរជាមុនបានជួយនៅពេលព្រះយេស៊ូវបានឆ្លើយតបចំពោះការល្បួងនិមួយៗជាមួយនឹងខទាំងឡាយពីព្រះគម្ពីរ (សូមមើល ម៉ាថាយ 4:3–10) ។ ការរៀបចំខាងព្រលឹងវិញ្ញាណមិនត្រឹមតែអាចជួយទ្រង់ឱ្យឈ្នះលើការល្បួងបានដោយជោគជ័យនៅពេញមួយជីវិតរបស់ទ្រង់នោះទេ គឺថែមទាំងអាចបង្រៀនដំណឹងល្អយ៉ាងមានឥទ្ធិពលតាមរយៈការបម្រើរបស់ទ្រង់ ។

ការបង្រៀនយុវវ័យតម្រូវឱ្យមានការរៀបចំច្រើនជាងគ្រាន់តែក្រឡេកមើល សៀវភៅសិក្សាមួយភ្លែតមុនពេលចាប់ផ្ដើមបង្រៀននោះទេ ។ ព្រះអម្ចាស់បានបញ្ជាថា « ចូរកុំខំប្រកាសព្រះបន្ទូលរបស់យើងឡើយ ប៉ុន្តែចូរខំព្យាយាមដើម្បីឱ្យបានព្រះបន្ទូលរបស់យើងជាមុនសិនចុះ » (គ. និង ស. 11:21) ។ យើងរៀបចំខាងព្រលឹងវិញ្ញាណតាមរយៈការសិក្សាព្រះគម្ពីរ និង ប្រសាសន៍ទាំងឡាយរបស់ព្យាការីដែលរស់នៅដោយការអធិស្ឋាន ដើម្បីរៀនពីគោលលទ្ធិពិត ។ នៅពេលយើងរៀបចំតាមរបៀបនេះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់សេចក្ដីពិតនៃគោលលទ្ធិ និង បំផុសគំនិតដល់យើងដើម្បីចងចាំពីបទពិសោធន៍នៃការរស់នៅតាមគោលលទ្ធិទាំងឡាយ ដែលយើងអាចចែកចាយបាន ។



*យុវវ័យពង្រឹងគ្នាទៅវិញទៅមក នៅពេលពួកគេចែកចាយពីបទពិសោធន៍នៃការរស់នៅតាមដំណឹងល្អរបស់ពួកគេ ។*

នៅពេលបង្រៀនយុវនារី អំពីសារៈសំខាន់នៃវិវរណៈផ្ទាល់ខ្លួន នោះ អ៊ីស្តេហ្វានី មែលេរ៉ូ មកពី លីម៉ា ពេរ៉ូ សើក្លូស្ដេកត្រូវបានបំផុសគំនិតឱ្យចែកចាយពីបទពិសោធន៍នៃការស្វែងរកទីបន្ទាល់របស់នាងកាលនាងមានអាយុ 14 ឆ្នាំ ។ នាងបានថ្លែងទីបន្ទាល់ដល់យុវនារីថា នៅពេលនាងបានអធិស្ឋានដោយស្មោះអស់ពីចិត្តដើម្បីដឹងពីសេចក្ដីពិតនៃដំណឹងល្អ ហាក់បីដូចជាមានសំឡេងមួយខ្សឹបប្រាប់ដល់ដួងចិត្តរបស់នាងនូវពាក្យដែលនាងមិនអាចបំភ្លេចបានថា ៖ « អ៊ីស្តេហ្វានី អ្នកដឹងថាវាជាការពិត ។ អ្នកតែងតែដឹង » ។

នៅពេលយើងសិក្សា និង រស់នៅតាមគោលលទ្ធិដែលយើងបង្រៀន នោះយើងនឹងក្លាយខ្លួនលើសពីគ្រូបង្រៀន—យើងនឹងក្លាយជាសាក្សីនៃសេចក្ដីពិត ។

***សំណួរពិចារណា*** ៖ *តើមានខគម្ពីរណាផ្សេងទៀតបង្ហាញពីរបៀបដែលព្រះអង្គសង្គ្រោះបានរៀបចំអង្គទ្រង់ដើម្បីបង្រៀនដែរឬទេ ? តើកិច្ចខិតខំរបស់អ្នកដើម្បីរៀបចំបង្រៀនបានជះឥទ្ធពលយ៉ាងមានប្រសិទ្ធភាពពីសារលិខិតរបស់អ្នកដោយរបៀបណា ?*

## សូមផ្ដោតលើតម្រូវការទាំងឡាយ

នៅក្នុងការសន្ទនាជាមួយជាមួយនាម៉ឺនវ័យក្មេងម្នាក់ នោះព្រះអង្គសង្គ្រោះបានបង្ហាញថា ទ្រង់បានយល់ពីតម្រូវការរបស់អ្នកដែលទ្រង់បង្រៀន ។ នាម៉ឺននោះបានចាប់ផ្ដើមសួរថា ៖ « តើត្រូវឱ្យខ្ញុំធ្វើដូចម្ដេច ឱ្យបានជីវិតរស់អស់កល្បជានិច្ច ? » បន្ទាប់ពីព្រះអង្គសង្គ្រោះបានបង្រៀនពីសារៈសំខាន់នៃការគោរពព្រះបញ្ញត្តិហើយ នោះនាម៉ឺនវ័យក្មេងបានតបថា « ខ្ញុំបានកាន់តាម [ព្រះបញ្ញាត្តិ] ទាំងនោះ តាំងតែពីក្មេងមកហើយ » ។ ដោយដឹងថាដួងចិត្តរបស់នាម៉ឺននោះនៅខ្វះ « សេចក្ដីមួយទៀត » នោះព្រះយេស៊ូវបានអញ្ជើញបុរសនោះឱ្យលក់របស់ទ្រព្យទាំងប៉ុន្មានដែលគាត់មាន ចែកទានដល់អ្នកទ័លក្រ ហើយដើរតាមទ្រង់ ។ (សូមមើលលូកា 18:18–23) ។ នៅពេលយើងអធិស្ឋានសម្រាប់វិវរណៈ

និង ការដឹងពីចំណាប់អារម្មណ៍ សេចក្ដីសង្ឃឹម និង បំណងប្រាថ្នារបស់យុវវ័យ នោះយើងនឹង—ដឹងដូចអ្វីដែលព្រះអង្គសង្គ្រោះបានដឹង—ដើម្បីបង្រៀន និង អញ្ជើញពួកគេដើម្បីរស់នៅតាមដំណឹងល្អនៅក្នុងរបៀបផ្ទាល់ខ្លួនជាច្រើនដ៏មានអត្ថន័យ ។

ប្រធាន ប៊ិយដ៍ ឃេ ផាកកឺ ប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « យុវវ័យរបស់យើងបានចម្រើនវ័យធំឡើងនៅក្នុងដែនដីរបស់សត្រូវ » ។[2] ក្នុងនាមយើងជាឪពុកម្ដាយ និង គ្រូបង្រៀន នោះយើងត្រូវយល់ពីការលំបាកទាំងឡាយដែលយុវវ័យរបស់យើងជួបប្រទះ ។ ខេវីន ធួធ្យេ ជាគ្រូបង្រៀនថ្នាក់សាលាថ្ងៃអាទិត្យយុវវ័យនៅក្នុងស្ដេក កូឡូមប៊ីន ខូឡូរ៉ាដូ បាននិយាយថា « បញ្ហាទាំងឡាយដែលយុវវ័យបានជួបប្រទះ មិនអាចត្រូវបានបង្រៀនចេញក្រៅពីសៀវភៅសិក្សាឡើយ ។ នោះគឺជាវិវរណៈផ្ទាល់ខ្លួនដែលយើងជាគ្រូបង្រៀនទទួលដើម្បីឈានទៅមុខ ហើយអាចរៀបចំយុវវ័យរបស់យើងដើម្បីប្រយុទ្ធជាមួយសាតាំងរាល់ថ្ងៃ ។ ខ្ញុំបានយល់ថាអ្នកមិនអាចគ្រាន់តែបង្ហាញខ្លួននៅថ្ងៃអាទិត្យជាមួយនឹងសៀវភៅសិក្សា ហើយបង្រៀនមេរៀននោះទេ » ។

*ឪពុកម្ដាយមានទំនួលខុសត្រូវជាចម្បង ដើម្បីជួយកូនៗរបស់ពួកគេឱ្យស្វែងរកសេចក្ដីពិតនៃដំណឹងល្អ ហើយយុវនារី និង យុវជនម្នាក់ៗមានទំនួលខុសត្រូវផ្ទាល់ខ្លួនដើម្បីមានការប្រែចិត្តជឿឱ្យបានពេញលេញទាំងស្រុង ។ អ្នកដឹកនាំ និង គ្រូបង្រៀនរបស់យុវវ័យ គាំទ្រនូវកិច្ចខិតខំទាំងនេះ ។*


រូបថតលំអរដោយ គ្រីស្ទីណា ស្មីធ

ការជួយយុវវ័យឱ្យរៀន និង រស់នៅតាមដំណឹងល្អនោះវាទាក់ទងនឹង កិច្ចខិតខំរួមគ្នារវាង ឪពុកម្ដាយ អ្នកដឹកនាំ អ្នកណែនាំ និង គ្រូបង្រៀនទាំងឡាយ ។ នៅពេលយើងស្វែករកការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចបង្រៀនគោលលទ្ធិយ៉ាងមានប្រសិទ្ធភាពដែលនឹងរៀបចំយុវវ័យសម្រាប់យកឈ្នះលើការល្បួង និង បញ្ហាទាំងឡាយដែលពួកគេជួបប្រទះ ។

***សំណួរពិចារណា ៖*** *តើបច្ចុប្បន្ននេះពិភពលោកមានភាពខុសប្លែកយ៉ាងណាទៅនឹង ជំនាន់កាលពីអ្នកនៅក្មេង ? តើបញ្ហាអ្វីខ្លះដែលអ្នកឃើញថាយុវវ័យជួបប្រទះ ? នៅពេលបានយល់គោលលទ្ធិ តើគោលលិទ្ធិនៃដំណឹងល្អមួយណាដែលនឹង ជួយពួកគេឱ្យទទួលបានជោគជ័យចំពោះបញ្ហាដែលជួបប្រទះ ?*

## អញ្ជើញយុវវ័យឱ្យស្វែងរកសេចក្ដីពិតនៃដំណឹងល្អ

ព្រះអង្គសង្គ្រោះបានបង្រៀនពួកសិស្សរបស់ទ្រង់ តាមវិធីជាច្រើនដែលលើកទឹកចិត្តពួកគេ ឱ្យស្វែងរកសេចក្ដីពិត ហើយទទួលទីបន្ទាល់ផ្ទាល់ខ្លួន ។ នៅពេលបង្រៀនដល់សាសាន៍នីហ្វៃ នោះទ្រង់មានព្រះបន្ទូលថា ៖

« យើងឃើញថា អ្នករាល់គ្នាទន់ខ្សោយ គឺអ្នករាល់គ្នាពុំយល់ពាក្យទាំងអស់របស់យើង ដែលព្រះវរបិតាទ្រង់បញ្ជាឱ្យយើង ប្រាប់អ្នករាល់គ្នាក្នុងពេលនេះ ។

« ដូច្នេះ ចូរអ្នករាល់គ្នាត្រឡប់ទៅផ្ទះវិញចុះ ហើយពិចារណាគិតអំពីរឿងទាំងឡាយ ដែលយើងបាននិយាយ ហើយចូរសូមដល់ព្រះវរបិតា ដោយនូវនាមយើង ដើម្បីឱ្យអ្នករាល់គ្នាអាចយល់ ហើយប្រុងប្រៀបចិត្តគំនិតរបស់អ្នកចាំថ្ងៃស្អែកហើយយើងនឹងយាងមកជួបអ្នកទៀត » (នីហ្វៃទី 3 17:2–3) ។

ការបង្រៀនដូចជាព្រះគ្រីស្ទ លើសពីការចែកចាយព័ត៌មាន ។ វាទាក់ទងនឹងការដឹកនាំយុវវ័យឱ្យយល់គោលលទ្ធិសម្រាប់ខ្លួនពួកគេ ។ នៅពេលយើងព្យាយាមបង្រៀនពួកគេអំពីដំណឹងល្អ នោះយើងនឹងក្លាយជាបុគ្គលម្នាក់ដែលមានប្រសិទ្ធភាពជាង ប្រសិនបើយើងជួយពួកគេស្វែងរកចម្លើយសម្រាប់ខ្លួនពួកគេ នោះអាចធ្វើឱ្យពួកគេទទួលទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេ ហើយបង្រៀន

ពួកគេពីរបៀបដើម្បីរកចម្លើយនៅពេលពួកគេមានសំណួរផ្សេងទៀត ។ ដូចដែលបានសង្កត់ធ្ងន់ដោយកម្មវិធីសិក្សាថ្មីរបស់យុវវ័យ *Come, Follow Me: Learning Resources for Youth (ចូរមកតាមខ្ញុំចុះ ៖ ធនធានសិក្សាសម្រាប់យុវវ័យ)* យើងអាចអញ្ជើញពួកគេចែកចាយពីបទពិសោធន៍នៃការរស់នៅតាមដំណឹងល្អ និង ថ្លែងទីបន្ទាល់ដល់មិត្តភក្តិរបស់ពួកគេពីអ្វីៗដែលពួកគេដឹងថាជាការពិត ។

ថ្មីនេះ អែលឌើរ គីម ប៊ី ខ្លាក ពួកចិតសិបនាក់ប្រចាំតំបន់ និង ប្រធាននៃសាសកវិទ្យាល័យ ប៊ី.វ៉ាយ.យូ–អៃដាហូ បានប្រាប់ពីរឿងមួយអំពីក្រុមឌីកុនដែលជាអ្នកណែនាំបានពិភាក្សាការអធិស្ឋានជាមួយពួកគេ ។ ភ្លាមនោះ ប្រធានក្រុមឌីកុនបានលើកដៃរបស់គាត់ឡើង ហើយនិយាយថា « ខ្ញុំសូមសួរសំណួរមួយដល់ក្រុមទាំងអស់គ្នា ។ តើមានអ្នកទាំងអស់គ្នាប៉ុន្មាននាក់ ដែលមានឆន្ទៈដើម្បីប្ដេជ្ញាចិត្តថាអធិស្ឋានទាំងពេលព្រឹក និង ពេលល្ងាចរៀងរាល់ថ្ងៃនៅសប្ដាហ៍នេះ ? » សមាជិកក្រុមទាំងអស់បានលើកដៃពួកគេឡើង លើកលែងតែយុវជនម្នាក់គត់ ដែលគ្មានទំនុកចិត្តថាគាត់អាចធ្វើតាមការអញ្ជើញនោះបាន ។ អ្នកណែនាំបានអង្គុយចុះវិញ ហើយ មើលនៅខណៈពេលដែលសមាជិកក្រុមបានបង្រៀន និង ថ្លែងទីបន្ទាល់ដល់មិត្តភក្ដិពួកគេអំពីការអធិស្ឋាន ដោយជួយឱ្យគាត់ទទួលបានទំនុកចិត្តដើម្បីទទួលយកការអញ្ជើញនោះ ។

***សំណួរពិចារណា ៖*** *តើអ្នកបានកត់សម្គាល់ថាគ្រូៗបានលើកទឹកចិត្តដល់សមាជិកក្នុងថ្នាក់តាមរបៀបណាខ្លះ ដើម្បីធ្វើឱ្យមានភាពសកម្មនៅក្នុងសិក្សានោះ ? តើអ្នកអាចជួយយុវវ័យដែលអ្នកធ្វើការជាមួយឱ្យអភិវឌ្ឍទម្លាប់សិក្សាដំណឹងល្អបានដោយរបៀបណា ? ក្រៅពីការពិភាក្សា តើមានវិធីណាផ្សេងទៀត ដើម្បីដាក់បញ្ចូលយុវវ័យនៅក្នុងការរៀនដំណឹងល្អដែរឬទេ ?*

## សូមលើកទឹកចិត្តឱ្យមានមានការប្រែចិត្តជឿ

ការប្រែចិត្តជឿគឺជាដំណើរការពេញមួយជីវិតដែលបូករួមទាំងការសិក្សា និង ការរស់នៅតាមដំណឹងល្អជារៀងរាល់ថ្ងៃ ។ លើសពីការស្គាល់ដំណឹងល្អ នោះការប្រែចិត្តជឿ « តម្រូវឱ្យយើង *ធ្វើ* និង *ប្រែក្លាយខ្លួន ។* »[3] បន្ទាប់ពីបង្រៀនពួកសិស្សរបស់ទ្រង់អំពីសេចក្ដីសប្បុរសរបស់សាសន៍សាម៉ារីចិត្តល្អហើយ នោះព្រះអង្គសង្គ្រោះបានអញ្ជើញពួកគេឱ្យ « ទៅចុះ ហើយចូរអ្នកប្រព្រឹត្តបែបយ៉ាងនោះដែរ » (លូកា 10:37) ។ ទ្រង់បានលើកទឹកចិត្តពួកគេដើម្បីធ្វើខ្លួនឱ្យលើសពីអ្នកដែលគ្រាន់តែស្ដាប់ហើយឱ្យអនុវត្តដោយជំនឿលើការបង្រៀនទាំងឡាយរបស់ទ្រង់ ។

យើងត្រូវតែលើកទឹកចិត្តយុវវ័យឱ្យរស់នៅតាមដំណឹងល្អដោយឧស្សាហ៍ព្យាយាម ពីព្រោះជាធម្មតាការប្រែចិត្តជឿ មិនអាចកើតឡើងអំឡុងពេលនៃការបង្រៀនតែម្ដងនោះឡើយ ។ ការប្រែចិត្តជឿល្អបំផុតកើតឡើងនៅពេលដែលយុវវ័យយល់ពីគោលលទ្ធិពិត ហើយបង្កើតខ្នាតគំរូនៃការសិក្សាដំណឹងល្អ និង រស់នៅដោយសុចរិត នៅពេលយើងលើកទឹកចិត្តពួកគេដើម្បីអនុវត្តតាមនៅក្នុង *ចូរមកតាមខ្ញុំ* ។

គ្រីស្ដា វ៉ានីក ជាប្រធានយុវនារីនៅក្នុងស្តេក អារ៉ាប៉ាហូ ខូឡូរ៉ាដូ បាននិយាយថា « សព្វថ្ងៃនេះយុវវ័យប្រឈមមុននឹងឧបគ្គសមួយចំនួនធំ ដែលខ្ញុំពុំធ្លាប់បានឮពីមុនសោះ រហូតដល់ខ្ញុំមានអាយុកាន់តែច្រើន ។ ខ្ញុំបានអភិវឌ្ឍទីន្ទាល់របស់ខ្ញុំបានច្រើនបំផុតនៅពេលខ្ញុំបន្ដធ្វើវាដោយខ្លួនខ្ញុំផ្ទាល់ ហើយអាចបន្តទៅទៀត និង អនុវត្តតាមអ្វីៗដែលខ្ញុំបានរៀននៅក្នុងថ្នាក់យុវនារី ។ ការផ្ដល់ការអញ្ជើញ និង ឱកាសទាំងឡាយដល់យុវវ័យ ឱ្យអនុវត្តសេចក្ដីជំនឿរបស់ពួកគេនឹងជួយពួកគេឱ្យអភិវឌ្ឍគ្រឹះនៃទីបន្ទាល់របស់គេបានកាន់តែច្រើនតាំងពីពួកគេនៅក្មេងនៅឡើយ » ។

ការអញ្ជើញនៃការប្រែចិត្តជឿ គឺមិនមែនត្រឹមតែយើងរៀនដំណឹងល្អប៉ុណ្ណោះទេ តែយើងថែមទាំងផ្លាស់ប្ដូរដួងចិត្តរបស់យើងដោយសារតែអ្វីដែលយើងបានរៀន ។ យើងត្រូវតែជួយយុវវ័យរបស់យើងឱ្យយល់ថា « ការផ្លាស់ប្ដូរដ៏ធំ » (អាលម៉ា 5:14) នៃដួងចិត្តមិនអាចកើតឡើងភ្លាមៗបានទេ ប៉ុន្តែវាអាចកើតឡើងសន្សឹមៗ នៅពេលពួកគេអភិវឌ្ឍទម្លាប់សិក្សាយ៉ាងខ្ជាប់ខ្ជួន អធិស្ឋានជានិច្ច និង រក្សាព្រះបញ្ញត្តិទាំងឡាយ ។ នៅពេលពួកគេធ្វើបែបនេះ នោះពួកគេនឹងកត់សម្គាល់ឃើញថា បំណងប្រាថ្នា អាកប្បកិរិយា និង សកម្មភាពទាំងឡាយរបស់ពួកគេផ្លាស់ប្ដូរ ដើម្បីធ្វើត្រាប់តាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ ។

***សំណួរពិចារណា ៖*** *តើកិច្ចខិតខំទាំងឡាយរបស់អ្នកដើម្បីរៀន និង រស់នៅតាមដំណឹងល្អ ដើរតួយ៉ាងដូចម្ដេចខ្លះចំពោះការប្រែចិត្តជឿផ្ទាល់របស់អ្នក ? តើអ្នកត្រូវបានពង្រឹងដោយឪពុកម្ដាយ និង គ្រូបង្រៀន និង អ្នកដឹកនាំសាសនាចក្រដោយរបៀបណាខ្លះ ?*

## គាំទ្រដល់យុវវ័យរបស់យើង

*ចូរមកតាមខ្ញុំចុះ* គ្រាន់តែធ្វើជាតំណាងឱ្យផ្នែកមួយនៃកិច្ចខិតខំដើម្បីពង្រឹងដល់យុវវ័យប៉ុណ្ណោះ ។ បន្ថែមទៅលើទំនួលខុសត្រូវផ្ទាល់ខ្លួនរបស់យុវវ័យម្នាក់ៗដើម្បីប្រែក្លាយខ្លួនឱ្យកាន់តែប្រែចិត្តជឿបានទាំងស្រុងនោះ « ឪពុកម្ដាយមានតួនាទីចម្បងដើម្បីជួយកូនៗរបស់ពួកគេឱ្យស្គាល់ព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ » ។[4] យើងទាំងអស់គ្នាដែលជាអ្នកធ្វើការជាមួយយុវវ័យអាចគាំទ្រឪពុកម្ដាយ ហើយធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះនៅពេលយើងរៀបចំខាងព្រលឹងវិញ្ញាណ ដោយផ្ដោតលើតម្រូវការទាំងឡាយរបស់យុវវ័យ អញ្ជើញពួកគេឱ្យស្វែងរកសេចក្ដីពិតនៃដំណឹងល្អ ហើយផ្ដល់ឱកាសឱ្យពួកគេអនុវត្តដោយសេចក្ដីជំនឿ ហើយប្រែចិត្តជឿ ។ នៅពេលយើងព្យាយាមដើម្បីធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងក្លាយជាអ្នករៀន និង គ្រូបង្រៀនកាន់តែល្អជាងមុន ហើយយើងជួយដល់អនាគតអ្នកដឹកនាំរបស់សហគមន៍ និង សាសនាចក្ររបស់យើង ឱ្យកាន់តែក្លាយខ្លួនជាអ្នករៀន និង គ្រូបង្រៀនដែលមានឥទ្ធិពលដោយខ្លួនរបស់ពួកគេ ។ ■

## កំណត់ចំណាំ

1. *ការបង្រៀនដំណឹងល្អតាមរបៀបរបស់ព្រះអង្គសង្គ្រោះសៀវភៅណែនាំ* ***Come, Follow Me: Learning Resources for Youth*** *(ចូរមកតាមខ្ញុំចុះ ៖ ធនធានសិក្សាសម្រាប់យុវវ័យ* ឆ្នាំ 2012 ទំព័រ 2 ។
2. ប៊ិយដ៍ យេ ផាកកឺ « ប្រឹក្សាដល់យុវវ័យ »*លីអាហូណា*និង ***Ensign*** ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 16 ។
3. ដាល្លិន អេក អូក « The Challenge to Become » *លីអាហូណា* ខែ មករា ឆ្នាំ 2001 ទំព័រ 40 ***Ensign*** ខែ វិច្ឆិកា ឆ្នាំ 2000 ទំព័រ 33 ។
4. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* (ឆ្នាំ 2010) ចំណុច 1.4.1 ។

*សម្រាប់ព័ត៌មានបន្ថែមអំពី កម្មវិធីសិក្សាថ្មីរបស់យុវវ័យ សូមមើលគេហទំព័រ lds.org/youth/learn ។*

# សាសនាចក្រអនុវត្តកម្មវិធីសិក្សាថ្មីរបស់យុវវ័យសម្រាប់ឆ្នាំ 2013

នៅក្នុងដើមខែនេះ គ្រូបង្រៀន និង អ្នកដឹកនាំទូទាំងសាសនាចក្រនឹងចាប់ផ្ដើមអនុវត្តទាំងស្រុងនូវកម្មវិធីសិក្សាថ្មីរបស់យុវវ័យ *Come, Follow Me: Learning Resources for Youth* (ចូរមកតាមខ្ញុំ ៖ ធនធានសិក្សាសម្រាប់យុវវ័យ) ការប្រកាសដំបូងនៅក្នុងសារលិខិតពីគណៈប្រធានទីមួយ ខែ កញ្ញា ។

នៅក្នុងគេហទំព័រ lds.org/youth/learn គ្រូបង្រៀនថ្នាក់ យុវនារី បព្វជិតភាពអើរ៉ុន និង សាលាថ្ងៃអាទិត្យ និង អ្នកដឹកនាំទាំងឡាយអាចរកមេរៀនដែលមាន 23 ភាសា ។ គ្រប់មេរៀនទាំងអស់អាចធ្វើការបោះពុម្ពបាន ។ អស់អ្នកដែលគ្មានអ៊ីនធើរណែតប្រើប្រាស់គួរតែទាក់ទងអ្នកដឹកនាំបព្វជិតភាពក្នុងមូលដ្ឋានរបស់ពួកគេដើម្បីស្វែងរកវិធីដែល *ចូរមកតាមខ្ញុំ* នឹងអនុវត្តបាននៅក្នុងតំបន់របស់ពួកគេ ។

សារលិខិតពីគណៈប្រធានទីមួយបានសរសេរថា « កម្មវិធីសិក្សាថ្មីនេះ បានបញ្ចូលនូវគោលលទ្ធិគ្រឹះនៃដំណឹងល្អ ព្រមទាំងគោលការណ៍ទាំងឡាយសម្រាប់បង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ។ យើងមានទំនុកចិត្តថា [កម្មវិធីសិក្សាថ្មីនេះ] នឹងប្រទានពរដល់យុវវ័យក្នុងកិច្ចខិតខំរបស់ពួកគេដើម្បីប្រែចិត្តជឿទាំងស្រុងលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ » ។

នៅក្នុង *ចូរមកតាមខ្ញុំចុះ* រៀងរាល់ខែនៃឆ្នាំត្រូវបានចាត់ឱ្យមានប្រធានបទនៃគោលលទ្ធិ ហើយគ្រប់ថ្នាក់សាលាថ្ងៃអាទិត្យទាំងអស់ ទាំងថ្នាក់សាលាថ្ងៃអាទិត្យសម្រាប់យុវនារី និង បព្វជិតភាពអើរ៉ុន នឹងសិក្សាប្រធានបទនេះនៅខែនោះ ។

មេរៀននិមួយៗមានបួនវគ្គ ៖ វគ្គការរៀបចំខាងព្រលឹងវិញ្ញាណសម្រាប់គ្រូបង្រៀន យោបល់ដើម្បីណែនាំពីប្រធានបទ យោបល់សម្រាប់កម្មវិធីពិសេសៗ និង វគ្គអញ្ជើញយុវវ័យឱ្យអនុវត្ត ។ គ្រូបង្រៀនទាំងអស់ត្រូវបានស្នើរសុំឱ្យស្វែងរកការបំផុសគំនិតដើម្បីជ្រើសរើស និង កែតម្រូវមេរៀនអាស្រ័យលើតម្រូវការរបស់សិស្សរបស់ពួកគេ ។

គេហទំព័រនេះក៏ដាក់បញ្ចូលនូវវីដេអូដ៏មានសារៈសំខាន់ ដែលពន្យល់ពីរបៀបអនុវត្តកម្មវិធីសិក្សាថ្មីនេះ យោបល់សម្រាប់ការរៀបចំសកម្មភាពសិក្សាដែលពាក់ព័ន្ធ និង សៀវភៅណែនាំថ្មីមួយ *ការបង្រៀនដំណឹងល្អតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* (សៀវភៅណែនាំដល់ *Come, Follow Me: Learning Resources for Youth* ។ ■





រូបថតដោយ ធីជេ. ថូម៉ាស

*ខណៈពេលដែលបានចូលរួមនៅក្នុងគម្រោងដៃជំនួយនៃពួកមរមនទូទាំងទ្វីបអាហ្វ្រិក នោះសមាជិកទាំងឡាយនៃសាសនាចក្របានផ្ដល់ការបម្រើដ៏មានតម្លៃ សាងទំនាក់ទំនងជាអន្តរជំនឿ ឱ្យគេស្គាល់សាសនាចក្រកាន់តែច្រើន និង ស្ដាបនាទីបន្ទាល់របស់ពួកគេអំពីសេចក្ដីសប្បុរស ។*

## ទិវាបម្រើប្រចាំឆ្នាំលើកទីប្រាំមួយទូទាំងទ្វីបអាហ្វ្រិក

នៅថ្ងៃ សៅរ៍ ទី 18 ខែ សីហា ឆ្នាំ 2012 គេបានឃើញពួកបរិសុទ្ធរាប់ពាន់នាក់នៅក្នុងចំណោមប្រទេសអាហ្វ្រិកមួយចំនួនបានជួបជុំគ្នានៅក្នុងសហគមន៍របស់ពួកគេដើម្បីចូលរួមនៅក្នុងទិវាដៃជំនួយនៃពួកមរមនប្រចាំឆ្នាំលើកទីប្រាំមួយទូទាំងទ្វីបអាហ្វ្រិក ។

អែលឌើរ ស៊ី ធើរី វ៉ាទើរ ដែលជាអ្នកផ្សព្វផ្សាយសាសនាផ្នែកកិច្ចការសាធារណៈបានសសេរតាមអ៊ីម៉ែលថា « ជាធម្មតា វួដ និង សាខាទាំងឡាយបានចេញទៅទាំងអស់គ្នាដើម្បីផ្ដល់ការបម្រើពិសេសមួយ » ។ « ពួកគេបានរកដៃទាំងឡាយ ពួកគេបានជ្រើសរើសគម្រោងដែល ពិបាកដែលសំខាន់ ។ ពួកគេមានចំនួនច្រើននាក់ដោយមានបំណងជួយ ហើយពួកគេពិតជាបានបង្កើត មិត្តភក្តិជាច្រើនសម្រាប់សាសនាចក្រ » ។

អែលឌើរ អេដេស៊ីណា ជេ. អូឡូខាន់ទី នាយកផ្នែកកិច្ចការសាធារណៈសម្រាប់ប្រទេស អាហ្វ្រិកប៉ែកខាងលិច បាននិយាយនៅទិវាថ្ងៃបម្រើថា « វាជារបៀបមួយងាយស្រួលបំផុតដែលយើងអាចឆ្លើយតបនឹងការហៅរបស់ព្យាការីដើម្បីមានចិត្តសប្បុរសដល់អ្នកជិតខាងរបស់យើង ដើម្បីឆ្លើយតបនឹងតម្រូវការទាំងឡាយរបស់ពួកគេ ដើម្បីផ្ដល់ឱ្យច្រើនជាងទទួល ។ វាជាការងាយស្រួលបំផុតដើម្បីផ្សាយដំណឹងល្អតាមរយៈ—គំរូ » ។

## ឥឡូវនេះ គេហទំព័រ **Mormon.org** មាន 20 ភាសាហើយ

Mormon.org គឺជាគេហទំព័រដែលមានជាភាសា អាមេនី, ស៊ីប៊ូអាណូ, ចិន, ហូឡង់, អង់គ្លេស, បារាំង, អាល្លឺម៉ង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, កូរ៉េ, ឡាវៀន, ប៉ូឡូញ, ព័រទុយហ្គាយ, រុស្ស៊ី, អេស្ប៉ាញ, ស៊ុយអ៊ែត, តាហ្គាឡុក, ថៃ និង អ៊ុយក្រែន ។

សមាជិកម្នាក់ៗត្រូវបានលើកទឹកចិត្តឱ្យបង្កើតទម្រង់បែបបទផ្ទាល់ខ្លួននៃគេហទំព័រ Mormon.org របស់ពួកគេ តាមភាសាដែលពួកគេចង់បាន ហើយចែកចាយព័ត៌មានទាំងនោះជាមួយមនុស្សដទៃទៀត ។

## មុខងារពិតប្រាកដរបស់ព្រះគុណ

ខ្ញុំបានដក់ជាប់ក្នុងដួងចិត្តដោយសារអត្ថបទពីរនៅក្នុងច្បាប់ចេញផ្សាយនៅខែមេសា ឆ្នាំ 2012 ៖ អត្ថបទរបស់ អែលឌើរ ដេវីឌ អេ បែដណា « ដង្វាយធួន និង ដំណើរនៃជីវិតរមែងស្លាប់ » (ទំព័រ 12) និង អត្ថបទរបស់ ត្រីស្ទែន ទិក្វ ខាដុន « ព្រះគុណដ៏អស្ចារ្យ » (ទំព័រ 10) ។ សំណួររបស់ខ្ញុំអំពីមុខងារពិតប្រាកដនៃព្រះគុណនៅក្នុងជីវិតរមែងស្លាប់របស់យើង និង ដំណើតជីវិតរបស់យើងដើម្បីទទួលជីវិតអស់កល្បជានិច្ចត្រូវបានឆ្លើយតបយ៉ាងល្អឥតខ្ចោះ ។ ខ្ញុំមានអំណរគុណសម្រាប់អត្ថបទទាំងនេះ—អត្ថបទទាំងនេះបានបង្កើនការយល់ដឹងរបស់ខ្ញុំជាច្រើន ហើយខ្ញុំពិចារណាអត្ថបទនោះម្ដងហើយម្ដងទៀត ។

**អែម៉ាញូអែល អាដុ ហ្គាមហ្វី ប្រទេស ហ្គាណា**

## ការកែលំអ

នៅក្នុងសារលិខិតគណៈប្រធានទីមួយខែ មករា ឆ្នាំ 2012 « ការរស់នៅក្នុងជីវិតដ៏ពោរពេញ » យើងបានធ្វេសប្រហែសជាមួយនឹងពាក្យដកស្រង់របស់ ម៉ារី អាន វ៉ាដម៉ាឆើ ។ ពាក្យដកស្រង់នេះមាននៅក្នុងទំព័រទី 5 របស់ *លីអាហូណា* ។ ពាក្យដកស្រង់ដើមរបស់ អ្នកស្រី វ៉ាដម៉ាឆើ សរសេរថា « ជួនកាល ភាពក្លាហានគឺជាសំឡេងដ៏ស្ងាត់ស្ងៀមនៅចុងបញ្ចប់នៃថ្ងៃនោះ ដោយនិយាយថា ខ្ញុំនឹងព្យាយាមធ្វើវាម្ដងទៀតនៅថ្ងៃស្អែក » ។ វាបានលេចចេញនៅក្នុងចំណោមការបោះពុម្ពផ្សាយផ្សេងទៀតដោយ អ្នកស្រី វ៉ាដម៉ាឆើ *ជានិច្ចកាលភាពក្លាហានមិនតែងតែមកជាសំឡេងព្រួញឡើយ* (ឆ្នាំ 2009) យើងសុំអភ័យទោសចំពោះការមើលរំលងនេះ ។

*ច្បាប់នេះមានទូវអត្ថបទ និង សកម្មភាពទាំងឡាយដែលអាចប្រើប្រាស់ សម្រាប់ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗ ។*

**« ភាពធំមហិមានៃប្រាជ្ញារបស់ព្រះ » ទំព័រ 20 ៖** សូមពិចារណា ដោយពិភាក្សាប្រៀបធៀបគ្នាពីប្រាជ្ញារបស់លោកិយ ជាមួយប្រាជ្ញារបស់ព្រះ ។ អ្នកអាចនឹងអាននៅនីហ្វៃទី 2 9:28–29 ហើយសូមគិតពីស្ថានភាពទាំងឡាយដែលប្រាជ្ញាលោកិយមានភាពខុសពីប្រាជ្ញាដែលបង្រៀនដោយដំណឹងល្អ ។ សូមសម្រេចចិត្តថាតើផ្លូវណាមួយដែលអ្នកនឹងរើសយកនៅក្នុងស្ថានភាពនីមួយៗ ។

**« បាវចនាម៉្ញូតឆលឆ្នាំ 2013 » ទំព័រ 50 ៖** សូមអានអត្ថបទរបស់ អេលែន អេស. ដាល់ថុន និង ដេវីឌ អិល. ប៊ិកស្ពីពីបាវចនាម៉្ញូតឆលឆ្នាំ 2013 ។ សូមពិចារណាពីយោបល់ទាំងឡាយដែលសមាជិកម្នាក់ៗរបស់គ្រួសារ អាចជួយឱ្យគេហដ្ឋានក្លាយជាទីដ៏បរិសុទ្ធ ។ អ្នកអាចនឹងមានបំណងចង់បង្ហាញរូបភាពរបស់ព្រះវិហារបរិសុទ្ធ នៅក្នុងគេហដ្ឋានរបស់អ្នក ហើយដាក់គោលដៅដើម្បីចូលរួមព្រះវិហារបរិសុទ្ធជាគ្រួសារ ។

**« ការហាត់រៀនជាបន្ត» ទំព័រ 56 ៖** សូមពិចារណាដោយធ្វើកម្មវិធីបង្ហាញទេពកោសល្យគ្រួសារ ។ សូមផ្ដល់យោបល់ថាសមាជិកម្នាក់ៗនៃគ្រួសារអាចរៀបចំដើម្បីចែកចាយជំនាញ ឬ ការសម្ដែងមួយ ។ បន្ទាប់មកទៀត សូមអានអត្ថបទ « ការហាត់រៀនជាបន្ត » និង ពិភាក្សាពីរបៀបដែលការអនុវត្ត និង ចែកចាយទេពកោសល្យអាចប្រទានពរដល់អស់អ្នកដែលនៅជុំវិញយើង ។

**« ទីបន្ទាល់របស់អ៊ីវ៉ីលីនអំពីព្រះវិហារបរិសុទ្ធ » ទំព័រ 70 ៖** សូមពិចារណាដោយបង្កើតអ្នកស្រាវជ្រាវរកសំណួរអំពី « ទីបន្ទាល់គ្រួសារ » ។ សូមដាក់រូបភាពនៅជុំវិញបន្ទប់ ហើយឱ្យសមាជិកគ្រួសារប្រមូលយករូបណាដែលពួកគេជឿ (ឧទាហរណ៍ ៖ រូបភាពរបស់គ្រួសារអ្នក ព្រះវិហារបរិសុទ្ធ ប្រធាន ថូម៉ាស អេស ម៉នសុន បុណ្យជ្រមុជទឹក ក្រដាសដង្វាយមួយភាគក្នុងដប់ យុវវ័យស្លៀកពាក់បានសមរម្យ) ។ សូមបញ្ចប់ដោយពិភាក្សាគ្នាថាហេតុអ្វីបានអ្នកជឿលើអ្វីៗទាំងអស់នេះ ។

## មេរៀននៅក្នុងទីងងឹត

នៅថ្ងៃមួយក្នុងខែ តុលា កូនស្រីរបស់យើង ឈ្មោះ ជូលា ដែលជានិច្ចកាលនៅអត់ស្ងៀមនៅក្នុងកម្មវិធីរាត្រីជួបជុំក្រុមគ្រួសារនោះទេ បាននិយាយថា « យើងមិនធ្លាប់មានរាត្រីជួបជុំក្រុមគ្រួសារនៅក្នុងទីងងឹតសោះ ។ តើយើងអាចធ្វើអញ្ចឹងបានទេ ? យើងឆ្ងល់ពីរបៀប និង អ្វីដែលយើងអាចបង្រៀននាងនៅក្នុងទីងងឹតបាន ។

យើងបានបិទភ្លើង ហើយវាងងឹតសឹង ។ បន្ទាប់មក ស្វាមីរបស់ខ្ញុំបានបើកទូរស័ព្ទដៃរបស់គាត់ ហើយចាប់ផ្ដើមបង្រៀនអំពីពន្លឺនៃព្រះគ្រីស្ទ ។ គាត់បានបង្ហាញពីរបៀបដែលពន្លឺនៃព្រះគ្រីស្ទ អាចនាំយើងចេញពីទីងងឹត ហើយនាំយើងទាំងក្រុមគ្រួសារត្រឡប់ទៅកាន់ទ្រង់វិញ ។ ពន្លឺចេញមកពីទូរស័ព្ទ មិនសូវភ្លឺប៉ុន្មានទេ ប៉ុន្តែវាភ្លឺល្មមដែលយើងអាចមើលឃើញ ។

នៅពេលដែលទូរស័ព្ទដល់ពេលវាបិទដោយស្វ័យប្រវត្តិ នោះយើងអាចបង្ហាញកូនស្រីរបស់យើងថា តើជីវិតរបស់យើងនឹងទៅជាបែបណា បើគ្មានព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទនោះ ។ ព្រះវិញ្ញាណបានដក់ជាប់ក្នុងដួងចិត្តយើងយ៉ាងខ្លាំង ហើយកូនស្រីរបស់យើងក៏មានតារាវភាពទាំងស្រុង ។ សូម្បីតែមកដល់ពេលនេះ នាងនៅតែចងចាំពីរាត្រីជួបជុំក្រុមគ្រួសារ និង សារលិខិតគួរឱ្យស្រឡាញ់របស់យើងដែលបានបង្រៀននាង ។

**វ៉ាលឌ្បេរីយ៉ា លីម៉ា ដូស សាន់តូស ប្រទេស ប្រេស៊ីល**

# មេរៀនរយៈពេលប្រាំនាទី



ដោយ គ្រីស្តូហ្វើរ ជេម ស្មីធ

នៅចុងបញ្ចប់ឆ្នាំសិក្សានៅសាកលវិទ្យាល័យរបស់ខ្ញុំ ខ្ញុំត្រូវចូលរួមក្នុងពិធីបញ្ចប់ការសិក្សា ដែលអ្នកបញ្ចប់ការសិក្សាថ្មីៗទាំងអស់ពាក់សំលៀកបំពាក់ និង មួកតាមទំនៀមទំលាប់ ទទួលបរិញ្ញាបត្រមកពីអ្នកមានបណ្ដាស័ក្តិខ្ពស់ ។ ខ្ញុំទន្ទឹងរង់ចាំគ្រានេះ គឺពិធីប្រារព្ធឆ្នាំសិក្សារយៈពេលបួនឆ្នាំដ៏ពិបាក ។ នៅព្រឹកនៃការប្រារព្ធពិធី ខ្ញុំបានទទួលលិខិតមួយច្បាប់មកពីសាកលវិទ្យាល័យ ប៉ុន្តែពុំបានបើកមើលទេ ។

ពិធី ចាប់ផ្ដើមនៅម៉ោង 1 កន្លះថ្ងៃ ហើយខ្ញុំបានរៀបចំដើម្បីថតរូបថតមុនពេលវាចាប់ផ្ដើម ។ ជាអកុសល ខ្ញុំត្រូវតម្រង់ជួរដើម្បីថតរូប ហើយខ្ញុំបានមើលទ្រនិចនាឡិការំកិលកាន់តែជិតទៅៗ ដល់ពេលចាប់ផ្ដើមពិធី ។ ប៉ុន្តែខ្ញុំបានរង់ចាំយ៉ាងយូរ ដើម្បីខ្ញុំថតរូបថតបានតាមកំណត់ ។ ទីបំផុត វាបានបញ្ចប់ក្នុងរយៈពេល 10 នាទីមុនពេលពិធីបញ្ចប់ការសិក្សាចាប់ផ្ដើម ខ្ញុំបានរត់ទៅកាន់សាលប្រជុំ ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលខ្ញុំបានទៅដល់ទីនោះ ទ្វារទាំងឡាយ ត្រូវបានបិទ ហើយមានអ្នកសន្តិសុខយាមការពារ ។ ខ្ញុំបានសុំចូលទៅខាងក្នុង ប៉ុន្តែអ្នកយាមបានបដិសេធ ដោយប្រាប់ខ្ញុំថា ខ្ញុំត្រូវមកកន្លែងអង្គុយមុនម៉ោង 15 នាទី ។ នោះគឺជាលើកទីមួយ ដែលខ្ញុំបានឮអំពីតម្រូវការនេះ ដូច្នេះខ្ញុំបានតវ៉ា ។ ប៉ុន្តែសន្តិសុខពុំចេញទេ ។ ខ្ញុំបានខិតខំរយៈពេលបួនឆ្នាំ ដើម្បីទទួលបានបរិញ្ញាបត្រនេះ ហើយខ្ញុំពុំអាចយកបាននៅក្នុងពិធីនេះ ។ ខ្ញុំត្រូវអង្គុយនៅក្នុងច្រកបន្ទប់ជាមួយនឹងអ្នកមកមើល ។

នៅពេលខ្ញុំត្រឡប់ទៅផ្ទះវិញ ហើយបើកមើលសំបុត្រ ដែលខ្ញុំបានទទួលនៅព្រឹកនោះ ខ្ញុំអានការណែនាំយ៉ាងច្បាស់ថា ត្រូវទៅដល់កន្លែងអង្គុយ យ៉ាងហោចណាស់ 15 នាទីមុន ឬ នឹងមិនអនុញ្ញាតឱ្យចូល ។ ខ្ញុំមានអារម្មណ៍ដូចជា ស្ត្រីព្រហ្មចារីល្ងង់ខ្លៅម្នាក់ នៅក្នុងរឿងប្រៀបធៀបរបស់ព្រះអង្គសង្គ្រោះដូច្នោះដែរ ៖

« តែកំពុងដែល [ស្ត្រីព្រហ្មចារីល្ងង់ខ្លៅ] ទាំងនោះទៅទិញ ប្ដីក៏មកដល់ ហើយពួកនាងដែលបានបម្រុងជាស្រេច ក៏ចូលទៅ ក្នុងរោងការជាមួយគ្នា រួចគេបិទទ្វារ ។

« ឯនាងព្រហ្មចារីឯទៀត ក៏មកអង្វរថា លោកម្ចាស់ៗអើយ សូមបើកឱ្យយើងខ្ញុំផង ។

*ខ្ញុំបានខកម៉ោងកន្លែងអង្គុយ ត្រឹមតែរយៈពេលប្រាំនាទីប៉ុណ្ណោះ ។ ប្រាកដណាស់ ពេលវេលាប៉ុណ្ណឹង មិនអាចនឹងរារាំងខ្ញុំមិនឱ្យចូលរួមក្នុងការបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យរបស់ខ្ញុំបានទេ ។*

« តែគាត់ឆ្លើយថា ខ្ញុំប្រាប់នាងរាល់គ្នាជាប្រាកដថា ខ្ញុំមិនស្គាល់នាងទេ » (ម៉ាថាយ 25:10–12) ។

ទោះជាត្រូវរារាំងមិនឱ្យចូលក្នុងពិធីសំខាន់ ហាក់ដូចជាលទ្ធផលធ្ងន់ធ្ងរមួយ ដោយសារតែអ្វីដែលចាត់ទុកថា ជាកំហុសតូចមួយក្ដី ក៏ខ្ញុំបានដឹងថា វាគឺដូចជាការជ្រើសរើស និង លទ្ធផលទាំងឡាយផងដែរ ។ នៅពេលខ្ញុំលើកចុងដំបងមួយឡើងពីដី នោះខ្ញុំក៏លើកចុងដំបងម្ខាងទៀតដែរ ។ ដូចគ្នាទៅនឹងការជ្រើសរើស ខ្ញុំពុំមែនជ្រើសរើសធ្វើសកម្មភាពតែប៉ុណ្ណោះទេ ប៉ុន្តែក៏មាននូវលទ្ធផលមកជាប់ជាមួយផងដែរ—ជាលទ្ធផលដែលនឹងកើតឡើងដោយមិនបានដឹងមុន ។

គឺជាសាតាំងដែលចង់ឱ្យយើង គិតផ្ដោតតែទៅលើការជ្រើសរើសដោយពុំគិតអំពីលទ្ធផល ។ ជាញឹកញាប់ វាធ្វើដូច្នោះ ដោយការល្បួងចិត្តរបស់យើង ឱ្យផ្ដោតទៅលើចំណង់ខាងរូបកាយ « ចំណង់របស់សាច់ឈាម » (នីហ្វៃទី 2 2:29) និង ការបំពេញចិត្តភ្លាមៗ ។

ផ្ទុយទៅវិញ ព្រះវរបិតាសួគ៌របស់យើង មានព្រះទ័យចង់ឱ្យយើងផ្ដោតទៅលើសុភមង្គល និង ពរជ័យដ៏អស់កល្បជានិច្ច ។ ទ្រង់រំពឹងឱ្យយើងពិចារណាអំពីលទ្ធផលទាំងឡាយ នៅពេលយើងធ្វើការសម្រេចចិត្ត ពីព្រោះ លទ្ធផល ជាចំណែកនៃការលើកទឹកចិត្តរបស់យើង ៖ « ពួកគេមានសិទ្ធិនឹងរើសយកឥស្សរភាពនិង ជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះជាអ្នកសង្គ្រោះសង្គ្រោះដ៏ធំរបស់មនុស្សលោកទាំងអស់ ឬក៏រើសយកការជាប់ឃុំឃាំង និង ការស្លាប់ » (នីហ្វៃទី 2 2:27) ។

ខណៈដែលខ្ញុំពុំមានអំណរគុណចំពោះការខកខានក្នុងការទទួលបរិញ្ញាបត្រជាផ្លូវការរបស់ខ្ញុំ នោះខ្ញុំមានអំណរគុណចំពោះបទពិសោធន៍នេះ ដែលបានបង្រៀនខ្ញុំអំពីប្រាជ្ញាដ៏អស់កល្ប—ដែលខ្ញុំពុំចង់ធ្វើការសម្រេចចិត្តមួយ ដែលរារាំងខ្ញុំមិនឱ្យទទួលបាននូវការស្វាគមន៍ឱ្យចូលទៅក្នុងវត្តមានរបស់កូនកម្លោះនោះឡើយ ។ ជាជាងត្រូវបានបិទទ្វា ហើយប្រាប់ថា « ខ្ញុំមិនស្គាល់នាងទេ » នោះខ្ញុំព្យាយាមដើម្បីធ្វើការសម្រេចចិត្ត ដែលនឹងអនុញ្ញាតឱ្យខ្ញុំស្ដាប់ទ្រង់មានបន្ទូលនេះជំនួសវិញថា « ចូរឱ្យឯប្រកបដោយសេចក្ដីអំណររបស់ចៅហ្វាយឯងចុះ » (ម៉ាថាយ 25:21) ។ ■

រូបថត © PHOTOSPIN




រូបភាពគំនូរដោយ អេ. ធី. ហ្វ៊ីម

# យ៉ូសែប ស្ម៊ីធ

យ៉ូសែប ស្ម៊ីធ មានអាយុ 14 ឆ្នាំ នៅពេលលោក **អធិស្ឋាន** ដើម្បីដឹងថា ព្រះវិហារណាមួយត្រឹមត្រូវ ។ ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវ គ្រីស្ទ បានលេចមកឯលោក ហើយលោកបានរៀនដឹងថា គ្មានព្រះវិហារណាមួយ នៅលើផែនដីនេះ មានសេចក្ដីពិតពេញលេញនោះទេ ។ យ៉ូសែប ស្ម៊ីធ បានជួយស្ដារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទពិតឡើងវិញ ហើយបានក្លាយជាព្យាការីទីមួយ នៃថ្ងៃចុងក្រោយ ។ ជាចំណែកនៃកិច្ចការរបស់លោក លោកបានបកប្រែព្រះគម្ពីរមរមនចេញមកពី**ផ្ទាំងចំណារមាស** ហើយបានដឹកនាំពួកបរិសុទ្ធឱ្យសាងសង់ព្រះវិហារបរិសុទ្ធដំបូងគេ នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ គឺ **ព្រះវិហារបរិសុទ្ធខឺតឡង់ ។**



មន្ត្រីម្នាក់ដែលទៅសាសនាផ្សេង បន្ទាប់ពីបានជួបប្រធាន ឡូរ៉េនសូ ស្នូ រួចបានសរសេរថា ៖ « ទឹកមុខរបស់លោកគឺមានអំណាចនៃសេចក្ដីសុខសាន្ត វត្តមានរបស់លោកគឺជាការអធិស្ឋាននៃសេចក្ដីសុខសាន្ត ។ នៅក្នុងជម្រៅនៃក្រសែភ្នែកដ៏ស្រទន់របស់លោក មិនគ្រាន់តែជា ‹ កន្លែងអធិស្ឋានដ៏ស្ងៀមស្ងាត់ប៉ុណ្ណោះទេ › គឺថែមទាំងជាគេហដ្ឋានខាងវិញ្ញាណផងដែរ ។ ... អារម្មណ៍ដ៏ចម្លែកបំផុតបានគ្របដណ្ដប់លើខ្ញុំ ថាខ្ញុំ ‹ បានឈរនៅទីដ៏បរិសុទ្ធ ›» ។

សូមមើល « ផ្លេក់ត្រសក់, មើមឆៃថាវ និង ទីបន្ទាល់ ៖ ការបំផុសគំនិតមកពីខ្សែជីវិត និង ការបង្រៀនរបស់ ឡូរ៉េនសូ ស្នូ » ទំព័រ 12 ។

CAMBODIAN
4 02107 81258 4

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ